**Declassified to Public**
**06 September 2012**



សំណុំរឿងលេខ ០១/១៨-០៧-២០០៧-អវតក/អជសដ

# ការវិភាគសម្ដីសាក្សី(រស់)សម្រាប់សវនាការ

## មាតិកា

**I. ប្រវត្តិវិទូ អ្នកសារព័ត៌មាន និងអ្នកបណ្ណសារ ..... 3**

1. CHANDA, NAYAN ..... 3
2. CHANDLER, DAVID ..... 4
3. ជ័យ សូភារ៉ា ..... 15
4. DUNLOP, NIC ..... 17
5. ETCHESON, CRAIG ..... 23
6. KA SUNBAUNAT ..... 24
7. SIRONI-GUILBARD FRANCOISE ..... 25

**II. ជនរងគ្រោះនៃមន្ទីរ ស-២១ ..... 26**

8. វ៉ាន់ ណាត ..... 26

**III. សន្តិសុខ ឬបុគ្គលិកមន្ទីរ ស-២១ ..... 35**

9. ចៀម សឿ ..... 35
10. ខៀវ ចេស ហៅ ពៅ ..... 39
11. ឈុន ផល ..... 44
12. ហ៊ឹម ហ៊ុយ ..... 51
13. គក ស្រស់ ..... 61
14. គង់ ផៃ ..... 68
15. ឡាច មាន ..... 74
16. ម៉ក់ ស៊ីធីម ..... 80
17. ម៉ម ណៃ ហៅ ចាន់ ..... 84
18. មាស ប៉េងគ្រី ..... 98
19. ញែម អេន ..... 103
20. ញេប ហួ ..... 111
21. ប៉េស ម៉ាត់ ..... 115
22. ប្រាក់ ខន ..... 119
23. សោម ម៉េត ..... 131
24. សេក ឌន ..... 137

25. សួស ធី ....................................................................................................................................141

26. គយ តេង ....................................................................................................................................150

**IV. សាក្សីអង្គហេតុផ្សេងទៀតនៃកម្ពុជាប្រជាធិបតេយ្យ ....................................................................156**

27. ចេក សំ ហៅ សោម សំអុល ....................................................................................................156

**V. អ្នកទោសមន្ទីរស-២១ ....................................................................................................................161**

28. ប៊ូ ម៉ុន ....................................................................................................................................161

29. ផាច សៀក ហៅ ថាច សៀក ........................................................................................................165

30. អ៊ុក បុនសេង ...........................................................................................................................170

**VI. សាក្សីនៅមន្ទីរម-១៣ ....................................................................................................................174**

31. ចាន់ ខន ....................................................................................................................................174

32. ចាន់ វឿន ..................................................................................................................................179

33. អ៊ុច ស៊ន ហៅ អ៊ុច សាន .............................................................................................................184

# I. ប្រវត្តិរូប អ្នកសារព័ត៌មាន និងអ្នកបណ្ណសារ

## 1. CHANDA, NAYAN

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

*Evidence Summary in Progress*

## 2. CHANDLER, DAVID

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីបានបង្ហាញភស្តុតាងស្តីពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* រចនាសម្ព័ន្ធនិងគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹងមន្ទីរស-២១ សាក្សីនេះបានបង្ហាញភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)*, ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការយកមនុស្សធ្វើជាទាសករ សកម្មភាពអមនុស្សធម៌ ការបង្កការឈឺចាប់ដ៏ធ្ងន់ធ្ងរ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])*, ការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ក្រៅច្បាប់ *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញជនជាប់ឃុំឃាំង *(141-142)*។ ភស្តុតាងដែលគាត់បានបង្ហាញមានការពាក់ព័ន្ធទៅនឹងបទចោទទី1 ទី2 និងទី3 ដែលមានចែង នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. បច្ចុប្បន្ន សាក្សីនេះគឺជាសាស្ត្រាចារ្យចូលនិវត្តន៍ផ្នែកប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យ Monash បន្ទាប់ពីបានបំពេញអាជីពជាអ្នកសិក្សាស្រាវជ្រាវអស់រយៈពេលជាង40 ឆ្នាំរួចមក។ គាត់ត្រូវបានគេទទួលស្គាល់ថាជាអ្នកប្រាជ្ញឈានមុខលំដាប់ពិភពលោក ដែលមានការយល់ដឹងអំពីរបប និងឯកសារផ្សេងៗ នៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់អាចប្រើភាសាខ្មែរទាំងក្នុងការនិយាយ និងការសរសេរបានយ៉ាងស្ទាត់ជំនាញ។ សាក្សីគឺជាអ្នកនិពន្ធសៀវភៅជាច្រើន ដែលនៅក្នុងនោះរួមមាន៖ *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*, *The Tragedy of Cambodian History: Politics, War and Revolution since 1945*, *Facing the Cambodian Past*, *Brother Number One: A Political Biography of Pol Pot*, និង *សម្លេងពីមន្ទីរស-២១: Terror and History in Pol Pot's Secret Prison*, ហើយគាត់ជាសហនិពន្ធនៃសៀវភៅ *Pol Pot Plans the Future: Confidential Leadership Documents from Democratic Kampuchea, 1976-1977*, *Revolution and Its Aftermath in Kampuchea*, និង *The Khmers*.

3. ក្នុងការស្រាវជ្រាវដើម្បីសរសេរសៀវភៅរបស់គាត់ដែលមានចំណងជើងថា៖ *សម្លេងពីមន្ទីរស-២១: Terror and History in Pol Pot's Secret Prison ("សម្លេងពីមន្ទីរស-២១")* សាក្សីបានសិក្សាវិភាគទៅលើសំណុំឯកសារនៅមន្ទីរស-២១ ទាំងស្រុង ដោយរួមមាន "ចម្លើយសារភាព" ចំនួនលើសពី4,000 ដែលត្រូវបានរក្សាទុកនៅសារមន្ទីរទួលស្លែង។ គាត់ក៏បានសម្ភាសអតីតបុគ្គលិក អ្នករក្សាបណ្ណសារនិងអ្នកជាប់ឃុំឃាំងនៅមន្ទីរស-២១ និងសាក្សីនានាដែលធ្លាប់រស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាច្រើននាក់ផងដែរ។ *សម្លេងពីមន្ទីរស-២១* ត្រូវបានប្រើប្រាស់ជាឯកសារមួយផ្នែករបស់សំណុំរឿងក្តី (ERN 00192667-00192932 (ភាសាអង់គ្លេស)) ហើយត្រូវបានបកប្រែជាភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក។ ក្នុងរយៈពេលនៃការស៊ើបអង្កេតរបស់តុលាការ ឌុច បានបញ្ជាក់ថា គាត់បានអានសៀវភៅ *សម្លេងពីមន្ទីរស-២១* ព្រមទាំងទទួលស្គាល់ថាជា "ការវិភាគយ៉ាងហ្មត់ចត់ជាប្រព័ន្ធមួយទៅលើឯកសារពាក់ព័ន្ធទាំងអស់"[1]។

## ជម្លោះប្រដាប់អាវុធ

4. តាមរយៈឯកសារនានា សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញពីការវាយប្រហាររបស់កងទ័ពវៀតណាមមកលើខេត្តស្វាយរៀង ដែលស្ថិតក្នុងដែនដីកម្ពុជាប្រជាធិបតេយ្យក្នុងខែតុលា ឆ្នាំ1977 ដែលឈានដល់ការកាត់ផ្តាច់ទំនាក់ទំនងការទូតរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមនៅដើមខែមករាក្នុង ឆ្នាំ1978 ដោយក្នុងពេលនោះ ប៉ុល ពត បានអំពាវនាវតាមរលកវិទ្យុកម្ពុជាប្រជាធិបតេយ្យឱ្យ "ចូលធ្វើសង្គ្រាមទាំងអស់គ្នា" ប្រឆាំងនឹងវៀតណាម[2]។ សាក្សីបានផ្តល់ភស្តុតាងដែលបង្ហាញថា "ខ្មាំង" ដែលត្រូវចាប់ខ្លួន និងជាប់ឃុំនៅមន្ទីរស-២១នោះ គឺ "សុទ្ធតែត្រូវចោទប្រកាន់យ៉ាងពេញទំហឹងថាឃុបឃិតជាមួយនឹងវៀតណាម"[3] ដែលបណ្តាលឱ្យមានការកម្ទេចនៅភូមិភាគបូព៌ា ក្នុងទិសដៅកម្ចាត់ឱ្យអស់ជនដែលត្រូវគេសង្ស័យថាបានជួយវៀតណាម[4]។ សាក្សីបានបង្ហាញភស្តុតាង ដែលជម្រុញឱ្យមានភាពតឹងតែងនៅក្នុងការប្រយុទ្ធគ្នាជាមួយវៀតណាម ហើយនិងការកម្ទេចនៅភូមិភាគបូព៌ាក្នុងអំឡុងឆ្នាំ1978[5]។ សាក្សីបាននិយាយថា នៅក្នុងខែមេសា ក្នុងឆ្នាំ1978 មានជនដែលរងគ្រោះដោយសារការកម្ទេចនេះជាច្រើនត្រូវបានបញ្ជូនមកមន្ទីរស-២១ "ដែលឡានដឹកអ្នកទោសខ្លះនោះត្រូវបត់ទៅទិសដៅផ្សេង" បានសេចក្តីថាអ្នកទោសទាំងនោះ "ត្រូវគេដឹកសម្លាប់ដោយមិនចាំបាច់សួរចម្លើយ"[6]។

## រចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

5. សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញថាកម្មាភិបាលមន្ទីរស-២១ ធ្វើការក្រោមការត្រួតពិនិត្យរបស់គណៈអចិន្ត្រៃយ៍បក្ស ព្រោះមន្ទីរស-២១ ត្រូវ បានគេចាត់ទុកថាជាកងវរសេធំឯករាជ្យ ដែលត្រូវគោរពតាមវិន័យកងទ័ព[7]។ សាក្សីបានផ្តល់ភស្តុតាងអំពីបេសកកម្មរបស់មន្ទីរស-២១ "ដែលត្រូវការពារគណៈអចិន្ត្រៃយ៍បក្ស" ដែលក្នុងន័យការពារនេះ "មន្ទីរស-២១បានចូលរួមចំណែកសម្លាប់អ្នកទោសទាំងអស់ ហើយនិងចូលរួមចំណែកផ្លាស់ប្តូរប្រវត្តិរូបផ្ទាល់ខ្លួនរបស់អ្នកទោសទាំងនោះ ដើម្បីភ្ជាប់ពួកគេឱ្យត្រូវនឹងតម្រូវការ និងការសង្ស័យនានារបស់បក្ស"[8]។ លើសពីនេះទៀត តាមរយៈឯកសារនោះ សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញពីវិធី "គ្រប់គ្រងប្រវត្តិរូបអ្នកជាប់ឃុំ និងការងាររដ្ឋបាលនៅមន្ទីរស-២១ ដែលមានលក្ខណៈដាច់ខាត និងប្រតិបត្តិទៅតាម 'វិន័យ' ដែលស្មុគស្មាញ ... ផ្តល់លទ្ធភាពឱ្យអ្នកយាមប្រើអំណាចទៅលើអ្នកទោស និងត្រូវត្រួតពិនិត្យមើលការអប់រំរៀនសូត្ររបស់អ្នកទោសទាំងនោះ"[9]។

6. សាក្សីបានបង្ហាញភស្តុតាងពីដំណាក់កាលខុសៗគ្នានៃការកម្ទេចក្រោមបញ្ជារបស់គណៈអចិន្ត្រៃយ៍បក្ស។ ជាដំបូង ទិសដៅផ្តោតតែទៅលើជនស៊ីវិល និងមន្ត្រីយោធាពីសង្គមចាស់ បន្ទាប់មកការកម្ទេចបានបង្កើនការយកចិត្តទុកដាក់ទៅលើសមាជិករបស់ ប.ក.ក[10]។ សាក្សីបានបង្ហាញភស្តុតាងអំពីមូលហេតុដែលបណ្តាលឱ្យការកម្ទេច ត្រូវផ្តោតទិសដៅទៅលើអ្នកការទូត បញ្ញវន្ត និងរួមទាំងសមាជិកជាន់ខ្ពស់នានារបស់បក្ស ដូចជា កុយ ធួន, ហ៊ូ នឹម, សឿ វ៉ាស៊ី ហៅ ឌឿន, សៀត ឆែ ហៅ ទុំ និង កែវ មាស ដោយអ្នកទាំងនោះ ត្រូវចាប់ខ្លួន ត្រូវបង្ខំឱ្យ "សារភាព" និងសម្លាប់នៅមន្ទីរស-២១[11]។

## តួនាទីរបស់ជនជាប់ចោទ

7. តាមរយៈឯកសារ សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញថា **ឌុច** គឺជាគ្រូបង្រៀនមួយរូបដែល "តឹងតែងច្បាស់លាស់ និងមានការតាំងចិត្តមោះមុត" ដោយគាត់បានដឹងពីអ្វីដែលគាត់បានធ្វើនៅមន្ទីរស-២១ ហើយគាត់បានជ្រើសយកជម្រើសបែបនោះ[12]។ សាក្សីបានផ្តល់នូវភស្តុតាង អំពីអ្វីដែល Francois BIZOT បានប្រាប់ដល់គាត់ក្នុងអំឡុងពេល Francois BIZOT ត្រូវបានចាប់បង្ខាំងនៅមន្ទីរម-១៣ ហើយយល់ឃើញថា **ឌុច** "យល់ឃើញថាប្រជាជនកម្ពុជាដែលមានការយល់ឃើញផ្សេងពីខ្លួននោះ គឺជាជនក្បត់ និងជាមនុស្សកុហក" និងដោយសារហេតុផលនេះ ទើប **ឌុច** "វាយអ្នកទោសដោយផ្ទាល់ដៃចំពោះជនដែលមិនព្រមនិយាយការពិត"។

8. តាមរយៈឯកសារ សាក្សីបានបង្ហាញនូវភស្តុតាង ក្នុងនាមជាអ្នក"ទទួលបន្ទុក"មន្ទីរស-២១ **ឌុច** បានខំប្រឹងប្រែង ក្នុងការគ្រប់គ្រងលើគ្រប់ផ្នែកប្រតិបត្តិការទាំងអស់របស់មន្ទីរស-២១ ព្រមទាំងរូប **ឌុច** ផ្ទាល់បាន "បង្ខំខ្លួនឯងព្រមទាំងអ្នកក្រោមបង្គាប់ឱ្យខិតខំធ្វើការយ៉ាងខ្លាំង"[13]។

9. តាមរយៈការសិក្សារបស់គាត់ទៅលើឯកសារដំបូងៗដែលបានមកពីមន្ទីរស-២១ សាក្សីបានផ្តល់នូវភស្តុតាងបង្ហាញថា នៅលើឯកសារទាំងនោះមានចំណាររបស់ **ឌុច** ដែលបានធ្វើឡើងក្នុងខែតុលា ឆ្នាំ 1975[14]។ ជាសរុប សាក្សីប៉ាន់ស្មានថា ចំណាររបស់ **ឌុច** មាននៅលើឯកសាររាប់សិបដែលជាចម្លើយសារភាព ហើយ "ចម្លើយសារភាព" មួយចំនួនត្រូវបាន **ឌុច** សង្ខេបដោយផ្ទាល់ដៃទៀតផង[15]។ នៅក្នុងសេចក្តីសង្ខេបទាំងនោះ **ឌុច** បានកំណត់នូវខ្សែរយៈផ្សេងៗដែលគាត់គិតថាមានទំនាក់ទំនងជាមួយនឹង "ចម្លើយសារភាពដទៃទៀត" ដោយបានស្នើឡើងពីការសួរចម្លើយនានាដែលបង្ហាញពីខ្សែរយៈថ្មីៗ ការវិភាគដោយហ្មត់ចត់បំផុត នៅក្នុងឯកសារមួយដែលមានចំណងជើងថា "ផែនការចុងក្រោយ" សរសេរក្នុងឆ្នាំ 1978 ដែលនៅក្នុងផែនការនោះ **ឌុច** បានព្យាយាមសំយោគ "ចម្លើយសារភាពនានា" ដែលយកបានក្នុងរយៈពេលពីរឆ្នាំឱ្យទៅជាផែនការក្បត់ល្អិតល្អន់មួយ[16]។ តាមរយៈឯកសារនេះផងដែរ សាក្សីបានផ្តល់នូវភស្តុតាងដែល បង្ហាញពីហេតុផលដែល ឌុច "មិនពេញចិត្ត" ជាមួយនិងភ្នាក់ងារសេអ៊ីអារបស់អាមេរិចកាំង និងបង្ហាញពីមូលហេតុដែល **ឌុច** បញ្ជាឱ្យបកប្រែជាភាសាខ្មែរនូវសៀវភៅរាយឈ្មោះនិងទីលំនៅរបស់ភ្នាក់ងារសេអ៊ីអាទូទាំងសកលលោក ដែលបានបោះពុម្ពផ្សាយជាភាសាអង់គ្លេស នៅភាគខាងកើតប៉ែរឡាំងនាអំឡុងទស្សវត្សឆ្នាំ1960[17]។

10. សាក្សីបានបង្ហាញនូវភស្តុតាងពីរយៈពេលប៉ុន្មានថ្ងៃដំបូងនៃការបង្កើតមន្ទីរស-២១ **ឌុច** បានកោះប្រជុំមួយដើម្បីណែនាំបុគ្គលិកថា ពួកគេអាចវាយដំអ្នកទោសបាន និងមិនត្រូវគិតថាទង្វើនេះជាអំពើសាហាវព្រៃផ្សៃនោះទេ[18]។ ក្រោយមកនៅលើឯកសារមន្ទីរស-២១ មានបញ្ជាដែលសរសេរដោយ **ឌុច** ទៅកាន់អ្នកធ្វើការក្រោមបង្គាប់ឱ្យធ្វើទារុណកម្ម រួមទាំងទារុណកម្មដែលមានលក្ខណៈធ្ងន់ធ្ងរផងដែរ ហើយ **ឌុច** បានផ្ញើលិខិតដែលពោរពេញទៅដោយ "ពាក្យពេចន៍សាហាវព្រៃផ្សៃ" ទៅកាន់អ្នកទោសផងដែរ[19]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញពីការដែលអ្នកទោសមួយចំនួនបានសរសេរលិខិត អង្វរសុំក្តីមេត្តាពីថ្នាក់ដឹកនាំជាន់ខ្ពស់នានារបស់ ប.ក.ក ប៉ុន្តែ **ឌុច** មិនបានបញ្ជូនលិខិតទាំងនោះទៅឱ្យថ្នាក់លើរបស់ខ្លួនទេ[20]។ សាក្សីបានបង្ហាញនូវភស្តុតាងពី **ឌុច** និងអ្នកក្រោមបង្គាប់របស់ **ឌុច** "ដែលបានធ្វើ

ឱ្យអ្នកទោសឈឺចាប់ក្នុងកម្រិតធ្ងន់ធ្ងរច្រើនរាប់មិនអស់ ដោយគ្មានញញើតញញើម ជាប្រព័ន្ធ និងដោយគ្មានវិប្បដិសារីទាល់តែសោះ"[21]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

11. សាក្សីបានបង្ហាញនូវភស្តុតាងដែលបញ្ជាក់ថា ការលាក់ការណ៍ គឺជាគន្លឹះសំខាន់នៃប្រតិបត្តិការរបស់មន្ទីរ ស-២១។ ការលាក់ការណ៍នៅមន្ទីរស-២១ ត្រូវបានរក្សាដោយបូកបញ្ចូលវិធានការណ៍ផ្សេងៗ រួមមាន ការបំបាត់ចោលនូវអ្នកនៅជុំវិញខ្លួន និងរក្សាអ្នកដែលនៅស្ថិតនៅខាងក្រៅឱ្យនៅឆ្ងាយពីបរិវេណ ដោយហាមប្រាមមិនឱ្យមានទំនាក់ទំនងរវាងអង្គភាពដែលទទួលបន្ទុកផ្សេងគ្នា ដោយដាក់វិធានហាមមិនឱ្យបុគ្គលិកសូម្បីតែមើលទៅ "ខ្មាំង" តាមបង្អួចបើកចំហរ ដោយដាក់អ្នកទោសដែលមានតួនាទីសំខាន់ៗឱ្យនៅដោយឡែកពីគេ ហើយចុងបញ្ចប់គឺសម្លាប់អ្នកទោសចោលទាំងអស់[22]។

12. សាក្សីបានបង្ហាញនូវភស្តុតាងជាទូទៅអំពីឯកសារនៅមន្ទីរស-២១ និងពីមូលហេតុដែលបណ្តាលឱ្យមន្ទីរនោះមានលក្ខណៈយ៉ាងទូលំទូលាយ[23]។ សាក្សីមានលទ្ធភាពអាចនឹងបង្ហាញនូវភស្តុតាងអំពីឯកសារនានាដែលបង្ហាញពីការវិវឌ្ឍក្នុងអំឡុងពេលដែលមន្ទីរស-២១ មានប្រតិបត្តិការ។

## រចនាសម្ព័ន្ធរដ្ឋអំណាច

13. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា **ឌុច** ជា "មេបញ្ជាការ" របស់មន្ទីរឃុំឃាំង[24]។ **ឌុច** ត្រូវបានជួយជ្រោមជ្រែងដោយអនុប្រធានរបស់គាត់ឈ្មោះ ឃឹម វ៉ាត, ហៅ ហ៊ី ក៏ដូចជាអ្នកក្រោមបង្គាប់ជាន់ខ្ពស់ដទៃទៀត ដូចជា ប៉េង, ម៉ម ណៃ និង ហ៊ឹម ហ៊ុយ[25]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបញ្ជាក់ថាឯកសារទាំងនោះបានបង្ហាញយ៉ាងច្បាស់ថា ហ៊ី បានរាយការណ៍ឱ្យ **ឌុច**[26]។ វិន័យនៅមន្ទីរស-២១ មានលក្ខណៈតឹងរ៉ឹងបំផុត និង "ដោយត្រូវទន្ទេញវិន័យទាំងនោះឱ្យចាំ [ហើយនិង] តម្រូវឱ្យមានការអោនលំទោនចំពោះរដ្ឋអំណាច និងត្រូវស្តាប់បង្គាប់ដោយមិនចាំបាច់សួរនាំ"[27]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

14. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា គ្មានជនណាម្នាក់ត្រូវបានដោះលែងពីមន្ទីរស-២១ នោះទេ[28]។ គាត់បានបង្ហាញនូវភស្តុតាងអំពីឯកសារនានា ដែលបញ្ជាក់ពីលេខសម្គាល់ផ្សេងៗរបស់អ្នកទោសនៅមន្ទីរស-២១ ហើយនិងការផ្លាស់ប្តូរលេខសម្គាល់ទាំងនោះ។ សាក្សីបាននិយាយថា តាមការប៉ាន់ស្មាន

"ដីជាក់លាក់" នោះ ចំនួនអ្នកទោសសរុបដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ ទាំងអស់គឺ14,000 ហើយចំនួនមនុស្សជាអតិបរមាដែលមន្ទីរស-២១អាចដាក់មានចំនួនប្រហែល1,500នាក់[29]។ ការប្រែប្រួលចំនួនអ្នកទោសគឺយោងទៅលើសភាពការណ៍ជាក់លាក់ ដែលបានកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាពិសេសក្នុងការកម្ទេចនៅភូមិភាគបូព៌ាក្នុងឆ្នាំ1978[30]។ សាក្សីក៏អាចបង្ហាញភស្តុតាងផងដែរអំពីប្រភេទប្រវត្តិរបស់អ្នកទោសនានា និងរយៈពេលដែលអ្នកទោសទាំងនោះត្រូវបានគេ "ឃុំខ្លួនទុក" មុនពេល "កម្ទេច"[31]។

15. សាក្សីបានផ្តល់នូវភស្តុតាងដែលបង្ហាញពី "បេសកកម្ម និងកាតព្វកិច្ចរបស់មនុស្ស ដែលបំពេញការងារនៅមន្ទីរស-២១នោះ មិនមានចែងក្នុងច្បាប់ទេ...[ហើយ] កម្ពុជាប្រជាធិបតេយ្យមិនមានក្រមច្បាប់ និងប្រព័ន្ធតុលាការទេ"[32]។ លើសពីនេះទៀត សាក្សីបានផ្តល់នូវភស្តុតាងដែលបង្ហាញពីកំហុសតូចតាចតែត្រូវគេចាត់ទុកថាជា "បទល្មើស" ហើយអ្នកទោសត្រូវបង្ខំឱ្យ "សារភាព" នោះមកបូកផ្សំគ្នាបន្តិចម្តងៗរហូតដល់កម្រិតទោស "ក្បត់ជាតិ" តាមរយៈការបកស្រាយសកម្មភាពសព្វបែបយ៉ាងដែលអ្នកទោសបានប្រព្រឹត្តថាជាអំពើទុយ៍សក្បត់ជាតិ[33]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

16. សាក្សីបានបង្ហាញភស្តុតាងជាទូទៅអំពីការបែងចែករបបអាហារដ៏តិចតួចបំផុត ការដាក់អ្នកទោសឱ្យនៅផ្សេងពីគេឯង និងអំពីរបបដែលពោរពេញទៅដោយវិន័យតឹងរ៉ឹង[34]។

## ការសួរចម្លើយ

17. សាក្សីបានបង្ហាញភស្តុតាងអំពីការដែលថា អ្នកទោសត្រូវបានចោទប្រកាន់ ពីព្រោះពួកគេបានប្រព្រឹត្តខុស ឬថា ពួកគេបានប្រព្រឹត្តខុស ដូច្នេះហើយបានជានាំឱ្យមានការចោទប្រកាន់"[35] និងអំពីការ ដែលអ្នកទោសមិនទាំងបានដឹងផងថាខ្លួនឯងផ្ទាល់បានប្រព្រឹត្តបទឧក្រិដ្ឋអ្វីនោះ។ សាក្សីបានបង្ហាញភស្តុតាងពីតួនាទីរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ ដែលសាក្សីបានរៀបរាប់ថា"ជាពួកដែលត្រូវល្បួង និងបន្លាចអ្នកទោសរហូតទាល់តែពួកគេនោះអាចសរសេរជាចម្លើយសារភាពដែលត្រូវរ៉ូវគ្នាជាមួយនឹង 'ការដឹងឮ' របស់បក្សអំពី 'បទល្មើសនានា' របស់ពួកគេទៅតាមការយល់ដឹងរបស់បក្សពីការប្រែប្រួលប្រវត្តិរបស់ពួកគេ"[36]។ សាក្សីបានរៀបរាប់ពីវិធីក្នុងការបង្ខំឱ្យអ្នកទោស "សារភាព" ពី "ខ្សែរយៈ" ក្បត់របស់ពួកគេ ដែល ត្រូវគេយកមកប្រើជាមូលហេតុសម្រាប់ការចាប់ខ្លួនរបស់អ្នកទោសទាំងនោះ និងដើម្បីកំណត់ ឬធ្វើឱ្យស្រប

ទៅច្បាប់ចំពោះការចាប់ខ្លួនជនដទៃទៀត ដែលចាត់ទុកថាជាខ្មែរយៈ ក្នុងគោលបំណងបង្កើត "ចំណាប់អារម្មណ៍ថាមានការសមគំនិតក្បត់ដ៏ធំធេងទូទាំងប្រទេសមួយ [ដែល] សមដូចគោលគំនិតរបស់ ឌុច ព្រមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្លួន បានគិតទុកជាស្រេច"[37]។ សាក្សីបានបង្ហាញនូវភស្តុតាងអំពីវិធីសាស្ត្រក្នុងការសួរចម្លើយ ជាពិសេសពីការទាមទារឲ្យមានតុល្យភាពរវាងការប្រើទារុណកម្ម និងការប្រើបច្ចេកទេសចិត្តសាស្ត្រ ព្រមទាំងវិធីបង្រៀនពីការប្រើប្រាស់អំពើអស់ទាំងនោះនៅមន្ទីរស-២១[38]។ សាក្សីបានបង្ហាញនូវភស្តុតាងពាក់ព័ន្ធនឹងកំនត់ត្រាជាឯកសារនៃការសួរចម្លើយ រួមមាន វិធីសាស្ត្រក្នុងការកត់ត្រាផ្សេងៗគ្នារបស់ "ទិន្នន័យព័ត៌មាន" ដែលមានចំណារដាក់ថា "គ្មានចំណាប់អារម្មណ៍លុបចោល"[39] ជាដើម។

18. សាក្សីបានបង្ហាញនូវភស្តុតាងជាមូលដ្ឋានអំពីមាតិកា ខ្លឹមសារ ព្រមទាំងការបំរែបំរួលតាមពេលវេលារបស់ "ចម្លើយសារភាពនានា" នៅមន្ទីរស-២១ ផងដែរ។ "ចម្លើយសារភាព" ភាគច្រើន ត្រូវបានចែកចេញជាបួនផ្នែកគឺ៖ ប្រវត្តិរូបផ្ទាល់ខ្លួនរបស់អ្នកទោស ប្រវត្តិ "សកម្មភាពក្បត់នានា" របស់អ្នកទោស ការរៀបចំគម្រោងផែនការបំផ្លិចបំផ្លាញផ្សេងៗ និងផ្នែកចុងក្រោយគឺបញ្ជី "ខ្មែរយៈ" ពួកក្បត់[40]។

19. សាក្សីបានបង្ហាញនូវភស្តុតាងតាមរយៈការពិនិត្យពិច័យទៅលើការរៀបរៀង [ចម្លើយសារភាព] … ដែលបានបង្ហាញថា ឌុច និងសហការីរបស់ខ្លួនមានមោទនភាពចំពោះភាពហ្មត់ចត់ និងវិធីសាស្ត្រទំនើបៗរបស់ពួកគេ។ ពួកគេចង់ធ្វើឲ្យមន្ទីរស-២១ ក្លាយទៅជាមជ្ឈមណ្ឌលសួរចម្លើយគំរូ និងឲ្យគេចាត់ទុកពួកខ្លួនជាអ្នកជំនាញសន្តិសុខអាជីពផងដែរ"[41]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

20. សាក្សីបានបង្ហាញនូវភស្តុតាងដែលបញ្ជាក់ថា អ្នកទោសស្ថិតនៅក្នុងមន្ទីរស-២១ទាំងអស់ ត្រូវបានគេចាត់ទុកជាប្រព័ន្ធ ដូចសត្វធាតុ ដោយយោងទៅលើសភាពដែលអ្នកទោសទាំងនោះត្រូវបានគេឃុំ។ ការចាត់ទុកមនុស្សដូចជាសត្វធាតុបែបនេះ គឺជាកត្តាមួយដែល "ជម្រុញឲ្យមានអំពើហិង្សារីករាលដាលឡើង" នៅមន្ទីរស-២១[42]។ យោងតាមរយៈការសិក្សាយ៉ាងល្អិតល្អន់របស់គាត់ទៅលើឯកសារផ្សេងៗនោះ សាក្សីដែលជាអ្នកជំនាញមានការយល់ឃើញថា "មានអំពើសាហាវព្រៃផ្សៃ ដែលមិនអាចរាប់អស់ផ្សេងៗទៀត និងរបៀបនៃការធ្វើទារុណកម្មច្រើនរយបែបទៀត ដែលមិនត្រូវបានគេកត់ត្រាឡើយ" នៅមន្ទីរស-២១ នេះ[43]។

21. តាមរយៈឯកសារ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថាទារុណកម្មត្រូវបានធ្វើឡើង "ដំណើរមួយដែលមានការកម្រិតកាន់តែធ្ងន់ធ្ងរទៅៗ និងមានគោលបំណងច្បាស់លាស់" ដែលការធ្វើទារុណកម្មភាគច្រើនសុទ្ធតែ "មានចេតនា និងដោយមានបញ្ហា" និង "ជារឿយៗចាំបាច់ត្រូវមានការអនុញ្ញាតពីថ្នាក់លើ ហើយដែលមានពេលខ្លះក៏គ្មានការអនុញ្ញាត"[44]។ សាក្សីបានបង្ហាញនូវភស្តុតាង អំពីការប្រព្រឹត្តិហួសពីបញ្ហា ហួសហេតុ ដែលអំពើទារុណកម្ម និងសកម្មភាពសាហាវយង់ឃ្នងបំផុតត្រូវបានបរិយាយនៅក្នុងឯកសារទាំងនោះ[45]។ ចំពោះការកម្រិតមិនឱ្យបន្តការធ្វើទារុណកម្មណាមួយ អាចនឹងត្រូវធ្វើឡើងមិនមែនដោយសារតែពួកគេផ្តល់ការគោរពចំពោះជនរងគ្រោះ ឬដោយសារយល់ឃើញថាអំពើទារុណកម្មទាំងនោះអមនុស្សធម៌នោះទេ គឺដោយសារតែមាគ៌ានយោបាយ ដែលតម្រូវឱ្យទារុណកម្មត្រូវធ្វើឡើងស្របគ្នាជាមួយនឹង "ការធ្វើនយោបាយ" ដើម្បីទទួលបានចម្លើយសមស្រប។ មានការកំណត់មិនឱ្យមានការធ្វើទារុណកម្មខ្លាំងហួសហេតុពេកខ្លះដែរ ប៉ុន្តែការកំណត់ទាំងនោះមិនមែនដោយសារការគោរពសិទ្ធិជនរងគ្រោះ ឬការដាក់ទណ្ឌកម្មនោះ វាហួសហេតុពេកនោះទេ។ ការកំណត់ទាំងនោះគឺធ្វើតាមមាគ៌ាបក្សដែលកំណត់ថា ការធ្វើទារុណកម្មត្រូវធ្វើឱ្យស៊ីសង្វាក់គ្នានឹងការធ្វើនយោបាយ ដើម្បីទទួលបានចម្លើយសារភាពសមស្រប។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា "សុខុមាលភាពរបស់អ្នកទោសមិនដែលបានគេគិតគូរម្តងណាទេ លើកលែងតែអ្នកទោសណាដែលស្លាប់មុនពេលសារភាព"[46]។ ប្រសិនបើអ្នកទោសស្លាប់ដោយសារការធ្វើទារុណកម្ម មុនពេល "ចម្លើយសារភាពរបស់ពួកគេបានបញ្ចប់" នោះអ្នកសួរចម្លើយនឹងត្រូវសង្ស័យថាចង់ធ្វើវិទ្ធង្សនា។ ទោះបីជាមានការកំណត់ច្បាស់លាស់អំពីកម្រិត រវាងការធ្វើទារុណកម្មតិចតួចបំផុត និងការធ្វើទារុណកម្មធ្ងន់ធ្ងរក៏ដោយ ក៏អ្នកសួរចម្លើយ "តែងតែភ័ន្តច្រឡំលំអៀងទៅការធ្វើទារុណកម្មធ្ងន់ធ្ងរ ប៉ុន្តែអ្នកសួរចម្លើយទាំងនោះក៏កម្រនឹងទទួលទារុណកម្មណាស់ ជាជាងការធ្វើទារុណកម្មដោយមានការទទួលខុសត្រូវ ហើយពួកគេក៏មិនបានទទួលការតបស្នងអ្វីទាល់តែសោះដែរ"[47]។ សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញថា គ្មានការបដិសេធមិនព្រមប្រព្រឹត្តអំពើទារុណកម្មដូចដែលមានរៀបរាប់នៅក្នុងឯកសារមន្ទីរស-២១ នោះឡើយ[48]។

22. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា នៅពេលដែលពេលវេលាចេះតែទៅមុខ ការសួរចម្លើយកាន់តែឆាប់បញ្ចប់ រីឯ "ចម្លើយសារភាព" កាន់តែខ្លីទៅៗ[49]។ សាក្សីបានចងក្រងបញ្ជីរាយនាមវិធីសាស្ត្រផ្សេងៗពីគ្នាក្នុងការធ្វើទារុណកម្ម ដូចមានរៀបរាប់នៅក្នុងឯកសារ និងដូចដែលសាក្សីនានាដែលគាត់

សម្ភាសន៍បានលើកឡើង[50]។ វិធីសាស្ត្រក្នុងការសួរចម្លើយ និងធ្វើទារុណកម្ម ត្រូវបានបង្រៀនក្នុងវគ្គសិក្សាដែលបានរៀបចំសម្រាប់បុគ្គលិកមន្ទីរស-២១ ហើយ **ឌុច** ផ្ទាល់ជាអ្នកដែលចារនៅលើឯកសារនានា ដើម្បីឱ្យអ្នកក្រោមបង្គាប់របស់ខ្លួនប្រើទារុណកម្ម ដើម្បីច្រិចយកចំនុចសំខាន់នានាពីក្នុង "ចម្លើយសារភាព" ដែលកំពុងតែរៀបចំ[51]។ អ្នកទោសតែងតែត្រូវគេបង្ខំឱ្យគោរពបូជារូបសុខន ដែលនេះជាវិធីសាស្ត្រមួយ សម្រាប់បំបាក់ស្មារតី និងចាត់ទុកអ្នកទោសទាំងនោះដូចសត្វធាតុ ចំពោះអ្នកទាំងឡាយណាដែលនៅតែចាត់ទុកខ្លួនឯងថាជា "ជនបដិវត្តន៍"[52]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

23. សាក្សីបាននិយាយថា តាមការប៉ាន់ស្មាន "ដ៏ជាក់លាក់" ចំនួនអ្នកទោសដែលត្រូវគេសម្លាប់នៅមន្ទីរស-២១ទាំងអស់ គឺ 14,000[53] ហើយចំនួនមនុស្សដែលត្រូវគេធ្វើឃាតជាប្រចាំនៅជើងឯកនោះ មានពីចន្លោះពីដប់ពីរនាក់ ដល់លើសពីបីរយនាក់ក្នុងមួយថ្ងៃៗ[54]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថាគ្មានការបដិសេធត្រូវបានលើកឡើងចំពោះការសម្លាប់អ្នកទោសនៅក្នុងឯកសារក្នុងមន្ទីរស-២១ នោះទេ[55]។

## បញ្ហាផ្សេងៗ

24. សាក្សីបានបង្ហាញនូវភស្តុតាងពីការរកឃើញមន្ទីរស-២១ ដោយជនជាតិវៀតណាមជាដំបូង ក្នុងខែមករា ឆ្នាំ១៩៧៩[56] ពីការរៀបចំ និងការវិវឌ្ឍរបស់សារមន្ទីរទួលស្លែង និងពីរបៀបក្នុងការថែរក្សាឯកសារដែលមាននៅទីនោះ[57]។ សាក្សីក៏នឹងអាចបង្ហាញនូវភស្តុតាងបានដែរ អំពីសភាពលក្ខណៈជាទូទៅនៃការប្រមូលឯកសារនៅមន្ទីរស-២១ ដោយរួមទាំងចន្លោះខ្វះខាតនានាដែលមាននៅក្នុងបណ្ណសារ ហើយនិងផលប៉ះពាល់របស់វាចំពោះស្ថិតិ និងសេចក្តីសន្និដ្ឋានផ្សេងៗទៀតដែលអាចដកស្រង់ចេញមកពីឯកសារទាំងនោះ។

## សក្ខីកម្មមុនៗ

25. សាក្សីបានផ្តល់នូវសក្ខីកម្ម ចំនួនប្រាំពីរជាមុនដល់សហព្រះរាជអាជ្ញា។

(1) បទសម្ភាសនរបស់ David CHANDLER ក្នុងខ្សែភាពយន្ត *Pol Pot et les Khmers Rouges* ដោយ ARTE, មិនមានចុះថ្ងៃទី, D69, ERN V 00172512.

(2) បទសម្ភាសន៍របស់ David CHANDLER ក្នុងខ្សែភាពយន្ត *Inside Pol Pot's Secret Prison* ដោយ Bill BRUMMEL ឆ្នាំ 2002, D69, ERN V 00172525

(3) បទសម្ភាសន៍របស់ David CHANDLER ក្នុងខ្សែភាពយន្ត *Khmer Rouge History of Genocide* ដោយ Pierr-Andre BOUTANG ឆ្នាំ 2001 D69, ERN V 00172506

(4) សៀវភៅនិពន្ធដោយ David CHANDLER មានចំណងជើងថា *The Tragedy of Cambodian History* ឆ្នាំ 1991, D91, ERN 00193067-00193488

(5) សៀវភៅនិពន្ធដោយ David CHANDLER មានចំណងជើងថា *Brother Number One: A Political Biography of Pol Pot* ក្នុង 1999, ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, ERN 00182074-00182084

(6) David CHANDLER "Strategies for Survival in Kampuchea" ក្នុង *Current History*, ក្នុងខែ មេសា ឆ្នាំ 1983, D56, S 00034698-00034703

(7) សៀវភៅនិពន្ធដោយ David CHANDLER មានចំណងជើងថា *សម្លេងពីមន្ទីរស-២១: Terror and History in Pol Pot's Secret Prison* ឆ្នាំ 1999, ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, D91/I, ERN 00192667-00192932

## ឯកសារពាក់ព័ន្ធ

26. ឯកសារដូចមានរាយនាមខាងក្រោម គឺជាឯកសារក្នុងចំណោមឯកសារផ្សេងៗទៀត ដែលមានពាក់ព័ន្ធនឹងភស្តុតាងដែលផ្តល់ដោយសាក្សីរូបនេះ៖

(1) សាក្សីក៏អាចមានលទ្ធភាពផ្តល់សាក្ខីកម្មទៅនិងសារព័ន៌របស់បណ្ណសារនៅមន្ទីរស-២១ ដោយឡែកសាក្សីក៏បានសង្ខេបការវិភាគរបស់ខ្លួននៅក្នុងសៀវភៅរបស់គាត់ផងដែរ *សម្លេងពីមន្ទីរស-២១* ទំព័រ ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, D91/I (ERN 00192667-00192932 (ភាសាអង់គ្លេស).

(2) សាក្សីក៏ធ្លាប់បានវិភាគឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនិងមន្ទីរស-២១ផងដែរ ដែលមាននៅក្នុង: សៀវភៅនិពន្ធដោយ David CHANDLER, Ben KIERNAN និង CHANTHOU Boua មានចំណងជើងថា *Pol Pot Plans the Future: Confidential Documents from Democratic Kampuchea* ឆ្នាំ1988, ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, ERN 00103989-00104170

## 3. ជ័យ សុភារ៉ា

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីបានបង្ហាញនូវភស្តុតាងពីឯកសារដើម ភស្តុតាង និងអ្វីផ្សេងៗទៀតដែលបានប្រទះឃើញនៅក្នុង និងជុំវិញបរិវេណមន្ទីរស-២១ និងមុំទួលស្លែង។ ភស្តុតាងដែលគាត់បានផ្តល់ឲ្យ មានការពាក់ព័ន្ធទៅនឹងបទចោទទី1 ទី2 និង ទី3 នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ពេលនោះសាក្សីមានអាយុ24ឆ្នាំ ភេទប្រុស សញ្ជាតិកម្ពុជា កើតនៅថ្ងៃទី24 ខែតុលា ឆ្នាំ1950។ នៅខែឧសភា ឆ្នាំ1979 គាត់បានចាប់ផ្តើមបំពេញការងារនៅកន្លែងមួយដែលគេស្គាល់ថាជាសារមន្ទីរទួលស្លែង[58] រហូតមកទល់ពេលនេះ។ បច្ចុប្បន្ន សាក្សីមានឋានៈជាអនុប្រធាននៃអគ្គនាយកដ្ឋានសារមន្ទីរ ទទួលបន្ទុកសារមន្ទីរបទឧក្រិដ្ឋប្រល័យពូជសាសន៍ទួលស្លែង នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ[59]។

## សង្ខេបភស្តុតាង

3. នៅពេលដែលសាក្សីបានចាប់ផ្តើមការងារនៅសារមន្ទីរ*ទួលស្លែង* គាត់នៅក្នុងអគារ ឃ។ គាត់រួមជាមួយបុគ្គលិកដទៃទៀត បានចងក្រងបញ្ជីឯកសារនានាដែលពួកគាត់ប្រមូលបានពីផ្ទះដែលស្ថិតនៅជុំវិញមន្ទីរឃុំឃាំង ដែលឯកសារទាំងនោះភាគច្រើនយកមកពីផ្ទះដែលស្ថិតនៅទិសបូព៌ា ខាងក្រៅរបងសារមន្ទីរក្នុងពេលបច្ចុប្បន្ននេះ[60]។ ចម្លើយសារភាពរបស់ កែ គឹមហួត ក៏ស្ថិតនៅក្នុងចំណោមឯកសារទាំងនោះដែរ[61]។ ក្រោយមកក្នុងឆ្នាំ១៩៧៩ មានអតីតអ្នកទោសនៅមន្ទីរស-២១ម្នាក់ ឈ្មោះ អ៊ុង ប៉ិច បានចូលមកធ្វើការ ហើយមានតួនាទីជាប្រធានសារមន្ទីរទួលស្លែងនេះដែរ[62]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា នៅពេលដែលឯកសារបាននាំយកមកទុកក្នុងសារមន្ទីរហើយឯកសារទាំងនោះមិនដែលបានរុះរើទេ ហើយត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ត្រីរក្សាឯកសារ។ សូម្បីតែអ្នកសិក្សាស្រាវជ្រាវក៏ត្រូវគេចាត់ឲ្យមានបុគ្គលិកគ្រប់គ្រងផងដែរ[63]។

4. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា ឯកសារទាំងនោះត្រូវបានរក្សាទុកនៅក្នុងអគារ ខ ដែលពីដើមឡើយ គឺទុកក្នុងទូឯកសារធ្វើពីកញ្ចក់រហូតដល់ឆ្នាំ1992 ដែលសាកលវិទ្យាល័យ Cornell បានធ្វើទូរ

ទើបឯកសារទាំងនោះត្រូវបានគេយកមករៀបដាក់នៅលើធ្នើទូដាក់សៀវភៅវិញ។ ក្នុងឆ្នាំ2000 សារមន្ទីរបានខ្ចីទូដែកសុវត្ថិភាពសម្រាប់រក្សាឯកសារពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយនិងឯកសារៗទៀត រួមទាំងចម្លើយសារភាពរបស់ កែ គឹមហួត ក៏ត្រូវយកមករក្សាទុកក្នុងទូដែកសុវត្ថិភាពដែរដើម្បីការពារកុំឱ្យភ្លើងឆេះ[64]។

5. សាក្សីបានបង្ហាញនូវភស្តុតាងអំពីខ្សែភាពយន្តរូបភាពឯកសារ ដែលជាការរៀបចំដោយឡែកពីការផ្តិតរូបថត ដាក់បញ្ចាំងនៅក្នុងសារមន្ទីរ *ទួលស្លែង* ក្រោមការត្រួតពិនិត្យរបស់បុគ្គលិកដែលជាមន្ត្រីក្រសួងឃោសនាការ វប្បធម៌និងព័ត៌មាន[65]។ ខ្សែភាពយន្តនោះត្រូវបានកាត់តដោយ អ៊ឹង ប៊ុច ។

## សក្ខីកម្មមុនៗ

6. សាក្សីបានផ្តល់សក្ខីកម្មចំនួនបីជាមុនជូនដល់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ ជ័យ សូភារ៉ា ដោយ ក.ស.ច.ស ចុះថ្ងៃទី 25 ខែមីនា ឆ្នាំ 2008, D 83/1, ERN 00188801-00188804 (ភាសាអង់គ្លេស).

(2) បទសម្ភាសន៍របស់ ជ័យ សូភារ៉ា ក្នុងកម្មវិធីទូរទស្សន៍កម្ពុជាប៉ុស្តិ៍លេខ 5 *Day of Hatred* ឆ្នាំ 2002, D69, ERN V 00172526 (ភាសាខ្មែរ).

(3) បទសម្ភាសន៍របស់ ជ័យ សូភារ៉ា ដោយ Peter Maguire, ចុះថ្ងៃទី 3 ខែកុម្ភៈ 2000, D61/I, ERN 00002558-00002569 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

7. សាក្សីនឹងបង្ហាញនូវឯកសារពាក់ព័ន្ធជូនក្នុងពេលសវនាការ។

## 4. DUNLOP, NIC

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ពាក់ព័ន្ធនិងមន្ទីរស-២១ សាក្សីរូបនេះបានបង្ហាញនូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការយកមនុស្សធ្វើជាទាសករ សកម្មភាពអមនុស្សធម៌ ការបង្កការឈឺចាប់ដ៏ធ្ងន់ធ្ងរ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ក្រៅច្បាប់ *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញជនជាប់ឃុំឃាំង *(141-142)*។ ភស្តុតាងដែលបង្ហាញដោយសាក្សីមានការពាក់ព័ន្ធទៅនឹងបទចោទទី1 ទី2 និងទី3 ដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីរូបនេះមានអាជីពជាអ្នកប្រកបរបរថតរូបសេរី ដែលមានទីតាំងនៅទីក្រុងបាងកក។ គាត់មានចំណាប់អារម្មណ៍ជាយូរមកហើយមកលើប្រទេសកម្ពុជា និងការវិវត្តរបស់ប្រទេសនេះ។ នៅក្នុងឆ្នាំ 1999 គាត់"បានរក **ឌុច** ឃើញជាថ្មីម្តងទៀត" ដោយគាត់បានជួប ហើយនៅចំណាំ **ឌុច** ក្នុងភូមិមួយនាភាគខាងលិចនៃប្រទេសកម្ពុជា បន្ទាប់ពីបាត់ដំណឹងពីទីកន្លែងស្នាក់អាស្រ័យរបស់ **ឌុច** អស់រយៈពេលជាងម្ភៃឆ្នាំរួចមក។ គាត់គឺជាអ្នកនិពន្ធសៀវភៅ *ពេជ្ឈឃាតបាត់ខ្លួនៈ រឿងមួយក្នុងរបបខ្មែរក្រហម* ដែលនិយាយពីជីវប្រវត្តិរបស់ **ឌុច**។ នៅក្នុងការ ស្រាវជ្រាវដើម្បីសរសេរសៀវភៅនេះ គាត់បានសម្ភាសន៍ **ឌុច** និងក្រុមគ្រួសាររបស់ **ឌុច** ព្រមទាំងមនុស្សជាច្រើនទៀតដែលបានជួប **ឌុច** ហើយគាត់ក៏បានវិភាគទៅលើឯកសារនៅទួលស្លែងផងដែរ។

3. ផ្នែកផ្សេងៗនៃសៀវភៅ *ពេជ្ឈឃាតបាត់ខ្លួន* ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងក្តី[66]។ នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតតុលាការ **ឌុច** បានបញ្ជាក់ថា **ឌុច** បានអានសៀវភៅ *ពិជ្ឈឃាតបាត់ខ្លួន* ។ **ឌុច** បានបញ្ជាក់ពីផ្នែកខ្លះដែលសាក្សីបានសរសេរហើយត្រឹមត្រូវ និងផ្នែកខ្លះដែលសរសេរមិនបានត្រឹមត្រូវទេ[67]។

4. សាក្សីក៏អាចមានលទ្ធភាពបង្ហាញនូវភស្តុតាងអំពីស្ថានភាពជុំវិញការសម្ភាសន៍នានារបស់ **ឌុច** ដែលបានរៀបចំដោយ UNHCR នៅក្នុងខែឧសភា និងខែមិថុនា ឆ្នាំ1999 ផងដែរ។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីនឹងផ្តល់ព័ត៌មានស្តីពីជីវប្រវត្តិរបស់ **ឌុច** រួមមាន ទីកន្លែងកំណើត ជីវិតពីកុមារភាព គ្រួសាររបស់ ឌុច ការសិក្សានិងការបន្តការសិក្សា និងចូលរួមបដិវត្តន៍កុម្មុយនីស្តរបស់ **ឌុច** ជាដើម[68]។ សាក្សីបានបង្ហាញនូវភស្តុតាងពីអំឡុងពេលក្នុងជីវិតដែល **ឌុច** បានកាត់ផ្តាច់ទំនាក់ទំនងជាមួយនឹងក្រុមគ្រួសារខ្លួន[69]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្ភាសន៍អ្នកនៅរស់រានមានជីវិតពី ម-១៣ ម្នាក់ ឈ្មោះ ហាម អ៊ីន[70] ដែលបានរៀបរាប់ពីតួនាទីរបស់ ឌុច ក្នុងអំឡុងឆ្នាំ1973 នៅពេលដែល ហាម អ៊ីន ជាអ្នកទោសមួយរូបនៅទីនោះ។ ហាម អ៊ីន ដែលពេលនេះបានស្លាប់បាត់ទៅហើយនោះ បានប្រាប់សាក្សីថា គាត់ត្រូវបាន **ឌុច** សួរចម្លើយ ហើយ **ឌុច** បានប្រាប់គាត់ថា គាត់នឹងត្រូវដោះលែងឲ្យមានសេរីភាពប្រសិនបើគាត់យល់ព្រមតាមដានអ្នក ដែលជាប់គុកជាមួយគ្នានោះ[71]។ ហាម អ៊ីន បានប្រាប់សាក្សីផងដែរ ពីស្ថានភាពនៃការឃុំខ្លួនដែលយ៉ាប់យ៉ឺនបំផុត ការសម្លាប់និងការធ្វើទារុណកម្ម រួមទាំងការសម្លាប់រង្គាលទៅលើអ្នកទោសចំនួន200 នាក់ក្នុងរយៈពេលតែពីរថ្ងៃ និងការសម្លាប់អ្នកទោសរាប់រយអ្នកទៀត ដែលស្ថិតនៅក្នុងគុកក្នុងខែមេសា ឆ្នាំ1975[72]។ សាក្សីបានផ្តល់នូវភស្តុតាងដែលគាត់បានសម្ភាសន៍ ចាន់ វឿន ដែលបានប្រាប់គាត់ថា **ឌុច** បានសម្លាប់មនុស្សដោយផ្ទាល់ដៃ "ជាច្រើន" នៅមន្ទីរម-១៣ ហើយ ចាន់ វឿន ផ្ទាល់ធ្លាប់បានឃើញដោយផ្ទាល់ភ្នែកពេលដែល **ឌុច** បាញ់សម្លាប់អ្នកទោស[73]។

6. សាក្សីបានបង្ហាញនូវភស្តុតាងពី **ឌុច** ហើយនិងមនុស្សរបស់ **ឌុច** នៅមន្ទីរម-១៣ ដែល "បានជួយគ្នាសំអាតទាហានទីក្រុងក្រោយពីរដ្ឋាភិបាល លន់ ណុល បានដួលរំលំ"[74] មួយយប់មុនពេល **ឌុច** ត្រឡប់ទៅស្រុកកំណើតដែលអមដោយទាហានការពារខ្លួនផងនោះ[75]។ សាក្សីបានបង្ហាញនូវភស្តុតាងពីដំណើរទស្សនកិច្ចរបស់ **ឌុច** ទៅកាន់អតីតសាលារៀនរបស់ខ្លួន ដែលនៅទីនោះ ឌុច បានយកសៀវភៅដែលមានចំណងជើងថា *ទារុណកម្ម* (*La Torture*) និពន្ធដោយ Alec Mellor និយាយពីការកើតមាននូវទារុណកម្មនារបបសម័យទំនើបនៃប្រទេសបារាំង។ ក្រោយមកសៀវភៅនេះ ត្រូវបានគេរក្សាទុកនៅក្នុងបន្ទប់មួយសម្រាប់ប្រើប្រាស់ក្នុងការធ្វើទារុណកម្មទៅលើជនបរទេសនៃជាប់ឃុំនៅមន្ទីរស-២១[76]។

7. អ្នកសួរចម្លើយនៃមន្ទីរស-២១ ឈ្មោះ ប្រាក់ ខន បានប្រាប់ទៅសាក្សីពីវិធីដែល **ឌុច** ប្រើក្នុងការពិនិត្យមើលការសួរចម្លើយដោយ **ឌុច** ត្រូវយកចម្លើយសារភាពទៅអាន ហើយបញ្ជូនត្រឡប់មកវិញដោយមានចំណារឱ្យសួរចម្លើយបន្ថែមទៀតមកជាមួយ[77]។

8. សាក្សីបានបង្ហាញនូវភស្តុតាងពីការងាររបស់ **ឌុច** ដែលបានសរសេរនៅក្នុងឆ្នាំ1978 *ផែនការរួមចុងក្រោយ* (*The Last Joint Plan*) ជាឯកសារចងក្រង និងសង្ខេបចម្លើយសារភាពរាប់រយ ដែលសាក្សីបានរៀបរាប់ថា "ខ្លឹមសាររបស់ឯកសារនោះភាគច្រើន... គឺជាគម្រោងនៃរដ្ឋប្រហារប្រឆាំងនឹងអង្គការ"[78]។ សាក្សីក៏បានបរិយាយផងដែរពីការវិភាគរបស់គាត់ទៅលើចម្លើយសារភាពរបស់ កែ គឹមហួត ជាអតីតគ្រូរបស់ **ឌុច** ដែលត្រូវគេចាប់ខ្លួន និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ហើយ "អំពើក្បត់" របស់គាត់ប្រឆាំងនឹងអង្គការផ្ទាល់ត្រូវបាន ឌុច កត់ត្រានៅក្នុង *The Last Joint Plan*[79]។

9. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា បន្ទាប់ពីរបស់របបប្រល័យពូជសាសន៍បានដួលរំលំ **ឌុច** "នៅតែមានភាពជិតស្និទជាមួយនឹងថ្នាក់ដឹកនាំ" របស់កម្ពុជាប្រជាធិបតេយ្យដដែល ដោយសាក្សីបានប៉ាន់ស្មានថា "**ឌុច** ច្បាស់ជាមាននរណាម្នាក់នៅក្នុងបក្សការពារមិនខាន ជននោះអាចជា សុន សេន ដែលជាអតីតចៅហ្វាយរបស់ **ឌុច**"[80]។ សាក្សីបានបង្ហាញនូវភស្តុតាងពីបទសម្ភាសន៍របស់គាត់ជាមួយនឹងអ្នកកគង្វាលឈ្មោះ Christopher Lapel ជាបុគ្គលដែល **ឌុច** គោរពក្នុងពេលដែលគាត់ប្រកាន់យកគ្រីស្តសាសនា[81]។

10. សាក្សីបានបង្ហាញនូវភស្តុតាងពីស្ថានការណ៍នានា នាដើមឆ្នាំ1999 ដែលគាត់បានជួប **ឌុច** ចំនួនពីរលើក (ពេលនោះ **ឌុច** ជាអ្នកផ្សព្វផ្សាយសាសនាម្នាក់) នៅភូមិ *តាសាញ់* ស្រុក *សំឡូត*[82]។ ក្រោយមកទៀតនៅខែមេសា ឆ្នាំ១៩៩៩ សាក្សីនិង Nate THAYER បានសម្ភាសន៍ ឌុច ដែលនៅក្នុងបទសម្ភាសន៍នោះ ឌុច បានទទួលសារភាពដោយចំហរពីតួនាទីរបស់គាត់នៅមន្ទីរស-២១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[83]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

11. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានសម្ភាសន៍ Ho Van Tay ជាអ្នកកាសែតមួយរូប ដែលជាជនមួយក្នុងចំណោមមនុស្សដំបូងមួយក្រុមដែលបានរកឃើញមន្ទីរស-២១ មុនគេ កាលពីថ្ងៃទី7 ខែមករា ឆ្នាំ 1979 ក្នុងពេលដែលវៀតណាមបណ្តេញខ្មែរក្រហមពីទីក្រុងភ្នំពេញ[84]។ Van Tay បានរៀបរាប់ប្រាប់សាក្សីយ៉ាងលំអិតពីសាកសព ដែលទើបនឹងត្រូវគេសម្លាប់ថ្មីៗ ឧបករណ៍ដែលគេប្រើសម្រាប់ធ្វើ ទារុណកម្ម

គំនរឯកសារផ្សេងៗ ព្រមទាំងសភាពលក្ខណៈ ដែលទិដ្ឋភាពទាំងអស់នេះ ទំនងជាបង្ហាញថា ទើបតែមានមនុស្សចាកចេញពីទីកន្លែងនេះថ្មីៗ[85]។ សាក្សីបានផ្តល់នូវភស្តុតាងពីបទសម្ភាសន៍របស់ខ្លួនជាមួយនឹងបណ្តាប្រជាជនដែលរស់នៅក្នុងមន្ទីរម-១៣ ផ្សេងៗទៀត ដូចជា អតីតអ្នកទោសឈ្មោះ ហាម អ៊ីន ហើយសាក្សីក៏ត្រូវបានគេបង្ហាញឱ្យស្គាល់ពីទីតាំងទីពីររបស់មន្ទីរម-១៣ ផងដែរ ដែលគេហៅថា *ត្រពាំងច្រាប*[86]។

12. សាក្សីបានបង្ហាញនូវភស្តុតាងពីសភាពលក្ខណៈនៅក្នុងមន្ទីរស-២១ ដែលបានប្រែក្លាយទៅជាសារមន្ទីរទួលស្លែង ពេលដែលគាត់បានមកទស្សនាលើកដំបូងក្នុងឆ្នាំ1989[87]។

13. សាក្សីបានផ្តល់នូវភស្តុតាងដែលគាត់បានសម្ភាសន៍អតីតអ្នកថតរូបនៅមន្ទីរស-២១ ឈ្មោះ ញ៉ែម អេន[88]។

14. សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្ភាសន៍របស់គាត់ជាមួយនឹងប្រជាជន ដែលរស់នៅជិតតំបន់*ទួលស្លែង* ដោយគេបានប្រាប់គាត់ថាមានមនុស្សនៅរស់ ដែលពួកគេបានប្រទះឃើញពេលដែលពួកគេត្រឡប់មកតំបន់នេះវិញក្រោយឆ្នាំ1979[89]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

15. សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្ភាសន៍របស់គាត់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ជុំ ម៉ី ដែលបានរៀបរាប់យ៉ាងលំអិតពីប្រវត្តិរបស់គាត់ ដែលស្ថិតនៅក្នុងការឃុំខ្លួន ត្រូវគេសួរ ចម្លើយ និងធ្វើទារុណកម្មក្នុងមន្ទីរស-២១[90]។ សាក្សីក៏បានលើកឡើងពីបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ ដែលបានធ្វើកាលពីថ្ងៃទី6 ខែវិច្ឆិកា ឆ្នាំ1978 ដែលមានឈ្មោះ ជុំ ម៉ី ក្នុងនោះហើយ មានចារជាលាយលក្ខណ៍អក្សរថា “ទុកសិន”[91]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

16. សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្ភាសន៍របស់ខ្លួនជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ជុំ ម៉ី ដែលបានរៀបរាប់យ៉ាងលំអិតពីប្រវត្តិរបស់គាត់ដែលស្ថិតនៅក្នុងការឃុំខ្លួន ត្រូវគេសួរ ចម្លើយ និងធ្វើទារុណកម្មក្នុងមន្ទីរស-២១[92]។

## ការសួរចម្លើយ

17. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានសិក្សាទៅលើឯកសាររបស់មន្ទីរស-២១ មួយ ដែលមានចំណងជើងថា "វិធីសាស្ត្រក្នុងការសួរចម្លើយ"[93] និងការសិក្សារបស់គាត់ទៅលើឯកសារផ្សេងៗជាច្រើនទៀតនោះ គាត់បានឃើញលិខិតឆ្លើយឆ្លង ដែលសរសេរជាលាយលក្ខណ៍រវាង **ឌុច** និងអ្នកទោសមិនបានបញ្ជាក់ឈ្មោះម្នាក់ ដោយអ្នកទោសនោះបានអង្វរសុំរួចជីវិត ប៉ុន្តែត្រូវ **ឌុច** តបទៅវិញថា "ខ្ញុំដឹងត្រឹមតែថា អ្នកឯងមិនស្មោះត្រង់នឹងបក្ស"[94]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្ភាសន៍របស់ខ្លួនជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ជុំ ម៉ី ដែលបានរៀបរាប់យ៉ាងលំអិតពីប្រវត្តិ របស់គាត់ដែលស្ថិតនៅក្នុងការឃុំខ្លួន ត្រូវគេសួរចម្លើយ និងធ្វើទារុណកម្ម ក្នុងមន្ទីរស-២១[95]។ សាក្សីបានផ្តល់នូវភស្តុតាងពីការសម្ភាសន៍របស់គាត់ជាមួយនឹងអតីតអ្នកសួរចម្លើយ នៅមន្ទីរស-២១ ឈ្មោះ ប្រាក់ ខន ដែលបានរៀបរាប់ពីការសួរចម្លើយនានា នៅមន្ទីរស-២១[96]។ ប្រាក់ ខន បានប្រាប់ទៅសាក្សីពីវិធីដែល **ឌុច** ប្រើក្នុងការពិនិត្យការសួរចម្លើយ ដោយ **ឌុច** ត្រូវយកចម្លើយសារភាពតាំងនោះទៅអាន ហើយបញ្ជូនត្រឡប់មកវិញដោយមានចំណារឲ្យបន្ត ការសួរចម្លើយ[97]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា រាល់ចម្លើយសារភាពដែលពាក់ព័ន្ធ និងខ្លួន ត្រូវតែលុបចោល មុននឹង **ឌុច** បញ្ជូនឯកសារទៅឲ្យថ្នាក់ដឹកនាំជាន់ខ្ពស់នានា[98]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

18. សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្ភាសន៍របស់គាត់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ជុំ ម៉ី ដែលគាត់បានរៀបរាប់យ៉ាងលំអិតពីប្រវត្តិរបស់គាត់ដែលស្ថិតនៅក្នុងការឃុំខ្លួន ត្រូវគេសួរចម្លើយ និងធ្វើទារុណកម្មក្នុងមន្ទីរស-២១[99]។ សាក្សីបានផ្តល់ភស្តុតាងតាមរយៈការរៀបរាប់របស់អតីតអ្នកសួរចម្លើយនៅមន្ទីរស-២១ ឈ្មោះ ប្រាក់ ខន ពីការធ្វើទារុណកម្ម នៅមន្ទីរស-២១[100] និងការដែល **ឌុច** ធ្វើទារុណកម្មទៅលើអ្នកទោសដោយផ្ទាល់ដៃ ដោយឆក់ខ្សែភ្លើង និងគ្រាមួយ ដែល **ឌុច** បានវាយអ្នកសួរចម្លើយម្នាក់ដែលបានប្រព្រឹត្តកំហុស[101]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

19. សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្ភាសន៍របស់ខ្លួនជាមួយនឹង ចាន់ វឿន ដែលបានប្រាប់គាត់ថា នៅមន្ទីរម-១៣ **ឌុច** បានសម្លាប់មនុស្សដោយផ្ទាល់ដៃ "ជាច្រើន" ហើយ ចាន់ វឿន បានឃើញដោយផ្ទាល់ភ្នែកពេលដែល **ឌុច** បាញ់អ្នកទោសម្នាក់ស្លាប់[102]។

## បញ្ហាផ្សេងៗ

20. សាក្សីបានបង្ហាញនូវភស្តុតាងអំពីសភាពនៃការប្រមូលឯកសារនៅមន្ទីរស-២១ ក្នុងសារមន្ទីរទួលស្លែង។

## សក្ខីកម្មមុនៗ

21. សាក្សីបានមិនបានផ្តល់សក្ខីកម្មជាមុនដល់សហព្រះរាជអាជ្ញាទេ។

## ឯកសារពាក់ព័ន្ធ

22. ឯកសារដូចខាងក្រោមនេះ គឺជាឯកសារមួយក្នុងចំណោមឯកសារផ្សេងៗទៀត ដែលមានការពាក់ព័ន្ធដល់ភស្តុតាងដែលផ្តល់ដោយសាក្សីរូបនេះ:

(1) DUNLOP, Nic *ពិឃាតបាត់ខ្លួន* ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ERN 00078697-00078699 (ភាសាអង់គ្លេស)

## 5. ETCHESON, CRAIG

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

*Evidence Summary in Progress*

**6. KA SUNBAUNAT**

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ពាក់ព័ន្ធនិងមន្ទីរស-២១ សាក្សីរូបនេះបានបង្ហាញនូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)*។ ភស្តុតាងដែលបង្ហាញដោយសាក្សីមានការពាក់ព័ន្ធជាមួយនឹងបទចោទទី1 ទី2 និងទី3 ដែលមាននៅក្នុងដីការបញ្ជូនរឿងឲ្យជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីរូបនេះជាសាស្ត្រាចារ្យចិត្តវេជ្ជវិជ្ជា និងជាព្រឹទ្ធបុរសមហាវិទ្យាល័យវេជ្ជសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនាទីក្រុងភ្នំពេញ។ សាក្សីរូបនេះ រួមជាមួយនឹងវេជ្ជបណ្ឌិត Francoise Sironi-Guilbard សរសេរនូវរបាយការណ៍ជំនាញខាងចិត្តវិទ្យាមួយរបស់ **ឌុច** បានធ្វើនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ដែលឯកសារនេះត្រូវបានយកមកប្រើប្រាស់ជាផ្នែកមួយនៃសំណុំរឿងក្តីផងដែរ។

## សក្ខីកម្មមុនៗ

3. សាក្សីបានផ្តល់នូវសក្ខីកម្មចំនួនមួយជាមុនជូនដល់សហព្រះរាជអាជ្ញាៈ

   (1) របាយការណ៍វាយតម្លៃចិត្តសាស្ត្ររបស់ កាំង ហ្កេកអ៊ាវ , ហៅ **ឌុច**, ចុះថ្ងៃទី31 ខែមីនា ឆ្នាំ2008, B1/IV, ERN 00177506-00177576 (FRE), ERN 00211082-00211151 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

សាក្សីនឹងបង្ហាញនូវឯកសារពាក់ព័ន្ធក្នុងពេលសវនាការ។

**7. SIRONI-GUILBARD FRANCOISE**

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីរូបនេះបានបង្ហាញនូវភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)*។ សក្ខីកម្មរបស់គាត់មានការពាក់ព័ន្ធទៅនឹងបទចោទទី1 ទី2 និងទី3 ដែលមានចែងក្នុងដីកាបញ្ជូនរឿងឱ្យជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីរូបនេះជាអ្នកជំនាញចិត្តវិទ្យាជនជាតិបារាំង នៅសាកលវិទ្យាល័យ Paris 8។ សាក្សីរួមជាមួយនិងវេជ្ជបណ្ឌិត KA Sunbaunat បានសរសេររបាយការណ៍ជំនាញខាងចិត្តវិទ្យាមួយរបស់ ឌុច ដែលបានធ្វើនៅថ្ងៃទី31 ខែមីនា ឆ្នាំ2008 ហើយឯកសារនេះត្រូវបានយកមកប្រើប្រាស់ជាផ្នែកមួយនៃសំណុំរឿងក្ដីផងដែរ។

## សក្ខីកម្មមុនៗ

3. សាក្សីបានផ្ដល់សក្ខីកម្មចំនួនមួយជាមុនជូនដល់សហព្រះរាជអាជ្ញា:

(1) របាយការណ៍វាយតម្លៃចិត្តសាស្ត្ររបស់ កាំង ហ្គេកអ៊ាវ , ហៅ **ឌុច** បានធ្វើនៅថ្ងៃទី 31 ខែមីនា ឆ្នាំ2008, B1/IV, ERN 00177506-00177576 (FRE), ERN 00211082-00211151 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

សាក្សីនឹងបង្ហាញនូវឯកសារពាក់ព័ន្ធក្នុងពេលសវនាការ។

# II. ជនរងគ្រោះនៃមន្ទីរ ស-២១

## ៨. វ៉ាន់ ណាត

### ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ពាក់ព័ន្ធនិងមន្ទីរស-២១ សាក្សីរូបនេះបានបង្ហាញនូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការយកមនុស្សធ្វើជាទាសករ សកម្មភាពអមនុស្សធម៌ ការបង្កការឈឺចាប់ដ៏ធ្ងន់ធ្ងរ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្មនិងអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញជនជាប់ឃុំឃាំង *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងដែលបង្ហាញដោយសាក្សីរូបនេះ មានការពាក់ព័ន្ធទៅនឹងបទចោទទី1 ទី2 និងទី3 ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ។

### ជីវប្រវត្តិរបស់សាក្សី

2. កាលពីថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានអាយុ29 ភេទប្រុស សញ្ជាតិកម្ពុជា កើតនៅថ្ងៃទី5 ខែមេសា ឆ្នាំ1946[103]។ មុនថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានរបរជាអ្នកគូររូបនៅក្នុងខេត្តបាត់ដំបង។ នៅថ្ងៃទី20 ខែធ្នូ ឆ្នាំ1977 គាត់ត្រូវបានឈ្លបសហករចាប់ខ្លួន។ ជាដំបូង គាត់ត្រូវគេឃុំខ្លួនធ្វើទារុណកម្ម និងសួរចម្លើយនៅវត្តកណ្តាល ប៉ុន្តែនៅថ្ងៃទី7 ខែមករា ឆ្នាំ1978 គេក៏យកគាត់ទៅមន្ទីរ ស-២១[104] ដែលនៅទីនោះ គាត់ត្រូវគេដាក់គុករហូតដល់របបនោះត្រូវផុតរលត់។ គាត់ត្រូវគេទុកជីវិតឲ្យជាបន្ទាន់ដោយសារតែគាត់មានជំនាញជាវិចិត្រករចំណានមួយរូប[105]។ សាក្សីបានត្រឡប់ទៅកាន់មន្ទីរ ស-២១ នៅក្នុងខែសីហា ឆ្នាំ1979 ហើយត្រូវបានគេស្នើឲ្យជួយរៀបចំសារមន្ទីរទួលស្លែង នៅមុនពេលដែលសារមន្ទីរទួលស្លែងបើកជាស្ថាពរនៅថ្ងៃទី7 ខែមករា ឆ្នាំ1980 សាក្សីបានគូររូបភាពពណ៌ធម្មជាតិជាច្រើនផ្ទាំង ដែលត្រូវបានដាក់តាំងរហូតមកទល់សព្វថ្ងៃនេះ[106]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីបានបង្ហាញនូវភស្តុតាងពី **ឌុច** ដែលគេស្គាល់ថាជា "បងខាងកើត/បូព៌ា" ជាប្រធានគ្រប់គ្រងមន្ទីរ ស-២១ទាំងស្រុង[107] ជាបុគ្គល "ដែលបានដឹងឮគ្រប់បែបយ៉ាង និងបានគ្រប់គ្រងគ្រប់សកម្មភាព រួមទាំងការចេញបញ្ជា ការកែប្រែ ការប្រើទារុណកម្ម ដោយសារបុគ្គលនេះជាប្រធានជាន់ខ្ពស់"[108]។ **ឌុច** ចូលមកក្នុងគុក "ស្ទើរតែរៀងរាល់ថ្ងៃ" ប៉ុន្តែសាក្សីមិនបានឃើញ **ឌុច** ពីកន្លែងណាក្រៅពីកន្លែងគូររូបនោះ ទេ[109]។ **ឌុច** តែងតែមកមើលគាត់ ហើយបានប្រាប់គាត់ថា ខ្លួនគឺជាប្រធាននៅមន្ទីរស-២១[110]។ គ្រប់ពេលដែល **ឌុច** មកដល់គុក គ្រប់ៗគ្នាត្រូវតែគោរព **ឌុច**[111]។ មានពេលមួយនោះ ពួកអ្នកសួរចម្លើយបានមកមើលគាត់គូររូប ហើយ **ឌុច** បាននិយាយទៅកាន់ពួកនោះដោយមានវត្តមានរបស់សាក្សី។ **ឌុច** បានសួរទៅកាន់អ្នកសួរចម្លើយទាំងនោះពីការឆ្លើយរបស់អ្នកទោស ហើយដាក់បញ្ជាឱ្យពួកគេសួរឱ្យសាហាវ[112]។ សាក្សីក៏បានឮ **ឌុច** បញ្ជាកម្មាភិបាលម្នាក់ឱ្យបន្តប្រតិបត្តិការងាររបស់ខ្លួនដែលធ្វើឱ្យកម្មាភិបាលនោះភ័យឡើងមុខស្លេក[113]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការសម្រេចភ្លាមនានារបស់ **ឌុច** ថាជនណាត្រូវទុកឱ្យរស់ និងជនណាត្រូវសម្លាប់ចោល[114]។

4. សាក្សីបានបង្ហាញភស្តុតាងពីពេលដែលគាត់បានជួប **ឌុច** ពេលដំបូងនៅក្នុងគុក ហើយ **ឌុច** បានសួរគាត់មុនពេលដែលបញ្ជាឱ្យគាត់គូររូបរបស់ ប៉ុល ពត តាមរូបថតថា គាត់ជាកូនកាត់ចិនឬ ហើយគាត់ចេះគូររូបនេះអស់រយៈពេលប៉ុន្មានហើយ[115]។ នៅពេលដែល **ឌុច** មកមើលគាត់គូររូប (**ឌុច**) "សើចឮខ្លាំង" និងសប្បាយចិត្តណាស់[116]។

5. សាក្សីបានបង្ហាញនូវភស្តុតាងពីហេតុការណ៍ដែល ប៊ូ ម៉េង ត្រូវបានគេនាំត្រឡប់ទៅ បន្ទប់ឃុំខ្លួនវិចិត្រករដោយជាប់ច្រវាក់ និងមានរបួសយ៉ាងធ្ងន់ធ្ងរ។ ឌុច បានបញ្ជា ប៊ូ ម៉េង ថ្វាយបង្គំខ្លួននៅចំពោះមុខសាក្សី ហើយ **ឌុច** បានជេរប្រទេច និងធាក់ ប៊ូ ម៉េង ត្រង់ក្បាល ធ្វើឱ្យគាត់សន្លប់នៅលើកម្រាលឥដ្ឋ។ បន្ទាប់មក **ឌុច** បាននិយាយហើយថែមទាំងសើចយ៉ាងព្រៃផ្សៃទៀតថា "អញទ្រាំមើលមុខវាមិនបានទេ" មានន័យថា ប៊ូ ម៉េង "លែងមានប្រយោជន៍ទៀតហើយ" ដូច្នេះបើ "ទុកធ្វើជីវាប្រសើរជាង"។ សាក្សីបានស្នើសុំឱ្យ **ឌុច** ទុកឱកាសដល់ ប៊ូ ម៉េង ម្តងទៀត ហើយ **ឌុច** ក៏បានឆ្លើយតបថា ប្រសិនបើ ប៊ូ ម៉េង បរាជ័យម្តងទៀត ឯង ណាត នឹងត្រូវទណ្ឌកម្ម[117]។

6. សាក្សីបានបង្ហាញនូវភស្តុតាងបញ្ជាក់ពីពេលដែលគាត់បានចាកចេញពីមន្ទីរស-២១ នៅវេលាថ្ងៃត្រង់ នាថ្ងៃទី7 ខែមករា ឆ្នាំ1979 គាត់បានឃើញ **ឌុច** ចាន់ និងទាហានប្រដាប់ដោយអាវុធជាច្រើន នាក់ទៀត ឈរនៅកាច់ជ្រុងផ្លូវ360[118]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

7. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់ត្រូវគេឃុំខ្លួននៅមន្ទីរស-២១ អស់រយៈពេលមួយឆ្នាំ ចាប់ពីខែមករា ឆ្នាំ1978 ដល់ខែមករា ឆ្នាំ1979។ គាត់ត្រូវបានគេដឹកមកមន្ទីរស-២១ តាមរយៈក្បួនឡានចំនួនពីរ នៅក្នុងឡានដែលគាត់ជិះនោះ មានអ្នកទោសដែលគេដាក់ខ្នោះរួមគ្នាជាបីជួរ ហើយក្នុងមួយជួរៗមានគ្នាប្រាំមួយនាក់ មានអ្នកបើកបរម្នាក់ អ្នកកាន់បញ្ជីឈ្មោះម្នាក់ និងអ្នកយាមពីរនាក់[119]។ ឡាននោះឈប់នៅផ្លូវ360 គាត់ក៏ត្រូវគេបណ្តើរចូលមន្ទីរស-២១ ហើយត្រូវគេសួរនាំពីប្រវត្តិសង្ខេបរបស់គាត់[120]។ អ្នកទោសទាំងនោះត្រូវគេចងមុខ ចងខ្សែទាក់ករួមគ្នា ថតរូប និងបន្ទាប់មកត្រូវគេបណ្តើរយកទៅបន្ទប់ឃុំឃាំង។ សាក្សីត្រូវគេយកទៅជាន់លើនៃអគារ ឃ ហើយដាក់ខ្នោះរួមជាមួយនឹងអ្នកទោសម្ភៃអ្នកផ្សេងទៀតដែលតំរៀបជាជួរ[121]។

8. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានដឹងថា បន្ទប់ឃុំជាន់ខាងលើទុកសម្រាប់ឃុំអ្នកទោស "ឋានៈទាប" ហើយបន្ទប់ឃុំខ្នាតតូចដាក់អ្នកទោសបានតែម្នាក់ដែលស្ថិតនៅជាន់ក្រោម ទុកសម្រាប់ឃុំអ្នកទោសដែលមាន "ឋានៈខ្ពស់"[122]។ ប្រពន្ធរបស់អ្នកទោសទាំងនោះ ត្រូវឃុំខ្លួននៅបន្ទប់ឃុំខ្លួនខ្នាតធំស្ថិតនៅជាន់ទីពីរក្នុងអគារ គ រីឯអ្នកទោសស្រ្តីដែលនៅលីវវិញ ត្រូវគេដាក់ក្នុងបន្ទប់ឃុំតូចៗជាន់ក្រោម[123]។ នៅពេលដែលសាក្សីត្រឡប់ទៅ ទួលស្លែង វិញ "ក្នុងខែវិច្ឆិកា ឬធ្នូ ឆ្នាំ1979" គាត់បានឃើញបទបញ្ជាសរសេរដោយដៃសម្រាប់អ្នកទោសនៅលើក្តារខៀន ប៉ុន្តែដោយពីមុនមកគាត់ផ្ទាល់មិនត្រូវបានគេសួរចម្លើយ គាត់មិនបានដឹងពីបទបញ្ជាទាំងនោះទេ[124]។

9. សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញថា អគារដែលស្ថិតនៅខាងត្បូងនៃ អគារ ក ចន្លោះផ្លូវ350 និង 360 ក៏ត្រូវគេប្រើសម្រាប់ឃុំខ្លួន និងសួរចម្លើយអ្នកទោសផងដែរ[125]។ គាត់បានឮអ្នកយាមនិយាយប្រាប់គ្នាពីបន្ទប់ឃុំថ្មីៗនៅក្នុងអគារ ក ថាជា "គុកពិសេស" ទុកសម្រាប់ដាក់អ្នកទោសដែលមានឋានៈខ្ពស់ៗ[126]។ សាក្សីបានដឹងថា បន្ទាប់ពីឆ្នាំ1979 ពីផ្នែកខាងក្រោយរហូតដល់ផ្នែកខាងលិចនៃមន្ទីរស-២១ គឺជាកន្លែងរោងជាងឈើ ជាងដែក ជួសជុលរថយន្ត កន្លែងចិញ្ចឹមជ្រូក ដាំស្ពៃសម្រាប់អ្នកទោស និងជាកន្លែងបោកគក់[127]។

10. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា រយៈពេលមួយខែ[128] បន្ទាប់ពីគាត់ចូលមកដល់មន្ទីរស-២១ គាត់ត្រូវប្តូរទៅបង្ខាំងនៅក្នុងបន្ទប់មួយក្រោមការឃាមកាមយ៉ាងហ្មត់ចត់ ហើយគេប្រាប់គាត់ឱ្យគូររូប។ ក្នុងពេលដែលគាត់គូររូប គាត់មានឱកាសឃើញដោយផ្ទាល់ភ្នែកចំពោះការនាំអ្នកទោសចេញ-ចូលក្នុងមន្ទីរស-២១[129]។

11. សាក្សីបានដឹងពីបញ្ជីឈ្មោះវាយអង្គុលេខដែលមានឈ្មោះរបស់ខ្លួននៅមន្ទីរស-២១ ដោយមានចំណាររបស់ ឌុច ជាទឹកខ្មៅពណ៌ក្រហមដាក់ថា "ទុកមួយគ្រាសិន"[130]។

12. សាក្សីបានធ្វើការប៉ាន់ស្មានថាមានអ្នកទោស "មិនតិចជាមួយម៉ឺននាក់ទេ" ដែលត្រូវឃុំខ្លួននៅមន្ទីរ ស-២១[131]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

13. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា **ឌុច** ត្រូវបានគេស្គាល់ថាជា "បងឌុច" ផងដែរ ដោយមានឋានៈជាប្រធានគ្រប់គ្រងមន្ទីរស-២១ទាំងមូល ហើយ ហ៊ ("បងបស្ទឹម") មានឋានៈជាអនុប្រធាន កងទ័ព[132]។ ម៉ម ណៃ ហៅ ចាន់ គឺជាងអនុប្រធានទទួលបន្ទុកសួរចម្លើយ ប៊ុន ជាអនុរបស់ ម៉ម ណៃ, ហ៊ឹម ហ៊ុយ គឺជាអ្នកអមដំណើរប្រធានពេលដឹក អ្នកទោសទៅខាងក្រៅ ប៉េង និង ហ៊ឹម ហ៊ុយ ជាអ្នកយកមនុស្សទៅសម្លាប់ ហើយ សួស ធី ជាអ្នកទទួលបន្ទុកខាងបញ្ជីឈ្មោះ។ គាត់បានដឹងពីតួនាទីទាំងអស់នេះនៅពេលដែលគាត់គូរគំនូរ[133]។ ប្រាក់ ខន គឺជាអ្នកសួរចម្លើយ ហើយ ញ៉ែម អេន ជាអ្នកថតរូប[134]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

14. សាក្សីបានបង្ហាញនូវភស្តុតាងពីឡានដែលដឹកគាត់ចូលមកមន្ទីរស-២១នោះ មានអ្នកទោសនារីម្នាក់ និងក្មេងចំនួនពីរនាក់[135]។ នៅពេលដែលគាត់បានមកដល់មន្ទីរស-២១ជាដំបូង អគារទាំងបួនគឺពោរពេញទៅដោយអ្នកទោស[136]។ ប្រពន្ធរបស់អ្នកទោសទាំងនោះត្រូវគេឃុំខ្លួននៅក្នុងបន្ទប់ឃុំខ្លួនខ្នាតធំស្ថិតនៅជាន់ទីពីរ ក្នុងអគារ គ ប៉ុន្តែអ្នកទោសស្ត្រីនៅលើវត្រូវឃុំខ្លួននៅក្នុងបន្ទប់ឃុំខ្លួនខ្នាតតូចៗជាន់ខាងក្រោម[137]។ សាក្សីបានឃើញជនបរទេស ដែលត្រូវគេឃុំដោយឡែកនៅក្នុងបន្ទប់ឃុំខ្លួនតូចៗ[138] នៅក្នុងខែកក្កដា ឆ្នាំ 1978 គាត់បានឃើញអ្នកទោស "ប្រហែលជាជនជាតិអាមេរិចកាំង" ចំនួនពីរនាក់ នៅក្នុងខែធ្នូ ឆ្នាំ1978 មានអ្នកទោស "ប្រហែលជាជនជាតិអូស្ត្រាលី" ចំនួនពីរនាក់ ហើយមានថ្ងៃមួយនោះ គាត់បានឃើញជនជាតិវៀតណាមប្រហែលជាប្រាំពីរទៅប្រាំបីនាក់ក្នុងឯកសណ្ឋានទាហាន[139]។ ក្នុងពាក់កណ្តាលឆ្នាំ

00288881



1978 គេបានបញ្ជូនអ្នកទោសមកពីភូមិភាគបូព៌ាចូលមកក្នុងគុកយ៉ាងច្រើនជារៀងរាល់ថ្ងៃ សាក្សីបានឃើញអ្នកទោសរាប់រយនាក់ ដែលមើលទៅសុទ្ធតែជាទាហាន ដែលត្រូវគេបញ្ជូនមកឃុំខ្លួនត្រឹមតែមួយថ្ងៃពីរប៉ុណ្ណោះ។ បន្ទាប់មកក្នុងខែសីហា និងខែកញ្ញា មន្ទីរឃុំឃាំងមានសភាពកាន់តែស្ងាត់ទៅៗ សូម្បីតែអ្នកយាមអ្នកទោសនៅមន្ទីរស-២១ ក៏ត្រូវគេចាប់និងឃុំខ្លួនដែរ[140]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

15. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា បន្ទាប់ពីថតរូបរួចហើយ គាត់ត្រូវគេចងជើងដាក់ក្នុងបន្ទប់ឃុំឃាំងរួម ជាមួយអ្នកទោស50 នាក់ផ្សេងទៀត[141]។ គេឱ្យគាត់ហូបត្រឹមតែបបរាវចំនួនពីរពេលក្នុងមួយ ថ្ងៃ គឺនៅម៉ោង8ព្រឹក និង8យប់ ហើយមិនសូវមានទឹកហូបទេ[142]។ អ្នកទោសត្រូវអ្នកយាមគុកបាញ់ទឹកសំអាតជារៀងរាល់បួនថ្ងៃម្តង ដោយប្រើទុយោបាញ់ពីមាត់ទ្វារបន្ទប់ឃុំឃាំង[143]។ សុខភាពរបស់គាត់បានចុះខ្សោយយ៉ាងខ្លាំងពេញរយៈពេលមួយខែ ដែលគាត់ត្រូវគេឃុំខ្លួននៅក្នុងបន្ទប់ឃុំរួម ហើយទោះបីជាមានពេទ្យសម្រាប់ព្យាបាលជាមូលដ្ឋានសម្រាប់អ្នកមានជម្ងឺក៏ដោយ ក៏មានអ្នកទោស "ជាច្រើន" បានស្លាប់នៅពេលយប់[144]។

## ការសួរចម្លើយ

16. សាក្សីបានបង្ហាញនូវភស្តុតាងពីការសួរចម្លើយភាគច្រើន ដែលបានធ្វើឡើងនៅក្រៅរបងមន្ទីរស-២១[145] ដែលស្ថិតនៅក្នុងអគារ ក ដែលនៅទីនោះ មានបន្ទប់ឃុំឃាំងមួយសម្រាប់អ្នកទោសម្នាក់ ការសួរចម្លើយ "ប្រហែល" ជាធ្វើឡើងនៅទីនោះផងដែរ[146]។ នៅក្នុងខែធ្នូ ឆ្នាំ1978 អគារ ក ត្រូវបានប្រើសម្រាប់ការសួរចម្លើយ ដោយសារតែអ្នកទោសមួយចំនួនធំត្រូវបានយកចេញ ធ្វើឱ្យកន្លែងនោះមានសភាពស្ងប់ស្ងាត់[147]។ ក្នុងឆ្នាំ1978 ចន្លោះពីខែកុម្ភៈដល់ខែកញ្ញា មានអ្នកទោសចំនួនពីដប់ទៅដប់ប្រាំនាក់ ដែលត្រូវអ្នកសួរចម្លើយនាំខ្លួនទៅសួរចម្លើយម្តងម្នាក់ៗជារៀងរាល់ថ្ងៃ ប៉ុន្តែចាប់ពីកាលបរិច្ឆេទនោះមក ចំនួនអ្នកទោសត្រូវគេនាំទៅសួរចម្លើយបានធ្លាក់ចុះ[148]។ អ្នកទោសត្រូវបានគេសួរចម្លើយបីដងក្នុងមួយថ្ងៃ ពីម៉ោង7-11ព្រឹក ពីម៉ោង2-5ល្ងាច និងពីម៉ោង 7-11យប់[149]។ គាត់បានឮសម្លេងស្រែករបស់អ្នកសួរ ចម្លើយដែលចោទអ្នកទោសទាំងនោះថាជាភ្នាក់ងារសេអ៊ីអា ឬកាហ្សេបេ[150]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

17. សាក្សីបានបង្ហាញនូវភស្តុតាងអំពីការដែលគាត់បានឮសម្រែករបស់អ្នកទោស "ពីគ្រប់ទិសទាំងអស់" នៅមន្ទីរស-២១ រួមទាំងសម្រែករបស់កុមារផងដែរ[151]។ មានពេលខ្លះ គាត់បានឃើញអ្នកទោសមានស្នាមរបួសនៅលើខ្នងរបស់ពួកគេ[152]។ គាត់បានឃើញគេចងព្យួរអ្នកទោសក្បាលសំយ៉ុងចុះទៅក្រោមទម្លាក់ចូលទៅក្នុងទឹក[153] ហើយអ្នកទោសផ្សេងៗទៀតក៏បានប្រាប់គាត់ផងដែរពីការដែលពួកគេត្រូវគេធ្វើទារុណកម្ម ដូចជា: PHA Tha Chan ត្រូវគេយកទៅដាក់នៅក្នុងទូទឹកកក និង អ៊ឹង ប៊ិចត្រូវគេដកក្រចកជាដើម[154]។ មានពេលមួយនោះ អ្នកសួរចម្លើយបានសួររកកញ្ចប់ស៊ីម៉ង់ត៍ពីគាត់ លុះក្រោយមក គាត់បានឃើញអ្នកទោសត្រូវគេបណ្ដើរចេញទៅដោយមានស៊ីម៉ង់ត៍ពាសពេញផ្ទៃមុខ[155]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការដែលគាត់បានឃើញ ប៊ូ ម៉េង វិលត្រឡប់មកវិញ បន្ទាប់ពីបាត់មុខពីបន្ទប់ឃុំខ្លួនពួកវិចិត្រករមួយរយៈមក ដោយត្រូវគេដាក់ច្រវ៉ាក់ និងមានស្នាមរបួស បែកឈាមពាសពេញរាងកាយ[156]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

18. សាក្សីបានបង្ហាញនូវភស្តុតាងថា គាត់មិនដែលបានឃើញ ឌុច សម្លាប់នរណា ឬបានឃើញគេសម្លាប់នរណាម្នាក់ឡើយ[157]។ ប៉ុន្តែនៅពេលដែលត្រូវគេឃុំខ្លួននៅក្នុងបន្ទប់ឃុំខ្លួនរួម មានអ្នកទោសពីប្រាំបីទៅប្រាំបួននាក់បានស្លាប់ក្នុងរយៈពេលតែមួយខែ ហើយសាកសពត្រូវបានគេយកចេញនៅពេលយប់[158]។ គាត់ក៏បានឃើញអ្នកទោសស្ត្រីលោតសម្លាប់ខ្លួនឲ្យស្លាប់ដោយផ្ទាល់ភ្នែកផងដែរ[159]។ បន្ទាប់ពីឆ្នាំ1979 សាក្សីបានដឹងថាអ្នកទោសទាំងនោះត្រូវបានគេកប់នៅក្បែរអគារនានា នៃមន្ទីរស-២១[160]។ សាក្សីបានបង្ហាញនូវភស្តុតាងនៅថ្ងៃទី14 ខែមករា ឆ្នាំ1979 គឺពេលដែលគាត់ត្រឡប់មកយកសំលៀកបំពាក់របស់គាត់វិញ ពេលនោះមានធំក្លិនស្អុយរលួយ ហើយគាត់បានឃើញសាកសពជាច្រើន ប៉ុន្តែគាត់មិនបានពីមូលហេតុ នៃការស្លាប់របស់ពួកគេនោះទេ[161]។

## សក្ខីកម្មមុនៗ

19. សាក្សីបានផ្ដល់សក្ខីកម្មចំនួន១៨ ដល់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ព-អ.វ.ត.ក ចុះថ្ងៃទី 14 សីហា 2006, D2.11, ERN 00146810-6812 (ភាសាអង់គ្លេស).

(2) បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 8 មករា 2008, D28/9, ERN 00163735-00163755 (ភាសាអង់គ្លេស).

(3) បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ស្តីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី 27 កុម្ភៈ 2008, D48/2, ERN 00197998-00198008 (ភាសាអង់គ្លេស).

(4) កំណត់ហេតុនៃការតទល់មុខគ្នារបស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 29 កុម្ភៈ 2008, D54, ERN 00166561-00166570 (ភាសាអង់គ្លេស).

(5) សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ 1998, ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, ERN 00106023-00106055 (ភាសាអង់គ្លេស).

(6) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងគេហទំព័រ CBC News, ចុះថ្ងៃទី 27 តុលា 2002. No ERN, មិនទាន់មាននៅក្នុងសំណុំរឿង http://www.cbc.ca/sunday/cambodia/story.html បើកមើលថ្ងៃទី31 តុលា 2008 (ភាសាអង់គ្លេស).

(7) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *ស-២១: ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម,* ដោយ ឫទ្ធិ ប៉ាន់ ឆ្នាំ 2002, D69, ERN V 00172620.

(8) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *Pol Pot et les Khmer Rouges* ដោយ ARTE, គ្មានកាលបរិច្ឆេទ, D69, ERN V 00172512.

(9) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត ដោយ DC-Cam និងក្រសួងការបរទេសសហរដ្ឋអាមេរិកាំង, ឆ្នាំ 2004, D69, ERN V 00172588.

(10) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *Cambodia Report* ដោយ Phil Rees, គ្មានកាលបរិច្ឆេទ, D69, ERN V 00172527.

(11) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *Mit den Moerden Leben: Das Erbe der Roten Khmer* ខែ កក្កដា 2000, D69, ERN V 00172511.

(12) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *Die Angkar* ដោយ H&S Filmproduktion, ឆ្នាំ 1981, D92/I, ERN V 00172442.

(13) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *Inside Pol Pot's Secret Prison* ដោយ Bill BRUMMEL, ឆ្នាំ 2002, ERN V 00172525.

(14) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុង NHK News Report, គ្មានកាលបរិច្ឆេទ, D69, ERN V 00172582.

(15) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *The Khmer Rouge Rice Fields,* D69, ERN V 00172604.

(16) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *ហ៊ឹម ហ៊ុយ និង វ៉ាន់ ណាត* ឆ្នាំ 2000, D69. ERN V 00172485.

(17) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *Bophana: Une tragedie Cambodgienne* ដោយ ឫទ្ធី ប៉ាន់ ឆ្នាំ 1996, D69, ERN V 00172595.

(18) បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្ត *Fragile Hopes from the Killing Fields* ដោយ Tiara DELGADO, D69, ERN V 00172547.

## ឯកសារពាក់ព័ន្ធ

20. ឯកសារដូចមានរាយនាមខាងក្រោម គឺជាឯកសារនានាក្នុងចំណោមឯកសារផ្សេងៗទៀត ដែលមានការពាក់ព័ន្ធនឹងភស្តុតាង ដែលផ្តល់ដោយសាក្សី:

(1) រូបគំនូរទាំង14ផ្ទាំងរបស់ វ៉ាន់ ណាត, ភ្ជាប់ទៅនឹង បទសម្ភាសន៍របស់ វ៉ាន់ ណាតដោយ ក.ស.ច.សអ.វ.ត.កចុះថ្ងៃទី 8 មករា 2008, D28/9 at ERN 00163742-00163755 (ភាសាអង់គ្លេស).

(2) *រូបគំនូរទាំង12ផ្ទាំងរបស់ វ៉ាន់ ណាត*, dated 1979-1980, D69, ERN P 0000022-0000033.

(3) បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ ដែលមានចំណារទឹកខ្មៅពណ៌ក្រហមរបស់ **ឌុច** “ទុកមួយរយៈសិន” ក្នុងភាពយន្តរបស់ ឫទ្ធី ប៉ាន់ *ស-២១: ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម* ក្នុងចន្លោះពេល 00:21:00 ដល់ 00:21:50

(4) ស-២១ “រូបពង្រាង” របស់ វ៉ាន់ ណាត, ចុះថ្ងៃទី7 មករា1978, នៅលើគំរបខាងក្រៅសៀវភៅរបស់ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait*.

# III. សន្តិសុខ ឬបុគ្គលិកមន្ទីរ ស-២១

## 9. ចៀម សឿ

### ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីបានបង្ហាញនូវភស្តុតាងពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)*។ ពាក់ព័ន្ធនឹងមន្ទីរស-២១ សាក្សីបានបង្ហាញនូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)*, ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនោះ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ក្រៅច្បាប់ ព្រមទាំងការធ្វើទុក្ខបុកម្នេញជនជាប់ឃុំឃាំង *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ សាក្សីបានបង្ហាញនូវភស្តុតាងដែលមានការពាក់ព័ន្ធនឹងបទចោទទី1 ទី2 និងទី3 ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

### ជីវប្រវត្តិរបស់សាក្សី

2. នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានអាយុ18ឆ្នាំ ភេទប្រុស សញ្ជាតិកម្ពុជា កើតនៅឆ្នាំ1957[162]។ ក្នុងឆ្នាំ1973 គាត់ត្រូវបានគេចាប់មកពីផ្ទះរបស់ឪពុកម្តាយគាត់ ដើម្បីចូលរួមជាមួយខ្មែរក្រហមប្រយុទ្ធប្រឆាំងនឹងទាហាន លន់ ណុល[163]។ ក្នុងឆ្នាំ1974 គាត់ត្រូវគេបញ្ជូនទៅធ្វើជាទាហានស្រុក និងមួយឆ្នាំក្រោយមក គាត់ក៏ត្រូវគេបញ្ជូនទៅអង្គភាពមួយក្នុងស្រុក75 ដើម្បីធ្វើចំការ[164]។ បន្ទាប់ពីខ្មែរក្រហមចូលកាន់អំណាច សាក្សីបានចូលរួមការបណ្តុះបណ្តាលទាហាន និងការងារកសិកម្មបន្ថែមទៀត មុនពេលដែលត្រូវគេបញ្ជូនទៅធ្វើការនៅមន្ទីរស-២១ ក្នុងឆ្នាំ1976 ឬ1977[165]។ សាក្សីធ្លាប់ធ្វើជាអ្នកយាមផ្នែកខាងក្រៅនៃមន្ទីរស-២១ រហូតដល់ពេលដែលវៀតណាមចូលឈ្លានពាន[166]។ ក្រោយឆ្នាំ1979 សាក្សីបាន "សារភាព" ហើយត្រូវគេបញ្ជូនទៅរៀនសូត្រ[167]។

### ជម្លោះប្រដាប់អាវុធ

3. សាក្សីបានបង្ហាញនូវភស្តុតាងថា បន្ទាប់ពីខែមេសា ក្នុងឆ្នាំ1975 សាក្សីត្រូវបានទទួលការបណ្តុះបណ្តាលពី កម្មាភិបាលកងពល703 ជាមួយនឹងប្រជាជនចំនួន100 ឬ200 នាក់ផ្សេងទៀតដែលមកពីខេត្តកំពង់

ឆ្នាំង។ អ្នកចូលរួមក្នុងការបណ្ដុះបណ្ដាលត្រូវគេចែកជាក្រុមផ្សេងៗគ្នា ក្រោយមក ចាន់ បានប្រាប់គាត់ថា មានក្រុមមួយដែលនឹងត្រូវគេបញ្ជូនទៅវៀតណាម[168]។ សាក្សីបានបង្ហាញនូវភស្តុតាង ពីការវាយប្រហាររបស់វៀតណាមមកលើកម្ពុជាក្នុងឆ្នាំ1976[169]។ ក្នុងខែមករា ឆ្នាំ1979 ពេលដែលកំពុងបំពេញការងារនៅមន្ទីរស-២១ សាក្សីបានឮសម្លេងគ្រាប់កាំភ្លើងពីខាងអ្នកលឿង ពួកអ្នកដឹកនាំទាំងអស់បានរត់ហើយគ្មាននរណាប្រាប់អ្នកណាឡើយ[170]។ ក្រោយពីការឈ្លានពានរបស់វៀតណាម សាក្សីបានដឹងថា ប៉េង អតីតប្រធានអង្គភាពអ្នកយាមនោះ ត្រូវបានវៀតណាមសម្លាប់នៅភាគខាងកើតភូមិត្នោតពង[171]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីបានបង្ហាញនូវភស្តុតាង ដែល ប៉េង បានប្រាប់គាត់ថា ឌុច ជាអ្នកគ្រប់គ្រងមន្ទីរស-២១[172]។ **ឌុច** "ខ្លាំងណាស់" អ្នកណាក៏ខ្លាច **ឌុច** ដែរ – សាក្សីជឿជាក់ថា ប្រសិនបើគាត់បានប្រព្រឹត្តកំហុស សូម្បីតែជាកំហុសតូចមួយក៏ដោយ នោះគាត់នឹងត្រូវគេយកទៅឃុំខ្លួនមិនខាន[173]។ សាក្សីជឿជាក់ថា មានតែ **ឌុច** ទេដែលអាចចេញ បញ្ជាឲ្យគេចាប់ ហុង ដែលជាប្រធានអង្គភាពយាមកាមខាងក្រៅ[174]។ សាក្សីនិយាយថា ប៉េង បានប្រាប់គាត់ថា **ឌុច** មានគម្រោងដាក់មនុស្សទាំងអស់នៅក្នុងគុកប្រសិន បើខ្មាំងតែម្នាក់រត់រួច[175]។

5. ឌុច និង ហ៊ី បានកោះប្រជុំផ្សេងៗក្នុងអង្គភាពការពារ អប់រំពួកគេអំពីនយោបាយ និងផ្ដល់ការណែនាំដើម្បីជៀសវាងមិនឲ្យមានសត្រូវរត់រួច[176]។ ឌុច បានលើកពីសត្រូវវៀតណាម ប្រាប់អ្នកយាម កុំឲ្យដេកពេលកំពុងធ្វើការ និងព្រមានពួកគេថា ប្រសិនបើពួកគេមិនអាច "កសាងខ្លួន" បាននោះទេ ពួកគេនឹងត្រូវចាប់ខ្លួន[177]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីបានបង្ហាញនូវភស្តុតាង ដែលបញ្ជាក់ថា គាត់គឺជាអ្នកយាមខាងក្រៅមន្ទីរស-២១ ពីឆ្នាំ1976 ឬ 1977 ដល់ឆ្នាំ1979[178]។ នៅជុំវិញមន្ទីរស-២១ មានអ្នកយាមព័ទ្ធជុំវិញចំនួនបីជុំ ហើយសាក្សីគឺជាអ្នកយាមនៅខាងក្រៅបង្អស់[179]។ ក្នុងមួយក្រុមៗមានអ្នកយាមទាំងអស់ដប់ពីរនាក់ អ្នកយាមដែលនៅក្នុងក្រុមជាមួយសាក្សីដេកជាមួយគ្នាទាំងអស់នៅក្នុងផ្ទះមួយ ហើយត្រូវយាមកាមកន្លែងតែមួយ គឺកន្លែងជិតកាច់ជ្រុង *ទួលទំពូង* ដោយពួកគាត់មានភារកិច្ចការពារមន្ទីរស-២១ពីខ្មាំងសត្រូវ និងដើម្បីកុំឲ្យអ្នកទោសលួចរួច[180]។ អ្នកយាមនៅផ្នែកខាងក្រៅត្រូវហូបបាយនៅម៉ោងពេលខុសគ្នាពីអ្នកយាមនៅផ្នែកខាងក្នុង និងមានអាហារដ្ឋានមួយស្ថិតនៅខាងត្បូងមន្ទីរស-២១[181]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

7. សាក្សីបានបង្ហាញនូវភស្តុតាង ដែល ប៉េង បានប្រាប់គាត់ថា ឌុច ជាប្រធានមន្ទីរស-២១[182]។ សាក្សីបានដឹងថា ហ៊ី មានភាពស្និទស្នាលជាមួយនឹងថ្នាក់ដឹកនាំនៅមន្ទីរស-២១[183] ចាន់ ទទួលបន្ទុក "បែងចែកភារកិច្ច"[184] ហ៊ឹម ហ៊ុយ ទទួលបន្ទុកដឹកជញ្ជូនអ្នកទោស[185] ប៉េង ជាប្រធាន អ្នកយាមផ្នែកខាងក្រៅ[186] និង ហុង ជាប្រធានក្រុមរបស់សាក្សី[187]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

8. សាក្សីបានបង្ហាញនូវភស្តុតាង ដែលគាត់បានឃើញអ្នកទោសត្រូវបានគេដឹកឡានចូលមកក្នុងមន្ទីរស-២១ ប៉ុន្តែដោយឡានទាំងនោះសុទ្ធតែបិតជិត គាត់មិនអាចដឹងបានទេថា មានអ្នកទោសប៉ុន្មានអ្នកនៅក្នុងឡាន។ គាត់បានដឹងថា ជាទូទៅមានឡានមួយចំនួនមកពីកំពង់ឆ្នាំង គេមិនអនុញ្ញាតឱ្យអ្នកយាមដឹងពីប្រភពរបស់ឡានទាំងនោះទេ "លើកលែងតែឡានទាំងឡាយណា ដែលដឹកអ្នកទោសមកពីទិសបូព៌ា"[188]។ សាក្សីបានបង្ហាញនូវភស្តុតាងថា គាត់បានឃើញតែអ្នកទោសជាខ្មែរប៉ុណ្ណោះ[189] ប៉ុន្តែមានពេលមួយនោះគាត់បានឃើញអ្នកទោសដែលមានសំបុរសត្រូវអ្នកយាមមន្ទីរស-២១ដុតទាំងរស់[190]។ សាក្សីបាននិយាយថា ពេលដែលអ្នកយាមបំពានវិន័យ នោះពួកគេនឹងត្រូវគេចាត់ទុកថាជាខ្មាំង ឬជាវៀតណាម ហើយនឹងត្រូវគេចាប់ខ្លួន[191]។ ហុង ជាប្រធានក្រុមរបស់សាក្សី ត្រូវគេចាប់ខ្លួន និងដាក់គុកនៅមន្ទីរស-២១ ព្រោះតែបាននិយាយពីរឿងលួចបេះផ្លែខ្នុរ[192]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

9. សាក្សីបានបង្ហាញភស្តុតាង ដែលគាត់បានដឹងថាមានមនុស្សត្រូវគេនាំយកទៅជើងឯកដើម្បីសម្លាប់[193]។ ក្នុងឆ្នាំ1977 ឬឆ្នាំ1978 នៅពេលដែលសាក្សីកំពុងឈរយាមនៅជិតវត្ត*ទួលទំពូង* គាត់បានឃើញអ្នកទោសបរទេស ("ខ្ពស់ហើយមានសក់ក្រហម") ត្រូវគេដុតទាំងរស់នៅកាច់ជ្រុងផ្លូវ។ គាត់បានឃើញអ្នកយាមបីនាក់នាំអ្នកទោសនោះយកទៅផ្លូវ ពួកគេឱ្យអ្នកទោសអង្គុយចុះ ហើយនៅពេលដែលអ្នកទោសនោះមានជីវិតនៅឡើយ ពួកគេ "កង់ឡានទៅដាក់ពីលើអ្នកទោស"។ សាក្សីមានការជឿជាក់ថា អ្នកយាមបានចាក់សាំងទៅលើកង់ឡានទាំងនោះ និងដុតអ្នកទោសទាំងរស់ សាក្សីខ្លាចពេកមិនប៊ានមើលទេ ប៉ុន្តែពេលដែលគាត់ត្រឡប់ទៅមើលទិដ្ឋភាពនោះម្តងទៀតវិញ អ្នកទោសនោះ "ត្រូវគេដុតរួចទៅហើយ"[194]។

## សក្ខីកម្មមុនៗ

10. សាក្សីបានផ្ដល់សក្ខីកម្មចំនួន៣ជាមុនជូនដល់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ ចៀម សឿ ដោយ ក.ស.ច.ស ចុះថ្ងៃទី 23 តុលា 2007, D22/12, ERN 00225099-00225118 (ភាសាអង់គ្លេស).

(2) បទសម្ភាសន៍របស់ ចៀម សឿ ក្នុងខ្សែភាពយន្ត *Shadow of the Past* ដោយ Express TV, គ្មានកាលបរិច្ឆេទ, D69, ERN V 00172520.

(3) បទសម្ភាសន៍របស់ ចៀម សឿ ដោយ DC-Cam ចុះថ្ងៃទី 10 May 2005, ERN 00088876-00088909 (ភាសាខ្មែរ).

## ឯកសារពាក់ព័ន្ធ

11. សាក្សីនឹងបង្ហាញជូននូវឯកសារពាក់ព័ន្ធក្នុងពេលសវនាការ។

## 10. ខៀវ ចេស ហៅ ពៅ

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីបានបង្ហាញនូវភស្តុតាងពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* រចនាសម្ព័ន្ធ និងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ពាក់ព័ន្ធនឹងមន្ទីរស-២១ សាក្សីរូបនេះបានផ្តល់នូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147) (62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់រង្គាលមនុស្សឃាត និងការសម្លាប់ក្រៅច្បាប់ និងការធ្វើទុក្ខបុកម្នេញជនជាប់ឃុំឃាំង *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងដែលសាក្សីបានផ្តល់ឲ្យមានការពាក់ព័ន្ធទៅនឹងបទចោទទី1 ទី2 និងទី3 ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានអាយុ12ឆ្នាំ ភេទប្រុស សញ្ជាតិកម្ពុជា កើតនៅក្នុងឆ្នាំ 1963[195]។ គាត់បានបង្ហាញនូវភស្តុតាងពីការដែលគាត់បានចូលរួមក្នុងកងកុមារខ្មែរក្រហម[196] បន្ទាប់មកក្នុងខែមេសា ឆ្នាំ1975 សាក្សីបានចូលហ្វឹកហាត់ជាទាហាន និងហាត់ពត់លត់ដំធ្វើការដោយដែអស់រយៈពេលជិតមួយឆ្នាំនៅបឹងទំពុន ក្រុងភ្នំពេញ ហើយ ចាន់ ជាអ្នកទទួលឲ្យចូល[197]។ ក្នុងឆ្នាំ1976 សាក្សីនិងកុមារដទៃទៀតដែលនៅក្នុងកង ត្រូវគេបញ្ជូនទៅមន្ទីរស-២១ ដែលនៅទីនោះ សាក្សីបានធ្វើជា អ្នកយាមអស់រយៈពេល3 ខែ[198]។ ក្រោយមក គាត់ក៏ត្រូវគេបញ្ជូនមកការដ្ឋានដោយសារតែបងប្អូនជីដូនមួយរបស់គាត់ដែលជាសមាជិកនៅមន្ទីរស-២១ដែរនោះ ត្រូវបានគេចាប់ខ្លួននិងសម្លាប់ចោល[199]។ គាត់នៅធ្វើការនៅឯការដ្ឋាននោះរហូតដល់ពេលដែលរបបខ្មែរក្រហមដួលរលំ។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីបានបង្ហាញនូវភស្តុតាងពីការដែលគាត់បានឮសម្លេងប្រយុទ្ធគ្នា និងបានឃើញមនុស្សរត់នៅពេលនោះ គឺពេលដែលរបបខ្មែរក្រហមដួលរលំ[200]។

## វចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

4. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា វិន័យរបស់មន្ទីរស-២១ បានហាមប្រាមមិនមានទំនាក់ទំនងជាមួយបុគ្គលដែលស្ថិតនៅក្រៅអង្គភាព ហើយប្រសិនបើមាននរណាម្នាក់សួរ "នឹងត្រូវគេកម្ទេច"[201]។ ហ៊ រ (HOR) បានធ្វើការណែនាំពីគោលការណ៍នានារបស់បក្សៈ ពួកអ្នកយាមត្រូវគេព្រមានថាមិនឲ្យដេកលក់ក្នុងពេលបំពេញការងារ ហើយប្រសិនបើមានអ្នកទោសស្លាប់ ឬលួចរត់ ជាគោលការណ៍របស់មន្ទីរស-២១ គឺអ្នកយាមដែលទទួលខុសត្រូវនោះ នឹងត្រូវឃុំខ្លួនជំនួសអ្នកទោសដែលរត់រួច[202]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីបានបង្ហាញនូវភស្តុតាងក្នុងឆ្នាំ1976 គាត់បានឃើញ **ឌុច** ចូលមកពិនិត្យមើលមន្ទីរស-២១ ពីរដងក្នុងមួយសប្តាហ៍ គាត់បានឃើញ ឌុច ពីអគារដែលគាត់ធ្វើការ ប៉ុន្តែគាត់មិនបានដឹងពីមូលហេតុនៃការចូលមកត្រួតពិនិត្យទាំងនោះទេ[203]។ គាត់បានឃើញ ឌុច អមដំណើរដោយកងការពារចំនួនពីរដងក្នុងពិធី "បុណ្យខួបអនុស្សាវរីយ៍"[204]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីបានបង្ហាញនូវភស្តុតាងនៅពេលដែលគាត់បានបំពេញការងារជាអ្នកយាមនៅមន្ទីរស-២១ ក្នុងឆ្នាំ 1976 អស់រយៈពេលបីខែ ហើយក្នុងអំឡុងពេលនោះ គាត់បានរស់នៅក្នុងផ្ទះមួយស្ថិតនៅក្រៅរបង និងខាងលិចមន្ទីរឃុំឃាំង[205]។ គាត់បានស្វែងយល់ពីកាតព្វកិច្ចរបស់គាត់ពីអ្នកយាមពេញវ័យអស់រយៈពេលបីអាទិត្យ បន្ទាប់មកគាត់ត្រូវទៅយាម "អ្នកទោសកម្រិតស្រាល" តែម្នាក់ឯង ដែលស្ថិតនៅជាន់ខាងលើ អគារ ឃ នៃមន្ទីរស-២១[206]។ សាក្សីបានបង្ហាញនូវភស្តុតាងថា គាត់បានដឹងត្រឹមតែឈ្មោះរបស់អ្នកទោសដែលស្ថិតនៅក្នុងបន្ទប់ឃុំឃាំងដែលគាត់យាមប៉ុណ្ណោះ ហើយគាត់មិនបានដឹងពីឈ្មោះអ្នកទោសនៅក្នុងបញ្ជីឈ្មោះផ្សេងៗឡើយ[207]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា មានវេនយាមសរុបទាំងអស់ចំនួនបួន ពីរវេនសម្រាប់ថ្ងៃ និងពីរវេនទៀតសម្រាប់ពេលយប់។ នៅមន្ទីរស-២១ មានអង្គភាពការពារមួយ ដែលនៅក្នុងនោះរួមមាន អង្គភាពការពារខាងក្នុង អង្គភាពសួរចម្លើយ

និងអង្គភាពចាប់ខ្លួន[208]។ អ្នកទោសត្រូវគេសួរចម្លើយនៅក្នុងអគារមួយស្ថិតនៅខាងលិចផ្លូវចូលមន្ទីរស-២១ បច្ចុប្បន្ន នៅពេលដែលគេនាំអ្នកទោសចេញពីបន្ទប់ឃុំឃាំង គេត្រូវពិនិត្យមើលឈ្មោះនៅលើបញ្ជីឈ្មោះអ្នកទោស ហើយអ្នកសួរចម្លើយនឹងបញ្ជូនត្រឡប់មកវិញនៅពេលយប់[209]។ សាក្សីបានបង្ហាញនូវភស្តុតាងនៅក្នុងឆ្នាំ1976 នៅពេលដែលគាត់ធ្វើការនៅមន្ទីរស-២១ ពេលនោះមានអ្នកទោស "មួយចំនួនតូច" ប៉ុណ្ណោះ ត្រូវ "បាត់ខ្លួន" ប៉ុន្តែក្រោយពេលដែលបានចាកចេញមក គាត់បានដឹងថា មានអ្នកទោស "ជាច្រើន" បានបាត់ខ្លួន[210]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

7. សាក្សីបានបង្ហាញនូវភស្តុតាងដែល ហ៊ុយ បានរៀបចំចាត់ចែងអ្នកយាម ត្រួតពិនិត្យមើលបន្ទប់ឃុំឃាំង និងត្រួតពិនិត្យមើល ថាតើអាហាររបស់អ្នកទោសគ្រប់គ្រាន់ដែរឬទេ។ ប្រសិនបើពិនិត្យទៅឃើញមិនគ្រប់គ្រាន់ទេ នោះអ្នកយាមនឹងត្រូវនាំយកទៅ "រៀនសូត្រ"[211]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានឃើញ ហ៊ុយ និងអ្នកក្រោមបង្គាប់របស់ ហ៊ុយ នាំអ្នកទោសចេញ-ចូលគុក[212]។ ហ៊ុយ ត្រូវធ្វើការក្រោមបង្គាប់របស់ ហ៊ី[213]។ សាក្សីបានបង្ហាញនូវភស្តុតាង ដែលបង្ហាញថា ធី ជាអ្នកទទួលបន្ទុកខាងទាហាន និងបញ្ជីឈ្មោះអ្នកទោស[214] ហើយ ច្រឹក ហៅ ភាព ជាអ្នកទទួលបន្ទុកអង្គភាពសួរចម្លើយ និងវាយអង្គុលីលេខ[215]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

8. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា អ្នកទោសដែលជាប់ឃុំក្នុងមន្ទីរស-២១ គឺមកពី "កងពលចល័ត ក្រសួង មន្ទីរ រោងចក្រ និងកងកម្លាំងប្រដាប់អាវុធ"[216]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់ បានឃើញអ្នកទោសត្រូវគេរុំមុខបិតជិតដើរចូលទៅក្នុងមន្ទីរស-២១ ហើយអ្នកទោសដែលគាត់យាមទាំងប៉ុន្មានសុទ្ធតែត្រូវដាក់ច្រវាក់គ្រប់ពេល[217]។ គាត់បានបង្ហាញនូវភស្តុតាងដែលអ្នកទោសនៅទីនោះត្រូវគេ "ចាត់ទុកដូចឆ្កែឆ្មា"[218]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

9. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា ជានិច្ចជាកាលអ្នកទោសត្រូវគេដាក់ច្រវាក់ក្នុងបន្ទប់ឃុំឃាំង គ្មានខ្នើយកើយ គ្មានមុង និងភួយទេ[219]។ នៅទីនោះ មានវិន័យតឹងរ៉ឹងនានាសម្រាប់អ្នកទោសដូចជា ពួកគេត្រូវសុំទឹកផឹកពីអ្នកយាម សុំការអនុញ្ញាតទៅបន្ទោរបង់ ឬបត់ជើងតូច ដាក់ក្នុងកេះគ្រាប់

ដែលអ្នកយាមឲ្យទៅពួកគេ[220]។ បន្ទប់ឃុំឃាំងត្រូវគេសំអាត ចំពោះតែពេលណាមានក្លិនស្អុះទឹកនោមប៉ុណ្ណោះទេ ហើយអ្នកទោសត្រូវអ្នកយាមបាញ់ទឹកទុយយោ[221] ឲ្យងូតពីរដងក្នុងមួយថ្ងៃ[222]។ អាហារដែលផ្តល់ឲ្យអ្នកទោស គឺដូចគ្នានឹងអាហារដែលផ្តល់ឲ្យបុគ្គលិកមន្ទីរស-២១ គ្រាន់តែ អ្នកទោសទទួលបាន "តិចតួចជាងតែប៉ុណ្ណោះ"[223]។

## ការសួរចម្លើយ

10. សាក្សីបានបង្ហាញនូវភស្តុតាងពីការសួរចម្លើយ ដែលបានធ្វើឡើងខាងកើតច្រកចូលសារមន្ទីរទួលស្លែងបច្ចុប្បន្ន។ នៅពេលដែលគេយកអ្នកទោសចេញពីកន្លែងសួរចម្លើយ ឈ្មោះរបស់អ្នកទោសទាំងនោះនឹងត្រូវគេគូសចេញពីបញ្ជីឈ្មោះ ប៉ុន្តែដោយសាក្សីជាអនក្ខរជន សាក្សីប្រើឲ្យអ្នកទោសអានបញ្ជីឈ្មោះ ហើយប្រាប់ឈ្មោះទាំងនោះដល់ខ្លួន។ នៅពេលល្ងាច អ្នកសួរចម្លើយត្រូវនាំខ្លួនអ្នកទោសទាំងនោះទៅកាន់បន្ទប់ឃុំឃាំងវិញ[224]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

11. សាក្សីបានបង្ហាញនូវភស្តុតាងនៅពេលដែលអ្នកទោសត្រឡប់មកពីឲ្យគេសួរចម្លើយវិញ ពួកគេមានស្នាមជាំនៅលើមុខ និងស្នាមដាច់នៅលើខ្នង[225]។ អ្នកទោសបានប្រាប់គាត់ថា ពួកគេនៅតែត្រូវគេវាយទោះបីជាបានឆ្លើយគ្រប់សំណួរហើយក៏ដោយ ព្រោះអ្នកសួរចម្លើយខ្លាចអ្នកទោសទាំងនោះនៅមានលាក់លៀមអ្វីផ្សេងៗទៀត[226]។ សាក្សីមិនបានដឹងថា តើការវាយនោះ ជាគោលការណ៍ផ្លូវការ ឬក៏ជាការសម្រេចរបស់បុគ្គលដែលជាអ្នកសួរចម្លើយឡើយ[227]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

12. សាក្សីបានបង្ហាញនូវភស្តុតាងបន្ទាប់ពីបញ្ចប់ការសួរចម្លើយ អ្នកទោសត្រូវគេ "នាំចេញទៅក្រៅ" ហើយគាត់មិនដែលបានឃើញអ្នកទោសទាំងនោះត្រឡប់មកវិញទេ[228]។ សាក្សីបានបង្ហាញនូវភស្តុតាងក្នុងឆ្នាំ 1976 នៅពេលដែលគាត់មកធ្វើការនៅក្នុងមន្ទីរស-២១ មានអ្នកទោសតែ "មួយចំនួនតូច" ប៉ុណ្ណោះដែល "បានបាត់ខ្លួន" ប៉ុន្តែក្រោយពេលដែលគាត់ចាកចេញទៅ គាត់បានដឹងថា មានអ្នកទោស "ជាច្រើន" នាក់ត្រូវបានបាត់ខ្លួន[229]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានឃើញប្រធានក្រុមយាមរបស់គាត់ឈ្មោះ ហុង ត្រូវ ហ៊ុយ និងអ្នកក្រោមបង្គាប់របស់ ហ៊ុយ ចាប់ខ្លួន។ ក្រោយមកគាត់បានដឹងថា ហុង ត្រូវគេចាប់ខ្លួនដោយសារតែបងប្រុសរបស់គាត់ធ្វើជាទាហាន លន់ ណុល[230]។ សាក្សីបានបង្ហាញនូវ

ភស្តុតាងដែល បងប្អូនជីដូនមួយរបស់ ហុង ឈ្មោះ មឿង ដែលស្ថិតនៅក្នុងអង្គភាពសេដ្ឋកិច្ចមន្ទីរស-២១ ក៏ត្រូវគេចាប់ខ្លួន និងសម្លាប់ចោលដែរ[231]។

## សក្ខីកម្មមុនៗ

13. សាក្សីបានផ្តល់នូវសក្ខីកម្មចំនួនប្រាំជាមុនដល់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ ខៀវ ចេស ដោយ ក.ស.ច.ស, 28 វិច្ឆិកា 2007, ERN 00163642-00163648 (ភាសាអង់គ្លេស), 00163636-00163641 (ភាសាខ្មែរ), ឯកសារ D28/2.

(2) បទសម្ភាសន៍របស់ ខៀវ ចេស ក្នុងអត្ថបទមានចំណងជើងថា "ការជួបជុំគ្នាឡើងវិញរបស់អតីតយុទ្ធជនមន្ទីរ ស-២១" ដោយ ហ៊ុយ វណ្ណៈ ក្នុងទស្សនាវដ្តី *ស្វែងរកការពិត* របស់ DC-Cam, លេខ 31, កក្កដា 2002, D5/2, ERN 00104911-00104912 (ភាសាអង់គ្លេស).

(3) បទសម្ភាសន៍របស់ ខៀវ ចេស ក្នុង *The Ghosts of S-21* ដោយ Brook LARMER ក្នុង *Newsweek*, សីហា 13, 2001. No ERN. មិនទាន់មានក្នុងសំណុំរឿង. http://www.newsweek.com/id/76783/output/print បើកមើលថ្ងៃទី31 តុលា 2008 (ភាសាអង់គ្លេស)

(4) បទសម្ភាសន៍របស់ ខៀវ ចេស ក្នុង *Inside Pol Pot's Secret Prison*, ខ្សែភាពយន្តនិពន្ធដោយ Bill BRUMMEL, D69, ERN V 00172525.

(5) បទសម្ភាសន៍របស់ ខៀវ ចេស ក្នុងខ្សែភាពយន្ត *ស-២១: ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម* ដោយ ឫទ្ធី ប៉ាន់ ឆ្នាំ2002, D69, ERN V 00172620.

## ឯកសារពាក់ព័ន្ធ

12. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធក្នុងពេលសវនាការ។

## 11. ឈុន ផល

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីបានបង្ហាញភស្តុតាងពីរចនាសម្ព័ន្ធនិងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ពាក់ព័ន្ធនឹងមន្ទីរស-២១ សាក្សីរូបនេះបានផ្ដល់នូវភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការយកមនុស្សធ្វើជាទាសករ សកម្មភាពអមនុស្សធម៌ ការបង្កការឈឺចាប់ដ៏ធ្ងន់ធ្ងរ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់រង្គាល មនុស្សឃាត ការសម្លាប់ក្រៅច្បាប់ដល់ជនជាប់ឃុំឃាំង *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងដែលសាក្សីបានបង្ហាញមានការពាក់ព័ន្ធទៅនឹងបទចោទទី 1 ទី2 និងទី3 ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានអាយុប្រហែល15ឆ្នាំ ភេទប្រុស សញ្ជាតិកម្ពុជា កើតឆ្នាំ 1962។ សាក្សីបានបង្ហាញនូវភស្តុតាងក្នុងខែខែមិថុនា ឆ្នាំ1975 ដែលសាក្សីត្រូវមេស្រុកនាំយកមកជាមួយនឹងកុមារៗជាច្រើន ទៀតដែលរស់នៅក្នុងភូមិជាមួយគ្នា ហើយពួកគាត់ទាំងអស់ត្រូវគេនាំយកទៅរៀនសូត្រយុទ្ធសាស្ត្រយោធាជាមួយនឹងកងពល703 ក្រោមការគ្រប់គ្រងរបស់ ទុយ[232]។ បន្ទាប់ពីធ្វើស្រែបាន ប៉ុន្មានខែរួចមក គាត់ត្រូវគេបញ្ជូនមកធ្វើការនៅមន្ទីរស-២១[233]។ ពីឆ្នាំ1976 រហូតដល់ខែធ្នូ ឆ្នាំ1978 គាត់បានធ្វើជាអ្នកយាមខាងក្រៅផង និងខាងក្នុងផងក្នុងមន្ទីរស-២១[234]។ ក្នុងអំឡុងខែធ្នូ ឆ្នាំ1978 គេបានបញ្ជូនគាត់ទៅធ្វើស្រែនៅជើងឯក ក្នុងអំឡុងពេលនោះគាត់ត្រូវបានគេប្រើឲ្យជីករណ្ដៅសាកសពជាច្រើន ហើយមានពេលមួយនោះ គាត់ត្រូវគេប្រើឲ្យកប់សាកសពដែលគេទើបនឹងសម្លាប់ថ្មីៗ[235]។ គាត់នៅជើងឯករហូតដល់វៀតណាមឈ្លានពាន។

## វចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

3. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានចូលរួមក្នុងអង្គប្រជុំនានានៅសាលានយោបាយ ដែលមានវាគ្មិន មិនស្គាល់ឈ្មោះ បាននិយាយពីការវាយយួន (វៀតណាម) និងខ្មាំងសេអ៊ីអា "ដែលស៊ីរូងផ្ទៃក្នុង"។ គាត់បានឮទៀតថា ទាហាន លន់ ណុល ជាខ្មាំង ហើយគាត់ក៏បានឮផងដែរពីផែនការនានា ដែលត្រូវកសាងទំនប់ និងជីកប្រឡាយ[236]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការដែលគាត់បានសរសេរ "ប្រវត្តិរូបផ្ទាល់ខ្លួន" របស់គាត់ពេលដែលគាត់នៅស-២១ ប៉ុន្តែគាត់បានលាក់បាំងពីការពិតដែលប្តីរបស់បងស្រីគាត់ត្រូវបានគេចាប់ខ្លួនក្នុងជំនាន់ លន់ ណុល ព្រោះមានមនុស្សម្នាក់ដែលធ្វើការជាមួយសាក្សី ត្រូវបានគេចាប់ខ្លួន ដោយសារតែ "ការពាក់ព័ន្ធ" ដែលមាននៅក្នុងប្រវត្តិរូបរបស់បុគ្គលនោះ[237]។ សាក្សីបានឮថា "ប្រជាជន17មេសា សុទ្ធតែជាបញ្ញវ័ន្ត និងទាហាន លន់ ណុល" ត្រូវគេចាប់ខ្លួននាំមកមន្ទីរស-២១[238]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីបានបង្ហាញនូវភស្តុតាងដែល **ឌុច** គឺជា "មេដឹកនាំជាន់ខ្ពស់" ហើយគាត់មិនដែលឃើញអ្នកណាធំជាង **ឌុច** ចូលទៅមន្ទីរស-២១ទេ[239]។ **ឌុច** ចូលមកមន្ទីរស-២១ នៅពេលដែលឡានអ្នកទោសចូលមកដល់ ហើយ "បន្ទាប់ពីបញ្ចប់ការងាររួចស្រេចហើយ" គាត់ឃើញ **ឌុច** ចេញទៅវិញ[240]។ សាក្សីបានដឹងថា ឌុច ជាអ្នកគ្រប់គ្រងអ្នកសួរចម្លើយ ដោយហេតុនេះហើយទើបសាក្សីសន្និដ្ឋានថា ប្រសិនបើគ្មានការអនុញ្ញាតពី ឌុច ទេ អ្នកសួរចម្លើយមិនហ៊ានវាយអ្នកទោសទាំងនោះទេ[241]។ នៅពេល ឌុច ចូលមកមន្ទីរស-២១ ភាគច្រើន **ឌុច** ចូលទៅអគារកណ្តាល ហើយមានពេលខ្លះ **ឌុច** ក៏ទៅកាន់អគារផ្សេងៗផងដែរ[242]។ មានតែម្តងគត់ដែល **ឌុច** បាននិយាយទៅកាន់សាក្សី ដោយប្រាប់ទៅសាក្សីថា 'អ្នកយាម ប្រយ័ត្នកុំដេកលក់ឲ្យសោះ'[243]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីបានបង្ហាញនូវភស្តុតាងពីពេលដែលគាត់បានមកដល់មន្ទីរស-២១ នាដើមឆ្នាំ1976 ហើយគាត់ចាប់ធ្វើការនៅទីនោះរហូតដល់ចុងឆ្នាំ1978 ដោយគាត់ធ្វើទាំងក្នុងអង្គភាពអ្នកយាមខាងក្រៅផង និងយាមខាងក្នុងផង ដែលក្នុងអំឡុងពេលនោះ គាត់ត្រូវបានគេបញ្ជូនទៅជើងឯករយៈពេលមួយខែរហូតដល់ពេលដែលវៀតណាមចូលឈ្លានពាន[244]។

6. ក្នុងតួនាទីជាអ្នកយាមផ្នែកខាងក្រៅ គាត់បានដឹងថា មានក្រុមអ្នកយាមទាំងអស់ចំនួនបួនក្រុម ដែលក្នុងមួយក្រុមៗមានគ្នាដប់ពីរនាក់ ហើយពួកគេដេករួមគ្នានៅក្នុងផ្ទះមួយស្ថិតនៅភាគខាងត្បូងឆៀងខាងលិចមន្ទីរស-២១[245]។ ឡានប្រើសម្រាប់ដឹកអ្នកទោសចេញ-ចូលមន្ទីរឃុំឃាំងនោះ ត្រូវរក្សាទុកនៅក្នុងមន្ទីរស-២១ តែម្តង ហើយឡានទាំងនោះមានពាក់ស្លាកមន្ទីរស-២១ទៀតផង។ ក្រុមអ្នកយាមដដែល ជាអ្នកយកអ្នកទោសចេញនិងចូល[246]។ ប៉ុន្តែសម្រាប់អង្គភាពចាប់ខ្លួន ជាអង្គភាពដាច់ដោយឡែង ហើយពួកគេក៏ប្រើយានជំនិះ ដើម្បីនាំអ្នកទោសចូលមន្ទីរស-២១ ដែរ[247]។

7. សាក្សីបានបង្ហាញនូវភស្តុតាងពីអ្នកយាមផ្នែកខាងក្នុងនៃ"អគារកណ្តាល" បានដឹងថា នៅពេលអ្នកទោសបានចូលទៅក្នុងមន្ទីរស-២១ ឈ្មោះរបស់អ្នកទោសទាំងនោះ ត្រូវគេកត់ត្រា[248] ហើយបទបញ្ជាសម្រាប់អ្នកយាមពេលយាមកាមអ្នកទោស គឺត្រូវមើលកុំធ្វេសប្រហែស កុំឱ្យអ្នកទោសចងក ត្រូវត្រួតពិនិត្យមើលសោរ និងមេសោរ និងប្រាប់អ្នកទោសកុំឱ្យកំរើក[249]។ ប្រធានក្រុមអ្នកយាមនឹងជេរកូនក្រុមរបស់ខ្លួន ដែលវ៉ៃអ្នកទោស ហើយចោទថាពួកគេបាន "ធ្វើឱ្យខូចនយោបាយ" ព្រោះអ្នកទោសទាំងនោះត្រូវទុកសួរចម្លើយ និង "កសាងឯកសារ" សិន[250]។ នៅមន្ទីរស-២១ មានវេនយាមទាំងអស់ចំនួនបួន ហើយអ្នកយាមម្នាក់ៗត្រូវទទួលវេនយាមពីរផ្លាស់ប្តូរគ្នាទាំងវេនថ្ងៃនិងយប់[251]។

8. សាក្សីបានបង្ហាញនូវភស្តុតាងថាមានអ្នកសួរចម្លើយទាំងអស់ដប់ពីរនាក់ក្នុងមួយក្រុម ប្រធានក្រុមជាអ្នក "រៀបចំចាក់សោរក្នុងពេលប្រគល់អ្នកទោសទៅឱ្យអ្នកសួរចម្លើយ"[252]។ នៅពេលដែលអ្នកសួរចម្លើយចូលមកយកអ្នកទោស ពួកគេត្រូវប្រគល់បញ្ជីឈ្មោះទៅឱ្យប្រធានក្រុមអ្នកយាម[253]។

9. សាក្សីបានបង្ហាញនូវភស្តុតាងនៅពេលដែលគាត់នៅជើងឯក គាត់បានឃើញរថយន្តដឹកជញ្ជូនជាច្រើនពាក់ស្លាកមន្ទីរស-២១[254]។

10. សាក្សីបានបង្ហាញនូវភស្តុតាងពីទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចែកចាយសម្រាប់ឱ្យអ្នកយាមអាន ហើយទស្សនាវដ្តីនោះ "និយាយអំពីការកសាងលទ្ធិសង្គមនិយមបែបប្រជាធិបតេយ្យ"[255]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

11. សាក្សីបានបង្ហាញនូវភស្តុតាងដែល ឌុច គឺជា "ថ្នាក់ដឹកនាំជាន់ខ្ពស់" នៅមន្ទីរស-២១[256] ហើយនៅពេលដែលសាក្សីបានមកដល់មន្ទីរស-២១ ជាលើកដំបូងក្នុងឆ្នាំ1976 អ្នកគ្រប់គ្រងសាក្សីគឺ ហ៊ី និង ប៉េង[257]។ ហ៊ី ជាអ្នករៀបចំវគ្គសិក្សានយោបាយផ្សេងៗ[258]។ ជាញឹកញាប់ សាក្សីបានឃើញ ប៉េង "ដើរត្រួតពិនិត្យ" រៀងរាល់ពីរបីថ្ងៃម្តង[259]។ សាក្សីបានឃើញ ចាន់ នៅមន្ទីរស-២១[260] ហើយ ហ៊ុយ ទទួលបន្ទុកដឹកអ្នកទោសចេញនិងចូលមន្ទីរឃុំឃាំង[261]។ ប្រធានក្រុមរបស់សាក្សីមានឈ្មោះថា កុន ហើយ ថេត គឺជាប្រធានក្រុមប្អូន ដែលក្រោយមកអ្នកទាំងពីរត្រូវគេចាប់ខ្លួន[262]។

12. បុគ្គលិកនៅមន្ទីរស-២១ ទាំងអស់ កម្រនឹងមានឱកាសជួបជុំគ្នាណាស់។ តាមធម្មតា ប្រធានមន្ទីរត្រូវកោះប្រជុំតែប្រធានក្រុមប៉ុណ្ណោះ ហើយប្រធានក្រុមជាអ្នកពាំនាំផែនការទៅឱ្យសមាជិកក្នុងក្រុម ដែលគ្មានសិទ្ធក្នុងការសម្រេច ដោយខ្លួនឯងអ្វីទាំងអស់[263]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

13. សាក្សីបានបង្ហាញនូវភស្តុតាងពីពេលដែលគាត់កំពុងយាម គាត់បានឃើញឡានដឹកអ្នកទោសចេញ និងចូលមន្ទីរស-២១ "ពេលខ្លះក៏ញឹកញាប់ ពេលខ្លះក៏មិនសូវញឹកញាប់" ប៉ុន្តែគាត់មិនបានដឹងថាអ្នកទោសទាំងនោះមកពីណា ហើយគេក៏មិនបានប្រាប់គាត់មុនដែរថាមានឡានដឹកអ្នកទោសមក[264]។ គាត់បានឃើញអ្នកទោសមានទាំងស្រីនិងប្រុសនៅមន្ទីរស-២១ អ្នកទោសវៀតណាមដែលត្រូវគេឃុំក្នុងបន្ទប់ឃុំខ្នាតតូចសម្រាប់ដាក់អ្នកទោសតែម្នាក់នោះ ចូលមកមន្ទីរស-២១ "ប្រហែលជាក្នុងឆ្នាំ1978" (ទោះបីជាមានវៀតណាមចេះនិយាយភាសាខ្មែរម្នាក់បានប្រាប់សាក្សីថា គាត់ជាអ្នកនេសាទត្រី មិនមែនជាទាហានក៏ដោយ) ហើយគាត់ក៏បានឃើញអ្នកទោសបស្ចិមប្រទេសត្រូវគេនាំចូលមកផងដែរ[265]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបញ្ជាក់ថា មានអ្នកទោសដែលជាជនជាតិព្នង និងថៃខ្លះៗដែរ[266]។

14. អ្នកទោសដែលមាន"ឋានៈខ្ពស់"ថ្នាក់ខេត្ត ដូចជា គណៈស្រុក[267] ត្រូវគេដាក់នៅក្នុង "គុកពិសេស" ដែលស្ថិតនៅកាច់ជ្រុងផ្លូវ360 និងស្ថិតនៅមុខមន្ទីរស-២១។ គេធ្វើការបែងចែកកន្លែងសម្រាប់ទទួលទានអាហាររបស់អ្នកទោសពិសេសឱ្យនៅខាងលិចមន្ទីរស-២១ និងកន្លែងមួយផ្សេងសម្រាប់ឱ្យអ្នកទោស "ដែលទោសពៃរ៍ត្រូវបានគេសម្រាល" ទទួលទានអាហារ[268]។ អ្នកយាមនៅមន្ទីរស-២១ខ្លួនឯង ក៏ត្រូវគេ

ចាប់ខ្លួន ដាក់គុក ត្រូវគេចោទថាក្បត់ជាតិពេលដែលមានអ្នកទោសធ្វើអត្តឃាត ឬពេលដែលអ្នកយាមវ៉ៃអ្នកទោស ឬ "និយាយមិនសមរម្យ"[269]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

15. សាក្សីបានបង្ហាញនូវភស្តុតាងចំពោះការដែលមានពេទ្យផ្សេងគ្នាសម្រាប់ព្យាបាលឱ្យបុគ្គលិក និងអ្នកទោស ប៉ុន្តែពួកគេគ្រាន់តែជា "ពេទ្យសាមញ្ញ" ដែលលាងតែរបួស និងព្យាបាលតែគ្រុនក្តៅប៉ុណ្ណោះ មិនមែនជាវេជ្ជបណ្ឌិតឡើយ[270]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការដែលគាត់មិនបានដឹងថា មានការប្ញមឈាម[271] ប៉ុន្តែក្រោយឆ្នាំ1979 គាត់បានឮថា អ្នកទោសស្រីត្រូវបានគេរំលោភ[272]។ សាក្សីបានបង្ហាញនូវភស្តុតាង ថាគាត់ទទួលបន្ទុកឱ្យអ្នកទោសលុតជង្គង់ ពេលអ្នកទោសត្រូវដាក់ខ្នោះក្នុងបន្ទប់ឃុំឃាំង[273]។

## ការសួរចម្លើយ

16. សាក្សីបានបង្ហាញនូវភស្តុតាងដែលអ្នកសួរចម្លើយ "មានសិទ្ធនិងមុខងារអាចវ៉ៃសួរចម្លើយ [អ្នកទោស] ដើម្បីកសាងឯកសារបាន"[274]។ ក្នុងមួយក្រុមមានអ្នកសួរចម្លើយទាំងអស់ចំនួនដប់ពីរនាក់ ហើយប្រធានក្រុមជាអ្នក "ចាត់ចែងរៀបចំចាក់សោរប្រគល់អ្នកទោសទោសឱ្យអ្នកសួរចម្លើយ"[275]។ នៅពេលដែលអ្នកសួរចម្លើយចូលមកយកអ្នកទោស ពួកគេត្រូវប្រគល់បញ្ជីឈ្មោះអ្នកទោសទៅឱ្យប្រធានក្រុមអ្នកយាម[276]។ ពេលខ្លះការសួរចម្លើយអាចមានប្រើពេលដល់ទៅមួយថ្ងៃមួយយប់ ចែកជាបួន ឬប្រាំវគ្គសួរចម្លើយ[277]។ គេអនុញ្ញាតឱ្យអ្នកយាមនិយាយជាមួយអ្នកទោស ប៉ុន្តែអាចនិយាយត្រឹមតែការជួយសម្រួលត្រៀមលក្ខណៈដល់ការសួរចម្លើយប៉ុណ្ណោះ និងដើម្បីប្រាប់អ្នកទោសឱ្យបានដឹងថា ប្រសិនបើយល់ព្រមសហការក្នុងការសួរចម្លើយ គេនឹងទទួលបានការអនុញ្ញាតឱ្យវិលត្រឡប់ទៅសហករវិញ[278]។ អ្នកយាមត្រូវគេហាមប្រាមមិនឱ្យសួរសំណួរស៊ីជម្រៅលើសពីនេះឡើយ[279]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

17. អ្នកសួរចម្លើយ "មានមុខងារនិងសិទ្ធក្នុងការវ៉ៃសួរចម្លើយអ្នកទោសដើម្បកសាងឯកសារ"។ សាក្សីបានបង្ហាញនូវភស្តុតាងដែលរៀងរាល់ពេល គាត់តែងបានឃើញអ្នកទោសមានរបួសត្រឡប់ពីការសួរចម្លើយវិញ ហូរឈាម និងពោរពេញទៅដោយការឈឺចាប់[280]។ ពេលខ្លះអ្នកទោសត្រឡប់មកវិញទាំងស្រឡាំងកាំង ដោយសារតែត្រូវគេឆក់ខ្សែភ្លើង[281]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

18. សាក្សីបានបង្ហាញនូវភស្តុតាងពីអ្នកទោសដែលស្លាប់ នៅកន្លែងដែលឃាមកាមដោយអ្នកផ្សេងទៀត[282]។

19. សាក្សីបានបង្ហាញនូវភស្តុតាងដែលពួកគាត់ត្រូវបានគេប្រាប់ថា អ្នកទោសដែលយកចេញពីមន្ទីរស-២១ ត្រូវគេបញ្ជូនត្រឡប់ទៅស្រុកកំណើតវិញ រហូតដល់ពេលដែលគាត់ទៅធ្វើការនៅជើងឯង ទើបគាត់បានដឹងថា តាមពិតពួកអ្នកទោសទាំងនោះ ត្រូវគេយកចេញទៅសម្លាប់នៅជើងឯកនេះឯង[283]។

20. ពេលដែលគាត់ធ្វើការនៅជើងឯក គេប្រើគាត់ឲ្យជីករណ្ដៅកប់ខ្មោច ហើយមានយប់មួយនោះ គេប្រើគាត់ឲ្យកប់សាកសពដែលទើបនឹងសម្លាប់ថ្មីៗ ដែលរណ្ដៅទាំងនោះស្ថិតនៅជិតផ្នូរខ្មោចចិន។ គាត់ចំណាំឡានពីររបស់មន្ទីរស-២១[284]។ គាត់មិនដែលបានឃើញជនរងគ្រោះជាកុមារនៅជើងឯកទេ[285]។

## សក្ខីកម្មមុនៗ

21. សាក្សីបានផ្ដល់សក្ខីកម្មចំនួនបួនជាមុនជូនដល់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ ឈុន ផល ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី15 ខែមករា ឆ្នាំ2008, D28/15, ERN 00163811-00163815 (ភាសាអង់គ្លេស).

(2) បទសម្ភាសន៍របស់ ឈុន ផល ដោយ DC-Cam ចុះថ្ងៃទី8 ខែកក្កដា ឆ្នាំ2002, ERN 00056966-00057009 (ភាសាខ្មែរ), ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ 19.29 (អត្ថបទសង្ខេបជាភាសាអង់គ្លេស នៅ ERN 00185281-00185283)

(3) បទសម្ភាសន៍របស់ ឈុន ផល ដោយ ក.ស.ច.ស-អ.វ.ត.ក ស្ដីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2008, D48/1, ERN 00197993-00197997 (ភាសាអង់គ្លេស).

(4) កំណត់ហេតុនៃការតទល់មុខគ្នារបស់ ឈុន ផល ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2008, D52, ERN 00165434-00165440 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

22. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងពេលសវនាការ។

## 12. ហ៊ឹម ហ៊ុយ

### ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីបានបង្ហាញនូវភស្តុតាងស្តីពីជម្លោះប្រដាប់អាវុធ*(16-18 & 144-145)* រចនាសម្ព័ន្ធនិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ពាក់ព័ន្ធនឹងមន្ទីរស-២១ សាក្សីបានផ្តល់នូវភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការយកមនុស្សធ្វើជាទាសករ សកម្មភាពអមនុស្សធម៌ ភាពឃោរឃៅចាប់ក្រៃលែង *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ធ្វើទារុណកម្ម និងសកម្មភាពអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ក្រៅច្បាប់ទៅលើជន ជាប់ឃុំឃាំង *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងដែលសាក្សីបានបង្ហាញមាន ការពាក់ព័ន្ធទៅនឹងបទចោទទី1 ទី2និងទី 3 ដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

### ជីវប្រវត្តិរបស់សាក្សី

2. នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានអាយុ21ឆ្នាំ ភេទប្រុស សញ្ជាតិកម្ពុជា មិនចាំថាកើតខែណាក្នុងឆ្នាំ1954[286]។ សាក្សីបានចូលបដិវត្តន៍នៅពេលដែលត្រូវគេកេណ្ឌចូលកងវរសេនាតូច112 កងទ័ពភូមិភាគពិសេស ហើយក្រោយមកត្រូវប្តូរទៅកងវរសេនាតូច143 វិញ[287]។ បន្ទាប់ពីថ្ងៃទី17 ខែមេសា អង្គភាពរបស់សាក្សីត្រូវបានបញ្ជូនទៅធ្វើចំការនៅព្រៃស ដែលគាត់បាននៅទីនោះរហូតដល់ដើមឆ្នាំ1976 គឺពេលដែលគាត់ត្រូវបញ្ជូនមកធ្វើជាអ្នកយាមនៅមន្ទីរស-២១[288]។ គាត់បានឡើងឋានៈជាបន្តបន្ទាប់ នឹងបានក្លាយទៅជាប្រធានអ្នកយាមនៅមន្ទីរស-២១ អ្នកដែលធ្លាប់កាន់តំណែងនេះពីមុនត្រូវបានគេកម្ទេចជាបន្តបន្ទាប់[289]។ ការទទួលខុសត្រូវរបស់គាត់ រួមមាន គ្រប់គ្រងកម្លាំងអ្នកយាមនៅមន្ទីរស-២១ ទទួលអ្នកទោស នាំអ្នកទោសចេញពីបន្ទប់ឃុំឃាំង[290] និងត្រួតពិនិត្យអាវុធនៅក្នុងឃ្លាំង[291]។ សាក្សីក៏បាននិយាយផងដែរថា គាត់គឺជាប្រធានអង្គភាពទទួលបន្ទុកបញ្ជូនអ្នកទោសពីមន្ទីរស-២១ ទៅជើងឯក[292] ហើយគាត់បានសារភាពថាបានសម្លាប់អ្នកទោសដោយផ្ទាល់តាមបញ្ជារបស់ ឌុច និងថ្នាក់ដឹកនាំ ផ្សេងៗទៀត[293]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីបានបង្ហាញនូវភស្តុតាងដែល ឌុច បានបញ្ជាគាត់ឱ្យចាប់ទាហានវៀតណាមនៅភូមិភាគបូព៌ានៅលើសមរភូមិស្វាយរៀងក្នុងឆ្នាំ1977 និងឆ្នាំ 1978[294]។ ទាហានវៀតណាមផ្សេងៗទៀត ត្រូវចាប់ខ្លួននៅលើសមរភូមិត្រូវបញ្ជូនមកមន្ទីរស-២១ "ម្តងហើយម្តងទៀត" តាមរយៈអង្គភាពផ្សេងៗ[295]។ អ្នកទោសសង្គ្រាមវៀតណាមគ្រប់ៗរូបត្រូវគេចុះបញ្ជី ថតរូប មុននឹងគេនាំយកទៅឃុំខ្លួននៅក្នុងបន្ទប់ឃុំខ្លួនខ្នាតតូចស្ថិតនៅផ្នែកខាងលិចនិងត្បូងនៃមន្ទីរស-២១។ ពួកគេត្រូវក្រុមរបស់ ចាន់ សួរចម្លើយអស់រយៈពេល "ប្រហែលជាកន្លះខែ"[296] ក្នុងអគារក្រៅមន្ទីរស-២១[297] មុនពេលត្រូវគេសម្លាប់តាមការបញ្ជារបស់ ឌុច ហ៊ី និង ប៉េង នៅផ្នែកខាងលិច និងខាងត្បូងនៃមន្ទីរស-២១ (មិនដែលសម្លាប់នៅជើងឯកទេ)។ សាកសពរបស់ពួកទាហានវៀតណាមទាំងនោះ ត្រូវគេថតរូបទុក[298]។

## វចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ

4. សាក្សីបានបង្ហាញនូវភស្តុតាងដែល សុន សេន បានកោះប្រជុំមួយនៅក្បែរផ្ទះរបស់ ឌុច កាលពីថ្ងៃទី17 ខែមេសា ឆ្នាំ1977 ដើម្បីបង្រៀនពីខ្មាំង ជាពិសេស "ភ្នាក់ងារសេអ៊ីអា និងយួន"[299]។ សាក្សីបានដឹងពីមន្ទីរសន្តិសុខនានា ច្រើនជាមន្ទីរស-២១ រួមមានការដ្ឋាននៅ ពោធិ៍បាន ដែលគេស្គាល់ជា "មន្ទីរ-15" ជាកន្លែងដែលសាក្សីទៅប្រមូលអ្នកទោស និងកន្លែងមួយទៀតនៅ ពោទន្លេ ក្នុងស្រុកកោះធំ ដែលជាកន្លែងដែលសាក្សីទៅដោះលែងកម្មាភិបាលព្រៃសដែលជាប់ឃុំនៅទីនោះ[300]។ សាក្សីបានបង្ហាញនូវភស្តុតាង នៅពេលដែលសាក្សីសុំឱ្យបញ្ជូនខ្លួនពីមន្ទីរស-២១ ទៅសមរភូមិមុខ គេប្រាប់គាត់ថា គាត់ "បានដឹងរឿងច្រើនពេក" ដូច្នេះត្រូវបន្តនៅមន្ទីរស-២១ទៀត[301]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីបានបង្ហាញនូវភស្តុតាងដែល **ឌុច** ជាប្រធានមន្ទីរស-២១[302] ហើយព្រៃសក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **ឌុច** ផងដែរ[303]។ គាត់បានបង្ហាញភស្តុតាងដែល **ឌុច** បានចេញបញ្ជាឱ្យចាប់ខ្លួន ហើយ **ឌុច** មានពាក់ព័ន្ធនៅក្នុងផែនការដឹកជញ្ជូនក្នុងការចាប់ខ្លួនដែលសំខាន់ៗ[304]។ សាក្សីបានបង្ហាញនូវភស្តុតាងថា មានពេលខ្លះ ឌុច "ដឹកនាំការចាប់ខ្លួនដោយផ្ទាល់" ប៉ុន្តែ "បានតែនៅភ្នំពេញ" ជិតផ្សារធំថ្មីប៉ុណ្ណោះ[305]។ សាក្សីបានបង្ហាញនូវភស្តុតាងថា ឌុច "បានចេញបញ្ជាឱ្យធ្វើទារុណកម្មអស់ទាំងនោះ"[306]។ គាត់បានបញ្ជាក់ពីភស្តុតាងដែល **ឌុច** "ទៅត្រួតពិនិត្យមើលការសម្លាប់" នៅជើងឯក ដោយមើលពីមាត់រណ្តៅ

សាកសព ហើយ **ឌុច** បានបញ្ជាឱ្យពេទ្យឃាតអារកជនរងគ្រោះបន្ថែមពីលើការប្រើរបារដែកវាយទៅលើកញ្ចឹងកទៀត[307]។ សាក្សីបានបង្ហាញនូវភស្តុតាងដែល **ឌុច** បានបញ្ជាគាត់ឱ្យសម្លាប់មនុស្សម្នាក់ ហើយ ឌុច បានមកជើងឯកម្តង ឬពីរដង ហើយមានម្តងនោះមកជាមួយ ហ៊ា និងនិរសាររបស់គាត់[308]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការប្រជុំរៀនសូត្រ ត្រូវធ្វើឡើងនៅមន្ទីរស-២១ ដែលនៅក្នុងអង្គប្រជុំនោះ **ឌុច** បានរៀបរាប់ពីខ្មាំងអង្គការ[309]។ **ឌុច** ក៏បានបញ្ជាអ្នកយាមឱ្យប្រាប់អ្នកទោសដែលជាឪពុកម្តាយកុំឱ្យកូនរបស់ខ្លួនឡូឡា នៅពេលស្ថិតក្នុងការឃុំឃាំងក្នុងមន្ទីរស-២១[310]។ ឌុច ក៏បានបញ្ជាឱ្យចាប់ខ្លួនកម្មាភិបាលមន្ទីរស-២១ នានាផងដែរ[311]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីបានបង្ហាញនូវភស្តុតាងដែលមានបុគ្គលិកមន្ទីរស-២១ជាច្រើននាក់ មកពីកងពល703 ហើយបុគ្គលិកទាំងនោះត្រូវបែងចែកជាផ្នែកៗ រួមមាន ផ្នែកសួរចម្លើយ ផ្នែកការពារ ផ្នែកសេដ្ឋកិច្ច និងដាំស្ល[312]។ ពីពេលមុនសាក្សីក៏បានរៀបរាប់ពី "កងកុមារ" ផងដែរ[313]។ គាត់បង្ហាញនូវភស្តុតាងដែលបង្ហាញថាគាត់ជាអ្នកទទួលអ្នកទោស កត់ឈ្មោះ និងបញ្ជូនអ្នកទោសទាំងនោះទៅឱ្យ សួស ធី[314]។

7. ពេលខ្លះកម្លាំងនៅមន្ទីរស-២១ ចេញទៅប្រមូលអ្នកទោស ចាត់តាំងឱ្យមានអ្នកយាមពីរនាក់សម្រាប់អ្នកដែលត្រូវគេចាប់ខ្លួនម្នាក់ នៅក្នុងឆ្នាំ1977-1978 គាត់ត្រូវគេបញ្ជូនឱ្យទៅចាប់មនុស្សនៅខេត្ត បាត់ដំបង ខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តតាកែវ និងកំពង់សោម ដោយនាំយកទៅជាមួយនូវលិខិត ផ្តល់សិទ្ធដែលបានពី **ឌុច** ទោះបីជាសាក្សីបានដឹងប្រាកដ ថាតើថ្នាក់លើមួយណាដែលចេញបញ្ជាសម្រាប់ការចាប់ខ្លួននោះក៏ដោយ[315]។

8. សាក្សីបានបង្ហាញនូវភស្តុតាងដែលអ្នកសួរចម្លើយបានទទួលអ្នកទោសពី ចាន់ ប៉ុន និង ធី ហើយគាត់ក៏បានយកអ្នកទោសទាំងនោះទៅដាក់នៅផ្ទះដែលស្ថិតនៅម្តុំខាងកើតទួលស្លែង[316]។ បុគ្គលិកមន្ទីរស-២១ត្រូវចោទប្រកាន់ពីបទ ដូចជា "មិនស្តាប់តាមការណែនាំ" ត្រូវបញ្ជូនទៅធ្វើស្រែនៅព្រៃស ហើយប្រសិនបើ "មាននរណាម្នាក់បានប្រព្រឹត្តកំហុសមួយផ្សេងទៀត នឹងត្រូវបញ្ជូនត្រឡប់មកគុកមន្ទីរស-២១វិញ"[317]។

9. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា ទាំងអ្នកយាមនិងអ្នកទោស គឺសុទ្ធតែរស់នៅក្នុងសភាពភ័យខ្លាច ដោយគិតជារៀងរាល់ថ្ងៃថាថ្ងៃនេះអាចជាថ្ងៃចុងក្រោយរបស់ពួកគេ[318]។ សាក្សីបានបង្ហាញនូវ

ភស្តុតាងពីការដែលអ្នកទោសត្រូវសម្លាប់និងកប់ពីដំបូងនៅមន្ទីរស-២១ ហើយនិង "កំណាកំណើតជើងឯក ក្នុងឆ្នាំ1977"[319]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

10. សាក្សីបានបង្ហាញនូវភស្តុតាងដែល ឌុច ជាប្រធានមន្ទីរស-២១[320] ហ៊ី ជាអនុប្រធាន ហើយ "អ្នកដឹកនាំថ្នាក់ធំ" នៃផ្នែកសួរចម្លើយគឺ ចាន់ និង ប៉ុន ប្រធានផ្នែកខាងដាំស្លរគឺ ម៉េង សួស ធី ជាអ្នកទទួលបន្ទុកខាងបញ្ជីឈ្មោះ[321] និង ហ៊ុយ ហ៊ុយ ស្រែ នេះ ជាអ្នកទទួលបន្ទុកនៅព្រៃស[322]។ ផល ក៏ជាប្រធានរបស់ ហ៊ុយ ដែរ[323]។ គាត់បានផ្តល់នូវភស្តុតាងដែល ឌុច "ជាអ្នកសម្រេច ហ៊ី មិនប៉ានធ្វើអ្វីទាំងអស់"[324]។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីបានបង្ហាញនូវភស្តុតាងដែល ហ៊ី បានស្នើឲ្យសង់ផ្ទះឈើនៅជើងឯក និងឲ្យចាត់តាំងក្រុមរបស់ ហ៊ឹម ហ៊ុយ ឲ្យបញ្ជូនអ្នកទោសពីមន្ទីរស-២១ ទៅជើងឯក[325]។ គាត់បានបង្ហាញនូវភស្តុតាងដែល ហ៊ី បានទៅត្រួតពិនិត្យមើលជើងឯកជាច្រើនលើក ច្រើនសារ[326]។

11. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា ប៉េង (ប្រធានផ្នែកការពារ), ប៊ូ (អ្នកសួរចម្លើយ) និង ហ៊ី បានជាអ្នកចាប់ ហ៊ុយ ស្រែ នៅផ្ទះរបស់ ឡុន នុន បន្ទាប់ពីនោះមក ហ៊ុយ ស្រែ ក៏ត្រូវជំនួសដោយ ផល[327]។

12. មន្ទីរស-២១ មានអំណាចក្នុងការចាប់ខ្លួនមនុស្សអគ្គបញ្ជាការមន្ទីរភស្តុភារ[328]។ **ឌុច** "ជាអ្នកសម្រេច" ថាត្រូវសម្លាប់អ្នកណា ហើយ **ឌុច** ជាអ្នកប្រាប់ ហ៊ី ឲ្យបញ្ជាទៅក្រុមរបស់គាត់[329]។ សាក្សីបានបង្ហាញនូវ ភស្តុតាងដែល សុន សេន "ជាអ្នកទទួលខុសត្រូវពីលើ **ឌុច**"[330]។ គាត់បានបង្ហាញនូវភស្តុតាងពី មាស ប៉េងគ្រី ឈុន ផល និង តយ តេង ក្រោមការគ្រប់គ្រងរបស់គាត់នៅមន្ទីរស-២១ ហើយសាក្សីជាអ្នកផ្តល់ការណែនាំដល់ពួកគេ។ ជាក់ស្តែង គាត់បានចាត់តាំងឲ្យក្រុមរបស់ តយ តេង ឲ្យប្រជុំគ្នា និងឃាមអ្នកទោសអ្នកទោសនៅជើងឯក[331]។ គាត់បានចាប់ខ្លួនមនុស្សជាមួយ មាស ប៉េងគ្រី នៅក្នុងខេត្តបាត់ដំបង ក្នុងឆ្នាំ1977 ហើយនិងចាប់ខ្លួនមនុស្សជាមួយ ឈុន ផល ក្នុងខេត្តតាកែវ ក្នុងឆ្នាំ1977-1978[332]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

13. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា ជនរងគ្រោះ "មកពីគ្រប់ទីកន្លែង" មានគ្រប់ប្រភេទតាំងពី "កម្មាភិបាលថ្នាក់ខ្ពស់ រហូតដល់ប្រជាជនសាមញ្ញ" មន្ត្រីរាជការក្នុងរបប លន់ ណុល និងបុគ្គលិកមកពីក្រសួងនិងមន្ទីរផ្សេងៗ[333]។ គាត់បាននូវភស្តុតាងដែលបង្ហាញថា មានអ្នកទោសជាច្រើនត្រូវបញ្ជូន

មកពីកងទ័ពភូមិភាគខាងជើង ដែលអមដោយសំបុត្រក្នុងស្រោមបិតជិតផ្ញើមកឱ្យ **ឌុច**[334]។ គាត់បានបង្ហាញនូវភស្តុតាងដែលបង្ហាញថា "យ៉ាងហោចណាស់មានប្រជាជនចំនួនពី 10,000 ដល់ 20,000" ត្រូវបានសម្លាប់នៅមន្ទីរស-២១[335]។ សាក្សីបានបង្ហាញនូវភស្តុតាងថា គាត់មិនដែលបានដឹកក្មេងទៅជើងឯកទេ[336]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

14. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា របបអាហារអ្នកទោសនៅមន្ទីរស-២១ មានបបរាវតែមួយវែកដែលចែកឱ្យពីរដងក្នុងមួយថ្ងៃសម្រាប់មនុស្សម្នាក់ ហើយអ្នកទោសត្រូវទទួលទានទាំងដៃជើងជាប់ច្រវ៉ាក់[337]។ នៅពេលដែលអ្នកទោសឈឺ "ពួកគេត្រូវទទួលការព្យាបាលនៅនឹងកន្លែង ដោយមិនគិតទេថា ជម្ងឺនោះធ្ងន់ធ្ងរកម្រិតណា"[338]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានឃើញអ្នកទោសមានស្នាមរបួសបន្ទាប់ពីត្រឡប់មកពីការសួរចម្លើយវិញនោះ[339]។

## ការសួរចម្លើយ

15. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា ចាន់ និង ប៉ុន គឺជាកម្មាភិបាលជាន់ខ្ពស់បំផុតនៅក្នុងការសួរចម្លើយ[340] ប៉ុន្តែគាត់មិនដែលបានឃើញ ឌុច សួរចម្លើយឡើយ[341]។ គាត់បានបង្ហាញនូវភស្តុតាងដែលគាត់ឃើញអ្នកទោសមានស្នាមរបួស ក្រោយពីត្រឡប់មកពីសួរចម្លើយវិញ[342]។ សាក្សីក៏បានសារភាពផងដែរថា ខ្លួនបានចូលរួមក្នុងការសួរចម្លើយនិងធ្វើទារុណកម្ម ដោយមិនបាច់ទទួលបញ្ជាទេ ព្រោះនេះជាកាតព្វកិច្ចជាប្រក្រតីរបស់គាត់[343]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

16. សាក្សីបានបង្ហាញនូវភស្តុតាងដែល ឌុច "ចេញបញ្ជាឱ្យធ្វើទារុណកម្មទាំងអស់"[344]។ គាត់បានបង្ហាញនូវភស្តុតាងដែលគាត់បានឃើញស្នាមរបួសនៅលើអ្នកទោសដែលត្រឡប់មកវិញក្រោយពេលសួរចម្លើយ[345]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

17. គាត់បានបង្ហាញនូវភស្តុតាងដែល ឌុច គឺជាអ្នកសម្រេចចំពោះការសម្លាប់[346]។ សាក្សីបានបង្ហាញនូវភស្តុតាង ដែល ប៉េង យកក្មេងទៅសម្លាប់នៅក្នុងបរិវេណមន្ទីរស-២១ ហើយ "កប់សពក្មេងទាំងនោះនៅប្រហែល100 ម៉ែត្រនៅខាងជើង និងខាងក្រោយគុក"[347]។ សាក្សីបានបង្ហាញនូវភស្តុតាងដែល

កម្មាភិបាល មកពីកងពល703 ត្រូវគេសម្លាប់ "នៅក្នុងមន្ទីរស-២១ និងសម្លាប់នៅជើងឯកផងដែរ"[348]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា "មិនដែលមានការដោះលែងណាមួយឡើយ។ (ពួកគេ) ឱ្យតែចូល គឺត្រូវគេសម្លាប់"[349]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលទាហានក្រោមបង្គាប់របស់ខ្លួនបានសម្លាប់អ្នកទោសវៀតណាម "នៅខាងក្រោយទួលស្លែង"[350]។

18. សាក្សីបានបង្ហាញនូវភស្តុតាងលំអិតពីដំណើរការយកអ្នកទោសពីមន្ទីរស-២១ ដឹកជញ្ជូនអ្នកទោសទៅជើងឯក និងការសម្លាប់អ្នកទោសទាំងនោះ[351]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា "ក្រុមដែលទទួលបានការចាត់តាំងឱ្យសម្លាប់គឺជាក្រុមរបស់ ប៉េង និងក្រុមរបស់ តេង ក្រុមនីមួយៗមានគ្នាចំនួនដប់នាក់។ សាក្សីជាសមាជិកនៅក្នុងក្រុមចាប់ខ្លួននិងទទួលអ្នកទោស។ ក្រុមនេះជាអ្នកបញ្ជូនអ្នកទោសទៅជើងឯក។ ក្រុមនេះក៏ទទួលបញ្ជាឱ្យសម្លាប់មនុស្សផងដែរ"[352]។ ក្រុមរបស់ តយ តេង ត្រូវជីករណ្តៅកប់ខ្មោច និងយាមអ្នកទោសនៅពេលដែលក្រុមនេះមកដល់ទីកន្លែងសម្លាប់មនុស្ស[353]។ សាក្សីបានបង្ហាញនូវភស្តុតាងថា តែងមានអ្នកទោសពី50-60នាក់ នៅជើងឯក ពួកគេប្រើរយៈពេលមួយម៉ោងនៅក្នុងផ្ទះឈើដែលស្ថិតនៅលើទីតាំងនោះ មុននឹងធ្វើការសម្លាប់[354]។ អ្នកទោសត្រូវគេហៅឈ្មោះឱ្យចូលមកម្តងមួយៗ ដាក់ខ្នោះនឹងរុំមុខបិតជិត ដើរសំដៅទៅរណ្តៅហើយត្រូវគេវាយសម្លាប់នឹងរបារដែក រីឯបំពង់ករបស់ពួកគេត្រូវគេអារនឹងកាំបិតស្តៅ[355]។ សាក្សីបានបង្ហាញភស្តុតាងថា គាត់បានសម្លាប់អ្នកទោសទាំងនោះតាមបញ្ជារបស់ **ឌុច** និង ហ៊ី[356] មានពេលមួយនោះបញ្ជាឱ្យ "វាយ [អ្នកទោស] យ៉ាងដំណំនឹងកំណាត់ឈើវែង... ដែលអ្នកទោសទាំងនោះត្រូវរិលមុខដួលទៅក្នុងរណ្តៅ [នឹងត្រូវគេអារកនៅក្នុងរណ្តៅនោះ]"[357]។

19. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា ទោះបីជាក្រោយពេលដែលវាលពិឃាដត្រូវបានបង្កើតនៅជើងឯកក៏ដោយ ក៏ការសម្លាប់មនុស្សនៅទីពិឃាដរបស់មន្ទីរស-២១ដដែល នៅពេលដែលចំនួនអ្នកទោសតិច ហើយពួកគេ "សុទ្ធតែជាអ្នកធំ"[358]។

## សក្ខីកម្មមុនៗ

20. សាក្សីបានផ្តល់សក្ខីកម្មចំនួនម្ភៃប្រាំបួនជាមុនជូនដល់សហព្រះរាជអាជ្ញា:

(1) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស ចុះថ្ងៃទី18 ខែកញ្ញា ឆ្នាំ2007, ERN 00161595-00161604 (ភាសាអង់គ្លេស), ERN 00148089-00148101 (ភាសាបារាំង), ERN 00146643-00146653 (ភាសាខ្មែរ), D19/V.

(2) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស ចុះថ្ងៃទី19 ខែកញ្ញា ឆ្នាំ2007, ERN 00146635-00146642 (ភាសាខ្មែរ), ERN 00148079-00148088 (FRE), ERN 00161587-00161695 (ភាសាអង់គ្លេស), D19/VI.

(3) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស ចុះថ្ងៃទី 18 ខែមករា ឆ្នាំ2008, D51/2, at ERN 00164451, ERN 00164449-00164452 (ភាសាអង់គ្លេស).

(4) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស ចុះថ្ងៃទី14 ខែមីនា ឆ្នាំ2008, D76/I, ERN 00189035-00189037 (ភាសាអង់គ្លេស).

(5) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស-អ.វ.ត.កស្តីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2008, D48/1, ERN 00197993-00197997 (ភាសាអង់គ្លេស).

(6) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស-អ.វ.ត.កស្តីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2008, D48/2, ERN 00197998-00198008 (ភាសាអង់គ្លេស).

(7) កំណត់ហេតុនៃការតទល់មុខគ្នារបស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2008, D52, ERN 00165434-00165440 (ភាសាអង់គ្លេស).

(8) កំណត់ហេតុនៃការតទល់មុខគ្នារបស់ ហ៊ឹម ហ៊ុយ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2008, D54, ERN 00166561-00166570 (ភាសាអង់គ្លេស).

(9) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ Craig Etcheson/ឆាំង យុ ចុះថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ1996 (សង្ខេប), ERN 00104941-00104944 (ភាសាអង់គ្លេស),

(10) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ សួរ ប៊ុនសូ (Bunsou Sour)/Kate Hill ចុះថ្ងៃទី7 ខែកក្កដា ឆ្នាំ2006 (ប្រតិចារឹក), ERN 00087753-00087764 (ភាសាអង់គ្លេស),

(11) ជីវប្រវត្តិផ្ទាល់ខ្លួនរបស់ ហ៊ឹម ហ៊ុយ ចុះថ្ងៃទី10 ខែវិច្ឆិកា 1977, No ERN (but in CaseMap) (ភាសាអង់គ្លេស), ERN 00052499-00052506 (ភាសាខ្មែរ)

(12) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ឆ្នាំ2002 (ប្រតិចារិកមួយផ្នែករបស់ក.ស.ព *"ស-២១: ម៉ាស៊ីនសម្លាប់មនុស្ស"*), ERN 00078303-00078304 (ភាសាអង់គ្លេស).

(13) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ Peter Maguire គ្មានកាលបរិច្ឆេទ (ប្រតិចារឹក), ERN 00104913-00104924 (ភាសាអង់គ្លេស),

(14) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ Peter Maguire គ្មានកាលបរិច្ឆេទ (ប្រតិចារឹក), ERN 00104925-00194940 (ភាសាអង់គ្លេស),

(15) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុង *Phnom Penh Post* ចុះថ្ងៃទី22 ខែមករា – ដល់ថ្ងៃទី4 ខែកុម្ភៈ 1999, ERN 00087797-00087799 (ភាសាអង់គ្លេស).

(16) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងខ្សែភាពយន្ត *ហ៊ឹម ហុយ និង វ៉ាន់ ណាត* ឆ្នាំ2000, D69, ERN V 00172485.

(17) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងខ្សែភាពយន្ត *Mit den Mördern leben: Das Erbe der Roten Khmer* ខែកក្កដា ឆ្នាំ2000, D69, ERN V 00172511.

(18) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងខ្សែភាពយន្ត *Inside Pol Pot's Secret Prison* ដោយ Bill BRUMMEL ចុះថ្ងៃទី4 ខែកក្កដា ឆ្នាំ2000, D69 ERN V 00172525.

(19) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងខ្សែភាពយន្ត *Cambodia Report* ដោយ Phil REES, គ្មានកាលបរិច្ឆេទ, D69, ERN V 00172527.

(20) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងខ្សែភាពយន្ត *Bophana, Une tragedie Cambodgienne* ដោយ ឫទ្ធី ប៉ាន់ ឆ្នាំ1996, D69, ERN V 00172595.

(21) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងខ្សែភាពយន្ត *Pol Pot, Journey to the Killing Fields* ដោយ TVK, គ្មានកាលបរិច្ឆេទ, D69, ERN V 00172603.

(22) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងខ្សែភាពយន្ត *ស-២១: ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម* ដោយ ឫទ្ធី ប៉ាន់ ឆ្នាំ2002, D69, ERN V 00172620.

(23) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុង *Report on the Meeting With a Former KR Named Him Huy* ដោយ ទឹម ស, ចុះថ្ងៃទី15 ខែកញ្ញា ឆ្នាំ1990, D61/I, ERN 00171153 [new]-0000171154 (ភាសាអង់គ្លេស).

(24) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ដោយ Ben Kiernan ចុះថ្ងៃទី14 ខែកក្កដា ឆ្នាំ1996, D61/I, ERN 00171147-00171152 (ភាសាខ្មែរ).

(25) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងអត្ថបទមានចំណងជើងថា "ការជួបជុំគ្នាឡើងវិញរបស់អតីតយុទ្ធជនមន្ទីរស-២១" ដោយ ហ៊ុយ វណ្ណៈ ក្នុងទស្សនាវដ្ដី *ស្វែងរកការពិត* របស់ DC-Cam, លេខ 31, ខែកក្កដា ឆ្នាំ2002, D5/2, ERN 00104911-00104912 (ភាសាអង់គ្លេស).

(26) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុង *Time Short for Genocide Justice in Cambodia* ដោយ Justine Smith ក្នុងទូរសារប្រចាំថ្ងៃ, ចុះថ្ងៃទី7 ខែមេសា ឆ្នាំ2007. មិនមាន ERN. មិនទាន់មានក្នុងសំណុំរឿង. http://www.telegraph.co.uk/news/worldnews/1547994/Time-short-for-genocide-justice-in-Cambodia.html បើកមើលថ្ងៃទី31 ខែតុលា ឆ្នាំ2008 (ភាសាអង់គ្លេស).

(27) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងអត្ថបទ *"ជនរងគ្រោះក្នុងរបបខ្មែរក្រហម និងពេជ្ឈឃាតស្វែងរកការស្រុះស្រួលគ្នា"* ដោយ KER Munthi, Associated Press, ចុះថ្ងៃទី 21 ធ្នូ 2005. គ្មាន ERN, មិនទាន់មានក្នុងសំណុំរឿង. http://www.boston.com/news/world/asia/articles/2005/12/21/khmer_rouge_victims_and_executioners_seek_reconciliation/ បើកមើលថ្ងៃទី 31 តុលា 2008 (ភាសាអង់គ្លេស).

(28) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងអត្ថបទ *"តើកម្ពុជាអាចរកយុត្តិធម៌បានទេ?"* ដោយ Bronwyn Sloan, *Deutsche Press Agentur*, ចុះថ្ងៃទ13 ខែសីហា ឆ្នាំ2006. គ្មាន ERN, មិនទាន់មាននៅក្នុងសំណុំរឿង (ភាសាអង់គ្លេស) http://www.globalpolicy.org/intljustice/tribunals/cambodia/2006/0413dpa.htm បើកមើលថ្ងៃទី31 ខែតុលា ឆ្នាំ2008 (ភាសាអង់គ្លេស).

(29) បទសម្ភាសន៍របស់ ហ៊ឹម ហ៊ុយ ក្នុងអត្ថបទ *Former Torturers Turn Accusers and Confront the Killing Fields* by Nick Meo for *The Times*, dated July 3, 2006. No ERN, មិនទាន់មាននៅក្នុងសំណុំរឿង, http://business.timesonline.co.uk/tol/business/law/public_law/ article682269.ece បើកមើលថ្ងៃទី31 ខែតុលា ឆ្នាំ2008 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

21. ឯកសារដូចខាងក្រោមនេះ គឺជាឯកសារក្នុងចំណោមឯកសារនានា ដែលមានការពាក់ព័ន្ធនិងភស្តុតាងដែលផ្ដល់ឱ្យដោយសាក្សី:

(1) រូបថតរបស់ ហ៊ឹម ហ៊ុយ នៅមន្ទីរស-២១ បង្ហាញជាមួយក្រុមសន្តិសុខមួយក្រុម (គ្មានកាលបរិច្ឆេទ), ឯកសារ D69, ERN P 00005254.

## 13. គក ស្រស់

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ពាក់ព័ន្ធនឹងមន្ទីរស-២១ សាក្សីរូបនេះបានបង្ហាញនូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក បង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការយកមនុស្សធ្វើជាទាសករ សកម្មភាពអមនុស្សធម៌ ការបង្កការឈឺចាប់ដ៏ធ្ងន់ធ្ងរ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ក្រៅច្បាប់ *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងដែលសាក្សីបានបង្ហាញមានការពាក់ព័ន្ធទៅនឹងបទចោទទី 1 ទី2 និងទី 3 ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានអាយុ23ឆ្នាំ ភេទប្រុស សញ្ជាតិកម្ពុជា មិនចាំកើតខែណាក្នុងឆ្នាំ1953[359]។ គាត់ត្រូវគេកេណ្ឌឱ្យចូលទាហានក្នុងកងវរសេនាតូច138 ក្នុងឆ្នាំ1973 ហើយគាត់បានចូលរួមក្នុងព្រឹត្តិការណ៍ថ្ងៃទី17 ខែមេសា ឆ្នាំ1975 ដោយជាអ្នកគាំទ្រកម្លាំងពិសេស[360]។ បន្ទាប់ពីបានចូលរួមក្នុងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ គាត់ត្រូវបានគេចាត់តាំងឱ្យទៅយាមនៅអតីតគុក *Police Judiciaire* ជិតផ្សារថ្មី និងនៅមន្ទីរពេទ្យព្យាបាលមនុស្សវិកលចរិតនៅតាខ្មៅក្រោមការដឹកនាំរបស់ឌុច[361]។ មន្ទីរឃុំឃាំងទាំងពីរនេះ គឺប្រើសម្រាប់ពង្រឹងមន្ទីរស-២១នៅទួលស្លែង ដែលសាក្សីទទួលការចាត់តាំងក្នុងឆ្នាំ[362]។ សាក្សីគឺជាអ្នកយាមខាងក្រៅផង និងខាងក្នុងផងនៅមន្ទីរស-២១ ហើយនៅពាក់កណ្តាលខែធ្នូ ក្នុងឆ្នាំ1978 គាត់ត្រូវគេបញ្ជូនទៅធ្វើការនៅព្រៃស[363]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា **ឌុច** គឺជាប្រធានមន្ទីរស-២១[364] ហើយ **ឌុច** ក៏ធ្លាប់ជាប្រធាន គុកនៅមន្ទីរពេទ្យព្យាបាលរោគវិកលចរិតនៅតាខ្មៅ និងអតីត *Police Judiciaire* ផងដែរ[365]។

**ឌុច** ស្នាក់នៅមន្ទីរស-២១ជាអចិន្ត្រៃយ៍[366] ហើយ **ឌុច** ទទួលបន្ទុកចាត់តាំងប្រធានក្រុមនានា[367] បង្រៀនថ្នាក់នយោបាយ[368] និងត្រួតពិនិត្យឯកសារសួរចម្លើយ[369]។ សាក្សីនឹងនិយាយថា **ឌុច** គឺជា "មេបញ្ជាការទៅលើការងារទាំងស្រុង" រួមទាំង "ការបញ្ជាឱ្យសម្លាប់" ផងដែរ[370]។

4. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានឃើញ **ឌុច** ចូលទៅក្នុងបន្ទប់សួរចម្លើយស្ថិតនៅក្រៅបរិវេណគុកដើម្បីត្រួតពិនិត្យមើលការសួរចម្លើយ ប៉ុន្តែសាក្សីមិនដែលបានឃើញ **ឌុច** ធ្វើទារុណកម្ម សួរចម្លើយ ឬសម្លាប់អ្នកទោសទេ[371]។ សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានឃើញ **ឌុច** ចូលទៅក្នុងបន្ទាយដើម្បីណែនាំការងារ[372]។ **ឌុច** "ជាញឹកញាប់" តែងមកពិនិត្យមើលបន្ទប់ឃុំឃាំង ដើម្បីផ្តល់ការណែនាំជាក់លាក់[373]។ សាក្សីបានបង្ហាញនូវភស្តុតាងដែល **ឌុច** ជាអ្នកចេញបញ្ជាឱ្យមានការចាប់ខ្លួនមនុស្សនៅព្រៃស[374]។

5. សាក្សីបង្ហាញនូវភស្តុតាងដែល **ឌុច** បានចេញបញ្ជាឱ្យដាក់គុកបុគ្គលិកមន្ទីរស-២១ "ប្រសិនបើកម្មាភិបាលមានការពាក់ព័ន្ធ និងនិន្នាការ" រីឯអ្នកដែលធ្វើការមិនបានល្អ ត្រូវទទួលការណែនាំជាដំបូងសិន ហើយនឹងត្រូវគេចាប់ខ្លួនប្រសិនបើមិនអាចកសាងខ្លួនបាន[375]។

6. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់បានដឹងបន្ទាប់ពីរបបនោះត្រូវដួលរលំថា នៅពេលដែលជិតអស់មនុស្សពីមន្ទីរស-២១ ឌុច បានចេញបញ្ជាឱ្យសម្លាប់អ្នកទោសដែលនៅសល់ និងកម្មាភិបាលដប់នាក់ដែលជាប់គុក[376]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

7. សាក្សីបានធ្វើការជាអ្នកយាមនៅគុកមន្ទីរពេទ្យព្យាបាលរោគវិកលចរិតនៅតាខ្មៅ និងនៅគុកអតីត *Police Judiciaire* ជិតផ្សារថ្មី។ អ្នកដែលជាប់ឃុំមួយចំនួនបាន "ប្រាប់ការពិត" ហើយត្រូវគេដោះលែង[377] ប៉ុន្តែនៅពេលដែលអ្នកទោសទាំងនោះត្រូវគេបញ្ជូនមកមន្ទីរស-២១នៅទួលស្លែង គ្មានអ្នកជាប់ឃុំណាមួយមានជីវិតចាកចេញនោះទេ[378]។

8. សាក្សីបានបង្ហាញនូវភស្តុតាងដែលបង្ហាញថា មន្ទីរស-២១ស្ថិតនៅក្នុងសាលាទួលស្វាយព្រៃ និងមានអគារសម្រាប់ឃុំខ្លួនអ្នកទោសចំនួនបួន។ នៅពីមុខច្រកចូលខាងកើត មានកន្លែងសម្រាប់សួរចម្លើយមួយ

ហើយនៅជិតនោះ គឺជាផ្ទះរបស់ **ឌុច**។ អង្គភាពអ្នកយាមស្ថិតនៅកាច់ជ្រុងភាគពាយ័ព្យខាងក្រៅរបង រីឯកន្លែងទទួលទានអាហារសម្រាប់អង្គភាពអ្នកយាមគឺនៅជាប់នឹងរបង[379]តែម្តង។

9. សាក្សីបានបង្ហាញនូវភស្តុតាងថា នៅពេលដែលគាត់ចាប់ផ្តើមការងារនៅមន្ទីរស-២១ នៅទីនោះមានអ្នកទោសរួចទៅហើយ។ គាត់បានរៀបចំបន្ទប់ បន្ទប់ឃុំឃាំង និងសង់របងជុំវិញមន្ទីរឃុំឃាំង[380]។

10. សាក្សីគឺជាសមាជិកអ្នកយាមកងរយនៅមន្ទីរស-២១។ អ្នកយាមម្នាក់ៗត្រូវបានចាត់តាំងឱ្យយាមប្រាំម៉ែត្របួនជ្រុង[381]។ អ្នកយាមត្រូវរស់នៅក្នុងលក្ខខណ្ឌតឹងតែង ហើយមានភាពភ័យខ្លាចបារម្ភពីជីវិតរបស់ខ្លួនគ្រប់ពេល។ ពួកគេមិនអនុញ្ញាតឱ្យចាកចេញពីបរិវេណគុក ហើយក៏មិនអនុញ្ញាតឱ្យមានមិត្តស្រី ឬអ្នកមកសួរសុខទុក្ខដែរ[382]។

11. អ្នកយាមដែលដេកលក់នឹងត្រូវបញ្ជូនទៅព្រៃសដើម្បី "លត់ដំ" ហើយប្រសិនបើពួកគេនៅតែមិនខិតខំប្រឹងប្រែងធ្វើការទៀត ពួកគេនឹងត្រូវឃុំខ្លួននៅមន្ទីរស-២១[383]។ អ្នកយាមក៏ត្រូវគេចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរស-២១ដែរ ប្រសិនបើពួកសម្លាប់អ្នកទោសមុនពេលចម្រាញ់យកចម្លើយសារភាពដែលពេញចិត្តតាមរយៈការសួរចម្លើយ ឬប្រសិនបើអ្នកទោសលួចរត់ ឬធ្វើអត្តឃាតនៅក្នុងវេនយាមរបស់ខ្លួន[384]។

12. សាក្សីបានបង្ហាញនូវភស្តុតាងពីមនុស្សចំនួនដប់នាក់ ដែលមកពីកងអ្នកយាមអនុសេនាធំចំនួនបីដែលត្រូវចាប់និងឃុំខ្លួននៅមន្ទីរស-២១[385]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

13. សាក្សីបានបង្ហាញនូវភស្តុតាងដែល **ឌុច** គឺជាប្រធានមន្ទីរស-២១[386] និងជាប្រធានគុកនៅមន្ទីរពេទ្យព្យាបាលរោគវិកលចរិតនៅតាខ្មៅ និងអតីតគុក *Police Judiciaire*[387]។ ហ៊ី គឺជាអនុប្រធាន[388]។ ចាន់ គឺជាទីប្រឹក្សាម្នាក់របស់ ឌុច[389]។ ប៉េង គឺជាប្រធានអ្នកយាម[390] ហើយក៏ជាអ្នកមើលការខុសត្រូវដោយផ្ទាល់របស់សាក្សីដែរ។

14. ហ៊ុយ ខ្ពស់ជាអ្នកទទួលបន្ទុកព្រៃស ហើយ ហ៊ុយ ទាប ជាអ្នកទទួលបន្ទុកផ្នែកសួរចម្លើយ[391]។ អ្នកទោសខ្លាច ហ៊ុយ ទាប ណាស់ ព្រោះគាត់ធ្វើទារុណកម្មដោយផ្ទាល់ទៅលើអ្នកទោសក្នុងពេលកំពុងសួរចម្លើយ ប្រសិនបើអ្នកទោសមិនព្រមឆ្លើយឱ្យត្រូវចិត្តទេនោះ[392]។ ក្រុមរបស់ហ៊ុយ ក៏ត្រូវទទួលខុសត្រូវផងដែរក្នុងការចាប់ខ្លួនអ្នកទោស និងបញ្ជូនអ្នកទោសទៅជើងឯកផងដែរ។ ហ៊ុយ និង ប៉េង

ជាអ្នកចាត់តាំងមនុស្សឱ្យទៅសម្លាប់មនុស្សនៅជើងឯក[393]។ ធី ជាអ្នកទទួលបន្ទុកខាងកត់ត្រាឈ្មោះនិងលេខរបស់អ្នកទោស[394]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

15. សាក្សីបានបង្ហាញនូវភស្តុតាងដែលកម្មាភិបាលបានប្រាប់គាត់ថា អ្នកទោសដែលធ្លាប់ជាប់ឃុំនៅ *Police Judiciare* និងនៅមន្ទីរពេទ្យព្យាបាលរោគវិកលចរិត ត្រូវគេបញ្ជូនទៅមន្ទីរស-២១[395]។

16. សាក្សីបានបង្ហាញនូវភស្តុតាងថា អ្នកជាប់ឃុំត្រូវគេរុំមុខជិត និងដាក់ខ្នោះ ហើយត្រូវគេនាំចូលមន្ទីរស-២១ជាក្រុមៗដែលមានគ្នា30 នាក់ក្នុងមួយក្រុមដឹកតាមឡានដែលគ្របជិត[396] ដាក់អ្នកទោសឡើងជណ្តើរកកន្លែងអង្គុយគ្មាន[397]។ នៅពេលមកដល់ អ្នកទោសត្រូវថតរូប នឹងនាំយកទៅកន្លែងឃុំខ្លួន[398]។ បន្ទាប់ពីការសួរចម្លើយបានបញ្ចប់ អ្នកយាមនាំអ្នកទោសទៅកាន់ទីកន្លែងដែលអ្នកទោសត្រូវគេដាក់ខ្នោះ "ជាជួរៗ" ជាមួយគ្នា[399]។

17. នៅមន្ទីរស-២១ មានអ្នកទោសប្រហែលជា1,000 នាក់។ នៅពេលដែលគុកផ្ទុកមនុស្សដល់កម្រិតអតិបរមា អ្នកទោសដែលមានប្រវត្តិរូបសំខាន់ ដូចជា កម្មាភិបាល យុទ្ធជន នឹងត្រូវគេរក្សាទុកសម្រាប់សួរចម្លើយ រីឯអ្នកទោសផ្សេងៗទៀតត្រូវគេសម្លាប់ចោល[400]។ ស្ត្រី កុមារ និងអ្នកទោសដែលសំខាន់ត្រូវរក្សាទុកដោយឡែកពីអ្នកទោសដទៃទៀត។ ទោះបីជាកុមារមិនត្រូវបានគេឃុំខ្លួននៅមន្ទីរស-២១ ក៏ដោយ ក៏ពេលខ្លះកុមារដែលជាកូនរបស់ "ជនដែលមានឋានៈធំ" ត្រូវគេឃុំខ្លួន[401]។ ទាហានរបស់ខ្មែរក្រហមក៏ត្រូវចាប់ខ្លួនដែរ – ពេលដែលប្រធានក្រុមទាហានប្រព្រឹត្តកំហុស កូនទាហាននៅក្នុងក្រុមទាំងអស់ក៏ត្រូវឃុំខ្លួនផងដែរ "ទោះបីជាទាហានទាំងនោះមិនមានកំហុសអ្វីក៏ដោយ" [402]។

18. សាក្សីបានបង្ហាញភស្តុតាងពេលដែលគាត់យាមអ្នកទោសនៅខាងក្រៅក្នុងបរិវេណមន្ទីរស-២១[403]។ គាត់បានបង្ហាញនូវភស្តុតាងដែលបង្ហាញថា អ្នកទោសដែលនៅក្នុងនោះមានចម្រុះជាតិសាសន៍ ដែលត្រូវគេឃុំដោយឡែកពីគ្នា ខ្លះជាជនជាតិឥណ្ឌា ថៃ វៀតណាម តែគាត់មិនដែលបានឃើញទាហានវៀតណាមទេ[404]។ សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញថាគាត់មិន ដែលបានឃើញអ្នកទោសកុមារទេ[405]។

19. សាក្សីបានបង្ហាញនូវភស្តុតាងពីការចាប់ខ្លួនរបស់អ្នកយាមប្រហែលដប់នាក់ និងត្រូវគេឃុំខ្លួននៅមន្ទីរស-២១ ដោយសារតែពួកគេមិនបានបំពេញតួនាទីរបស់ខ្លួនឱ្យល្អ[406] ដូចជា បានសម្លាប់អ្នកទោសមុនពេល

ចម្រាញ់យកចម្លើយដែលត្រូវចិត្តតាមរយៈការសួរចម្លើយ ឬអ្នកទោសលួចរត់ ឬធ្វើអត្តឃាតក្នុងវេនយាមរបស់ខ្លួនជាដើម[407]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

20. សាក្សីបានបង្ហាញនូវភស្តុតាងពីពេលដែលអ្នកទោសទាំងនោះត្រូវគេនាំចូលមន្ទីរស-២១ ពួកគេត្រូវគេដាក់ខ្នោះដៃ ហើយជើងរបស់ពួកគេត្រូវដាក់ច្រវាក់ភ្ជាមនៅពេលដែលគេបញ្ជូនទៅដល់បន្ទប់ឃុំឃាំង[408]។

21. សាក្សីបានបង្ហាញនូវភស្តុតាងដែលអ្នកទោសមិនមានអាហារគ្រប់គ្រាន់[409]។ គាត់បានបង្ហាញជាភស្តុតាងថា អ្នកទោសត្រូវសំអាតខ្លួនរៀងរាល់ពីរថ្ងៃម្តង ដោយប្រើទុយោបាញ់ទឹកពីខាងក្រៅបន្ទប់ឃុំឃាំង[410]។ គ្មានពេទ្យសម្រាប់ព្យាបាលជម្ងឺរបស់អ្នកទោសទេ[411]។

22. សាក្សីបានបង្ហាញនូវភស្តុតាងដែលបញ្ជាក់ថា គាត់ទៅព្រៃសពីរដងក្នុងមួយឆ្នាំដើម្បីទៅធ្វើស្រែ[412]។ សាក្សីបានបង្ហាញភស្តុតាងដែលបង្ហាញពីការដែលប្រជាជនដែលជាបុរស និងស្ត្រី ព្រមទាំងជាអតីតទាហាន ត្រូវទទួលការលត់ដំនៅព្រៃស[413]។

## ការសួរចម្លើយ

23. សាក្សីបានបង្ហាញនូវភស្តុតាងបង្ហាញថា ក្រុមរបស់ ហ៊ុយ ជាអ្នកទទួលបន្ទុកក្នុងការសួរចម្លើយ[414]។ ក្នុងតួនាទីជាអ្នកយាម ការពាក់ព័ន្ធរបស់សាក្សីនៅក្នុងការសួរចម្លើយ គឺបានត្រឹមតែប្រគល់អ្នកទោសទៅឲ្យក្រុមសួរចម្លើយ នៅពេលដែលដល់វេនយាមរបស់ខ្លួនប៉ុណ្ណោះ។ ការសួរចម្លើយប្រព្រឹត្តទៅនៅក្នុងអគារដែលស្ថិតនៅខាងកើតនៃបរិវេណទួលស្លែង[415]។ ការសួរចម្លើយទាំងនោះ "មហាសែនព្រៃផ្សៃណាស់"[416]។ សាក្សីតែតែបានឮអ្នកទោសស្រែកក្នុងពេលគេកំពុងសួរចម្លើយ[417]។

24. សាក្សីបានបង្ហាញនូវភស្តុតាងដែលគាត់មិនដែលបានឃើញការសម្លាប់ ឬសួរចម្លើយដោយផ្ទាល់នោះទេ[418]។ គាត់បានបង្ហាញនូវភស្តុតាងដែលគាត់បានឃើញអ្នកទោសមានរបួសស្នាម បន្ទាប់ពីគេសួរចម្លើយចប់ និងបញ្ជូនត្រឡប់ទៅកាន់បន្ទប់ឃុំឃាំងវិញ[419]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

25. សាក្សីបានបង្ហាញនូវភស្តុតាងពីវិធីសាស្ត្រក្នុងការធ្វើទារុណកម្មរួមមានការឆក់ខ្សែភ្លើង និងការប្រើដង្កៀប "ទាញសាច់"[420]។ គាត់បានឃើញអ្នកទោសត្រឡប់ពីការសួរចម្លើយវិញដោយមាន "ស្លាកស្នាម"[421]។ សាក្សីបានបង្ហាញនូវភស្តុតាងពីការដែលក្រុមរបស់ ហ៊ុយ បានធ្វើទារុណកម្មទៅលើអ្នកទោសក្នុងពេលសួរចម្លើយ។ ជាញឹកញាប់ ហ៊ុយ ផ្ទាល់បានធ្វើទារុណកម្មទៅលើអ្នកទោស[422]។ សាក្សីបានបង្ហាញនូវភស្តុតាង ដែលគាត់បានឃើញអ្នកទោសត្រូវគេឆក់ខ្សែភ្លើង ហើយមានពេលនោះ គាត់បានឮសម្រែកអ្នកទោស ស្រែកថា "កុំ! សូមកុំប្រើដង្កៀបអី!" ហើយនិងសម្រែករបស់អ្នកសួរចម្លើយ[423]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

26. សាក្សីបានបង្ហាញនូវភស្តុតាងដែលអ្នកបើកឡានដឹកអ្នកទោសទៅបឹងជើងឯកបានប្រាប់គាត់ថា អ្នកទោសដែលត្រូវសួរចម្លើយទាំងអស់ ត្រូវគេបញ្ជូនទៅសម្លាប់បឹងជើងឯក ក្រោមបញ្ជារបស់ ឌុច[424]។ អ្នកទោសដែលសំខាន់ មានចំនួនតិច ត្រូវបានគេសម្លាប់នៅក្រៅរបងមន្ទីរស-២១ ដូចជា អ្នកទោសឥណ្ឌា ថៃ និងវៀតណាមជាដើម[425]។

27. សាក្សីបានបង្ហាញនូវភស្តុតាងពីគោលការណ៍របស់មន្ទីរស-២១ ដែលត្រូវសម្លាប់អ្នកទោសចោលទាំងអស់ដោយគ្មានដោះលែងនរណាឱ្យរួចខ្លួនមួយឡើយ។ គោលការណ៍នេះក៏ត្រូវអនុវត្តផងដែរចំពោះអ្នកទោសដែលចាប់ច្រឡំ ព្រោះកម្មាភិបាលមានការព្រួយបារម្ភខ្លាចប្រជាជនបានដឹងពីអ្វីដែលកំពុងកើតឡើងនៅមន្ទីរស-២១[426]។ អ្នកទោសក្នុងក្រុមធំៗ ត្រូវបញ្ជូនទៅជើងឯកសម្លាប់ទាំងអស់។ អ្នកទោសក្នុងក្រុមតូចៗ ត្រូវគេយកទៅអគារដែលស្ថិតនៅផ្នែកខាងលិចនៃបរិវេណទួលស្លែងដើម្បីសម្លាប់។ អ្នកយាមមិនមែនជាអ្នកបាញ់សម្លាប់អ្នកទោសទេ ប៉ុន្តែពួកគេជាអ្នកវាយអ្នកទោសឱ្យស្លាប់ដោយប្រើរបារដែក[427]។ សាក្សីបានបង្ហាញនូវភស្តុតាងបញ្ជាក់ពីវត្តមានរបស់គាត់ចំនួនបីលើក ក្នុងពេលដែលអ្នកទោសមកដល់តែគុកដាក់មនុស្សក្នុងកម្រិតអតិបរមាទៅហើយនោះ។ ក្នុងស្ថានភាពដូច្នេះ អ្នកទោសដែលមានឋានៈធំនឹងត្រូវជ្រើសយកទៅទុកដើម្បីសួរចម្លើយ ក្នុងពេលដែលអ្នកទៅផ្សេងៗទៀត ត្រូវគេយកទៅសម្លាប់នៅជើងឯក[428]។ ហ៊ុយ ដែលជាប្រធានព្រៃស ក៏ត្រូវគេចាប់ហើយសម្លាប់ដែរ[429]។

28. នៅពេលដែលមន្ទីរស-២១ ត្រូវបានគេបោះបង់ចោលក្នុងខែមករា ឆ្នាំ1979 ក្នុងខណៈដែលវៀតណាមកំពុងវាយលុកចូលមកនោះ អ្នកទោសដែលនៅសល់ទាំងប៉ុន្មានត្រូវគេសម្លាប់ទាំងអស់[430]។

## សក្ខីកម្មមុនៗ

29. សាក្សីបានផ្តល់នូវសក្ខីកម្មចំនួនបួនជាមុនជូនដល់សហព្រះរាជអាជ្ញា:

(1) គក ស្រស់ សម្ភាសដោយ Doug Niven ចុះថ្ងៃទី14-15 ខែតុលា ឆ្នាំ1997, D59, ឧបសម្ព័ន្ធលេខ 16, ERN 00164562-00164576 (ភាសាអង់គ្លេស).

(2) គក ស្រស់ សម្ភាសដោយ Doug Niven ចុះថ្ងៃទី15 ខែតុលា ឆ្នាំ1997, D59, ឧបសម្ព័ន្ធលេខ 15, ERN 00164577-00164582 (ភាសាអង់គ្លេស).

(3) បទសម្ភាសន៍របស់ គក ស្រស់ ក្នុងខ្សែភាពយន្តរបស់ Peter HERCOMBE *Pol Pot: The Killing Embrace* ឆ្នាំ2000, D69, ERN V 00172454 (ភាសាអង់គ្លេស និង ភាសាខ្មែរ) ក្នុងចន្លោះពេល 00:39:30-00:42:43

(4) បទសម្ភាសន៍របស់ គក ស្រស់ ដោយ ក.ស.ច.ស ចុះថ្ងៃទី3 ខែមេសា ឆ្នាំ2008, D78/10, ERN 00195395-00195401 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

30. សាក្សីនឹងបង្ហាញនូវឯកសារពាក់ព័ន្ធក្នុងពេលសវនាការ។

## 14. គង់ ផៃ

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ពាក់ព័ន្ធនឹងមន្ទីរស-២១ សាក្សីរូបនេះបានបង្ហាញនូវភស្តុតាងពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងដំណើរប្រព្រឹត្តទៅរបស់មន្ទីរសន្តិសុខនេះ *(20-42)* វចនាសម្ព័ន្ធអំណាច *(20-25)* ការចាប់មនុស្សដាក់គុក ការបង្ខាំងមនុស្សដោយខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការសួរចម្លើយ *(43-45 & 79-84)* ធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់រង្គាល មនុស្សឃាត និងការសម្លាប់ក្រៅច្បាប់ *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងដែលសាក្សីបានបង្ហាញមានការពាក់ព័ន្ធទៅនឹងបទចោទទី 1 ទី2 និងទី 3 ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីមានអាយុ14ឆ្នាំ កើតនៅថ្ងៃទី4 ខែឧសភា ឆ្នាំ1960។ សាក្សីបានបង្ហាញនូវភស្តុតាងថា ដំបូងឡើយគាត់គឺជាឈ្លបខ្មែរក្រហម បន្ទាប់មកនៅឆ្នាំ1976 គាត់ត្រូវបានគេបញ្ជូនទៅធ្វើស្រែនៅព្រៃស[431] និងបន្ទាប់មកនៅពាក់កណ្ដាលឆ្នាំ1977 គាត់ត្រូវបានបញ្ជូនទៅធ្វើជាអ្នកយាមផ្នែកខាងក្រៅនៅមន្ទីរស-២១[432] ហើយគាត់បានបន្តធ្វើការនៅទីនោះរហូតដល់ពេលបែកភ្នំពេញក្នុងឆ្នាំ1979[433]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីបានបង្ហាញនូវភស្តុតាងដែលបញ្ជាក់ថា "ប្រធានធំ" នៅមន្ទីរស-២១គឺ **ឌុច**[434] និវសាររបស់ **ឌុច** ឈ្មោះ ឆេន[435]។ សាក្សីបានឃើញ **ឌុច** នៅមន្ទីរស-២១[436] ក្នុងពេលដែលសាក្សីកំពុងយាម គាត់បានឃើញ **ឌុច** ចូលមកសួរចម្លើយអ្នកទោសនៅក្នុងគុកពិសេស[437]។

4. **ឌុច** និង ហ៊ី ជាអ្នកសួរចម្លើយអ្នកទោសបរទេស ឬអ្នកទោសដែលមានឋានៈខ្ពស់ដោយខ្លួនឯងផ្ទាល់[438] សាក្សីក៏បានរំលឹកផងដែរថា **ឌុច**, ហ៊ី និង ចាន់ បានសួរចម្លើយអ្នកទោសអាមេរិចកាំងបីនាក់[439] ដែលគេនាំមកមន្ទីរស-២១ ក្នុងឆ្នាំ1978។ ច្បាស់ជាងនេះទៅទៀត សាក្សីបានឃើញ **ឌុច** កំពុងតែសួរចម្លើយ

អ្នកទោសអាមេរិចកាំងម្នាក់ដែលស្លៀកតែខោខ្លី មានសក់រួញក្រហមវែងត្រឹមស្មា។ មុនពេល ឌុច សួរចម្លើយអ្នកទោសនោះមានពាក់អាវយឺត[440]។

5. ឌុច គឺជាអ្នកសម្រេចក្នុងការជ្រើសរើសបុគ្គលនៅ ស-២១[441]។ សាក្សីផ្តល់ភស្តុតាងថាគាត់បានចូលរួមវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិក ស-២១ ចំនួនពីរលើក ដែលរៀបចំឡើងដោយ **ឌុច**។ នៅ ក្នុងវគ្គបណ្តុះបណ្តាល គេបង្រៀនបុគ្គលិក ស-២១ ថា "យុទ្ធជនគឺជាទំពាំងរបស់បក្ស"[442]។ **ឌុច** ក៏បានបង្រៀនថា អ្នកទោសគឺជាសត្រូវ ហើយប្រសិនបើអ្នកទោសមិនឆ្លើយសារភាព យើងអាចប្រើទណ្ឌកម្មលើអ្នកទោស[443]។

6. សាក្សីផ្តល់ភស្តុតាងអំពីការជឿជាក់របស់គាត់ថា **ឌុច** បានរៀបចំសម្លាប់ភ្លាមលើអ្នកទោសនៅ ស-២១ ជាច្រើននាក់ មុនពេលវៀតណាមចូលឈ្លានពាន[444]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

7. សាក្សីផ្តល់ភស្តុតាងថា អ្នកយាមជុំវិញ ស-២១ មានចំនួនពីរខ្សែ និងកន្លែងប្រហារមួយនៅទិសខាងលិច[445]។ សន្តិសុខនៅមន្ទីរឃុំឃាំងគឺមានវិន័យ "តឹងរឹងណាស់"[446]។ គាត់បានឃើញនៅក្តារខៀននៅមន្ទីរឃុំឃាំងពិសេស ដែលបានសរសេរលើនោះថា "បទបញ្ជាមន្ទីរសន្តិសុខ"[447]។

8. ដំបូង សាក្សីយាមមន្ទីរឃុំឃាំងតូច ដែលជាកន្លែង "សំខាន់ជាង" មន្ទីរឃុំឃាំងធំ ដោយសារតែកន្លែងនោះឃុំមន្ត្រីជាន់ខ្ពស់ ឬអ្នកទោសបរទេស[448] រួមមានអ្នកទោសជនជាតិអាមេរិក និងជនជាតិវៀតណាម[449]។ កងចាប់ខ្លួនរបស់ ស-២១ ប្រើប្រាស់ឡានសូវៀត និងឡានចិនដើម្បីធ្វើការចាប់ខ្លួនមនុស្សនៅតាមភូមិភាគនានា[450]។

9. ពេលខ្លះ នៅក្នុងឆ្នាំ១៩៧៨ សាក្សីយាមច្រកទ្វារចេញចូលមន្ទីរឃុំឃាំងនៅទិសខាងត្បូង ទោះបីជាអ្នកទោសថ្នាក់ខ្ពស់ និងអ្នកសួរចម្លើយប្រើប្រាស់ច្រកទ្វារនៅទិសខាងជើងក្តី[451]។

10. សាក្សីបានផ្តល់ភស្តុតាងថា បីបួនថ្ងៃមុនថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គាត់ត្រូវបានគេបញ្ជូនទៅយាមនៅច្រកទ្វារចេញចូល "ដោយសារតែមានអ្នកទោសច្រើន"។ អ្នកទោសទាំងនោះ ត្រូវបានសម្លាប់ចោលទាំងអស់ ដោយអ្នកទោសខ្លះត្រូវបានគេសម្លាប់នៅ ស-២១ និងអ្នកទោសខ្លះទៀតត្រូវបានគេដឹកទៅជើងឯក មុនពេលបុគ្គលិក ស-២១ រត់គេច។ សាក្សីបានផ្តល់ភស្តុតាងថា គាត់បានឃើញការសម្លាប់នេះដោយផ្ទាល់ភ្នែករបស់គាត់[452]។

## វចនាសម្ព័ន្ធរដ្ឋអំណាច

11. សាក្សីបានផ្តល់ភស្តុតាងថា "ប្រធានជាន់ខ្ពស់" នៅស-២១ គឺ ឌុច[453]។ ហ៊ី គឺជាអនុប្រធាន និង ចាន់ គឺជាសមាជិកបក្ស[454]។ ស្រ៊ុ គឺជាប្រធានអ្នកយាម[455] និងម៉ូ (MAU) ជាប្រធានកងការពារសាក្សី[456]។ ហ៊ុយ និង ប៉េង គឺជាប្រធានកងចាប់ខ្លួន[457]។ ចាន់ គឺជា "សមាជិក" នៅស-២១ និងទទួលបន្ទុកបែងចែកបុគ្គលិកស-២១ ជាក្រុមតូចៗ។[458] សាក្សីបានផ្តល់ភស្តុតាងថា ជនដែលសម្លាប់អ្នកទោសដោយផ្ទាល់ រួមមាន ហ៊ុយ, ទ្រី និង ម៉ូ (MAU) ហើយ ទ្រី ជាអ្នកថតរូប[459]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

12. សាក្សីផ្តល់ភស្តុតាងថា នៅពេលគាត់កំពុងយាមនៅខាងក្រៅរបងរបស់ស-២១ គាត់បានឃើញគេយកអ្នកទោសចេញចូល[460] និងពេលខ្លះ គាត់ជាអ្នកនាំអ្នកទោស ដែលជាប់ខ្នោះដៃ និងបិទមុខជិតដោយផ្ទាល់ ដើម្បីទៅសួរចម្លើយនៅ "កន្លែងផ្សេងទៀត" នៅខាងកើតកន្លែងរបស់គាត់[461]។ សាក្សីបានផ្តល់ភស្តុតាងថា យោធាដែលមកពីទិសខាងលិច ត្រូវបានឃុំខ្លួននៅអគារប៉ែកខាងត្បូង[462]។ នៅឆ្នាំ១៩៧៨ សាក្សីបានឃើញអ្នកទោសជនជាតិអាមេរិកចំនួនបីនាក់ ត្រូវបានគេនាំចូលតាមច្រកទ្វារខាងត្បូងដែលជាច្រកទ្វារគាត់កំពុងយាម។ នៅពេលគាត់យកបាយឱ្យអ្នកទោសអាមេរិកម្នាក់ក្នុងចំណោមនោះនៅជាន់ទីពីរ គាត់បានឃើញថា អ្នកទោសជនជាតិអាមេរិកទាំងនោះត្រូវបានគេឃុំក្នុងបន្ទប់ផ្សេងគ្នា[463]។ ជនជាតិអាមេរិកទាំងនេះ ត្រូវបានគេចាប់ខ្លួនពីកោះនានានៅក្នុងឈូងសមុទ្រសៀម និងត្រូវបានគេមើលការខុសត្រូវយ៉ាងល្អ ដោយផ្តល់នូវម្ហូបអាហារ ទឹក និងបារី និងមិនមានវាយដំលើពួកនេះទេ[464]។ អ្នកយាមដែលមកប្តូរវេនគាត់ បានប្រាប់គាត់ថា "ពួកវាបានយកជនជាតិអាមេរិកទាំងបីទៅបាត់ហើយ" និងមិនដែលឃើញទៀតទេ[465]។

13. សាក្សី ផ្តល់ភស្តុតាងថា ពេលខ្លះគាត់ទៅយាមនៅបន្ទប់ឃុំខ្លួនអ្នកទោសស្រីជនជាតិវៀតណាម ដែលក្រោយមក គាត់ដឹងថា អ្នកទោសស្រីជនជាតិវៀតណាមទាំងនោះគឺជាស្រីពេស្យារបស់យោធាវៀតណាម ដែលខ្មែរក្រហមចាប់ខ្លួន។ គាត់ក៏ធ្លាប់បានយាមអ្នកទោសយោធាវៀតណាមភេទប្រុសដែរ[466]។

## ការសួរចម្លើយ

14. សាក្សី ផ្តល់ភស្តុតាងថា ការសួរចម្លើយធ្វើឡើង "ដើម្បីរកឱ្យឃើញខ្សែស្រឡាយ" និងសកម្មភាពឈ្លបយកការណ៍ ដែលជាទូទៅត្រូវបានចោទប្រកាន់ជាភ្នាក់ងារស៊ី អាយ អេ។ កំណត់ហេតុនៃការសួរចម្លើយ

មិនបានផ្តល់ឲ្យគ្រប់គ្នាដឹងនោះទេ[467]។ នៅពេលយាមនៅខាងក្រៅបង ស-២១ គាត់បានបើកទ្វារឲ្យអ្នកសួរចម្លើយ "ដែលធ្វើឲ្យគាត់ចាំមុខពួកទាំងនោះ" ដែលអ្នកសួរចម្លើយម្នាក់ក្នុងចំណោមនោះឈ្មោះ ទុយ[468]។

15. ឌុច និង ហ៊ី ធ្វើការសួរចម្លើយអ្នកទោសជាន់ខ្ពស់ និងអ្នកទោសបរទេសដោយផ្ទាល់[469] និងសាក្សីបានរំលឹកថា ឌុច ហ៊ី និង ចាន់ ជាអ្នកសួរចម្លើយអ្នកទោសអាមេរិកបីរូប[470] ដែលនាំមក ស-២១ នៅឆ្នាំ ១៩៧៨។ ជាពិសេស គាត់បានឃើញ **ឌុច** សួរចម្លើយអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសអាមេរិក ដែលមានតែខោខ្លី ដែលមានសក់រួញអង្កាញ់វែងពណ៌ក្រហមធ្លាក់ត្រឹមស្មា។ មុនពេល **ឌុច** សួរចម្លើយអ្នកទោសមានពាក់អាវយឺត[471]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

16. សាក្សីផ្តល់ភស្តុតាងថា នៅពេលគាត់កំពុងយាមអ្នកទោស និងយកអាហារឲ្យអ្នកទោស[472] គាត់បានឃើញអ្នកសួរចម្លើយធ្វើទារុណអ្នកទោសដោយប្រើរំពាត់[473] ខ្សែតី និងឆក់ខ្សែភ្លើង[474] និងគាត់បានឃើញស្នាមជាំ និងដំបៅរលួយនៅពាសពេញខ្លួនប្រាណរបស់អ្នកទោស[475]។ អ្នកទោសត្រូវបានគេដកក្រចកជើង ជ្រមុជក្នុងធុងទឹកកក[476] និងត្រូវបានចងភ្ជាប់នឹងបន្ទះឈើ និងដុតភ្លើង ដែលធ្វើឲ្យអ្នកទោសទាំងនោះក្តៅមិនអាចទ្រាំបាន ហើយទីបំផុតក៏ឆ្លើយសំនួរ[477]។ គាត់បានលឺសម្រែករបស់អ្នកទោស និងបានឃើញពេទ្យមកពិនិត្យព្យាបាលអ្នកទោសដែលរងរបួស។ សាក្សីផ្តល់ភស្តុតាងថា "អ្នកសួរចម្លើយទាំងអស់ធ្វើទារុណកម្មលើអ្នកទោស"[478]។ **ឌុច** បានបង្រៀនថា អ្នកទោសគឺជាសត្រូវ ដូច្នេះប្រសិនបើអ្នកទោសមិនផ្តល់ចម្លើយ យើងអាចធ្វើទារុណកម្មលើពួកទាំងនោះ[479]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

17. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសដែលត្រូវបានសួរចម្លើយ ត្រូវបានសម្លាប់ចោលទាំងអស់។ សាក្សីបានដឹងអំពីការសម្លាប់នេះ ដោយសារតែគេប្រាប់គាត់នៅក្នុងអំឡុងពេលបណ្តុះបណ្តាលដែលបានលើកឡើងថា ជាចុងក្រោយ អ្នកទោសទាំងអស់នឹងត្រូវសម្លាប់ចោល[480]។ សាក្សីផ្តល់ភស្តុតាងថា ជាធម្មតាអ្នកទោសត្រូវបានគេដឹកចេញដោយឡានធំៗ ឬប្រសិនបើមានអ្នកទោសតែបីបួននាក់ អ្នកទោសត្រូវធ្វើដំណើរដោយថ្មើរជើង។ សាក្សី មិនបានដឹងអំពីទីកន្លែងពិតប្រាកដ ដែលគេដឹកអ្នកទោសទាំងនោះចេញទៅនោះទេ ប៉ុន្តែគាត់បានដឹងយ៉ាងច្បាស់ថា គេនាំអ្នកទោសទាំងនោះទៅកន្លែងដែលពួកវាអាចសម្លាប់ ពីព្រោះអ្នកទោសទាំងនោះត្រូវបានយកចេញទៅបាត់នៅពេលយប់ ឬនៅពេលរសៀល[481]។

18. សាក្សីផ្តល់ភស្តុតាងថា គាត់បានឃើញការសម្លាប់អ្នកទោសកើតឡើងនៅក្នុង និងជុំវិញបរិវេណ ស-២១។ គាត់បានឃើញរណ្តៅធំមួយ "ដែលធំស្មើនឹងត្រពាំង" នៅផ្នែកខាងលិចនៃរបងគុក ស-២១[482]។ គាត់បានឃើញអ្នកទោសត្រូវបានគេសម្លាប់នៅកន្លែងប្រហារជីវិត ចម្ងាយពី២០ទៅ៣០ម៉ែត្រពីផ្ទះរបស់គាត់។ នៅក្នុងឧប្បត្តិហេតុមួយ ប្រហែលជាកណ្តាលអធ្រាត្រ សាក្សីបានលឺសម្រែក និងបានឃើញអ្នកទោសត្រូវបានគេវាយនឹងបន្ទះដែករហូតដល់ស្លាប់។

19. នៅក្នុងឧប្បត្តិហេតុផ្សេងមួយទៀត ប្រហែលម៉ោង៩ ឬម៉ោង១០យប់ សាក្សីបានឃើញអ្នកទោសត្រូវបានគេសម្លាប់នៅក្នុងបរិវេណ ស-២១។ គាត់បានឃើញអ្នកទោសមួយជួរត្រូវបានគេបិទមុខជិត ដៃចងទៅខាងក្រោយខ្នង ដែលគេបណ្តើរអ្នកទោសទៅមាត់រណ្តៅធំ និងសម្លាប់ចោល[483]។

20. សាក្សីផ្តល់ភស្តុតាងថា ជនដែលសម្លាប់អ្នកទោសដោយផ្ទាល់រួមមាន ហ៊ុយ, ទ្រី និង ម៉ូ (MAU) ដែលទ្រី ជាអ្នកថតរូប។ តាមការបញ្ជាពីខាងលើគឺថា អ្នកទោសជាន់ខ្ពស់ ត្រូវបានគេយកចេញទៅ និងត្រូវបានសម្លាប់ នៅពេលបញ្ចប់ការសួរសម្លើយ ដោយមិនចាំបាច់មានការយល់ព្រមពីថ្នាក់លើបន្ថែមទេ[484]។ ចំពោះអ្នកទោសតូចតាច កងប្រហារជីវិត ជារឿយៗត្រូវការជំនួយពីអ្នកយាម ដើម្បីយកអ្នកទោសដាក់លើរថយន្តធំៗ ដើម្បីយកទៅសម្លាប់ចោល[485]។ ចំពោះអ្នកទោសសំខាន់ ដូចជាអ្នកទោសបរទេសត្រូវបានគេសម្លាប់នៅកន្លែងប្រហារជីវិត ក្បែរ ស-២១។ ឌុច បានបញ្ជាឲ្យធ្វើដូច្នេះ ទោះបីជាគាត់មិនមានវត្តមានដោយផ្ទាល់នៅកន្លែងប្រហារជីវិតក៏ដោយ។

21. សាក្សីបានផ្តល់ភស្តុតាងថា ក្នុងអំឡុងវគ្គសិក្សា គេបានប្រាប់ពួកគាត់ថា ហ៊ូ យន់ និង ហ៊ូ នឹម ត្រូវបានគេសម្លាប់នៅ ស-២១ "ដោយសារញុះញង់ឲ្យមានចលាចល"[486]។

22. សាក្សីផ្តល់ភស្តុតាងថា បីបួនថ្ងៃមុនថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ អ្នកទោសជាច្រើនត្រូវបានគេសម្លាប់ ដែលអ្នកទោសខ្លះត្រូវបានសម្លាប់នៅ ស-២១ និងអ្នកទោសខ្លះទៀត ត្រូវបានគេដឹកបញ្ជូនទៅជើងឯក មុនពេលបុគ្គលិករត់គេចខ្លួន។ សាក្សីបានឃើញការសម្លាប់នេះ ដោយផ្ទាល់ភ្នែករបស់គាត់[487]។

## សក្ខីកម្មមុនៗ

23. សាក្សីធ្លាប់បានផ្តល់សក្ខីកម្មមុនចំនួនប្រាំមួយទៅឲ្យសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ គង់ ផៃ ដោយ DC-Cam ចុះថ្ងៃទី25 ខែកុម្ភៈ ឆ្នាំ2000, at ERN 000054619-00054629, ERN 00054619-4674 (ភាសាខ្មែរ) *(ឯកសារសង្ខេបជាភាសាអង់គ្លេសមាននៅ D61/1-00004,គ្មាន ERN).*

(2) បទសម្ភាសន៍របស់ គង់ ផៃ ដោយ DC-Cam ចុះថ្ងៃទី25 ខែកុម្ភៈ ឆ្នាំ2000 និងថ្ងៃទី23 ខែខែមិថុនា ឆ្នាំ2003, នៅ ERN 00054619-00054629, ERN 00054630-4674 (ភាសាខ្មែរ) *(ឯកសារសង្ខេបជាភាសាអង់គ្លេសមិនទាន់មឹង, គ្មាន ERN).*

(3) បទសម្ភាសន៍របស់ គង់ ផៃ ដោយ ក.ស.ព-អ.វ.ត.ក ចុះថ្ងៃទី 9 ធ្នូ 2006, ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ 23.5, ERN 00146781-6785 (ភាសាអង់គ្លេស), ERN 00078676-8682 (ភាសាខ្មែរ).

(4) បទសម្ភាសន៍របស់ គង់ ផៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 27 ធ្នូ 2007, D28/1, ERN 00163631-3635 (ភាសាអង់គ្លេស), ERN 00163626-3630 (ភាសាខ្មែរ).

(5) បទសម្ភាសន៍របស់ គង់ ផៃ ដោយ ក.ស.ច.ស- អ.វ.ត.ក ស្តីពីកំណត់ហេតុនៃការចុះធ្វើការស៊ើប អង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី 27 កុម្ភៈ 2008, D48/2, ERN 00197998-00198008 (ភាសាអង់គ្លេស).

(6) កំណត់ហេតុនៃការតទល់មុខគ្នារបស់ គង់ ផៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី 29 កុម្ភៈ 2008, D54, ERN 00166561-00166570 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

24. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធនានានៅពេលជំនុំជម្រះ។

## 15. ឡាច មាន

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងអំពីគោលនយោបាយ និងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹង ស-២១ សាក្សីនេះបានផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)*, រចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនដោយខុសច្បាប់ ភាពខ្វះការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការឈឺចាប់យ៉ាងខ្លាំងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [new])* និងការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត និងការធ្វើមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [new])*. ភស្តុតាងរបស់គាត់ ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ១៧ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សាក្សី មានសញ្ជាតិខ្មែរ ភេទប្រុស កើតថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ១៩៥៧[488]។ សាក្សីគឺជាយោធាខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ និងនៅឆ្នាំ១៩៧៥ សាក្សីត្រូវបាន ចាន់ យកទៅភ្នំពេញជាមួយអ្នកផ្សេងទៀត ដើម្បីទៅធ្វើការនិងរៀនសូត្រនៅទីនោះ។ សាក្សីផ្តល់ភស្តុតាងថា គាត់ត្រូវបានគេបញ្ជូនឱ្យទៅយាមនៅកន្លែងផ្សេងៗ រួមមាន គុក ប៉េហ្ស៊ី (*Police Judiciare*) ក្បែរផ្សារថ្មី មុនពេលបញ្ជូនគាត់ទៅធ្វើការនៅ ស-២១ នៅឆ្នាំ១៩៧៧។ គាត់បានចាប់ផ្តើមធ្វើការងារជាអ្នកយាម បន្ទាប់មកធ្វើការងារជាអ្នកវាយអង្គលីលេខ និងចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៨ គាត់ត្រូវបានគេបណ្តុះបណ្តាលឱ្យធ្វើជាអ្នកសួរចម្លើយ ដែលគាត់ទទួលដំណែងជាអ្នកសួរចម្លើយរហូតដល់ពេលវៀតណាមឈ្លានពាន[489]។ ចម្លើយសារភាពនៅសេសសល់ចំនួន១៥ ដែលមានសរសេរឈ្មោះសាក្សីថាអ្នកសួរចម្លើយ។

## វចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

3. សាក្សីផ្តល់ភស្តុតាងថា សុន សេន បានមក ស-២១ ជារៀងរាល់ខែម្តង ឬពីរខែមកម្តង ដើម្បីបង្រៀនអំពីវគ្គនយោបាយ[490]។ ស-២១ មានគោលនយោបាយថា បុគ្គលិកគ្មានសិទ្ធិ "រំលោភបំពាន"[491] លើកិច្ចការរបស់អ្នកផ្សេងទៀត និងមិនអនុញ្ញាតឱ្យទាក់ទងជាមួយកងផ្សេងទៀតនោះទេ[492]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីផ្តល់ភស្តុតាងថា "គ្រប់គ្នានិយាយថា" **ឌុច** គឺជាប្រធាន ស-២១[493]។ **ឌុច** ជាញឹកញាប់តែងតែចេញចូលកន្លែងសួរចម្លើយ ស-២១[494] និងរៀងរាល់បួន ឬប្រាំថ្ងៃម្តង គាត់បានផ្តល់ការបណ្តុះបណ្តាលអំពីការសួរចម្លើយ ជាពិសេសលើ "ចំណុចខ្សោយ"របស់អ្នកទោស អំពីក្បួនដោះស្រាយជាមួយអ្នកទោស"មិនសារភាព"[495] និង "រៀបរាប់អំពីអ្នកទោសដែលមានការជាប់ទាក់ទិននឹងបុគ្គលខ្លះទៀត"[496]។ សាក្សីបានផ្ញើច្បាប់ចម្លង "ចម្លើយសារភាព"របស់អ្នកទោសទៅឱ្យ **ឌុច**[497]។ កាលពីពេលមួយនោះ សាក្សីបានទូរសព្ទទៅ ឌុច នៅពេលអ្នកទោសម្នាក់មានការជាប់ទាក់ទងនឹង វន វ៉េត ។ ដំបូង ឌុច ប្រាប់សាក្សីមិនចាំបាច់សរសេរអំពីការជាប់ទាក់ទិននេះទេ ប៉ុន្តែក្រោយមក បន្ទាប់ពី **ឌុច** "បានត្រួតពិនិត្យ" **ឌុច** បានហៅសាក្សីត្រលប់មកវិញ និងឱ្យសាក្សី "សរសេរអំពីការជាប់ទាក់ទិននេះឡើងវិញ"[498]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីផ្តល់ភស្តុតាងថា អ្នកយាមផ្នែកខាងក្នុងត្រូវបានគេណែនាំឱ្យទប់ស្កាត់អ្នកទោសកុំឱ្យលួចរត់ ឬធ្វើអត្តឃាតខ្លួន[499]។ អ្នកយាមបានធ្វើការប្តូរវេនគ្នាពីម៉ោង៥ព្រឹក ដល់ម៉ោង១១ថ្ងៃ បន្ទាប់មកធ្វើការងារទូទៅនៅក្នុងនិងជុំវិញបរិវេណ ស-២១ និងត្រលប់មកយាមពីម៉ោង៥ល្ងាចរហូតដល់ម៉ោង១២យប់ ឬពីម៉ោង១២យប់រហូតដល់ម៉ោង៥ព្រឹក។ អគារផ្សេងគ្នា ត្រូវការពារដោយអ្នកយាមខុសគ្នា និងមិនអាច "រំលោភបំពាន"លើការងាររបស់អ្នកផ្សេងនោះទេ[500]។ អគារធំៗមានចំនួនបី៖ អគារនៅកាច់ជ្រុងខាងត្បូងសម្រាប់ឃុំអ្នកទោសជាន់ខ្ពស់។ អគារនៅកណ្តាលនៃទិសខាងកើត មានបន្ទប់ឃុំឃាំងធំៗសម្រាប់ឃុំអ្នកទោសដោយដាក់ឃ្នាងជើងធ្វើអំពីដែក និងអគារនៅកណ្តាលមានបន្ទប់តូចៗនៅជាន់ផ្ទាល់ដី និងនៅជាន់កណ្តាល[501]។ បន្ទាប់ពីមកដល់ ស-២១ អ្នកទោសត្រូវបានថតរូបដោយ អេន, សុង, និង និត[502] សាក្សីផ្តល់ភស្តុតាងថា កម្មាភិបាល និងអ្នកសួរចម្លើយនៅស-២១មួយចំនួន ត្រូវបានចាប់ខ្លួន។ នៅពេល "យកពួកទាំងនោះចេញ" ពួកនោះត្រូវបានគេយកក្រណាត់គ្រប និងត្រូវបានឃុំខ្លួននៅអគារខាងត្បូង[503]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

6. សាក្សីផ្តល់ភស្តុតាងថា "គ្រប់គ្នានិយាមថា" ឌុច គឺជាប្រធានស-២១[504]។ ហ៊ី គឺជាអនុប្រធាន[505] និង ប៊ុន ទទួលបន្ទុកលើការសួរចម្លើយអ្នកទោសដែលមានសារៈតាជាន់ខ្ពស់[506]។ សេង គឺជាប្រធានកងការពារ និង យ៉ែម យាន ហៅ ច្រិច, រី, រ៉ាត, អ៊ុន, វ៉េត, ផៃ គឺជាសមាជិក។ កងសួរចម្លើយ (តាមលំដាប់នៃឋានន្តរសក្តិ) មានដូចជា នន, ហេង, កាក់, ណន, ឃិត, អឿន, សេង, វ៉េត, និង ភាព ហៅ ច្រឹក។ អ្នកសួរចម្លើយជាន់ខ្ពស់គឺ ចាន់ និង ប៊ុន និងមានអ្នកផ្សេងទៀតចំនួនប្រាំមួយ ទៅប្រាំពីរនាក់ទៀត ដែលសាក្សីមិនអាចចាំឈ្មោះអ្នកទាំងនោះបាន[507]។ ធី និង ឡុន ទទួលបន្ទុកជាអ្នកទទួលអ្នកទោសទាំងពេលថ្ងៃ និងពេលយប់[508]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

7. សាក្សីផ្តល់ភស្តុតាងថា ស-២១ អាចផ្ទុកអ្នកទោសចំនួន "ប្រហែល1000នាក់"[509]។ គាត់បានឃើញអ្នកទោសប្រុសស្រី ប៉ុន្តែគាត់មិនបានឃើញកូនក្មេងនោះទេ[510]។ អ្នកទោសប្រុស និងអ្នកទោសស្រីត្រូវបានគេដាក់នៅក្នុងបន្ទប់ឃុំផ្សេងពីគ្នា និងអ្នកទោសស្រីមួយចំនួនត្រូវបានគេដាក់នៅក្នុងបន្ទប់ឃុំឃាំងរួម[511]។ គាត់ចាំថា គាត់បានឃើញ ជនជាតិវៀតណាម (គាត់ជឿជាក់ថាជាយោធា) និងអ្នកទោសជនជាតិអាមេរិក "ចំនួនពីរ ឬបីនាក់" នៅស-២១[512]។ សាក្សីផ្តល់ភស្តុតាងថា ប្រធានមន្ទីរពេទ្យ និងអ្នកគ្រប់គ្រងរោងចក្រនានា ត្រូវបានដាក់គុកនៅ ស-២១ ហើយគាត់បានឃើញ "ឡានដឹក"អ្នកទោស ចេញចូល ស-២១[513]។ សាក្សីផ្តល់ភស្តុតាងថា អ្នកសួរចម្លើយ និងអ្នកយាមខ្លួនឯង ក៏ត្រូវបានគេចាប់ខ្លួនដែរ[514]។ អ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងតូចៗ ត្រូវបានគេដាក់ច្រវ៉ាក់ជើងទាំងសងខាង លុះត្រាតែអ្នកទោសទាំងនោះត្រូវបានគេសួរចម្លើយលើសពីពីរលើក ដែលនៅពេលនោះ អ្នកទោសត្រូវបានដាក់ច្រវ៉ាក់ជើងតែម្ខាងប៉ុណ្ណោះ[515]។ អ្នកទោសដែលត្រូវបានគេសួរចម្លើយចប់សព្វគ្រប់ និងអ្នកទោសដែលគេចាត់ទុកថា "មិនចាំបាច់"សួរចម្លើយនោះទេ ត្រូវបានគេឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងរួម[516]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

8. សាក្សីផ្តល់ភស្តុតាងថា ជារឿយៗ អ្នកទោសត្រូវបានគេឃុំនៅក្នុងបន្ទប់តូចៗ និងស្ទើរតែងតែត្រូវបានគេដាក់ខ្នោះនៅជើងទាំងសងខាង[517]។ ជាធម្មតា អ្នកទោសពាក់តែខោខ្លីប៉ុណ្ណោះ និងអាវមួយនៅក្នុងអំឡុងពេលខែត្រជាក់ ប៉ុន្តែស្ត្រីត្រូវបានអនុញ្ញាតឱ្យស្លៀកពាក់ "តាមធម្មតា"[518]។ អ្នកទោសដេកនៅលើឥដ្ឋ[519]

និងបត់ជើងដាក់ក្នុងកេះគ្រាប់កាំភ្លើងទទេ[520]។ អ្នកទោសអាចងូតទឹកតែនៅពេលដែលបន្ទប់របស់អ្នកទោសត្រូវបានគេបាញ់ទឹកលាងសម្អាត[521]។ អ្នកទោសត្រូវបានគេផ្តល់បាយ លាយជាមួយទឹកស៊ុបចំនួនពីរលើកក្នុងមួយថ្ងៃ[522]។ សាក្សីផ្តល់ភស្តុតាងថា អ្នកទោសបានស្លាប់ដោយសារជម្ងឺ និងរោគរាគមួល[523]។ សាក្សីផ្តល់ភស្តុតាងថា ជារឿយៗ គាត់បានលឺសម្រែក និងសំលេងយំរបស់អ្នកទោស។ អ្នកទោសខ្លះប៉ុនប៉ងធ្វើអត្តឃាតខ្លួន។ ក្នុងពេលមួយនោះ អ្នកទោសម្នាក់បានដណ្តើមយកអាវុធរបស់អ្នកយាម និងសម្លាប់ខ្លួនឯង[524]។ អ្នកសួរចម្លើយម្នាក់ឈ្មោះ ទូច បានដាក់ថ្នាំ និងរំលោភលើអ្នកទោសស្រីម្នាក់ ប៉ុន្តែអ្នកទោសស្រីបានរាយការណ៍អំពីការប្រព្រឹត្តរបស់គាត់។ គាត់ត្រូវបានចាប់ខ្លួនបន្ទាប់ពីគាត់ព្យាយាម មិនបានសម្រេចក្នុងការធ្វើអត្តឃាតខ្លួន[525]។

## ការសួរចម្លើយ

9. ការសួរចម្លើយធ្វើឡើងនៅកន្លែងខាងក្រៅនៃជញ្ជាំងគុក ដែលស្ថិតនៅផ្លូវទៅផ្ទះរបស់ **ឌុច** ឬផ្ទះដទៃផ្សេងទៀតនៅខាងមុខគុក[526]។ ការធ្វើឯកសារធ្វើឡើងជាបីដំណាក់កាល៖ ដំណាក់កាលទីមួយ អ្នកទោសសរសេរចម្លើយសារភាពរបស់ខ្លួន។ ក្រោយមក ចម្លើយសារភាពត្រូវបានវាយអង្គលីលេខ។ ត្រឹមខែចុងក្រោយនៃរបបនេះ ការសួរចម្លើយធ្វើឡើងដោយមានការថតសម្លេង "ដើម្បីត្រួតពិនិត្យទាំងអ្នកសួរចម្លើយ និងអ្នកផ្តល់ចម្លើយ"[527]។

10. សាក្សីផ្តល់ភស្តុតាងអំពីការបណ្តុះបណ្តាលរបស់ **ឌុច**, កាក់, និង ផល ឬ ប៉ូច ដើម្បីឱ្យខ្លួនក្លាយជាអ្នកសួរចម្លើយម្នាក់ កាលពីចុងឆ្នាំ១៩៧៨។ ការរៀនដើម្បីក្លាយខ្លួនជាអ្នកសួរចម្លើយម្នាក់ ជាធម្មតាតម្រូវឱ្យមើលអ្នកសួរចម្លើយដែលមានបទពិសោធន៍នៅកន្លែងធ្វើការនៅក្នុងពេលសួរចម្លើយជាក់ស្តែង[528]។ ក្សីផ្តល់ភស្តុតាងថា គាត់ត្រូវដកទុកច្បាប់ចម្លង"ចម្លើយសារភាព"មួយច្បាប់ និងបញ្ជូនច្បាប់ចម្លងផ្សេងទៀតទៅឱ្យ **ឌុច**[529]។

11. ការសួរចម្លើយចាប់ផ្តើមដោយការចោទសំណួរអំពី "ប្រវត្តិនៃការក្បត់បក្ស" របស់ពួកគេ។ សាក្សីបានផ្តល់ភស្តុតាងថា ដំបូង គាត់សួរចម្លើយអ្នកទោសដែលមិនសូវសំខាន់ ឬត្រូវបានចាត់ទុកជា "ប្រភេទខ្សោយ"[530] ប៉ុន្តែក្រោយមក នៅពេលគាត់មានជំនាញប៉ិនប្រសប់ គាត់ត្រូវបានគេចាត់តាំងឱ្យធ្វើការងារសំខាន់៖ "ពេលខ្លះ [នៅពេល] [អ្នកសួរចម្លើយ] ចាស់ៗបានសួរចម្លើយអ្នកទោស ប៉ុន្តែមិនអាចយកចម្លើយសារភាពក្នុងរយៈពេលពីរខែ ឬបីខែ ពួកវាបានចាត់តាំងខ្ញុំឱ្យទៅសួរចម្លើយអ្នកទោសទាំងនោះ

ក្រែងលោខ្ញុំអាចយកចម្លើយសារភាពពីអ្នកទោសទាំងនោះបាន"[531]។ អ្នកទោសភាគច្រើនបានសារភាព "ក្លាមៗ" ថាខ្លួនជាសមាជិករបស់ស៊ីអាយអេ ឬបក្សពលករវៀតណាម[532]។

12. ការវិភាគលើចម្លើយសារភាពដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញថា ចម្លើយសារភាពអ្នកនៅរស់ចំនួន១៥ មានឈ្មោះរបស់សាក្សី ដែលធ្វើការងារជាអ្នកសួរចម្លើយចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៧៨ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[533]។

13. សាក្សីផ្តល់ភស្តុតាងថា ប៉ុន និង ចាន់ ទទួលបន្ទុកចំពោះការសួរចម្លើយអ្នកទោសជាន់ខ្ពស់[534]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

14. សាក្សីផ្តល់ភស្តុតាងថា **ឌុច** បានចាត់តាំង ហ៊ី ឱ្យធ្វើការសួរចម្លើយនៅ ស-២១ ប៉ុន្តែអ្នកសួរចម្លើយចាស់ៗ ក៏មានសិទ្ធិធ្វើការសួរចម្លើយដែរ[535]។ សាក្សីផ្តល់ភស្តុតាងថា នៅពេលអ្នកទោសដែលគាត់សួរចម្លើយមិនព្រមឆ្លើយសារភាព គាត់បាននាំអ្នកទោសនោះឱ្យ ហ៊ី ដើម្បីវាយអ្នកទាំងនោះនឹងមែកដើមត្របែក[536]។ ទោះបីជាសាក្សីផ្តល់ភស្តុតាងថា "ភាពសម្ងាត់យ៉ាងខ្លាំង" ត្រូវបានរក្សា "ក្នុងពេលធ្វើទារុណកម្ម"[537] គាត់ផ្តល់ភស្តុតាងថា នៅពេលកំពុងត្រូវបានគេវាយដំ អ្នកទោសត្រូវបានឆក់នឹងខ្សែភ្លើងនៅត្រចៀករបស់ពួកអ្នកទោស[538] និង "ប្រហែល"ជាការធ្វើទារុណកម្មធ្វើឱ្យថប់ដង្ហើមដោយថង់ប្លាស្ទិក[539]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានឃើញអ្នកទោសត្រូវបានគេធ្វើទារុណកម្ម "ដែលខ្នងអ្នកទាំងនោះហើមធំ និងឈឺចាប់"[540]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

15. សាក្សីផ្តល់ភស្តុតាងថា ទោះបីជាគាត់មិនដែលឃើញការសម្លាប់អ្នកទោស ប៉ុន្តែគាត់បានឃើញឡានដឹកអ្នកទោសបើកចេញចូល ស-២១[541]។ និងនៅពេលមានអ្នកទោស"ច្រើនពេក" អ្នកទោសមួយចំនួនត្រូវបានគេ"យកទៅបាត់"[542]។ សាក្សីផ្តល់ភស្តុតាងថា បន្ទាប់ពីអ្នកទោសផ្តល់ "ចម្លើយសារភាព"របស់គាត់ អ្នកទាំងនោះ "បានបាត់ខ្លួន" និងមិនឃើញត្រលប់មកវិញ ដែល"ប្រហែលត្រូវបានគេសម្លាប់ចោល"[543]។ សាក្សីផ្តល់ភស្តុតាងថា អ្នកទោសបានស្លាប់ដោយសារជម្ងឺ ឬរោគរាគមួល[544]។

## សក្ខីកម្មមុនៗ

16. សាក្សីបានផ្តល់សក្ខីកម្មពីមុនចំនួនបី ឱ្យទៅសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ ឡាច មាន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី24 ខែតុលា ឆ្នាំ2007, D22/13, ERN 00162782-00162793 (ភាសាអង់គ្លេស), 00162794-00162796 (ភាសាខ្មែរ).

(2) បទសម្ភាសន៍របស់ ឡាច មាន ដោយ ក.ស.ព-អ.វ.ត.ក ចុះថ្ងៃទី7 ខែធ្នូ ឆ្នាំ2006, D2.6/4, ERN 00146786-00146789 (ភាសាអង់គ្លេស).

(3) បទសម្ភាសន៍របស់ ឡាច មាន ដោយ DC-Cam ចុះថ្ងៃទី16 ខែខែមិថុនា ឆ្នាំ2002, D92/I, ERN 00057053-00057078

## ឯកសារពាក់ព័ន្ធ

17. ឯកសារខាងក្រោម ក្នុងចំណោមឯកសារផ្សេងទៀត មានការជាប់ទាក់ទងទៅនឹងភស្តុតាងរបស់សាក្សី៖

(1) DC-Cam *វិភាគអ្នកសួរចម្លើយនៅគុក ស-២១ ទួលស្លែង(1975-1979)* រៀបចំដោយ សើ សាយ្យាណា និង ឡាច វរល័ក្ខកល្យាណ, គ្មានកាលបរិច្ឆេទ, គ្មាន ERN, មិនទាន់មាននៅក្នុងសំណុំរឿង (ភាសាខ្មែរ).

## 16. ម៉ក់ ស៊ីធីម

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ទាក់ទង ស-២១ សាក្សីនេះផ្ដល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161),* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនដោយខុសច្បាប់ ភាពខ្វះការជំនុំជម្រះយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការឈឺចាប់ដ៏ខ្លាំង ប្រព្រឹត្តកម្មអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [new])* និងការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត និងការធ្វើមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [new]* ។ ការផ្ដល់ភស្តុតាងរបស់គាត់ ទាក់ទងនឹងបទចោទទី១ ទី២ និងទី៣របស់ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិ និងអត្តសញ្ញាណរបស់សាក្សី

2. សាក្សីមានអាយុប្រហែល១៩ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សាក្សីមានសញ្ជាតិខ្មែរ ភេទប្រុស កើតនៅឆ្នាំ១៩៥៧[545]។ សាក្សីផ្ដល់ភស្តុតាងថា បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច គាត់បានចូលរួមជាមួយកងកុមារ។ កងនេះត្រូវបានបញ្ជាឱ្យទៅភ្នំពេញ ដែលអមដំណើរដោយ ចាន់។ បន្ទាប់ពីធ្វើការផ្នែកកសិកម្ម និងរៀនសូត្រកលយុទ្ធយោធាបានបីបួនឆ្នាំ សាក្សីបានទទួលបន្ទុកការបណ្ដុះបណ្ដាលផ្នែកពេទ្យ។ នៅឆ្នាំ១៩៧៧ គាត់ត្រូវបានបញ្ជូនទៅធ្វើការនៅក្រុមវេជ្ជសាស្ត្រនៅ ស-២១ ដែលគាត់នៅបន្តការងារនៅទីនោះរហូតដល់ឆ្នាំ១៩៧៩[546]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីផ្ដល់ភស្តុតាងថា **ឌុច** គឺជា "ប្រធានគ្រប់គ្រងកងទាំងមូល"[547] ប៉ុន្តែគាត់បានឃើញ **ឌុច** តែនៅក្នុងអំឡុងពេលបាយនៅ ស-២១ ពេលរសៀលតែប៉ុណ្ណោះ[548]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីផ្ដល់ភស្តុតាងថា មានកងការពារ កងសួរចម្លើយ និងកងចាប់ខ្លួននៅស-២១[549]។ ទោះបីជាគាត់មិនបានឃើញកងចាប់ខ្លួន ប៉ុន្តែគាត់បានឃើញ"រថយន្តរបស់ក្រុមនេះចូលមក"[550]។ សាក្សីផ្ដល់

ភស្តុតាងថា កងពេទ្យមានទីតាំងស្ថិតនៅមុខ ស-២១ ដែល ទ្រី គឺជាប្រធានកងទាំងមូល។ ហួរ គឺជាប្រធានកងពិសេសរបស់ខ្លួន និងគ្រូពេទ្យផ្សេងទៀត រួមមាន ព្រំ សុខ (ដែលក្រោយឆ្នាំ១៩៧៩ គាត់បានក្លាយជាជំនួយការរបស់ **ឌុច**, ដាន, ថា និង ទ្រី ផ្សេងមួយទៀត[551]។ ប្រធានពេទ្យ និងកងពេទ្យ ជួបគ្នាមួយសប្តាហ៍ម្តង[552]។ ទ្រី និង ហួរ បានប្រាប់គាត់ថា ប្រសិនបើអ្នកទោសដែលគាត់ព្យាបាលមិនបានជាសះស្បើយនោះទេ គាត់នឹងត្រូវយកទៅសម្លាប់ចោល[553]។ ក្រោយមក ទ្រី និង ហួរ ដែលជាប្រធានពេទ្យ ត្រូវបានគេចាប់ខ្លួននិងដាក់ក្នុងមន្ទីរឃុំឃាំង[554]។

5. សាក្សីផ្តល់ភស្តុតាងថា គាត់ព្យាបាលឱ្យអ្នកទោសនៅក្នុង "អគារចំនួនបី"តែប៉ុណ្ណោះ ដែលអ្នកទាំងនោះមានរបួសបន្ទាប់ពីត្រលប់ពីការសួរចម្លើយវិញ ប៉ុន្តែគាត់មិនដែលទៅព្យាបាលអ្នកទោសនៅពេលអ្នកទាំងនោះកំពុងត្រូវបានគេសួរចម្លើយនោះទេ។ "អ្នកទោសរបួសភាគច្រើនត្រូវបានដាក់លើស្នែងរបួស នាំយកមកអគារវិញ"[555]។ សាក្សីផ្តល់ភស្តុតាងថា អ្នកសួរចម្លើយបានប្រាប់គាត់ឱ្យព្យាបាលអ្នកទោសទាំងឡាយណាដែលមិនទាន់បានសួរចម្លើយចប់សព្វគ្រប់។ គាត់ក៏ត្រូវបានគេប្រាប់ឱ្យព្យាបាលអ្នកទោសប្រសិនបើអ្នកទោសទាំងនោះជាមនុស្ស "សំខាន់" ហើយគាត់បានព្យាបាលឱ្យ "មេបញ្ជាការកងវរសេនាតូច/កងវរសេនាធំ" និងប្រពន្ធរបស់ពួកគេ[556]។ សាក្សីផ្តល់ភស្តុតាងថា ជាទូទៅឱសថដែលផ្តល់ឱ្យអ្នកទោសមិនមានប្រសិទ្ធភាពនោះទេ[557]។

6. សាក្សីផ្តល់ភស្តុតាងថា ក្នុងអំឡុងពេលរៀនសូត្រនិងស្វ័យទិតៀន ប្រធានពេទ្យ និងប្រធាន "កងវរយ" (អនុសេនាធំ) និង "កងហា"(កងអនុសេនាតូច) ជាអ្នកផ្តល់ "ការណែនាំ"[558]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

7. សាក្សីផ្តល់ភស្តុតាងថា **ឌុច** គឺជា "ប្រធានគ្រប់គ្រងកងទាំងមូល"[559]។ ទ្រី គឺជាប្រធានកងពេទ្យ ហួរ គឺជាប្រធានក្រុមពិសេសរបស់សាក្សី[560] និង ហ៊ី គឺជាប្រធានកងការពារ[561]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

8. សាក្សីផ្តល់ភស្តុតាងថា គាត់មិនដែលបានឃើញ ឬព្យាបាលអ្នកទោសជនជាតិវៀតណាមទេ ប៉ុន្តែគាត់បានឃើញអ្នកទោសជនជាតិចិន[562]។ គាត់ក៏បានឃើញមានអ្នកទោស "សំខាន់" មេបញ្ជាការកងវរសេនាតូច

និងកងវរសេនាធំ ព្រមទាំងប្រពន្ធរបស់ពួកគេ[563]។ ប្រពន្ធ និងកូនរបស់អ្នកទោស មិនត្រូវបានគេដាក់ច្រវាក់ជើងទេ ប៉ុន្តែត្រូវបានគេឃុំនៅក្នុងបន្ទប់ធំ[564]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

9. សាក្សីផ្តល់ភស្តុតាងថា ហួរ ដែលជាគ្រូពេទ្យម្នាក់ក្នុងចំណោមគ្រូពេទ្យផ្សេងៗទៀត បានប្រាប់គាត់ថាពិតជាមានការបូមយកឈាមនៅ ស-២១។ សាក្សីព្យាបាលអ្នកទោសដែលត្រូវបានគេបូមឈាមចេញ ដែលអ្នកទាំងនោះ "ស្លេកស្លាំងយ៉ាងខ្លាំង" គាត់បានឃើញអ្នកទោសប្រភេទនេះចំនួន "៣០-៤០នាក់"[565] ប៉ុន្តែគាត់មិនបានឃើញការបូមឈាមចេញដោយផ្ទាល់ទេ។ សាក្សីផ្តល់ភស្តុតាងថា គាត់មិនបានដឹងថាគេយកឈាមទៅធ្វើអ្វីនោះទេ[566] និងជាពិសេសគាត់មិនបានដឹងអំពីថា កញ្ចប់ឈាមត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យខាងក្រៅ ស-២១ ឬយ៉ាងណានោះទេ[567] ប៉ុន្តែគាត់បានបញ្ជាក់ថា គាត់បានឃើញកញ្ចប់ឈាម"មិនទាន់ប្រើ" ឬ"មិនល្អ" ចំនួន៣០-៤០កញ្ចប់ ដែលបោះបង់ចោលនៅក្រោមជណ្តើរ[568] ក្បែរផ្ទះគាត់រស់នៅ[569]។

## ការសួរចម្លើយ

10. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសត្រូវបានគេនាំទៅសួរចម្លើយ និងនៅពេលត្រលប់មកវិញ ពួកអ្នកទោសមានរបួសដោយសារការធ្វើទារុណកម្ម[570]។ សាក្សីផ្តល់ភស្តុតាងថា អ្នកសួរចម្លើយបានប្រាប់គាត់ឱ្យព្យាបាលអ្នកទោសទាំងឡាយណាដែលមិនទាន់ត្រូវបានសួរចម្លើយចប់សព្វគ្រប់[571]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

11. សាក្សីផ្តល់ភស្តុតាងថា អ្នកជាប់ឃុំមួយចំនួនដែលត្រលប់មកពីសួរចម្លើយ អ្នកទាំងនោះមានរបួសធ្ងន់ធ្ងរ។ អ្នកទោសខ្លះមានដំបៅធំៗនៅខ្នងរបស់ពួកគេ ខ្លះត្រូវបានគេដកក្រចកចេញ[572] និងខ្លះទៀតបានប្រាប់គាត់ថា ពួកគេត្រូវបានគេឆក់ខ្សែភ្លើង[573]។ អ្នកទោសខ្លះស្លាប់ដោយសាររបួស[574]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានព្យាបាលអ្នកទោសដែលត្រូវបានគេបូមឈាម ដែលអ្នកទាំងនោះមានសភាព "ស្លេកស្លាំងយ៉ាងខ្លាំង" ដែលជាសរុប គាត់ឃើញអ្នកទោសប្រភេទនេះចំនួន "៣០-៤០នាក់"[575] ប៉ុន្តែគាត់មិនបានឃើញការបូមឈាមដោយផ្ទាល់នោះទេ។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

12. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសម្នាក់ ពីរនាក់ ឬបីនាក់បានស្លាប់ជារៀងរាល់ថ្ងៃដោយសារវបួស ដូច្នេះ គាត់បានយកសពអ្នកទាំងនោះចេញ និងបានបញ្ចុះតាមអគារខាងក្រៅជញ្ជាំងគុក[576]។

## សក្ខីកម្មមុនៗ

13. សាក្សីបានផ្តល់សក្ខីកម្មពីមុនចំនួនបី ជូនទៅសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ ម៉ក់ ស៊ីធីម ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី30 ខែវិច្ឆិកា ឆ្នាំ2007, D28/8, ERN 00191126-00191131 (ភាសាអង់គ្លេស)

(2) កំណត់ហេតុនៃការតទល់មុខគ្នារបស់ ម៉ក់ ស៊ីធីម ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2008 00166561-00166570, D54 (ភាសាអង់គ្លេស)

(3) បទសម្ភាសន៍របស់ ម៉ក់ ស៊ីធីម ក្នុងខ្សែភាពយន្ត ស-*២១: ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម* ដោយ ឫទ្ធី ប៉ាន់ ឆ្នាំ2002, D69, ERN V 00172620.

## ឯកសារពាក់ព័ន្ធ

14. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធនៅក្នុងពេលជំនុំជម្រះ។

## 17. ម៉ម ណៃ ហៅ ចាន់

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និង រចនាសម្ព័ន្ធនិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹង ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ឃុំក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនដោយខុសច្បាប់ ភាពខ្វះការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [new])* និងការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត និងការធ្វើមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [new])*។ សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរម-១៣ និងតួនាទីរបស់ជនជាប់ចោទនៅក្នុងមន្ទីរនោះ។ ភស្តុតាងរបស់សាក្សីពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ៤២ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សាក្សីមានសញ្ជាតិខ្មែរ ភេទប្រុស កើតនៅឆ្នាំ១៩៣៣។ មុនឆ្នាំ១៩៧៥ សាក្សីគឺជាគ្រូបង្រៀន និងបានចូលរួមជាមួយបដិវត្តន៍កុម្មុយនីស្តនៅពាក់កណ្តាលទស្សវត្សឆ្នាំ១៩៦០ រហូតដល់ចុងទស្សវត្សឆ្នាំ១៩៦០[577]។ ក្នុងអំឡុងពេលដាក់គាត់នៅក្នុងមន្ទីរឃុំឃាំងដោយសារតែគាត់ជាជនកុម្មុយនីស្ត សាក្សីបានជួបនឹង **ឌុច** និងក្រោយមកបានធ្វើការងារជាមួយគាត់ក្នុងតួនាទីជាអ្នកសួរចម្លើយនៅមន្ទីរសន្តិសុខ ម-១៣ កាលពីដើមទស្សវត្សឆ្នាំ១៩៧០[578]។ បន្ទាប់ពីបែកភ្នំពេញនៅឆ្នាំ១៩៧៥ សាក្សី ឌុច និងអ្នកទោសទាំងឡាយនៅ ម-១៣ ត្រូវបានបញ្ជូនមកភ្នំពេញ ជាពិសេសអតីត Police Judiciare ក្បែរ *ផ្សារថ្មី*[579]។ ក្រោយមក សាក្សីធ្វើការងារជាមួយ **ឌុច** នៅក្នុង ស-២១ រហូតដល់បែក[580]។ ចម្លើយសារភាពនៅសេសសល់ចំនួន១១ មានសរសេរឈ្មោះសាក្សី ថាជាអ្នកសួរចម្លើយ។

3. សាក្សីផ្តល់ភស្តុតាងថា នៅចុងឆ្នាំ១៩៧៥ គាត់គឺជាអ្នកសួរចម្លើយ "អ្នកទោសថ្នាក់ទាប" នៅ ស-២១ រួមមាន អ្នកទោសយោធាជនជាតិវៀតណាម ក្រោយពេលគាត់បានរៀនភាសាវៀតណាម[581]។ គាត់គឺជាសមាជិកម្នាក់ ក្នុងចំណោមពេញសិទ្ធិពីរបីនាក់ទៀត ដែលធ្វើការនៅ ស-២១ ជាមួយ ឌុច, ហ៊ី, ហ៊ុយ, និង ផល[582]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានធ្វើការសួរចម្លើយរហូតដល់នៅសល់តែពីរ ឬបីថ្ងៃមុនពេលវៀតណាមចូលឈ្លានពាន[583] ដែលនៅពេលនោះ គាត់បានរត់ចេញពីភ្នំពេញ[584]។

## ជម្លោះប្រដាប់អាវុធ

4. សាក្សីផ្តល់ភស្តុតាងអំពីការវាយប្រយុទ្ធគ្នារវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ចាប់តាំងពីទសវត្សឆ្នាំ១៩៦០ រហូតដល់វៀតណាមឈ្លានពានភ្នំពេញនៅឆ្នាំ១៩៧៩។ ឌុច ផ្តល់កិច្ចការឲ្យគាត់ធ្វើការសួរចម្លើយយោធាវៀតណាម "ដែលចាប់បាននៅសមរភូមិមុខ" ជាពិសេសទាក់ទងនឹង "ស្ថានភាពយោធា" ដែលរួមមានការយកព័ត៌មានអំពី "កង ឋានន្តរសក្តិរបស់ពួកគេ ទីតាំងសមរភូមិដែលពួកគេឈរជើង ទីតាំងអាវុធយុទ្ធភណ្ឌរបស់ពួកគេ និងសមត្ថភាពជំនាញរបស់ពួកគេ"[585]។ សាក្សីផ្តល់ភស្តុតាងថា ជម្លោះជនជាតិវៀតណាមចាប់ផ្តើមកាលពីដើមឆ្នាំ១៩៧៣ និងអ្នកទោសសង្គ្រាមជនជាតិវៀតណាម ត្រូវបានបញ្ជូនទៅ ស-២១ ចាប់តាំងពីពេល "យួនវាយប្រហារតាមព្រំដែន"[586]។ នៅពេលជនជាតិវៀតណាមចូលមកជិតដល់ភ្នំពេញ សាក្សីបានស្ថិតនៅ "ខាងក្រៅ" ស-២១ "ដោយមានផែនការវាយប្រហារលើពួកយួន"[587]។

## រចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ

5. សាក្សីផ្តល់ភស្តុតាងថា គណៈកម្មាធិការមជ្ឈិមបក្សមានតែលោក ខៀវ សំផន, លោក នួន ជា និងលោក ប៉ុល ពត តែប៉ុណ្ណោះ។ គណមជ្ឈិមបក្សបានបង្កើតនូវគោលនយោបាយ ទ្រឹស្តី និងជំនឿនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងប្រទេសជាតិ ដោយសម្រេចជនប្រភេទណាត្រូវចាប់ខ្លួននិងបញ្ជូនទៅស-២១ និងបញ្ជាក់អំពីអត្ថន័យនៃការសួរចម្លើយដែលយកបាននៅ ស-២១[588]។ គោលនយោបាយកម្ពុជាប្រជាធិតេយ្យបានចែងថា "សមាជិកពេញសិទ្ធិ"តែប៉ុណ្ណោះ អាចមានសិទ្ធិណែនាំអ្នកផ្សេងៗទៀតឲ្យចូលរួមជាមួយបក្ស[589]។ គណៈកម្មាធិការមជ្ឈិមបក្សអនុវត្តទ្រឹស្តីស្វែងរក និង "កម្មេច"សត្រូវផ្ទៃក្នុង ព្រមទាំង "យួន"ផងដែរ[590]។ គោលនយោបាយចំពោះបុគ្គលិក ស-២១ គឺបុគ្គលិកទាំងអស់ត្រូវធ្វើការងាររបស់ខ្លួន និងមិនត្រូវសួរសំណួរអំពីកិច្ចការរបស់ផ្នែកផ្សេងៗទៀតនោះទេ[591]។

## តួនាទីរបស់ជនជាប់ចោទ

6. សាក្សីផ្តល់ភស្តុតាងថា មុនពេលមកគ្រប់គ្រង ស-២១ **ឌុច** គឺជាប្រធានមន្ទីរសន្តិសុខ ម-១៣[592] ដែលគាត់ "គ្រប់គ្រងកងសន្តិសុខទាំងមូល"នៅទីនោះ និងក៏ជាអ្នកសួរចម្លើយម្នាក់ផងដែរ[593]។

7. សាក្សីផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធាន ស-២១[594] ដែលគាត់ "ត្រួតពិនិត្យស-២១គ្រប់ពេលវេលាទាំងអស់ដោយគាត់មិនដែលធ្វើការនៅកន្លែងផ្សេងនោះទេ"[595]។ សាក្សីផ្តល់ភស្តុតាងថា នៅពេលគាត់មកដល់ភ្នំពេញដំបូង **ឌុច** គឺជាប្រធានគុកប៉េហ្ស៊ី ក្បែរ*ផ្សារថ្មី* និងក្រោយមកត្រូវបានបញ្ជូនទៅ ស-២១[596]។ កាលពីដំបូង ណាត គឺជាប្រធាន ស-២១ និង **ឌុច** គឺជាអនុប្រធាន។ ចាប់ពីពេលដែល ណាត ចាកចេញដើម្បីទៅធ្វើជាប្រធាននៅគុកប៉េហ្ស៊ី ឌុច បានក្លាយជាប្រធានស-២១[597]។

8. សាក្សីផ្តល់ភស្តុតាងថា **ឌុច** រៀបចំផ្នែកបុគ្គលិក និងអនុវត្តគោលនយោបាយផ្ទៃក្នុងនៅ ស-២១[598]។ ជាទូទៅ **ឌុច** ផ្តល់ការណែនាំ និងបញ្ជាឲ្យជឿជាក់លើអ្នកណែនាំ ដែលអ្នកទាំងនោះផ្សព្វផ្សាយសេចក្តីណែនាំ និងបទបញ្ជានានាទៅឲ្យបុគ្គលិក ស-២១។ ឌុច កម្រផ្តល់ការណែនាំ និងបញ្ជាដោយផ្ទាល់ ទៅដល់កម្មាភិបាលថ្នាក់ទាប[599]។ **ឌុច** "បង្រៀននយោបាយ ការពិនិត្យស្ថានការណ៍ មាគ៌ានយោបាយផលិតផលកសិកម្ម (និង) ការប្រយុទ្ធប្រឆាំងនឹងយួន"[600]។ សាក្សីបានបញ្ជាក់ថា "**ឌុច** បានដឹងអ្វីៗទាំងអស់នៅ ស-២១ និងជាអ្នកចេញសេចក្តីសម្រេចទាំងអស់នៅ ស-២១[601]។ ឌុច គឺជាបុគ្គលដែលមានសិទ្ធិផ្តល់អំណាចដល់បុគ្គលិក ស-២១ និងជាអ្នកទទួលបន្ទុកលើការឡើងដំណែង ឬវិន័យ[602]។

9. សាក្សីផ្តល់ភស្តុតាងថា ឌុច បានជ្រើសរើសអ្នកទោសសម្រាប់សួរចម្លើយ[603] និងអង្កេតមើលក្នុងអំឡុងពេលសួរចម្លើយ ប៉ុន្តែគាត់ក៏ចាកចេញផងដែរក្នុងពេលកំពុងសួរចម្លើយ[604]។ ប៉ុន្តែ សាក្សីក៏បានលើកឡើងថា "នៅពេលខ្ញុំសួរចម្លើយ **ឌុច** បានមកសួរសំណួរខ្ញុំ"[605]។ **ឌុច** គឺជាអ្នកពិនិត្យដំបូងបំផុតលើកំណត់ហេតុសួរចម្លើយទាំងអស់[606]។

10. សាក្សីផ្តល់ភស្តុតាងថា **ឌុច** ត្រួតពិនិត្យលើកងការពារ[607]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

11. ពីមុន ឌុច មានតួនាទីជាប្រធានមន្ទីរ ម-១៣ ដែលជាកន្លែងសន្តិសុខសម្រាប់ "ឃុំខ្លួន និងសួរចម្លើយប្រជាជន[608]។ អ្នកទោសនៅ ម-១៣ ត្រូវបានបញ្ជូនទៅទីនោះដើម្បីសួរចម្លើយ ដោយ "កងឃោធាកងស្រុក កងនារី" នៅក្នុងភូមិភាគ ដែលម-១៣ ស្ថិតនៅទីនោះ[609]។

12. សាក្សីផ្តល់ភស្តុតាងថា ស-២១ ដែលពីមុនជាសាលារៀន បានដំណើរការចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩[610]។ ស-២១ ស្ថិតនៅខាងលិចនៃមហាវិថីមុន្នីវង្ស និងផ្លូវតូចនៅខាងលិចនៃវត្តមហាមន្ត្រី[611]។ អ្នកទោសត្រូវបាននាំទៅ ស-២១ ដោយរថយន្តធំៗ[612] និងនៅពេលមកដល់ អ្នកទោសទាំងអស់ត្រូវបានចុះឈ្មោះ និងថតរូប[613]។

13. ស-២១ មានកន្លែងសម្រាប់ឃុំខ្លួន និងកន្លែងសម្រាប់សួរចម្លើយ ដែលការឃុំខ្លួនធ្វើឡើងនៅអគារធំរបស់សាលា និងការសួរចម្លើយធ្វើនៅក្នុងផ្ទះដែលព័ទ្ធជុំវិញ[614]។ ផ្ទះសម្រាប់សួរចម្លើយជាទៀងទាត់ ស្ថិតនៅខាងកើតគុក នៅចំពីមុខច្រកចេញចូលស-២១ នៅចន្លោះផ្លូវលេខ១០៥ ផ្លូវលេខ៣៦០ ផ្លូវលេខ១១៣ និងផ្លូវលេខ៣១០[615]។ ផ្ទះសម្រាប់សួរចម្លើយនៅទិសខាងត្បូងគុកដែលនៅចន្លោះផ្លូវលេខ៣៦០ ផ្លូវលេខ១៤៣ និងផ្លូវលេខ៣៥០ ត្រូវបានគេប្រើប្រាស់ជាកន្លែងសម្រាប់សួរចម្លើយអ្នកទោសពិសេស[616]។

14. ស-២១ ត្រូវបានបែងចែកចេញជាផ្នែកការពារ ដែលត្រួតពិនិត្យដោយ ហ៊ី ដែលទទួលបន្ទុកនាំអ្នកទោសជុំវិញអគារស-២១ ផ្នែកសួរចម្លើយចំនួនពីរ និងផ្នែកស្រែ ដែលមាន ហ៊ុយ ជាអ្នកត្រួតពិនិត្យ[617]។ ផ្នែកសួរចម្លើយចំនួនពីរ ត្រូវបានបែងចែកចេញជាកងពិសេស និងកងទូទៅ ដែលកងពិសេសទទួលបន្ទុកសួរចម្លើយអ្នកទោសសំខាន់ ឬឋានៈ និងឋានន្តរសក្តិខ្ពស់ (ឧទាហរណ៍ វន វ៉េត និង កុយ ធួន[618]) ហើយកងទូទៅទទួលបន្ទុកសួរចម្លើយអ្នកទោសឋានន្តរសក្តិទាប ជាពិសេសពួកយុទ្ធជន[619]។

15. សាក្សីនឹងអាចបង្ហាញនៅលើផែនទីអំពីទីតាំងផ្ទះរបស់ឌុច ផ្ទះរបស់សាក្សី ផ្ទះសួរចម្លើយ កន្លែងចម្អិនអាហារ និងកន្លែងបរិភោគអាហាររួមគ្នា កន្លែងទទួលអ្នកទោស និងកន្លែងរៀននយោបាយ[620]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

16. សាក្សីផ្ដល់ភស្ដុតាងថា ប្រតិបត្តិការរបស់ ស-២១ ទាំងមូល ត្រូវបានគណៈកម្មាធិការមជ្ឈិមត្រួតពិនិត្យ ដែលស្ថិតនៅ"ពីលើ" **ឌុច**[621]។ អំណាចបញ្ជាឲ្យចាប់ខ្លួន ទាំងនៅខាងក្នុងឬនៅខាងក្រៅ ស-២១ គឺត្រូវបានគ្រប់គ្រងទាំងស្រុងដោយគណៈកម្មាធិការមជ្ឈិមបក្ស។ **ឌុច** អាចស្នើសុំឲ្យចាប់ខ្លួន ប៉ុន្តែគណៈកម្មាធិការមជ្ឈិមជាអ្នកសម្រេច[622]។ របាយការណ៍សួរចម្លើយត្រូវបាន **ឌុច** បញ្ជូនទៅគណៈកម្មាធិការមជ្ឈិម ដើម្បីពិនិត្យ និងផ្ដល់ការណែនាំ[623]។ **ឌុច** និង គណៈកម្មាធិការមជ្ឈិមទាក់ទងគ្នាភាគច្រើនតាមទូរសព្ទ[624]។ សាក្សីនិយាយថា គាត់មិនដែរឃើញសមាជិករបស់គណៈកម្មាធិការមជ្ឈិមណាម្នាក់មកធ្វើទស្សនកិច្ចនៅ ស-២១ទេ[625]។

17. គណៈកម្មាធិការថ្នាក់ដឹកនាំ ស-២១ គឺ **ឌុច** ដែលជាប្រធាន "គ្រប់គ្រងអ្វីៗទាំងអស់"។ ហ៊ី ជាអ្នកដឹកនាំគ្រប់គ្រងកងការពារ ហ៊ុយ ជាអ្នកដឹកនាំគ្រប់គ្រងកងធ្វើស្រែ និង ប៉ុន ជាអ្នកដឹកនាំអ្នកសួរចម្លើយ និងជាប្រធានកងសួរចម្លើយពិសេស[626]។ អ្នកប្រឹក្សាជំនិតរបស់ **ឌុច** គឺ ហ៊ី និង ប៉ុន[627]។ ជាទូទៅ **ឌុច** ផ្ដល់ការណែនាំ និងបទបញ្ជាទៅឲ្យអ្នកប្រឹក្សាជឿទុកចិត្តរបស់ខ្លួន ដែលអ្នកទាំងនោះផ្សព្វផ្សាយសេចក្ដីណែនាំ និងបទបញ្ជាទៅបុគ្គលិក ស-២១ និង **ឌុច** កម្រចេញសេចក្ដីណែនាំ និងបទបញ្ជាដោយផ្ទាល់ទៅឲ្យកម្មាភិបាលថ្នាក់ទាប[628]។ អ្នកនាំសាររបស់ **ឌុច** គឺ ឆេន[629]។ សាក្សីជឿជាក់ថា កាលពីដំបូងបុគ្គលិក ស-២១ មានការលាយគ្នារវាងបុគ្គលិកពីកងពលធំលេខ៧០៣ របស់ ណាត និងមនុស្សរបស់ **ឌុច** ដែលមកពី អមលាំង និងមន្ទីរ ម-១៣[630]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

18. សាក្សីផ្ដល់ភស្ដុតាងថា នៅម-១៣ អ្នកទោសគឺជា "យោធា ប្រជាជន អ្នកបដិវត្តន៍ដែលធ្វើការនៅក្នុងស្រុក ឬកន្លែងណាក៏ដោយ"[631]។ គាត់មិនបានឃើញជនបរទេសណាម្នាក់នៅក្នុងមន្ទីរឃុំឃាំងនៅ ម-១៣ទេ[632]។

19. សាក្សីផ្ដល់ភស្ដុតាងថា ពេលខ្លះអ្នកមូលដ្ឋាននាំអ្នកទោសចូលក្នុង ស-២១ ប៉ុន្តែពេលខ្លះ ស-២១បានមកយកពួកអ្នកទោសដោយផ្ទាល់[633]។

20. សាក្សីផ្ដល់ភស្ដុតាងថា នៅ ស-២១ គាត់បានសួរចម្លើយអ្នកទោសសង្គ្រាមយោធាជនជាតិវៀតណាមជាច្រើន ប៉ុន្តែ "មិនលើសពី៥០នាក់ទេ"[634]។ គ្មានអ្នកទោសជនជាតិវៀតណាមណាម្នាក់ជាប្រជាជន

ស៊ីវិលនោះទេ[635]។ សាក្សីមិនចាំជនបរទេសណាមួយទេ ប៉ុន្តែគាត់បានចងចាំសមាជិកមួយចំនួនរបស់រណសិរ្សរួបរួមដើម្បីរំដោះជាតិសាសន៍ដែលត្រូវបានគេជិះជាន់ ដែលដំបូងឡើយត្រូវបានឃុំខ្លួន ប៉ុន្តែក្រោយមកត្រូវបានដោះលែងវិញ ដោយសារតែពួកគេជាសម្ព័ន្ធមិត្តនឹងគ្នា[636]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានលឺ ស៊ុំអាយអេ និងកាហ្សេប៉េ ត្រូវបានគេឃុំនៅ ស-២១[637]។ សាក្សីបានលើកឡើងថា គាត់ "មិនដែលដឹង"ថាមានអ្នកទោសមកពីប្រទេសលោកខាងលិចនោះទេ[638]។

21. ឈ្មោះ ឬហត្ថលេខារបស់សាក្សីមាននៅក្នុងបញ្ជីចំនួន២២ នៃបញ្ជីអ្នកទោស ស-២១ ដែលនៅរស់[639]។

## ការសួរចម្លើយ

22. សាក្សីផ្តល់ភស្តុតាងថា **ឌុច** បានធ្វើការសួរចម្លើយនៅ ម-១៣[640] និងឯកសារ ព្រមទាំងកំណត់ហេតុត្រូវបានបញ្ជូនទៅប្រធានភូមិភាគ វន វេត[641]។ វិធីសួរចម្លើយដែលធ្លាប់ប្រើប្រាស់នៅ ម-១៣ ក៏ត្រូវបានប្រើប្រាស់ផងដែរនៅ ស-២១[642]។

23. សាក្សីផ្តល់ភស្តុតាងថា ជនគ្រប់គ្នានៅ ស-២១ ត្រូវតែទទួលការសួរចម្លើយ[643]។ ការសួរចម្លើយតម្រូវ "ឲ្យស្វែងរកបណ្តាញអ្នកក្បត់"[644]។ អ្នកទោសត្រូវបានគេនាំទៅ ស-២១ ពីព្រោះពួកគេបានប្រព្រឹត្តបទលហុ បទមជ្ឈិម ឬឧក្រិដ្ឋធ្ងន់ធ្ងរ ហើយការសួរចម្លើយ គឺដើម្បី "សួរបញ្ជាក់"អំពីកំហុសទាំងនោះតែប៉ុណ្ណោះ។ សាក្សីលើកឡើងថា ការសួរចម្លើយ "ប្រហែល" ធ្វើឡើងដោយផ្អែកតាមសេចក្តីណែនាំដែលចេញមកពីបុគ្គលមានឋានន្តរសក្តិធំជាង ឌុច[645]។

24. **ឌុច** ជ្រើសរើសអ្នកទោសណាមួយដែលត្រូវបានសួរចម្លើយ[646]។ គាត់គឺជា "មនុស្សឧស្សាហ៍ម្នាក់ដែលចូលចិត្តអាន"។ សាក្សីលើកឡើងថា **ឌុច** បានមើលចម្លើយសារភាពទាំងអស់ ដែលគាត់បានអានជារៀងរាល់ថ្ងៃនៅផ្ទះរបស់គាត់[647]។ **ឌុច** បានហៅសាក្សីតាមខ្សែទូរសព្ទ និងបានទូរសព្ទ "ម្តង ឬពីរដង" សួរអំពីអ្នកទោសនីមួយៗ[648]។ នៅក្នុងករណីពិសេស នៅពេលមជ្ឈិមបក្សទូរសព្ទមក **ឌុច, ឌុច** បានទូរសព្ទហៅសាក្សីដើម្បីទៅសួរលើចំណុចមួយចំនួន[649]។ សាក្សីផ្តល់ភស្តុតាងថា ឌុច បានមកសួរសំណួរគាត់បន្ទាប់ពីគាត់បានធ្វើការសួរចម្លើយអ្នកទោសរួច[650]។

25. អ្នកយាម នាំអ្នកទោសទៅកន្លែងសួរចម្លើយនៅក្នុងអំឡុងពេលថ្ងៃ និងយកត្រលប់មកវិញបន្ទាប់ពីសួរចម្លើយចប់នៅពេលយប់[651]។ អ្នកទោសត្រូវបានដាក់ច្រវាក់ជើងនៅក្នុងបន្ទប់សួរចម្លើយ និងបត់ជើងដាក់ក្នុងកេះគ្រាប់កាំភ្លើង។ អ្នកទោសពិសេសត្រូវបានគេសួរចម្លើយនៅពេលយំខ្លួន[652]។

26. សាក្សីបានប្រាប់ថា ពាក្យសួរចម្លើយ"ក្ដៅ" ឬ"ត្រជាក់" មិនដែលប្រើប្រាស់ ឬមិនមាននៅក្នុងកងសួរចម្លើយណាមួយនោះទេ[653]។ គាត់បានលើកឡើងថា គេមិនដែលហៅអ្នកសួរចម្លើយមកប្រជុំទេ។ **ឌុច** គ្រាន់តែហៅសាក្សីដោយផ្ទាល់ ណែនាំគាត់ឱ្យធ្វើការសួរចម្លើយ "ដោយអង្កៀម" ដែលសាក្សីបានពិពណ៌នាថាជាវិធីសួរចម្លើយសំណួរដដែរៗជាច្រើនលើកច្រើនសារ[654]។ សាក្សីបានលើកឡើងថា ចំពោះអ្នកទោសម្នាក់ៗ គាត់ទទួលបានចម្លើយសារភាពតែបី ឬបួនទំព័រតែប៉ុណ្ណោះ[655]។

27. សាក្សីផ្ដល់ភស្តុតាងថា នៅពេលការសួរចម្លើយត្រូវបានបញ្ចប់ គាត់ត្រូវតែប្រគល់ភ្លាមឯកសារទាំងអស់ឱ្យទៅ **ឌុច** ដែល **ឌុច** នឹងវិភាគលើការសួរចម្លើយដើម្បីកំណត់ថាតើគោលដៅនៃការសួរចម្លើយមានលក្ខណៈ "គ្រប់គ្រាន់" "សមស្រប" និង "ចប់សព្វគ្រប់" ក្នុងការបញ្ជូនទៅគណៈកម្មាធិការមជ្ឈិមឬទេ។ **ឌុច** នឹងធ្វើចំណារលើឯកសារដើម្បីឱ្យសួរចម្លើយឡើងវិញ នៅពេលដែលចាំបាច់[656]។

28. **ឌុច** នឹងផ្ដល់សេចក្ដីណែនាំចំពោះអ្នកទោសមួយចំនួន បន្ទាប់ពីគាត់បានអាន "ចម្លើយសារភាព" ជាមុន[657]។ ប្រសិនបើតម្រូវឱ្យសួរចម្លើយឡើងវិញ អ្នកសួរចម្លើយមិនត្រូវបានផ្ដល់ឱ្យសាកសួរចម្លើយពីមុនដើម្បីបន្តការសួរចម្លើយនោះទេ ប៉ុន្តែអ្នកសួរចម្លើយត្រូវធ្វើការសួរចម្លើយជាថ្មី[658]។ ជាចុងក្រោយ "ចម្លើយសារភាព" និងឯកសារសួរចម្លើយទាំងអស់ ត្រូវបាន **ឌុច** បញ្ជូនទៅ "ថ្នាក់លើ"[659]។ ការសួរចម្លើយអ្នកទោសណាម្នាក់ អាចប្រើប្រាស់រយៈពេលរហូតដល់ពីរខែ[660]។ តាមរយៈនៃការសួរចម្លើយយោធាវៀតណាម ចម្លើយសារភាពខ្លះដែលទាក់ទងនឹងស្ថានភាពយោធា ត្រូវបានថតសម្លេងនិងផ្សព្វផ្សាយតាមវិទ្យុ[661]។

29. សាក្សីផ្ដល់ភស្តុតាងថា គាត់មិនដែលបានឃើញ **ឌុច** ចូលរួមក្នុងការសួរចម្លើយទេ ប៉ុន្តែគាត់បានចូលរួមមួយភ្លែតប៉ុណ្ណោះ ក្នុងពេលសាក្សីធ្វើការសួរចម្លើយយោធាជនជាតិវៀតណាម[662]។

30. នៅពេលគាត់កំពុងសួរចម្លើយអ្នកទោសជនជាតិវៀតណាម សាក្សីបានប្រើអ្នកទោសម្នាក់ ឈ្មោះ PHA Than Chan មកពីហាណូយមកបកប្រែឱ្យគាត់[663]។

31. មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការវិភាគលើចម្លើយសារភាព ដោយបានបង្ហាញឱ្យឃើញថា ចម្លើយសារភាពអ្នកទោសចំនួន១១១នាក់ មានឈ្មោះសាក្សីក្នុងតួនាទីជាអ្នកសួរចម្លើយ ចាប់ពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩[664]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

32. សាក្សីផ្តល់ភស្តុតាងថា នៅម-១៣ មានការប្រើប្រាស់ការធ្វើទារុណកម្ម"ខ្លះ" និងឧបករណ៍ធ្វើទារុណកម្ម ដែលគាត់បានឃើញ គឺមានតែរំពាត់តែប៉ុណ្ណោះ[665]។

33. សាក្សីផ្តល់ភស្តុតាងថា គាត់មិនបានដឹងអំពីការប្រើប្រាស់ការធ្វើទារុណកម្មមាននៅ ស-២១ទេ[666]។ សាក្សីមិនបានចាំជនម្នាក់ក្នុងចំណោមជនប្រាំនាក់ដែលចោទប្រកាន់ថាបានសួរចម្លើយ និងវាយដំលើ[667] ហើយសាក្សីបានបដិសេធការចោទប្រកាន់របស់ ប្រាក់ ខនថា គាត់បានធ្វើទារុណកម្មលើស្ត្រីម្នាក់ រួមគ្នាជាមួយ **ឌុច** និងអ្នកសួរចម្លើយផ្សេងទៀត[668]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

34. សាក្សីផ្តល់ភស្តុតាងថា គាត់មិនបានដឹងអំពីវាសនារបស់អ្នកទោសណាម្នាក់នៅ ស-២១ ទេ[669]។ ទាក់ទងនឹងការសួរចម្លើយអ្នកទោសជនជាតិវៀតណាម សាក្សីបានលើកឡើងថា "នៅពេលបញ្ចប់ការសួរចម្លើយ ពួកគេមិនដែលនាំអ្នកទោសទាំងនោះត្រលប់មកវិញទេ"[670]។ សាក្សីបានលើកឡើងថា គាត់មិនបានដឹងកន្លែងកប់សាកសពនៅស-២១ទេ ហើយគាត់ "ក៏មិនដែលធុំក្លិនសាកសពរលួយដែរ"[671]។ សាក្សីផ្តល់ភស្តុតាងថា ហ៊ី ទទួលបន្ទុកចាត់ចែងអ្នកទោសដែលស្លាប់ខណៈពេលជាប់ឃុំនៅ ស-២១[672]។

## សក្ខីកម្មមុនៗ

35. សាក្សីបានផ្តល់សក្ខីកម្មពីមុនចំនួនប្រាំ ឱ្យទៅសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ ម៉ម ណៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី26 ខែតុលា ឆ្នាំ2007, D22/14, ERN 00162809-0162820 (ភាសាអង់គ្លេស).

(2) បទសម្ភាសន៍របស់ ម៉ម ណៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី7 ខែវិច្ឆិកា ឆ្នាំ2007, D22/16, ERN 00162905-00162934 (ភាសាអង់គ្លេស).

(3) បទសម្ភាសន៍របស់ ម៉ម ណៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី14 ខែកុម្ភៈ ឆ្នាំ2008, D50/2, ERN 00164390-00164394 (ភាសាអង់គ្លេស).

(4) កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុរបស់ ម៉ម ណៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2008, D48/2, ERN 00197998-00198008 (ភាសាអង់គ្លេស).

(5) កំណត់ហេតុនៃការតទល់មុខគ្នារបស់ ម៉ម ណៃ ដោយ ក.ស.ច.ស-អ.វ.ត.ក ខែកុម្ភៈ ឆ្នាំ2008, D54, ERN 00166561-00166570 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

36. ឯកសារខាងក្រោម ក្នុងចំណោមឯកសារផ្សេងៗទៀត មានការពាក់ព័ន្ធទៅនឹងភស្តុតាងរបស់សាក្សី៖

(1) DC-Cam វិភាគ *អ្នកសួរចម្លើយនៅគុក ស-២១ ទួលស្លែង (1975-1979)* រៀបចំដោយ សើ សាយ្យាណា និង ឡាច វរល័ក្ខកល្យាណ, គ្មានកាលបរិច្ឆេទ, គ្មាន ERN, មិនទាន់មាននៅក្នុងសំណុំរឿង (ភាសាខ្មែរ).

(2) របាយការណ៍របស់ ម៉ម ណៃ ហៅ ចាន់ ចុះថ្ងៃទី1 ខែមករា ឆ្នាំ1977, រៀបរាប់អំពីផែនការការងារសម្រាប់រយៈ១០ពលបីខែដំបូងនៃឆ្នាំ១៩៧៧ នៅមន្ទីរស-២១. រួមជាមួយនឹងអនុសាសន៍សម្រាប់ធ្វើការសួរចម្លើយឲ្យមានប្រសិទ្ធភាពជាងមុន; ម៉ម ណៃ ត្រូវបានចាត់ឲ្យ "ក្តាប់ឲ្យបានអំពីអ្នកទោសថ្មីនិងអ្នកទោសចាស់", D64 ERN 00079150-00079155, (ភាសាខ្មែរ).

(3) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី23 ខែមករា ឆ្នាំ1977. រួមបញ្ចូលទាំងរបាយការណ៍របស់ ចាន់ ពិពណ៌នាអំពីការត្រួតពិនិត្យការនាំអ្នកទោស ចូល, D57, ERN 00002277-00002278 (ភាសាខ្មែរ).

(4) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី ២០-ឧសភា-១៩៧៧. រួមបញ្ចូលទាំងរបាយការណ៍របស់ ចាន់ អំពីអ្នកទោស៣៤ នាក់ដែលយកចូលមន្ទីរស-២១ ចាប់មកពីកងវរសេនាធំ ១៥២, D57, ERN 00088740-00088742 (ភាសាខ្មែរ).

(5) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី21 ខែឧសភា ឆ្នាំ1977 មានចំណងជើងថារបាយការណ៍របស់ ចាន់ ស្តីពីអ្នកទោស ១៣នាក់ ចាប់មកពីមន្ទីរ ស-២១, D57, ERN 00088738-00088739 (ភាសាខ្មែរ).

(6) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី22 ខែឧសភា ឆ្នាំ1977 ស-២១ បញ្ជីឈ្មោះអ្នកទោស មានចំណងជើងថា របាយការណ៍របស់ ចាន់ ស្តីពីអ្នកទោស ១៨នាក់ ចាប់មកពីមន្ទីរស-២១ ERN 00088736-00088737 D57 (ភាសាខ្មែរ).

(7) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី24 ខែឧសភា ឆ្នាំ1977 ស-២១ របាយការណ៍មានចំណងជើងថា "បងជាទីគោរព" បញ្ជីឈ្មោះអ្នកទោស ៦នាក់ ចាប់មកពីកងពលធំលេខ៥០២ ដែលត្រូវបញ្ជូនមកមន្ទីរស-២១. ERN 00161879-00161879 (ភាសាខ្មែរ).

(8) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី25 ខែឧសភា ឆ្នាំ1977 របាយការណ៍ស្តីពីអ្នកទោសចាប់មកពីកងវរសេនាធំលេខ១៥២ និងកងពលលេខ ១៦៤ ចុះហត្ថលេខាដោយចាន់. ERN 00088735-00088735 D57 (ភាសាខ្មែរ).

(9) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី27 ខែឧសភា ឆ្នាំ1977 ស-២១ បញ្ជីឈ្មោះអ្នកទោសដោយ ចាន់ របាយការណ៍របស់ ចាន់ ស្តីពីអ្នកទោស សួន ម៉ុក ហៅ ឌុម ចាប់មកពីក្រសួងពាណិជ្ជកម្ម បញ្ជូនចូលមន្ទីរស-២១. ERN 00072578-00072578 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(10) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី28 ខែឧសភា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ស្តីពីអ្នកទោស ៣នាក់ ចាប់ចូលមន្ទីរស-២១.ERN 00088734-00088734 D57 (ភាសាខ្មែរ).

(11) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី28 ខែឧសភា ឆ្នាំ1977 បញ្ជីឈ្មោះអ្នកទោស ស-២១ ដោយ ចាន់ បញ្ជីអ្នកទោស៣០នាក់. ERN 00072579-00072581 ដីការសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(12) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី31 ខែឧសភា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ស្តីពីអ្នកទោសចាប់ចូលមន្ទីរស-២១. ERN 00088733-00088733 D57 (ភាសាខ្មែរ).

(13) របាយការណ៍របស់ កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី 01-ខែខែមិថុនា-1977 របាយការណ៍របស់មន្ទីរស-២១ ផ្ញើជូន កាំង ហ្គេកអ៊ាវ មកពី គ្រីន នៅឯកំង់ផែកំពង់សោម អំពីអ្នកចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១. ឌុច ចារលើរឹមទំព័រខាងឆ្វេង: “បងចាន់ [សូម] ធ្វើការសួរចម្លើយត្រជាក់”. ERN 00002419-00002419 (ភាសាខ្មែរ).

(14) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី 02-ខែខែមិថុនា-1977 របាយការណ៍របស់ ចាន់ ស្តីពីអ្នកទោស. ERN 00088731-00088732. D57 (ភាសាខ្មែរ).

(15) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី2 ខែមិថុនា ឆ្នាំ1977 បញ្ជីឈ្មោះអ្នកទោស ស-២១ ដោយ ចាន់ បញ្ជីឈ្មោះអ្នកទោស ៥៨នាក់. ERN 00072572-00072577 ដីការសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(16) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី08 ខែសីហា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ស្តីពីអ្នកទោសដែលចូលមន្ទីរ ស-២១. ERN 00002442-00002444 D57 (ភាសាខ្មែរ).

(17) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី09 ខែសីហា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ស្តីពីអ្នកទោសចូលមន្ទីរស-២១. ERN 00002445-00002446 D57 (ភាសាខ្មែរ).

(18) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី11 ខែសីហា ឆ្នាំ1977 ដល់ថ្ងៃទី09 វិច្ឆិកា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ផ្ញើជូន **ឌុច** ស្តីពីអ្នកទោសដែលចូលមន្ទីរ ស-២១. ERN 00173333-00173454 D32/V- ឧបសម្ព័ន្ធ 05 (ភាសាខ្មែរ).

(19) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី12 ខែសីហា ឆ្នាំ1977. ERN 00052569-00052812, 00173333-1733454 D57, D32/V ឧបសម្ព័ន្ធ 05 (ភាសាខ្មែរ).

(20) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី06 ខែធ្នូ ឆ្នាំ1977 របាយការណ៍របស់ ចាន់ ផ្ញើជូន "បង" ស្ដីពីអ្នកទោសដែលចូលមន្ទីរ ស-២១. ERN 00088706-00088708 D57 (ភាសាខ្មែរ).

(21) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី11 ខែតុលា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ផ្ញើជូន "បង" ស្ដីពីអ្នកទោសដែលចូលមន្ទីរ ស-២១ ERN 00088702-00088702 D57 (ភាសាខ្មែរ).

(22) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី12 ខែតុលា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ផ្ញើជូន "បង" ស្ដីពីអ្នកទោសដែលចូលមន្ទីរ ស-២១. ERN 00072559-00072561 ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(23) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី13 ខែតុលា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ផ្ញើជូន "បង" ស្ដីពីអ្នកទោសដែលចូលមន្ទីរ ស-២១. ERN 00088703-00088705 D57 (ភាសាខ្មែរ).

(24) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី15 ខែតុលា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ស្ដីពីអ្នកទោសដែលចូលមន្ទីរស-២១. ERN 00040218-00040219 ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(25) ម៉ម ណៃ ហៅ ចាន់ បញ្ជីឈ្មោះអ្នកទោស ចុះថ្ងៃទី31 ខែតុលា ឆ្នាំ1977 របាយការណ៍របស់ ចាន់ ស្ដីពីអ្នកទោសដែលចូលមន្ទីរស-២១. ERN 00002458-00002459 D57 (ភាសាខ្មែរ).

(26) ម៉ម ណៃ ហៅ ចាន់ សៀវភៅកំណត់ហេតុ ចុះថ្ងៃទី17 ខែធ្នូ ឆ្នាំ1977 "ការសិក្សានៅក្នុងមន្ទីរ, ចុះថ្ងៃទី17 ខែធ្នូ ឆ្នាំ1977" ERN 00076152-00076284 (ភាសាខ្មែរ).

(27) ចម្លើយសារភាពរបស់ វ៉ាន់ ពីនី ចុះថ្ងៃទី20 ខែធ្នូ ឆ្នាំ1977 ។ ចំណាររបស់ ម៉ម ណៃ ហៅ ចាន់ នៅ ERN 00026177 (ចុះថ្ងៃទី 21 វិច្ឆិកា 1977) ERN 00026082-00026190 ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(28) ម៉ម ណៃ ហៅ ចាន់ សៀវភៅកត់ត្រារបស់ ស-២១ ចុះថ្ងៃទី 16 មករា 1978 ដល់ 25 កក្កដា 1978, ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឯកសារលេខ14.3 ERN 00077661-00078056 (ភាសាខ្មែរ).

(29) ចម្លើយសារភាពរបស់ James William CLARK ចុះថ្ងៃទី23 ខែឧសភា ឆ្នាំ1978។ ចំណារ/ហត្ថលេខារបស់ ម៉ម ណៃ នៅ ERN 00007051. ERN 00006979-00007051 ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ENG/KHM).

(30) ចម្លើយសារភាពរបស់ LE Wang Yeu ចុះថ្ងៃទី26 មិថុនា ឆ្នាំ1978។ ចំណារ/ហត្ថលេខារបស់ ម៉ម ណៃ នៅ ERN 00052956. ERN 00052949-00052958 ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(31) ចម្លើយសារភាពរបស់ Ronald K DEAN ចុះថ្ងៃទី 21-វិច្ឆិកា-1978 ដល់ 05-មករា-1979។ ចំណារ/ហត្ថលេខារបស់ ម៉ម ណៃ ហៅចាន់ នៅ ERN 00007243 ERN 00007138-00007244 ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាអង់គ្លេស/ ភាសាខ្មែរ).

(32) ចម្លើយសារភាពរបស់ NGO Anh Tuan ចុះថ្ងៃទី 14-ធ្នូ-1978 ដឹកនាំដោយ ម៉ម ណៃ ហៅ ចាន់ ហើយមានចំណារ/ហត្ថលេខារបស់គាត់ នៅ ERN 00066316. ERN 00066314-00066316 ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(33) ចម្លើយសារភាពរបស់ TRUONG Van Thuong, DANG Van Con, NGO Chin និង VINH Chinh ចុះថ្ងៃទី26 ខែធ្នូ ឆ្នាំ1978 ការសួរចម្លើយធ្វើឡើងដោយ ម៉ម ណៃ (Mam Nai) ហៅ ចាន់ ហើយមានចំណារ/ហត្ថលេខារបស់គាត់ នៅ ERN 00066321. ERN 00066317-00066321 ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ (ភាសាខ្មែរ).

(34) CHANDLER, David *សម្លេងពីមន្ទីរស-២១*, ERN 00192667-00192932. ERN 00192758 បង្ហាញរូបថតមួយដែលថតក្នុងឆ្នាំ1975 នៅឯមន្ទីរស-២១ ដែលសាក្សីថតជាមួយ ឌុច និងគ្រួសាររបស់ពួកគេ.

(35) ម៉ម ណៃ ហៅ ចាន់, ចុះថ្ងៃទី02 ខែមីនា ឆ្នាំ1976. កំណត់ហេតុស្វ័យទិទាន សរសេរដោយដៃ ចុះហត្ថលេខាដោយ ម៉ម ណៃ, ERN 00002694-00002694 (ភាសាខ្មែរ). មិនទាន់មានក្នុងសំណុំរឿងនៅឡើយទេ.

## 18. មាស ប៉េងគ្រី

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងអំពីគោលនយោបាយនិងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹង ស-២១ សាក្សីផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ឃុំក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនខុសច្បាប់ ភាពខ្វះការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការឈឺចាប់យ៉ាងខ្លាំង អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* និងការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត និងការធ្វើមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [new])*។

2. ទាក់ទងនឹង ស-២៤ "ព្រៃស" សាក្សីផ្តល់ភស្តុតាងអំពីការបង្កើត រយៈពេល និងប្រតិបត្តិការរបស់ជំរុំកសាងខ្លួន *(20 & 30)* រចនាសម្ព័ន្ធរដ្ឋអំណាច *(22)* និងប្រព្រឹត្តកម្មអមនុស្សធម៌លើជនជាប់ឃុំ *(72-78).* ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

3. សាក្សី មានអាយុ២០ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គាត់មានសញ្ជាតិខ្មែរ ភេទប្រុស កើតនៅឆ្នាំ១៩៥៥[673]។ នៅឆ្នាំ១៩៧៣ គាត់បានក្លាយទៅជាយោធាខ្មែរក្រហមម្នាក់នៅក្នុងកងវ័ពស្រុកលេខ១៨ (កោះធំ)[674] និងត្រូវបានបញ្ជូនទៅកងពលធំលេខ១២នៃកងវ័ពភូមិភាគពិសេស[675]។ បន្ទាប់ពីបែកទីក្រុងភ្នំពេញ គាត់ត្រូវបានជ្រើសតាំងឱ្យទៅរៀនបើកបរឱ្យកងពលធំលេខ៧០៣ នៅភ្នំពេញ[676] ក្រោយមកក្រោមការដឹកនាំរបស់ ណាត គាត់បានក្លាយជាអ្នករត់សំបុត្រឱ្យសេនាធិការនៅទីក្រុង[677]។ គាត់ត្រូវបានបញ្ជូនទៅធ្វើការជាអ្នកបើកបរឱ្យ ស-២១ ប្រហែលជានៅឆ្នាំ១៩៧៦ ប៉ុន្តែគាត់ក្រឡាប់ឡានកាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៧[678] និងត្រូវបានបញ្ជូនទៅលត់ដំខ្លួននៅព្រៃស ដែលគាត់នៅទីនោះរហូតដល់បែករបបនោះ[679]។

## វេទនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

4. សាក្សីផ្តល់ភស្តុតាងថា នៅពេលគាត់កំពុងធ្វើការជាអ្នករត់សំបុត្រសាលាក្រុង គាត់បានឃើញខ្សែភាពយន្តកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញអំពីស្ថានភាពជីវិតសម្បូរហូរហៀរនៅជនបទ ដែលគាត់សន្មតថាជារឿងពិត ប៉ុន្តែគាត់មិនដែលទទួលបានការអនុញ្ញាតឱ្យទៅទស្សនកិច្ចស្រុកកំណើតវិញទេ ដូច្នេះគាត់មិនដឹងអំពីព័ត៌មានពិតនៅទីនោះទេ[680]។ គាត់ក៏បានចូលរួមសន្និសិទបណ្តុះបណ្តាលនយោបាយចំនួនបីថ្ងៃនៅស្តាតជាតិ ដែលនៅពេលនោះ សុន សេន ជាអ្នកបង្រៀន[681]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានធ្វើការនៅព្រៃសជាមួយកងនារី ប៉ុន្តែនៅទីនោះមាន "ប្រព័ន្ធ" នយោបាយល្បីថា នរណាដែលដើរខុស ដូចជាមានទំនាក់ទំនងជាមួយស្ត្រីណាម្នាក់ ជននោះនឹងត្រូវបានសម្លាប់ចោល[682]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីផ្តល់ភស្តុតាងថា គាត់មិនដែលបើកឡានឱ្យ **ឌុច** ទៅកន្លែងណាមួយទេ ប៉ុន្តែគាត់បានត្រឹមតែជួបឌុច នៅពេលពួកគេហៅគាត់ឱ្យមកសិក្សា ឬប្រជុំនៅខាងត្បូងផ្ទះរបស់ ឌុច[683]។ សាក្សីបាននិយាយថាគាត់បានចូលរួមវគ្គសិក្សានយោបាយតែម្តងគត់នៅ ស-២១ ដែលកោះប្រជុំដោយ **ឌុច** ដែលបានបង្ហាញឯកសារ និងអំពាវនាវឱ្យអ្នកមានវត្តមានក្នុងកិច្ចប្រជុំ ឱ្យពង្រឹងកងរបស់ខ្លួន និងស្មោះត្រង់នឹងបដិវត្តន៍[684]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងថា អ្វីៗទាំងអស់នៅ ស-២១ ត្រូវបានបែងចែកដាច់ពីគ្នា។ កងរបស់គាត់ដាច់ស្រឡះចេញពីកងផ្សេងៗទៀត ហើយគាត់មិនដឹងអំពីកិច្ចការរបស់អ្នកផ្សេងទៀតទេ[685]។ **ឌុច** បានកោះប្រជុំវគ្គសិក្សានយោបាយមួយលើក ប៉ុន្តែជារឿយៗ ហ៊ុយ "ខ្លី" ជាអ្នកកោះប្រជុំ "វគ្គជីវិតរស់នៅ"[686]។

7. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសភាគច្រើនដែលគាត់ដឹកមកស-២១[687] អ្នកទាំងនោះមកពីកងពលធំ និងទៅដឹកនៅតំបន់មន្ទីរពេទ្យចិន[688]។ គាត់ និង ហ៊ឹម ហ៊ុយ បានទៅដឹកអ្នកទោសពីវិមានឯករាជ្យ និងខេត្តបាត់ដំបងទៅដាក់នៅ ស-២១។ អ្នកទោសទាំងអស់នេះត្រូវបានគេចាប់ខ្លួន និងបិទមុខដោយចងដៃទៅខាងក្រោយខ្នងរបស់ពួកគេ[689]។ នៅពេលគាត់បានទៅដល់ច្រកចេញចូលរបស់ស-២១ អ្នកយាមបានយកអ្នកទោសចូលទៅក្នុង[690]។

8. ដំបូង សាក្សីដឹកឈើទៅជើងឯកសម្រាប់សាងសង់ផ្ទះឈើនៅកន្លែងនោះ[691] ប៉ុន្តែក្រោយមក "ម្តង ឬ ពីរដង" គាត់បានដឹកអ្នកទោសចេញពី ស-២១ ទៅជើងឯក នៅពេលយប់[692]។ គាត់ត្រូវបានគេណែនាំឱ្យមានភាពប្រុងប្រយ័ត្ន[693]។ គាត់បើកឡាន Land Rover ដែលមានបាំងបិទជិតខាងក្រោយ ដែលមួយលើកៗ អាចដឹកបានអ្នកទោសបួនទៅប្រាំមួយនាក់ ដែលអ្នកទាំងអស់នោះមានរូបរាងកាយស្គមកំព្រឹង ហើយអ្នកទោសនោះត្រូវអមដំណើរដោយអ្នកយាមម្នាក់។ អ្នកទោសត្រូវបានគេបិទមុខជិត និងដៃរបស់ពួកគេត្រូវបានចងខាងក្រោយខ្នង និង "ត្រូវបានទាញ"ចេញពីលើឡានដោយក្រុមកំពុងរង់ចាំនៅជើងឯក ដើម្បីទទួលអ្នកទោស[694]។ អ្នកទោសត្រូវបានគេយកទៅផ្ទះឈើ[695] ហើយសាក្សី និងអ្នកយាមបានបើកត្រលប់ទៅស-២១វិញ ដោយមិនរង់ចាំរហូតដល់អ្នកទោសត្រូវបានសម្លាប់នោះទេ[696]។

9. នៅឆ្នាំ១៩៧៧ សាក្សីត្រូវបានបញ្ជូនទៅព្រៃសដើម្បីកសាងខ្លួន[697] ពីព្រោះគាត់បានដេកលក់នៅពេលបើកឡាន និងធ្វើឱ្យក្រឡាប់ឡានពេលធ្វើដំណើរពីខេត្តបាត់ដំបងមកខេត្តតាកែវវិញ។ គាត់មិនត្រូវបានគេសម្លាប់ដោយសារ "កំហុស"ដូចនេះទេ ពីព្រោះ ហ៊ឹម ហ៊ុយ ធានាគាត់[698]។ គាត់ត្រូវបានគេឃុំនៅព្រៃសរហូតដល់បែកភ្នំពេញនៅឆ្នាំ១៩៧៩[699]។

10. ការងារនៅព្រៃស ត្រូវតែបំពេញ"ដោយអនុលោមតាមផែនការតឹងរឹងបំផុត" ចាប់ពីម៉ោង៤ព្រឹករហូតដល់ម៉ោង១១ថ្ងៃ និងចាប់ពីក្រោយអាហារថ្ងៃត្រង់រហូតដល់ម៉ោង៦ល្ងាច និងមានការបន្ថែមការងារម្តងម្កាលនៅពេលយប់។ អាហារបរិភោគមិនគ្រប់គ្រាន់ និងមានគ្រូពេទ្យព្យាបាលអ្នកជម្ងឺជាច្រើននៅទីនោះ[700]។ គាត់ក៏បានលើកឡើងថា គាត់មិនដែលបានឃើញ **ឌុច** នៅព្រៃស ដែលនៅទីនោះ ហ៊ុយ គឺជាអ្នកទទួលខុសត្រូវ[701]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

11. សាក្សីបានលើកឡើងថា គាត់ស្គាល់ប្រធាន ស-២១ **ឌុច** និង "ហូ"[702]។ ហ៊ឹម ហ៊ុយ គឺជាមេរបស់គាត់និងផ្តល់ការណែនាំឱ្យគាត់[703]។ ហ៊ុយ ស្រែ ទទួលបន្ទុកនៅព្រៃស[704]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

12. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសភាគច្រើនដែលគាត់ដឹកមក ស-២១[705] គឺមកពីកងពលធំនានា និង អ្នកទោសខ្លះ គាត់ត្រូវទៅដឹកនៅតំបន់មន្ទីរពេទ្យចិន[706]។ នៅពេលគាត់មកដល់ច្រកចេញចូល ស-២១ អ្នកយាមបានមកយកអ្នកទោសចូលខាងក្នុង[707]។

13. សាក្សីផ្តល់ភស្តុតាងថា គាត់មិនដែលឃើញក្មេងៗនៅជើងឯកទេ[708]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

14. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសដែលគាត់ដឹក មានរូបរាងកាយស្គមទាំងអស់[709]។

15. ការងារនៅព្រៃស ត្រូវតែបំពេញ"ដោយអនុលោមតាមផែនការតឹងរឹងបំផុត" ចាប់ពីម៉ោង៤ព្រឹក រហូតដល់ម៉ោង១១ថ្ងៃ និងចាប់ពីក្រោយអាហារថ្ងៃត្រង់រហូតដល់ម៉ោង៦ល្ងាច និងមានការបន្ថែមការងារម្តងម្កាលនៅពេលយប់។ អាហារបរិភោគមិនគ្រប់គ្រាន់ និងគ្រូពេទ្យព្យាបាលអ្នកជម្ងឺជាច្រើននៅទីនោះ[710]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

16. សាក្សីផ្តល់ភស្តុតាងថា គាត់បានដឹងថា គ្មាននរណាម្នាក់អាចលួចរត់ចេញពី ស-២១ និងបានដឹងថា អ្នកទោស "បានបាត់ខ្លួន"[711]។ សាក្សីផ្តល់ភស្តុតាងថា នៅពេលគាត់ដឹកអ្នកទោសពីទួលស្លែង ទៅជើងឯក គាត់មិនបានរង់ចាំរហូតដល់គេសម្លាប់អ្នកទោសទាំងអស់នោះទេ[712]។ នៅ ស-២៤ ប្រជាជន "បានបាត់ខ្លួន" ក្រោយគេហៅទៅចូលរួមប្រជុំ ប៉ុន្តែសន្មតថា ពួកគេត្រូវបានសម្លាប់[713]។

## សក្ខីកម្មមុនៗ

17. សាក្សីបានផ្តល់សក្ខីកម្មពីមុនចំនួនប្រាំមួយទៅឲ្យសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ មាស ប៉េងគ្រី ដោយ DC-Cam, ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០២, ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ 19.112, ERN 00056824-00056837 (ភាសាខ្មែរ) (សង្ខេបជាភាសាអង់គ្លេសនៅ ERN 00184203-00184206).

(2) បទសម្ភាសន៍របស់ មាស ប៉េងគ្រី ដោយ DC-Cam, ចុះថ្ងៃទី22 ខែកុម្ភៈ ឆ្នាំ2003, ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ19.112, ERN 00051752-00051808 (ភាសាខ្មែរ) (សង្ខេបជាភាសាអង់គ្លេសនៅ ERN 00184203-00184206)

(3) បទសម្ភាសន៍របស់ មាស ប៉េងគ្រី ដោយ ក.ស.ច.ស-អ.វ.ត.ក, ចុះថ្ងៃទី29 ខែវិច្ឆិកា ឆ្នាំ2007, D28/7, ERN 00163704-00163708 (ភាសាអង់គ្លេស).

(4) កំណត់ហេតុនៃការតទល់មុខគ្នារបស់ មាស ប៉េងគ្រី ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2008, D52, ERN 00165434-00165440 (ភាសាអង់គ្លេស).

(5) បទសម្ភាសន៍របស់ មាស ប៉េងគ្រី ដោយ ក.ស.ច.ស-អ.វ.ត.ក ស្ដីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី26 ខែកុម្ភៈ ឆ្នាំ2008, D48/1, ERN 00197993-00197997 (ភាសាអង់គ្លេស).

(6) បទសម្ភាសន៍របស់ មាស ប៉េងគ្រី ក្នុងខ្សែភាពយន្ត *ស-២១: ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម* ដោយ ឫទ្ធី ប៉ាន់ ឆ្នាំ2002, D69, ERN V 00172620.

## ឯកសារពាក់ព័ន្ធ

18. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធនៅពេលជំនុំជម្រះ។

## 19. ញ៉ែម អេន

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ទាក់ទងនឹង ស-២១ សាក្សីនេះផ្ដល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)* វចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនខុសច្បាប់ ការខ្វះការជំនុំជម្រះយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [new])* ការសម្លាប់បំផុតពូជ ការធ្វើឃាតមនុស្ស និងការសម្លាប់អ្នកជាប់ឃុំដោយចេតនា *(107-128, 138, 139-140, 151 & 152 [new]).* ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ នៅក្នុងដីបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ១៥ឆ្នាំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សាក្សីមានសញ្ជាតិខ្មែរ ភេទប្រុស កើតនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៩។ គាត់ត្រូវបានខ្មែរក្រហមជ្រើសរើស និងបញ្ជូនទៅខេត្តកំពង់ឆ្នាំងជាមួយកូនក្មេងផ្សេងៗទៀតដែលនៅក្នុងឃុំជាមួយគាត់ និងក្រោយមកបញ្ជូនទៅភ្នំពេញ និងក្រោមការគ្រប់គ្រងរបស់ ណាត និង ពីន ក្នុងកងពលធំលេខ៧០៣[714]។ គាត់ត្រូវបានគេបញ្ជូនទៅប្រទេសចិនចំនួនប្រាំមួយខែ ដើម្បីបណ្ដុះបណ្ដាលថតរូប ដែលគាត់បានជួបជាមួយ ណាត នៅទីនោះ[715]។ នៅពេលគាត់ត្រលប់មកប្រទេសកម្ពុជា គាត់បានក្លាយជាអ្នកថតរូបឱ្យមន្ទីរសេនាធិការ ដែលគាត់ថតរូបក្នុងកិច្ចប្រជុំ និងទស្សនកិច្ចផ្លូវការនានា[716]។ គាត់ត្រូវបានបញ្ជូនទៅធ្វើការជាអ្នកថតរូបនៅ ស-២១ កាលពីដើមឆ្នាំ១៩៧៧ និងបានធ្វើការនៅទីនោះរហូតដល់ពេលបែករបបនោះ[717]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីបានជួប **ឌុច** ដំបូងនៅមន្ទីរពេទ្យមុន្នីវង្សក្បែរ *ផ្សារថ្មី* នៅឆ្នាំ១៩៧៦[718]។ សាក្សីលើកឡើងថា **ឌុច** គឺជា "មេដឹកនាំថ្នាក់ខ្ពស់បំផុត" នៅស-២១ ទទួលបន្ទុកលើកិច្ចការទាំងអស់[719] ដែលគាត់ "បានដឹងអ្វីៗទាំងអស់ ... បញ្ហាប្រទេសជាតិ ភ្នាក់ងារសម្ងាត់ កាហ្សេប៉េ ស៊ីអាយអេ និងអ្វីៗទាំងអស់ត្រូវតែបញ្ជូន

ទៅឲ្យគាត់តែម្នាក់ឯង"[720]។ សាក្សីក៏បានលើកឡើងថា ក្នុងអំឡុងពេលកិច្ចប្រជុំជាមួយ **ឌុច** គាត់បានលឺ សុន សេន និយាយថា "ស-២១ គឺជាកន្លែងសំខាន់បំផុតរបស់ជាតិ"[721]។

4. ឌុច បានបញ្ជូនរបាយការណ៍ទៅ ប៉ុល ពត និងនួន ជា[722]។ យោងតាមសាក្សី ឌុច ទទួលបញ្ជាពី ប៉ុល ពត នួន ជា សុន សេន និង "មន្ត្រីនៅគ្រប់ក្រសួងធំៗទាំងអស់"។ **ឌុច** មិនបានធ្វើការងារដោយឆន្ទៈដោយសេរីរបស់ខ្លួនទេ និងមិនអាចជៀសវាងការសម្លាប់មនុស្សទេ[723]។

5. សាក្សីនិយាយថា **ឌុច** "កម្រ"មកមើលពេលគាត់កំពុងថតរូបអ្នកទោសថ្មីៗ[724] ប៉ុន្តែគាត់បានយករូបថតឲ្យ **ឌុច** ដោយផ្ទាល់ ដែល**ឌុច** ចូលចិត្តគាត់ និងបានឲ្យគាត់នាឡិកាម៉ាករ៉ូឡិចជាអំណោយ[725]។

6. សាក្សីផ្តល់ភស្តុតាងថា គាត់បានឃើញ **ឌុច** សួរចម្លើយអ្នកទោសម្តងនៅឆ្នាំ១៩៧៧[726] ប៉ុន្តែគាត់បានដឹងថា ពេលខ្លះ **ឌុច** បានចូលរួមក្នុងការសួរចម្លើយ "អ្នកទោសសំខាន់ៗ" ម្តង ឬពីរដងក្នុងមួយខែ ដូចជាការសួរចម្លើយប្រធានតំបន់និងភូមិភាគ និងមេបញ្ជាការកងទ័ព[727]។ ឌុច បានដើរជុំវិញ និងបានពិនិត្យការសួរចម្លើយនៅ ស-២១[728] និង "ស្អប់អ្នកដែលធ្វើការសួរចម្លើយមិនត្រឹមត្រូវ ឬជនដែលមិនបានបំពេញកិច្ចការរបស់ខ្លួន"[729]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានឃើញ **ឌុច** បានយកដំបងធំមួយវាយលើអ្នកសួរចម្លើយម្នាក់ នៅពេលអ្នកសួរចម្លើយនេះមិនបានយកចម្លើយសារភាពច្បាស់ពីអ្នកទោសសង្គ្រាមជនជាតិវៀតណាម[730]។ ក្រោយមក អ្នកសួរចម្លើយនេះត្រូវបានគេសម្លាប់នៅ ស-២១[731]។ **ឌុច** ជាអ្នកសម្រេចផ្ទាល់លើការប្រហារជីវិតមន្ត្រីស-២១ ដោយមិនចាំបាច់ស្នើសុំការយល់ព្រមពីមេដឹកនាំជាន់ខ្ពស់នោះទេ[732]។

7. សាក្សីផ្តល់ភស្តុតាងថា គាត់បានចាកចេញពី ស-២១ ជាមួយ **ឌុច** នៅម៉ោង២ព្រឹក កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ហើយ **ឌុច** បានបញ្ជាឲ្យសម្លាប់អ្នកទោសដែលនៅសល់ទាំងអស់[733]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

8. សាក្សីផ្តល់ភស្តុតាងថា គាត់បានធ្វើការនៅ ស-២១ តាំងពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩។

9. កងថតរូបមានប្រជាជនប្រាំមួយនាក់ រួមមាន ស្រ៊ាង (ប្រធានក្រុម[734]) សុង, និត, សំ, ទី និងខ្លួនគាត់[735]។ គាត់បានមកដល់ ស-២១ នៅម៉ោង៦:៣០នាទីព្រឹកដើម្បីបរិភោគរួមគ្នា។ ការងារបានចាប់ផ្តើមពីម៉ោង៧ព្រឹក នៅពេលពួកគេត្រូវថតរូបអ្នកទោសដែលទើបនឹងមកដល់ថ្មីៗ។ ពួកគេបានឈប់សម្រាកនៅម៉ោង

១០ថ្ងៃ និងធ្វើការរហូតដល់ម៉ោង៥ល្ងាច។ នៅពេលពួកគាត់ត្រលប់ទៅផ្ទះវិញ គាត់លាងហ្វីល និងផ្តិតរូបថតដែលគាត់ទើបនឹងថត[736]។

10. សាក្សីផ្តល់ភស្តុតាងថា គេបានទាក់ទងគាត់តាមទូរស័ព្ទក្នុងបន្ទប់ថតរូប ដើម្បីប្រាប់អំពីការមកដល់របស់អ្នកទោស ដែលអ្នកទាំងនោះចូលមកក្នុងបន្ទប់ដោយរុំភ្នែកជិត[737]។ អ្នកទោសបានសួរសាក្សីថា ហេតុអ្វីបានជាពួកគេត្រូវបានចាប់ខ្លួន ប៉ុន្តែសាក្សីមិនអើពើនឹងសំណួររបស់ពួកគេ[738]។

11. កន្លែងដែលសាក្សីលាងហ្វីលរូបថតដែលគាត់ថតអ្នកទោស គឺនៅក្បែរផ្ទះរបស់ **ឌុច** ដែលស្ថិតនៅពីមុខក្រសួងផែនការ[739]។ សាក្សីលើកឡើងថា គាត់មិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងបរិវេណ ស-២១ ទេ[740]។

## **រចនាសម្ព័ន្ធរដ្ឋអំណាច**

12. សាក្សីផ្តល់ភស្តុតាងថា ដំបូង សុន សេន ជាអ្នកចេញបញ្ជាឱ្យ **ឌុច**។ សាក្សីដឹងអំពីរឿងនេះ ដោយសារតែគាត់បានចូលរួមក្នុងកិច្ចប្រជុំ "ដើម្បីរៀនសូត្រអំពីមាគ៌ារបស់អង្គការ"[741]។ គាត់បានលើកឡើងថា "សេចក្តីសម្រេចរបស់ **ឌុច** និងបញ្ជារបស់ សុន សេន គឺមានលក្ខណៈដូចគ្នា។ ពួកគេ មានចរន្តតែមួយ (ដែលហូរទៅហូរមក)។ ជាសរុបមក ជនទាំងពីរនេះគឺដូចតែគ្នា។ ប្រសិនបើ **ឌុច** មិនធ្វើរបាយការណ៍ទេ សុន សេន, ប៉ុល ពត និង នួន ជា មិនអាចដឹងអ្វីនោះទេ ... ឌុច គឺជាអ្នកសម្រេចថាតើនរណាត្រូវសម្លាប់។ គាត់គឺជាអ្នកដែលផ្តល់ភ្លើងខៀវឱ្យទៅ សុន សេន និង ប៉ុល ពត"[742]។ សាក្សីបានលឺ **ឌុច** និយាយថា គាត់បានបញ្ជូនឯកសារទៅឱ្យបងធំលេខមួយ និងបងធំលេខពីរ (ប៉ុល ពត និង នួន ជា)។ គាត់បានលើកឡើងថា សុន សេន ទទួលបានរបាយការណ៍របស់ ឌុច និង សុន សេន បានមកទស្សនកិច្ច ស-២១ មួយអាទិត្យម្តង[743] រហូតដល់ពេលដែលវៀតណាមចូលមកដល់[744]។ គាត់ក៏បានលើកឡើងថា សុន សេន និង **ឌុច** បានដាក់កិច្ចការឱ្យគាត់ធ្វើជារៀងរាល់ថ្ងៃ និងបាននិយាយថា "បញ្ហារបស់ពួកគេមានលក្ខណៈតឹងរឹង ហើយគាត់ត្រូវតែធ្វើកុំឱ្យមានកំហុស"[745]។

13. សាក្សីផ្តល់ភស្តុតាងថា **ឌុច** គឺជាប្រធាន ស-២១ ទទួលបន្ទុកលើកិច្ចការទាំងអស់ និង ហ៊ី គឺអនុប្រធានទទួលបន្ទុកផ្នែកយោធា នៅពេលដែល ចាន់ គឺជាសមាជិកទទួលបន្ទុកផ្នែកបកប្រែ[746]។ ស្រ៊ី ស្ថិតនៅក្នុងកងការពារពិសេស។ សមាសភាពកម្មាភិបាលដឹកនាំទាំងបីរូប រួមមាន ឌុច ហ៊ី និង ចាន់ ដែលត្រូវបានគេ

ហៅថា "គណៈកម្មាធិការស-២១"។[747] ចាន់ ដែល "ការបញ្ញាមានលក្ខណៈតឹងរឹង" គឺជាអ្នកទទួលខុសត្រូវដោយផ្ទាល់លើកងថតរូប[748]។

14. សាក្សីលើកឡើងថា រូបថត និងឯកសារទាំងអស់ត្រូវបានបញ្ជូនទៅ ប៉ុល ពត តាមរយៈ **ឌុច**៖ "ឯកសារទាំងអស់ដែលធ្វើនៅ ស-២១ ត្រូវបានបញ្ជូនទៅតា **ឌុច**។ តា **ឌុច** ឲ្យឯកសារទាំងនោះទៅ សុន សេន, ដែលគាត់ឲ្យឯកសារទាំងនោះទៅ នួន ជា និង ប៉ុល ពត"[749]។ សាក្សីលើកឡើងថា ប៉ង់ ("ភ្នាក់ងារពិសេសម្នាក់របស់ប៉ុល ពត"[750]) និង នឿន ("អ្នកបញ្ជូនសារនៅក្រុង" ជិតដិតនឹង សុន សេន[751]) បានមកផ្ទះ **ឌុច** ដោយឡានម៉ាកហ្ស៊ីប ដើម្បី"មកដឹកឯកសារយកទៅឲ្យ ប៉ុល ពត"[752]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

15. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសស្ទើរតែទាំងអស់ត្រូវបានគេដឹកមក ស-២១ ដោយឡានធំ និងពួកគេមកដល់ដោយរុំមុខជិត ប៉ុន្តែអ្នកទោសខ្លះបានដឹកមកដល់ដោយកូនឡាន។ ពេលខ្លះ អ្នកទោសត្រូវបានគេដឹកដោយឡានធំៗរបស់ ស-២១ និងពេលខ្លះ អ្នកទោសត្រូវបានដឹកដោយឡានរបស់ភូមិភាគផ្សេងៗ[753]។

16. នៅឆ្នាំ១៩៧៧ ចំនួនអ្នកទោសនៅ ស-១ បានកើនឡើង ដែលបានមកដល់២៤ម៉ោងក្នុងមួយថ្ងៃ ប៉ុន្តែត្រឹមឆ្នាំ១៩៧៨ ការដឹកអ្នកទោសមកមានសភាពធ្លាក់ចុះទៅ "មួយ ឬពីរលើក"ក្នុងមួយថ្ងៃ[754]។ សាក្សីលើកឡើងថា អ្នកទោសនីមួយៗត្រូវបានគេឲ្យស្លាកសម្គាល់ដែលមានដាក់លេខ និងកាលបរិច្ឆេទ និងបញ្ជីឈ្មោះអ្នកទោសត្រូវប្រគល់ឲ្យ ធី[755]។

17. សាក្សីប៉ាន់ប្រមាណថា អ្នកទោស ១០.០០០នាក់ ត្រូវបានឃុំខ្លួននៅ ស-២១[756]។ សាក្សីបានលើកឡើងថា គាត់ក៏បានថតរូបអ្នកទោសសង្គ្រាមជនជាតិវៀតណាមចំនួន២០នាក់ នៅក្នុងអំឡុងពេលដែល "ជនជាតិវៀតណាមបានវាយប្រហារ និងចូលមកក្នុងប្រទេសកម្ពុជានៅតាមតំបន់ព្រំដែន"[757]។ នៅឆ្នាំ១៩៧៧ គាត់បានថតរូបជនបរទេសលោកខាងលិចចំនួនពីរនាក់ ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ[758]។

## ការសួរចម្លើយ

18. សាក្សីផ្តល់ភស្តុតាងថា កន្លែងសម្រាប់សួរចម្លើយមានចំនួន "ប្រហែលដប់" នៅជុំវិញបរិវេណ ស-២១[759]។ គាត់បានលើកឡើងថា ម្តងនោះ គាត់បានឃើញ **ឌុច** សួរចម្លើយអ្នកទោសម្នាក់កាលពីឆ្នាំ១៩៧៧[760] ប៉ុន្តែគាត់បានដឹងថា **ឌុច** ចូលរួមក្នុងការសួរចម្លើយ "អ្នកទោសសំខាន់ៗ" ម្តង ឬពីរដងក្នុង

មួយខែ ដូចជាការសួរចម្លើយប្រធានភូមិភាគ និងប្រធានតំបន់ និងមេបញ្ជាការកងទ័ព[761]។ **ឌុច** បានដើរពិនិត្យមើលជុំវិញនៃការសួរចម្លើយនៅ ស-២១[762] និង "ស្អប់អ្នកដែលមិនបានធ្វើការសួរចម្លើយឱ្យបានត្រឹមត្រូវ ឬជនមិនបានបំពេញកិច្ចការរបស់ខ្លួន"[763]។ សាក្សីផ្ដល់ភស្តុតាងថា គាត់បានឃើញ **ឌុច** យកដំបងធំមួយវាយលើអ្នកសួរចម្លើយម្នាក់ នៅពេលអ្នកសួរចម្លើយនោះមិនបានយកចម្លើយសារភាពច្បាស់ពីអ្នកទោសសង្គ្រាមជនជាតិវៀតណាម[764]។ ក្រោយមក អ្នកសួរចម្លើយត្រូវបានគេយកទៅសម្លាប់នៅ ស-២១[765]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

19. សាក្សីផ្ដល់ភស្តុតាងថា គាត់បានឃើញគេធ្វើទារុណកម្មអ្នកទោសដោយឆក់ខ្សែភ្លើង។ គាត់បានដឹងថា គេដកក្រចកដៃរបស់អ្នកទោស និងជានិច្ចជាកាលមានសម្លេងយំស្រែកយ៉ាងខ្លាំង[766]។ សាក្សីផ្ដល់ភស្តុតាងថា **ឌុច** បានវាយអ្នកទោសនឹងរំពត់ផ្ដៅ។ សាក្សីនិយាយថា គាត់បានឃើញ **ឌុច** ប្រព្រឹត្តអំពើហិង្សាលើរូបរាងកាយនៅពីមុខ ស-២១ ជាប់ទៅនឹងកន្លែងធ្វើការរបស់គាត់[767]។ គាត់បានពោលថា "មនុស្សស្បែកស"ដែលចាប់បានមកពីកំពង់សោម ត្រូវបានគេធ្វើទារុណកម្មដូចគ្នានឹងអ្នកទោសផ្សេងទៀត[768]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

20. សាក្សីផ្ដល់ភស្តុតាងថា គាត់បានឃើញគេយកឡានធំៗមកដឹកអ្នកទោសចេញ។ ក្រោយមក គាត់បានដឹងថា អ្នកទោសទាំងនោះត្រូវបានគេដឹកទៅជើងឯក ដែលជាកន្លែងដែលគេសម្លាប់ពួកគាត់[769]។ គាត់បានពោលថា **ឌុច** ជាវៀយបញ្ជាកងពិសេសឱ្យថតរូបអ្នកទោសដែលស្លាប់ដើម្បីបញ្ជាក់អំពីការស្លាប់របស់ពួកគាត់[770]។ រូបថតអ្នកទោសសំខាន់ៗ ទាំងមុនពេលនិងក្រោយពេលសម្លាប់ ត្រូវបានគេផ្ញើទៅ សុន សេន និង ប៉ុល ពត ដើម្បីជាភស្តុតាងបង្ហាញថាពួកអ្នកទោសទាំងអស់នោះត្រូវបានសម្លាប់[771]។

21. សាក្សីផ្ដល់ភស្តុតាងថា ក្នុងចំណោមបុគ្គលិក៤០០នាក់មកពីស្រុកជាមួយគាត់ បុគ្គលិកចំនួន១៥០នាក់ត្រូវបានបាត់ខ្លួន[772]។ សាក្សីផ្ដល់ភស្តុតាងថា អ្នកយាមម្នាក់ត្រូវបានគេសម្លាប់ ពីព្រោះគាត់បានដេកលក់នៅពេលគាត់បំពេញភារកិច្ចនៅពេលយប់។ សាក្សីផ្ដល់ភស្តុតាងថា អ្នកទោសម្នាក់ក៏ត្រូវបានគេសម្លាប់ពីព្រោះគាត់ត្រូវបានគេចោទប្រកាន់ពីបទបំពុល ដោយសារតែគាត់មិនបានលាងបន្លែឱ្យបានត្រឹមត្រូវដែលធ្វើឱ្យនៅក្លិនថ្នាំសម្លាប់សត្វ[773]។

## សក្ខីកម្មមុនៗ

22. សាក្សីផ្តល់សក្ខីកម្មពីមុនចំនួនដប់ប្រាំមួយ ឲ្យទៅសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ ញ៉ែម អេន ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី1 ខែវិច្ឆិកា ឆ្នាំ2007, D22/15, ERN 00162833-00162851 (ភាសាខ្មែរ), ERN 00162852-00162871 (ភាសាអង់គ្លេស).

(2) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុង *ពិឃ្ឃាតបាត់ខ្លួន – រឿងមួយក្នុងរបបខ្មែរក្រហម* ដោយ Nic DUNLOP ឆ្នាំ2005, ទំព័រ 152-170.

(3) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុងខ្សែភាពយន្ត *សម្លេងពីមន្ទីរស-២១* – *Terror and History in Pol Pot's Secret Prison* ដោយ David CHANDLER ឆ្នាំ 1999, at pages 25, 27-28, 30, 36, 90, 99, 128, 139.

(4) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុង Nic DUNLOP *ពិឃ្ឃាតបាត់ខ្លួន* ទំព័រ 152-164, 168-170. No ERN, មិនទាន់មានក្នុងសំណុំរឿង (ភាសាអង់គ្លេស).

(5) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុង *Cambodia Genocide: Memories from Tuol Sleng Prison* ដោយ Peter Maguire, គ្មានកាលបរិច្ឆេទ. គ្មាន ERN, មិនទាន់មានក្នុងសំណុំរឿង http://www.fathom.com/feature/35706/ បើកមើលថ្ងៃទី31 ខែតុលា ឆ្នាំ2008 (ភាសាអង់គ្លេស).

(6) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុង *Cambodian Photographer Recalls Victims of Khmer Rouge Regime* ដោយ Robin McDowell ក្នុង Associated Press, គ្មានកាលបរិច្ឆេទ. គ្មាន ERN, មិនទាន់មាននៅក្នុងសំណុំរឿង http://www.thefreelibrary.com/CAMBODIAN+ PHOTOGRAPHER+RECALLS+VICTIMS+OF+KHMER+ROUGE+REGIME-a083855361 បើកមើលថ្ងៃទី31 ខែតុលា ឆ្នាំ2008 (ភាសាអង់គ្លេស).

(7) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុង *Chilling Start to Khmer Rouge Tribunal* ដោយ Thomas Bell ក្នុង *Daily Telegraph* ចុះថ្ងៃទី3 ខែវិច្ឆិកា ឆ្នាំ2007. គ្មាន ERN, មិនទាន់មាននៅក្នុងសំណុំរឿង http://www.telegraph.co.uk/news/worldnews/1568068/

Chilling-start-to-Khmer-Rouge-tribunal.html បើកមើលថ្ងៃទី31 ខែតុលា ឆ្នាំ2008 (ភាសាអង់គ្លេស).

(8) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុង *Out From Behind a Camera at a Khmer Torture House* ដោយ Seth Mydans, ចុះថ្ងៃទី26 ខែតុលា ឆ្នាំ2007 http://www.nytimes.com/2007/10/26/world/asia/27cambo.html បើកមើលថ្ងៃទី31 ខែតុលា ឆ្នាំ2008 (ភាសាអង់គ្លេស).

(9) បទសម្ភាសន៍របស់ ញ៉ែម អេន ដោយ Doug Niven និង Peter Maguire, ចុះថ្ងៃទី12 ខែមីនា ឆ្នាំ1997, ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 19.125, ERN 00078247-00078264 (ភាសាអង់គ្លេស).

(10) បទសម្ភាសន៍របស់ ញ៉ែម អេន ដោយ Peter Maguire, ចុះថ្ងៃទី3 ខែកុម្ភៈ ឆ្នាំ2000, D61/I, ERN 00002558-00002569 (ភាសាអង់គ្លេស).

(11) បទសម្ភាសន៍របស់ ញ៉ែម អេន ដោយ Nic DUNLOP, ចុះថ្ងៃទី25 ខែមករា ឆ្នាំ2001 និងថ្ងៃទី20 ខែធ្នូ ឆ្នាំ2002 D61/I, ERN 00171155-00171358 (ភាសាអង់គ្លេស).

(12) បទសម្ភាសន៍អន្តរជាតិរបស់ ញ៉ែម អេន ចុះថ្ងៃទី12 ខែមិនា ឆ្នាំ1997, ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 19.125, ERN 00078247-00078264 (ភាសាអង់គ្លេស)

(13) បទសម្ភាសន៍របស់ ញ៉ែម អេន ក្នុង *Pol Pot et les Khmers Rouges* ខ្សែភាពយន្តរបស់ ARTE, គ្មានកាលបរិច្ឆេទ, D69, ERN V 00172512.

(14) បទសម្ភាសន៍អន្តរជាតិរបស់ ញ៉ែម អេន ក្នុង *Pol Pot, Journey to the Killing Fields* ខ្សែភាពយន្តរបស់ TVK, គ្មានកាលបរិច្ឆេទ, D69, ERN V 00172603.

(15) បទសម្ភាសន៍អន្តរជាតិរបស់ ញ៉ែម អេន ក្នុង *Khmer Rouge History of Genocide* ខ្សែភាពយន្តរបស់ Pierre-Andre BOUTANG ឆ្នាំ 2001, D69, ERN V 00172506.

(16) **បទសម្ភាសន៍អន្តរជាតិរបស់ ញ៉ែម អេន ក្នុងខ្សែភាពយន្ត** *Inside Pol Pot's Secret Prison* **ដោយ** Bill BRUMMEL **ចុះថ្ងៃទី** 4 July 2000, D69, ERN V 00172525.

## ឯកសារពាក់ព័ន្ធ

23. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធនៅពេលជំនុំជម្រះ។

## 20. ញេប ហូ

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ។ ទាក់ទងនឹង ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ឃុំក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនខុសច្បាប់ និងភាពខ្វះការជំនុំជម្រះយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការរងការឈឺចាប់យ៉ាងខ្លាំង ការប្រព្រឹត្តអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [new]),* និងការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត ការសម្លាប់អ្នកជាប់ឃុំដោយចេតនា *(107-128, 138, 139-140, 151 & 152 [new])*។ ភស្តុតាងរបស់គាត់ជាប់ទាក់ទងនឹងបទចោទទី១ ទី២ និងទី២ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ៥៥ឆ្នាំ សញ្ជាតិខ្មែរ ភេទប្រុស និងកើតនៅឆ្នាំ១៩៥៣។ សាក្សីបានរៀនរហូតដល់ថ្នាក់ទី៨ និងក្រោយមកជួយឪពុកម្តាយរបស់គាត់រហូតដល់ឆ្នាំ១៩៧៤។ នៅឆ្នាំ១៩៧៤ គាត់ត្រូវបាន "គេបង្ខំឱ្យចូលបម្រើបដិវត្តន៍ប៉ុលពត"[774]។ គាត់បានព្យាយាមលួចរត់ ប៉ុន្តែគាត់ត្រូវបានគេចាប់ខ្លួន និងដាក់ក្នុងមន្ទីរឃុំឃាំងអស់រយៈពេល៥ខែ មុនពេលគាត់ត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ដោយសារតែមានការធានាពីប្អូនប្រុសរបស់គាត់ដែលជាយោធាម្នាក់របស់ តា ណាត[775]។ ក្រោយមក គាត់ត្រូវបានគេយកទៅភូមិព្រៃស ស្រុកកណ្តាលស្ទឹង និងស្ថិតនៅក្នុងកងសេដ្ឋកិច្ចលេខ១១២[776]។ គាត់បានទៅធ្វើការជាអ្នកយាមអ្នកទោសនៅ ស-២១ នៅខែមីនា ឆ្នាំ១៩៧៧ ដែលគាត់បានធ្វើការនៅទីនោះរហូតដល់បែករបបនេះ[777]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងថា នៅពេលរត់ចេញពីភ្នំពេញ គាត់និងបុគ្គលិក ស-២១ ផ្សេងទៀត ត្រូវបានពួកវៀតណាមដេញបាញ់[778]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីផ្តល់ភស្តុតាងថា **ឌុច** គឺជា "ប្រធានធំ" នៅ ស-២១។ **ឌុច** ជារឿយៗមកជួបនឹង ហ៊ (HOR) ប៉ុន្តែ សាក្សីបាននិយាយថា "គាត់មិនមកអគារ"ទេ[779]។

5. **ឌុច** បានហៅអ្នកយាមឱ្យមកប្រជុំស្តាប់ការណែនាំនៅក្បែរផ្ទះរបស់គាត់ ដែលគាត់បាននិយាយយ៉ាងក្លៀវក្លាអំពីបដិវត្តន៍ និងភាពសំខាន់ចាំបាច់នៃការយាមឱ្យបានត្រឹមត្រូវ[780]។ "ច្បាប់របស់ ឌុច" គឺថា ម្នាក់ត្រូវតែដឹងអំពីការងាររបស់ខ្លួនតែប៉ុណ្ណោះ[781]។ **ឌុច** បាននាំកងកម្លាំងរបស់ខ្លួនចូលធ្វើការនៅក្នុង ស-២១ បន្ថែមលើកម្លាំងរបស់ ណាត ហើយ **ឌុច** ហាមឃាត់មិនឱ្យទាក់ទងជាមួយកងកម្លាំងរបស់ ណាត ណាមួយទេ[782]។ អ្នកសួរចម្លើយដែលទៅប្រមូលយកអ្នកទោសមុនពេលសួរចម្លើយ "គឺជាមនុស្សរបស់ **ឌុច**"[783]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងថា អ្នកយាមត្រូវបានគេបែងចែកដោយយោងតាមពួកគេយាមនៅផ្នែកខាងក្នុង ឬនៅផ្នែកខាងក្រៅ[784]។ អ្នកយាមនៅផ្នែកខាងក្នុងត្រូវបានគេបែងចែកចេញពីដប់ក្រុម[785]។ ក្រុមអ្នកយាមធ្វើការប្តូរវេនគ្នា និងដូរគ្នាទៅបត់ជើងម្នាក់ម្តងនៅពេលថ្ងៃ[786]។ សាក្សីទទួលបន្ទុកយាមអគារខាងជើងនៅខាងស្តាំដៃ (សាក្សីបានបញ្ជាក់ថាជាអគារ គ)[787]។ អ្នកទោសដែលត្រូវបានគេសួរចម្លើយ និងអ្នកទោសដែលរង់ចាំគេសួរចម្លើយ ត្រូវបានដាក់នៅជាន់ផ្សេងគ្នា[788]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

7. សាក្សីផ្តល់ភស្តុតាងថា **ឌុច** គឺជា "ប្រធានធំ" នៅ ស-២១ ហ៊ គឺជាអនុប្រធានគាត់ និង ហ៊ុយ នៅព្រៃស គឺជាសមាជិកម្នាក់[789]។ សាក្សីបានពោលថា អ្នកសួរចម្លើយទាំងអស់ដែលមកយកអ្នកទោសពីបន្ទប់ឃុំឃាំង គឺជា "មនុស្សរបស់ ឌុច ទាំងអស់"[790]។ សាក្សីបានស្គាល់ឈ្មោះ ប៉ូច, ថៃ, ផូ, ស្រេង, អេង, ស្រ៊ុ ដែលអ្នកទាំងនេះជាអ្នកយាមផ្នែកខាងក្នុងទាំងអស់។ ហ៊ុយ, ម៉ន និង ស្រ៊ឹម នៅក្រុមផ្នែកខាងក្រៅ ដែលអ្នកទាំងនោះជាអ្នកចាប់ និងនាំយកអ្នកទោសចេញ និងពួកគេឈរជើងនៅប្រឡាយលូនៅទិសខាងលិច[791]។ បងប្រុសរបស់សាក្សីឈ្មោះ ប៉េង ក៏ធ្វើការនៅ ស-២១ ប៉ុន្តែក្រោយមក គាត់បានស្លាប់[792]។ សាក្សីស្គាល់ឈ្មោះ ចាន់[793]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

8. សាក្សីផ្តល់ភស្តុតាងថា គាត់បានឃាមបន្ទប់ឃុំឃាំងដែលដាក់អ្នកទោសស្រីៗ និងកូនក្មេង និងបាននិយាយថា អ្នកទោសប្រុសៗត្រូវបានដាក់ក្នុងបន្ទប់ឃុំឃាំងដាច់ពីគ្នា។ សាក្សីបានកត់សម្គាល់ថា កន្លែងដែលគាត់យាម មានអ្នកទោសប្រមាណ៨០នាក់[794] ប៉ុន្តែនៅក្នុងអគារដែលគាត់យាម មិនមានអ្នកទោសបរទេសទេ[795]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

9. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសត្រូវបានគេឱ្យបន្ទោបង់នៅក្នុងកេះដាក់គ្រាប់កាំភ្លើង[796]។ ពួកអ្នកទោសមានសភាពស្គមស្គាំង ពីព្រោះពួកគេមិនមានអាហារហូបគ្រប់គ្រាន់និងត្រូវបានគេធ្វើទារុណកម្ម[797] និងមិនមានសម្លៀកបំពាក់គ្រប់គ្រាន់ ដោយសារតែខោអាវរបស់គាត់ ត្រូវបានរហែកនៅពេលធ្វើទារុណកម្ម[798]។ អ្នកទោសត្រូវបានគេឱ្យអង្គុយចុះ និងបាញ់ទឹកទុយយោឱ្យងូតចំនួន២ដង ក្នុងមួយថ្ងៃ នៅកន្លែងពួកគេដេកតែម្តង[799]។

## ការសួរចម្លើយ

10. សាក្សីផ្តល់ភស្តុតាងថា អ្នកសួរចម្លើយបានមកបន្ទប់ឃុំឃាំងដែលយាមដោយអ្នកយាមគុក ដើម្បីមកនាំអ្នកទោសទៅកន្លែងផ្សេងគ្នាដើម្បីសួរចម្លើយ[800]។ សាក្សីផ្តល់ភស្តុតាងថា អ្នកទោសដែលត្រូវសួរចម្លើយត្រូវយកឡើងទៅខាងលើ និងអ្នកទាំងនោះអាចត្រូវបានគេសួរចម្លើយម្តងទៀត[801]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

11. សាក្សីផ្តល់ភស្តុតាងថា "អ្នកទោសមួយរយភាគរយត្រូវបានគេធ្វើទារុណកម្ម"[802]។ សាក្សីផ្តល់ភស្តុតាងថា គាត់បាននិយាយជាមួយសាក្សីជាច្រើន ដែលអ្នកទាំងនោះត្រូវបានគេធ្វើទារុណកម្ម និងវាយដំយ៉ាងខ្លាំង[803]។ គាត់បានលឺអ្នកទោសទ្រហ៊ូស្រែកហោយំ[804]។ អ្នកទោសមានរូបរាងកាយស្គមកំព្រឹង ដោយសារតែមិនមានអាហារបរិភោគគ្រប់គ្រាន់ និងត្រូវបានគេធ្វើទារុណកម្ម[805]។ គាត់មានស្នាមរំពាត់នៅលើរូបរាងកាយរបស់អ្នកទោស និងជារឿយអាវរបស់អ្នកទោសរហែកជាចំណែកៗ ដោយសារតែពួកគេត្រូវបានគេវាយដំយ៉ាងធ្ងន់ធ្ងរ[806]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

12. សាក្សីនិយាយថា នៅពេលបែកភ្នំពេញ ក្រុមរបស់ ហ៊ុយ បានយកឡានធំៗដឹកអ្នកទោសទាំងអស់ចេញ ប៉ុន្តែគាត់មិនបានដឹងអំពីកន្លែងដែលគេដឹកអ្នកទោសទៅនោះទេ។ ក្រោយមកប្រហែលដប់ថ្ងៃ អ្នកទោសទាំងអស់ត្រូវបានគេដឹកចេញទៅអស់។ អ្នកទោសនៅអគារ ក ត្រូវបានអ្នកយាមសម្លាប់នៅក្នុងបន្ទប់ឃុំឃាំង មុនពេលអ្នកយាមរត់ចេញ[807]។

## សក្ខីកម្មមុនៗ

13. សាក្សីបានផ្តល់ចម្លើយកសិណសាក្សីពីមុនចំនួនបួន ទៅឲ្យសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ ញ្ញេប ហូ ដោយ DC-Cam ចុះថ្ងៃទី11 ខែសីហា ឆ្នាំ2003, ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 19.126, ERN 00052075-00052093 (ភាសាខ្មែរ) (សង្ខេបជាភាសាអង់គ្លេស ERN 00183932-00183934)

(2) ប្រវត្តិរូបមន្ទីរស-២១របស់ ញ្ញេប ហូ, គ្មានកាលបរិច្ឆេទ, ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 19.126, ERN 00051618-00051633 (ភាសាខ្មែរ) (សង្ខេបជាភាសាអង់គ្លេស ERN 00183932-00183934).

(3) បទសម្ភាសន៍របស់ ញ្ញេប ហូ ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី19 ខែតុលា ឆ្នាំ2007, D22/10, ERN 00162693-00162705 (ភាសាអង់គ្លេស).

(4) បទសម្ភាសន៍របស់ ញ្ញេប ហូ ក្នុងអត្ថបទ "ការជួបជុំគ្នាឡើងវិញរបស់អតីតយុទ្ធជន មន្ទីរស-២១" ដោយ ហ៊ុយ វណ្ណៈ ក្នុងទស្សនាវដ្តី *ស្វែងរកការពិត* របស់ DC-Cam, លេខ 31, កក្កដា 2002, D5/2, ERN 00104911-00104912 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

14. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធនៅពេលជំនុំជម្រះ។

## 21. ប៉េស ម៉ាត់

### ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងគោលនយោបាយនិងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹង ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ឃុំក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនខុសច្បាប់ ភាពខ្វះការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* និងការធ្វើឱ្យទៅជាទាសករ ការឈឺចាប់យ៉ាងខ្លាំង និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [new])* និងការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត និងការមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [new])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុប្រហែល១៥ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ សាក្សីមានសញ្ជាតិខ្មែរ ភេទប្រុស និងកើតនៅឆ្នាំ១៩៦០។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច គាត់ត្រូវបានគេ "ប្រមូល" ជាមួយកូនក្មេងរួមមាន ម៉ក់ ស៊ីធីម ដែលគាត់ធ្លាប់បានទៅរៀននៅសាលា និងបាននាំពួកគាត់មកភ្នំពេញ។ នៅចុងឆ្នាំ១៩៧៥ គាត់បានសិក្សានៅ "សាលាបច្ចេកទេសយោធាលេខ៧០៣"[808]។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ ក្រុមរបស់គាត់ត្រូវបានគេជ្រើសរើសឱ្យទៅយាមអ្នកទោសនៅមន្ទីរពេទ្យចិត្តសាស្ត្រនៅតាខ្មៅ។ នៅចុងឆ្នាំ១៩៧៦ គាត់បានចាប់ផ្តើមធ្វើការងារនៅ ស-២១ ដែលជាកន្លែងគាត់ធ្វើការងារជាអ្នកយាមផ្នែកខាងក្នុង និងផ្នែកខាងក្រៅ រហូតដល់បែកភ្នំពេញនៅឆ្នាំ១៩៧៩[809]។

### ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងថា អ្នកយាមដូចគាត់ បានប្រាប់គាត់អំពីសង្គ្រាមរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម និងប្រាប់អំពីការចាប់ខ្លួនជនជាតិវៀតណាមពីព្រំដែនព្រៃវែង និងស្វាយរៀង។ គាត់ក៏បានឮ

តាមវិទ្យុអំពីសង្គ្រាម និងការចាប់ខ្លួនជនជាតិវៀតណាមនៅបន្ទប់បរិភោគអាហារ ទោះបីជា **ឌុច** មិនដែលលើកឡើងអំពីសង្គ្រាមក្នុងពេលប្រជុំក្តី[810]។ សាក្សីផ្តល់ភស្តុតាងថា នៅឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ គាត់បានឃើញអ្នកទោសជនជាតិវៀតណាមពីរបីនាក់នៅ ស-២១ ស្លៀកពាក់ឯកសណ្ឋានយោធា។ ពួកគេត្រូវបានគេដាក់ខ្នោះជើង និងពីរបីថ្ងៃក្រោយមក គាត់បានឃើញជនជាតិវៀតណាមទាំងនោះមានរបួស ដូច្នេះគាត់សន្និដ្ឋានថា ពួកគេត្រូវបានគេវាយដំ និងធ្វើទារុណកម្ម។ ក្រោយមក ពួកទាំងនោះបានបាត់ខ្លួន។ សាក្សីក៏បានឃើញស្ត្រីជនជាតិវៀតណាមពីរបីនាក់នាក់ក្នុងសម្លៀកបំពាក់ជាជនស៊ីវិល[811]។ អ្នកទោសជនជាតិវៀតណាម និងជនជាតិកម្ពុជា ត្រូវបានគេប្រព្រឹត្តតាមវិធីដូចគ្នា[812]។

## វេទនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ

4. សាក្សីផ្តល់ភស្តុតាងថា មានសាលានយោបាយមួយនៅខាងលិចមន្ទីរឃុំឃាំង ដែលចូលរៀនដោយមនុស្សជាច្រើន ដែល **ឌុច** បានចូលរួមដែរ ដែលនៅទីនោះ ពួកគេបានសិក្សាអំពី "ទស្សនៈដ៏ខ្លាំង" និងមិនចូលរួមគំនិតក្បត់ជាមួយវៀតណាម[813]។ នៅក្នុងកិច្ចប្រជុំមួយ មេក្រុមរបស់សាក្សី បានបង្រៀនថា ពួកគេ ពួកគេគួរជូនដំណឹងឲ្យអ្នកគ្រប់គ្នា ដែលជា"សកម្មជន" ឬប្រើទៅមនុស្សមិនស្គាល់ អំពីបញ្ហាដែលដាក់ចេញមកពីថ្នាក់លើ។ ក្រោយមក មេរបស់គាត់ពីរនាក់ឈ្មោះ នី និង ពូច ត្រូវបានគេចោទប្រកាន់ពីបទក្បត់ជាតិ[814]។ សាក្សីផ្តល់ភស្តុតាងថា គាត់បានឃើញប្រធានក្រុម និងប្រធានកង អាន *ទង់បដិវត្តន៍* ទោះបីជាខ្លួនគាត់មិនដែលអានក៏ដោយ[815]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីផ្តល់ភស្តុតាងថា គាត់បានជួបជាមួយ ឌុច តែម្តងនៅក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាល ដែលនៅពេលនោះ **ឌុច** បាននិយាយអំពី បង្រៀននៅសាលានយោបាយនៅទិសខាងលិចមន្ទីរឃុំឃាំង[816]។ ផ្សេងពីនេះ សាក្សីគ្រាន់តែបានឃើញ **ឌុច** ពីចម្ងាយពេលគាត់បានបើកឡានម៉ាកហ្ស៊ីបរបស់គាត់[817]។ សាក្សីផ្តល់ភស្តុតាងថា គាត់មិនដែលបានឃើញ **ឌុច** បែងចែកការងារដោយផ្ទាល់នៅក្នុងមន្ទីរឃុំឃាំងដោយផ្ទាល់ ឬនៅពេលអ្នកទោសត្រូវបាននាំចេញទេ[818]។ សាក្សីផ្តល់ភស្តុតាងថា **ឌុច** មិនដែលនិយាយអ្វីទាក់ទងនឹងសង្គ្រាមវៀតណាមនៅក្នុងកិច្ចប្រជុំនោះទេ[819]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងថា គាត់មានភារកិច្ចយាមនៅក្បែរគ្លីនិកស្ថិតនៅពីមុខ ស-២១ ដែលជាកន្លែង ម៉ក់ ស៊ីធីម ធ្វើការងារជាគ្រូពេទ្យ និងលាងរបួស[820]។ ទោះបីជាគាត់មិនដែលឃើញគេបូមយកឈាម ឬយកមនុស្សទៅពិសោធន៍ក្តីដោយផ្ទាល់ ប៉ុន្តែសាក្សីត្រូវបានអ្នកយាមដូចគ្នាប្រាប់ថា ឈាមត្រូវយកមកចាក់បញ្ចូលចំពោះអ្នកមានរបួស និងឈាមត្រូវបានគេរក្សាទុកនៅកន្លែងដែលគេហៅថាស្រះស្រង់[821]។

7. សាក្សីផ្តល់ភស្តុតាងថា គាត់បានទទួលការងាររបស់គាត់ពីមេក្រុមរបស់គាត់ឈ្មោះ ហេង។ កិច្ចប្រជុំធ្វើឡើងម្តងក្នុងមួយសប្តាហ៍ ដោយ ប៉េង ជាអ្នកធ្វើបទបង្ហាញ ដែលនៅកន្លែងនោះ សាក្សីត្រូវបានរៀនសូត្រអំពីនយោបាយ[822]។ សាលានយោបាយមួយស្ថិតនៅខាងលិចមន្ទីរឃុំឃាំង ដែលមានមនុស្សជាច្រើនចូលរៀន ដែលក្នុងនោះ ឌុច បានចូលរួមផងដែរ។ សាលានយោបាយនេះ បង្រៀនអំពីការមាន“ទស្សនៈរឹងមាំ” និងមិនសមគំនិតជាមួយវៀតណាម[823]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

8. សាក្សីផ្តល់ភស្តុតាងថា **ឌុច** ម៉ម ណៃ ហៅ ចាន់ និង ហ៊ី គឺជាប្រធាន អនុប្រធាន និងសមាជិករៀងៗខ្លួន និងអ្នកទាំងនេះ “ជិតស្និតនឹងគ្នា”[824]។ ហេងគឺជាមេក្រុមរបស់សាក្សី និងនៅពីលើ ហេង មាន នី, ពូច, ប៉េង, ហ៊ី និងបន្ទាប់មក ចាន់ និង **ឌុច**[825]។

9. សាក្សីផ្តល់ភស្តុតាងថា មេក្រុមរបស់គាត់បានប្រាប់ពួកគាត់ឲ្យរាយការណ៍អំពីអ្នកណាជាសកម្មជន និងអ្នកណានិយាយជាមួយជនមិនធ្លាប់ស្គាល់[826]។ សាក្សីផ្តល់ភស្តុតាងថា គាត់ជឿជាក់ថា បទបញ្ជានេះចេញដោយ “ថ្នាក់លើ” [827]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

10. សាក្សីផ្តល់ភស្តុតាងថា ទោះបីជាគាត់មិនដែលឃើញអ្នកទោសបរទេសក្តី[828] ប៉ុន្តែគាត់បានឃើញជនជាតិវៀតណាមពីរបីនាក់ស្លៀកឯកសណ្ឋានយោធា និងជនជាតិវៀតណាមស្រីម្នាក់មានសម្លៀកបំពាក់ស៊ីវិល[829]។ សាក្សីផ្តល់ភស្តុតាងថា មេរបស់គាត់ពីរនាក់ ឈ្មោះ នី និង ពូច ត្រូវបានចោទប្រកាន់ជា “ខ្មាំង” ហើយចោទពីបទជនក្បត់ និងមិនដែលបានឃើញគាត់ទៀតទេ[830]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

11. សាក្សីផ្តល់ភស្តុតាងថា ទោះបីជាគាត់មិនដែលឃើញការបូមយកឈាម ឬការពិសោធន៍មនុស្សដោយផ្ទាល់ក្តី ប៉ុន្តែអ្នកយាមដូចគាត់ បានប្រាប់គាត់ថា ការបូមយកឈាមគឺសម្រាប់បញ្ចូលឱ្យអ្នកមានរបួស ហើយឈាមត្រូវបានគេរក្សាទុកនៅស្រះស្រង់ ប៉ែកខាងកើតនៃ ស-២១[831]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

12. សាក្សីផ្តល់ភស្តុតាងថា គាត់បានឃើញជនជាតិវៀតណាមពីរបីនាក់ជាប់ខ្នោះជើង និងត្រូវរបួស ដូច្នេះគាត់សន្និដ្ឋានថា អ្នកទាំងនោះត្រូវបានគេវាយ និងធ្វើទារុណកម្ម[832]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

13. សាក្សីផ្តល់ភស្តុតាងថា គាត់មិនដែលបានឃើញអ្នកទោស ដែលពួកទាំងនោះបានបាត់ខ្លួនរហូត[833]។ សាក្សីផ្តល់ភស្តុតាងថា គាត់មិនដែលឃើញអ្នកទោសត្រូវបានគេសម្លាប់ជាក្រុមនោះទេ មុនពេលបែកភ្នំពេញឆ្នាំ១៩៧៩[834]។

## សក្ខីកម្មមុនៗ

14. សាក្សីផ្តល់សក្ខីកម្មពីមុនចំនួនមួយឱ្យទៅសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ ប៉េស ម៉ាត់ ដោយ ក.ស.ច.ស ចុះថ្ងៃទី18 ខែមីនា ឆ្នាំ2008, D76/2, ERN 00195706-00195710 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

15. សាក្សីនឹងបង្ហាញឯកសារពាក់ព័ន្ធនៅពេលជំនុំជម្រះ។

## 22. ប្រាក់ ខន

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងអំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* ប្រភេទនៃការវាយប្រហារជាទូទៅ ឬជាប្រព័ន្ធលើប្រជាជនស៊ីវិល *(10-18 & 131-133)* រចនាសម្ព័ន្ធ និងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹង ស-២១ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធរដ្ឋអំណាច *(20-25)* ការដាក់ឃុំក្នុងមន្ទីរឃុំឃាំង ការឃុំខ្លួនខុសច្បាប់ ភាពខ្វះការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការធ្វើឱ្យទៅជាទាសករ ការឈឺចាប់យ៉ាងខ្លាំង អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [new])* និងការសម្លាប់បំផុតពូជ ការធ្វើមនុស្សឃាត និងការធ្វើមនុស្សឃាតដោយចេតនា *(107-128, 138, 139-140, 151 & 152 [new])*។ ភស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងបទចោទទី១ ទី២ និងទី៣ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ២៤ឆ្នាំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ គាត់មានសញ្ជាតិកម្ពុជា ភេទប្រុស កើតនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៥១[835]។ ដំបូង សាក្សីបានចូលរួមជាមួយបដិវត្តន៍តាមរយៈការអំពាវនាវរបស់ព្រះអង្គម្ចាស់សីហនុ ដែលគាត់បានក្លាយជាយោធិនឃុំម្នាក់ចាប់ពីឆ្នាំ១៩៧៣ និងក្រោយមកក្លាយជាយុទ្ធជនម្នាក់នៅក្នុងកងកាំភ្លើងធំរបស់កងពលធំលេខ៧០៣។ គាត់ត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅ ស-២១ នៅចុងឆ្នាំ១៩៧៥ ដែលដំបូងឡើយគាត់ធ្វើជាអ្នកយាមនៅផ្នែកខាងក្រៅ[836]។ បន្ទាប់ពីធ្វើការក្នុងតួនាទីនេះអស់រយៈពេលបីឬបួនខែ គាត់បានផ្លាស់ទៅធ្វើការនៅផ្នែកខាងក្នុង ដែលគាត់បានក្លាយជាអ្នកសួរចម្លើយក្នុង "ក្រុមអង្កៀម"[837]។ គាត់បានធ្វើជាអ្នកសួរចម្លើយនៅ ស-២១ រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ចម្លើយសារភាពដែលនៅសេសសល់ចំនួន៥៦ មានមានសរសេរឈ្មោះសាក្សីជាអ្នកសួរចម្លើយ។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងថា ប៉ុល ពត បានប្រកាសវាយប្រយុទ្ធនឹងវៀតណាម ដែលចាប់ផ្តើមឡើងកាលពីដើមខែឧសភា ឆ្នាំ១៩៧៥។ គាត់បានផ្តល់ភស្តុតាងថា អ្នកទោសសង្គ្រាមជនជាតិវៀតណាមត្រូវបានគេនាំទៅ ស-២១ ចាប់តាំងពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩ ដើម្បីធ្វើការសួរចម្លើយ ហើយគាត់បានលឺចម្លើយសារភាពរបស់ទាហានវៀតណាមផ្សាយតាមវិទ្យុជារៀងរាល់ថ្ងៃ[838]។ អ្នករបួសដោយសារសង្គ្រាម ត្រូវបានគេដឹកមកភ្នំពេញ និងត្រូវការឈាមជាច្រើនដើម្បីបញ្ចូល ដែលឈាមទាំងនោះបូមពីអ្នកទោសនៅ ស-២១[839]។

## ជាទូទៅ ឬជាប្រព័ន្ធ

4. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសត្រូវបានគេនាំមក ស-២១ ពីគ្រប់ទិសទីទាំងអស់ក្នុងផ្ទៃប្រទេស[840]។

## រចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

5. សាក្សីផ្តល់ភស្តុតាងថា **ឌុច** និង សុន សេន បានបង្រៀនវគ្គទ្រឹស្តី និងនយោបាយមួយលើក ឬពីរលើកក្នុងមួយឆ្នាំ[841]។

## តួនាទីរបស់ជនជាប់ចោទ

6. សាក្សីផ្តល់ភស្តុតាងថា នៅពេលគាត់ចូលរួមក្នុងកងសួរចម្លើយ គាត់បានដឹងថា **ឌុច** គឺជាប្រធាន ស-២១[842] និងបានដឹងថា គាត់ជាអ្នកគ្រប់គ្រងលើប្រតិបត្តិការសួរចម្លើយ[843]។ **ឌុច** បានដើរពិនិត្យមើលជុំវិញ ស-២១ ដោយមានកាន់កាំភ្លើងមួយដើម[844]។ កងពិសេសយាមនៅផ្ទះរបស់ **ឌុច**[845]។

7. សាក្សីផ្តល់ភស្តុតាងថា **ឌុច** បានកោះប្រជុំវគ្គបណ្តុះបណ្តាលដល់បុគ្គល ស-២១ នៅផ្ទះរបស់គាត់ "ជារៀងរាល់សប្តាហ៍ ឬពីរសប្តាហ៍ម្តង" ដែលនៅក្នុងការប្រជុំនោះ គាត់បានណែនាំអ្នកសួរចម្លើយដោយផ្ទាល់ ជាទ្រឹស្តី និងអនុវត្តអំពីរបៀបធ្វើទារុណកម្ម[846]។ មុនពេលចាប់ផ្តើមការសួរចម្លើយ **ឌុច** បានផ្តល់ការណែនាំ ពេលខ្លះណែនាំដោយផ្ទាល់ និងពេលខ្លះតាមរយៈទូរសព្ទ[847]។ តាមរយៈនៃការសួរចម្លើយដោយផ្ទាល់[848] ពេលខ្លះ **ឌុច** បានចូលប្រឡូកក្នុងការសួរចម្លើយរបស់សាក្សី ដោយគាត់សួរចម្លើយប្រហែលកន្លះម៉ោង និងបានចាកចេញទៅបាត់[849]។ សាក្សីផ្តល់ភស្តុតាងថា **ឌុច** បានដើរពិនិត្យគ្រប់កន្លែងសួរចម្លើយជាទៀតទាត់ ដែលនៅពេលខ្លះគាត់សួរចម្លើយលើចំណុចពិសេសមួយចំនួន និងពេលខ្លះទៀត

"បានទាត់អ្នកទោសមួយជើង ឬពីរជើងទៀតផង"[850]។ សាក្សីបានឃើញ **ឌុច** សួរចម្លើយអ្នកទោសជនជាតិអូស្ត្រាលី និងអាមេរិក ដែលម្នាក់ឈ្មោះ David SCOTT ត្រូវបាន **ឌុច** ទាត់។ **ឌុច** និង ចាន់ បានសួរចម្លើយជនបរទេសជាសាធារណៈពីព្រោះគ្មាននរណាយល់ទេ [851]។

8. **ឌុច** បានចេញបញ្ជាដោយផ្ទាល់ឱ្យធ្វើការសួរចម្លើយ ពេលខ្លះចេញបញ្ជាដោយផ្ទាល់មាត់ និងពេលខ្លះជាលាយលក្ខណ៍អក្សរ[852]។ បញ្ជាទាំងនេះត្រូវតែអនុវត្តឱ្យបានម៉ត់ចត់[853]។ សាក្សីផ្តល់ភស្តុតាងថា **ឌុច** ត្រូវបានធ្វើទារុណកម្មលើអ្នកទោសដោយផ្ទាល់ តាមរយៈការវាយដំ និងការឆក់ខ្សែភ្លើង[854]។ នៅក្នុងឧប្បត្តិហេតុម្តងនោះ សាក្សីបានឃើញ **ឌុច** ជាមួយ ចាន់, ទិត, ហេដក ប៊ូ, ម៉េង និង ប៉ុន បានធ្វើទារុណកម្មជាបន្តបន្ទាប់លើស្ត្រីម្នាក់ នៅពេលស្ត្រីនោះមិនបានផ្តល់ "ព័ត៌មានសំខាន់"ដល់ **ឌុច**[855]។ សាក្សីបានឃើញ ឌុច និងអ្នកផ្សេងទៀតសើចនៅពេលពួកគេកំពុងធ្វើទារុណកម្ម[856]។ សាក្សីជឿជាក់ថា **ឌុច** ដឹងថា ចម្លើយសារភាពប្រហែលជាមិនពិតទេ ប៉ុន្តែគាត់មិនយកចិត្តទុកដាក់ទេ ពីព្រោះ "គាត់ជាមនុស្សឆ្កួតនឹងសង្គ្រាម និងធ្វើបាបប្រជាជន[857]។

9. សាក្សីផ្តល់ភស្តុតាងថា **ឌុច** វិន័យយ៉ាងតឹងរឹងចំពោះបុគ្គលិករបស់ខ្លួន។ ការខកខានក្នុងការគោរពបទបញ្ជា អាចធ្វើឱ្យបាត់ខ្លួន "ដែលមានន័យថា ត្រូវបានដាក់ឃុំក្នុងមន្ទីរឃុំឃាំង និងចុងក្រោយត្រូវបានសម្លាប់ចោល"[858]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

10. សាក្សីផ្តល់ភស្តុតាង ស-២១ បានចាប់ផ្តើមដំណើរការយ៉ាងហោចណាស់ចាប់ពីចុងឆ្នាំ១៩៧៥ ដែលត្រូវបានផ្លាស់ពីអតីតជាគុកប៉េហ្ស៊ី នៅលើផ្លូវលេខ៥១ ប្តូរទៅដាក់នៅអគារទួលស្លែង។ សាក្សីផ្តល់ភស្តុតាងថា អ្នកជិតស្និតនឹង ឌុច ភាគច្រើនជាអ្នកមានបទពិសោធន៍ធ្វើការពីមុនជាមួយគាត់នៅ ម-១៣ នៅក្នុងភូមិពិសេស ក្នុងអំឡុងសង្គ្រាមប្រឆាំងនឹងរបបលន់ ណុល[859]។ សាក្សីផ្តល់ភស្តុតាងថា បរិវេណរបស់ ស-២១ មានទីតាំងធំជាងសារមន្ទីរសព្វថ្ងៃនេះ ដែលខាងលិចទល់វត្តមហាមន្ត្រី ខាងត្បូងទល់នឹងវត្តទួលទំពូង និងខាងលិចទល់នឹងផ្លូវមុន្នីវង្ស[860]។

11. សាក្សីផ្តល់ភស្តុតាងថា ផ្នែកកងការពារផ្នែកខាងក្រៅរបស់ ស-២១ បានធ្វើការងារប្តូរវេនគ្នាយាមពីដង ចាប់ពីម៉ោង១២ថ្ងៃ រហូតដល់ម៉ោង១២ថ្ងៃត្រង់[861]។ អ្នកយាមមានចំនួនប្រហែល១០០០នាក់នៅ ស-

២១[862]។ សាក្សីផ្តល់ភស្តុតាងថា នៅពេលគាត់ធ្វើការជាអ្នកយាមផ្នែកខាងក្រៅ គាត់បានឃើញឡាន ស-២១ បើកចេញទៅប្រមូលអ្នកទោសក្រោមការគ្រប់គ្រងរបស់ "ប្រធានថ្នាក់ទាប" ឈ្មោះ ហ៊ឹម ហ៊ុយ និង ផេក ប៊ូ[863]។ សាក្សីផ្តល់ភស្តុតាងថា អ្នកទោសជាន់ខ្ពស់ត្រូវបានគេឃុំនៅអគារ ក និងនៅផ្ទះជាន់ទីពីរ ឬទីបីនៅទិសខាងកើត ដែលក្រោមការត្រួតពិនិត្យរបស់ **ឌុច** និង ប៉េង ។ អគារ ខ, គ និង ឃ គឺគ្រាន់តែស្ថិតក្រោមការត្រួតពិនិត្យរបស់ ប៉េង [864]។

12. នៅពេលកម្មាភិបាលកងសួរចម្លើយ និងកងការពារនៅ ស-២១ ត្រូវបានគេបោសសម្អាត គេបានយកកម្លាំងរបស់**ឌុច** ពីប៉ែកខាងលិចដែលសុទ្ធតែជាកូនក្មេងពីអាយុ១៣ឆ្នាំដល់១៥ឆ្នាំ មកជំនួសអ្នកត្រូវបានគេបោសសម្អាតទាំងនោះ[865]។

13. សាក្សីផ្តល់ភស្តុតាងថា នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ច្រកចេញចូលរបស់ ស-២១ ត្រូវបានបិទ និងអ្នកទោសទាំងអស់ "ត្រូវបានបោសសម្អាត និងដឹកជញ្ជូនចេញក្រៅ"។ នៅថ្ងៃទី៧ ខែមករា អ្នកទោសនៅសេសសល់ក្នុងអគារ ក "ត្រូវបានកម្ទេចចោលទាំងអស់"[866]។

## រចនាសម្ព័ន្ធរដ្ឋអំណាច

14. សាក្សីផ្តល់ភស្តុតាងថា **ឌុច** ជាអ្នកបញ្ជាលើ ស-២១ទាំងមូល ដែល **ឌុច** ទទួលបញ្ជាពីថ្នាក់លើ និងគាត់ជារឿយៗលើកឡើងអំពី សាឡុត ស (បងធំទីមួយ) និង នួន ជា (បងធំទីពីរ)[867]។ ហ៊ី គឺជាអនុប្រធានទទួលបន្ទុកផ្នែកសន្តិសុខ ការការពារ និងសេដ្ឋកិច្ច។ ហ៊ឹម ហ៊ុយ គឺជាប្រធានកងការពារ ទទួលបន្ទុកចាប់ខ្លួនអ្នកទោស និងបញ្ជូនអ្នកទាំងនោះទៅជើងឯក ព្រមទាំងទទួលបន្ទុកផ្នែកអគារខាងក្រៅផងដែរ[868]។ ម៉ម ណៃ ហៅ ចាន់ ដែលជាសហការីជិតដិតរបស់ **ឌុច** មួយរូប[869] ទទួលបន្ទុកផ្នែកឯកសារ និងការសួរចម្លើយជនបរទេស[870]។ ប៉េង ទទួលបន្ទុកលើអគារទាំងបួននៅ ស-២១[871] ទិត គឺជា "អ្នកដៃស្តាំ" របស់ **ឌុច** និងជាអ្នកត្រួតពិនិត្យការសួរចម្លើយ។ ប៊ុន និង ម៉េង គឺជាអ្នកសួរចម្លើយ ដែលកាលពីមុនពួកគាត់ជាសាស្ត្រាចារ្យ[872] និង សួស ធី ជាអ្នកកត់ត្រាឈ្មោះរបស់អ្នកទោសនៅ ស-២១[873]។ ទ្រី គឺជាប្រធានផ្នែកគ្រូពេទ្យ[874]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

15. សាក្សីផ្តល់ភស្តុតាងថា អ្នកទោសទាំងអស់មានចំនួនសរុប "ច្រើនជាង ១០.០០០នាក់"[875]។ ប្រភេទអ្នកទោសរួមមាន ប្រុស ស្រី យុវជន កូនក្មេង យោធា ជនស៊ីវិល ជនជាតិកម្ពុជា ជនជាតិអាមេរិក ជនជាតិអូស្ត្រាលី ជនជាតិវៀតណាម និងកម្មាភិបាល ស-២១[876]។ ស-២១ គឺជាមន្ទីរឃុំឃាំង "ទូទាំងប្រទេស" ដែលខេត្តទាំងអស់ត្រូវបញ្ជូនអ្នកទោសមក ស-២១។ សាក្សីនឹកឃើញយ៉ាងច្បាស់ថា អ្នកទោសមួយចំនួនត្រូវបានគេបញ្ជូនមកពីខេត្តបាត់ដំបង[877]។ សាក្សីក៏បានចាំថា អ្នកទោសមានផ្ទៃពោះម្នាក់ត្រូវបានគេសួរចម្លើយនៅ ស-២១ ដែលក្រោយមកអ្នកទោសនោះឆ្លងទន្លេកើតកូនប្រុសម្នាក់នៅក្នុងមន្ទីរឃុំឃាំង[878]។ អ្នកទោសខ្លះបានធ្វើអត្តឃាតខ្លួន តាមរយៈការចាក់ខ្លួនឯងដោយប្រើប៊ិច ឬអំបែងកែវ ការដុតខ្លួនឯងដោយចង្កៀង ឬលោតចុះពីអគារ[879]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

16. សាក្សីផ្តល់ភស្តុតាងថា នៅពេលគេមកនាំអ្នកទោស អ្នកទាំងនោះត្រូវបានដាក់ច្រវាក់ជើង ច្រវាក់ដៃ បិទមុខជិត និងចងដៃទាំងទោសទៅខាងក្រោយខ្នង[880]។ សាក្សីបានសន្និដ្ឋានថា អ្នកទោសត្រូវបានគេធ្វើទារុណកម្ម ដោយសារតែគាត់បានឃើញស្នាមលើខ្នងរបស់ពួកគេ និងក្រោយធ្វើទារុណកម្ម ខ្នង និងក្រចកដៃរបស់អ្នកទោសមានរបួសស្នាមរលួយ[881]។ គ្រូពេទ្យនឹងលាងសម្អាត និងរុំស្នាមរបួសនៅក្នុងអំឡុងពេលធ្វើទារុណកម្ម[882]។ អាហាររបស់អ្នកទោសគឺបបរជាមួយកូនចេក ដែលផ្តល់របបឲ្យមួយវែកសម្រាប់ម្នាក់ និងសាក្សីបានសង្កេតឃើញថា នៅក្នុងបន្ទប់នីមួយៗឃុំមនុស្សចំនួន១២នាក់[883]។ សាក្សីផ្តល់ភស្តុតាងថា ជាទូទៅអ្នកទោសត្រូវបានគេយកមកឃុំនៅក្នុងបន្ទប់ទូលាយ[884]។

17. សាក្សីផ្តល់ភស្តុតាងថា គាត់បានដឹងករណីរំលោភមួយករណីប៉ុណ្ណោះ ដែលប្រព្រឹត្តដោយបុគ្គលិកស-២១ ទៅលើអ្នកទោស ដែលករណីនេះកើតនៅក្នុងបន្ទប់សួរចម្លើយជាប់នឹងបន្ទប់ដែលសាក្សីធ្វើការ។ គេបានរកឃើញថា អ្នកសួរចម្លើយម្នាក់ឈ្មោះ ទូច ប្រព្រឹត្ត"ខុសសីលធម៌" ជាមួយអ្នកទោសស្រីម្នាក់ ដូច្នេះគាត់ត្រូវបានចាប់ខ្លួន និងក្រោយមកត្រូវបានសម្លាប់[885]។

## ការសួរចម្លើយ

18. សាក្សីផ្តល់ភស្តុតាងថា ក្រុមសួរចម្លើយមានចំនួនបីក្រុមនៅ ស-២១ គឺ "ក្រុមត្រជាក់" (គ្មានទារុណកម្ម) "ក្រុមក្តៅ" (ប្រើទារុណកម្ម) និង "ក្រុមអង្កៀម" (បន្តធ្វើទារុណកម្ម)[886]។ កន្លែងសួរចម្លើយរបស់ក្រុម

ទាំងបី ស្ថិតនៅជុំវិញខាងក្រៅបរិវេណអគារ[887]។ ជាធម្មតា ការសួរចម្លើយធ្វើឡើងចាប់ពីម៉ោង៧ដល់ម៉ោង១១ព្រឹក ពីម៉ោង២ដល់ម៉ោង៥ព្រឹក និងម៉ោង៧ដល់ម៉ោង១១យប់[888]។

19. សាក្សីផ្តល់ភស្តុតាងថា គាត់បានទទួលឈ្មោះអ្នកទោសត្រូវសួរចម្លើយ តាមបញ្ជារបស់ "ថ្នាក់លើ" តាមរយៈអ្នកនាំសាររបស់ **ឌុច** ឈ្មោះ ឆេន ឬ ចាន់។ សាក្សីបានឱ្យឈ្មោះអ្នកទោសត្រូវសួរចម្លើយឱ្យទៅ សួស ធី ដែលគាត់ពិនិត្យកំណត់ហេតុដើម្បីកំណត់អគារណាមួយដែលអ្នកទោសត្រូវបញ្ជូនឱ្យទៅសួរចម្លើយ។ សួស ធី បានឱ្យលេខបន្ទប់ទៅសាក្សី ដែលគាត់ផ្តល់វាឱ្យទៅកងការពារដើម្បីឱ្យចាក់សោរបន្ទប់ នឹងនាំអ្នកទោសឱ្យសាក្សី។ អ្នកទោសដែលជាប់ខ្នោះដៃ និងបិទមុខជិត ត្រូវបានសាក្សីនាំដើរទៅបន្ទប់សួរចម្លើយ បន្ទាប់មកសាក្សីបានដាក់ច្រវាក់ជើងជាប់នឹងតុ និងដោះខ្នោះដៃចេញ[889]។ នៅពេលបញ្ចប់ការសួរចម្លើយ សាក្សីបានបញ្ជូនឯកសារពេញលេញឱ្យទៅ **ឌុច** ឬ ចាន់ ដែលអ្នកទាំងពីរអាចនឹងបញ្ជាឱ្យធ្វើការសួរចម្លើយឡើងវិញ គូសរង្វង់ជុំវិញកន្លែងសារភាពណាមួយ ប្រសិនបើពួកគេតម្រូវឱ្យសួរចម្លើយបន្ថែមលើសកម្មភាពក្បត់ ឬការជាប់ពាក់ព័ន្ធណាមួយ[890]។ សាក្សីផ្តល់ភស្តុតាងថា គាត់អាចចំណាំអក្សរសរសេរ និងហត្ថលេខារបស់ **ឌុច**[891]។ ឌុច ឬ ចាន់ ជាអ្នកសម្រេចថាតើការសួរចម្លើយបានចប់សព្វគ្រប់ឬមិនទាន់ចប់[892]។ ប្អូនទៅដប់ថ្ងៃក្រោយមក អ្នកទោស "ត្រូវបានយកចេញទៅខាងក្រៅ និងបាត់ខ្លួន"[893] និងរបាយការណ៍នៃការសួរចម្លើយត្រូវបានធ្វើឡើងក្នុងរយៈពេលមួយខែ[894]។ សាក្សីផ្តល់ភស្តុតាងអំពីរបៀប **ឌុច** អង្កេតការសួរចម្លើយ អំពីការយកចម្លើយសារភាពទៅអាន និងអំពីចំណារលើចម្លើយសារភាពឱ្យធ្វើការសួរចម្លើយបន្ថែមទៀត[895]។ **ឌុច** បានចូលកន្លែងអ្នកសួរចម្លើយជាទៀតទាត់[896]។ អ្នកសួរចម្លើយមួយក្រុមផ្សេងទៀតត្រូវបានត្រៀមបម្រុងទុកចំពោះករណីពិសេស ដែលក្នុងក្រុមនោះរួមមាន ប៉ុន, ម៉ម ណៃ, ម៉េង, ទិត, និង **ឌុច** ខ្លួនឯង[897]។ មេដឹកនាំជាន់ខ្ពស់ និងថ្នាក់ធំ ត្រូវបានក្រុមនេះជាអ្នកសួរចម្លើយដែលធ្វើឡើងនៅក្នុងអគារធំ អគារ ក[898]។

20. នៅពេលអ្នកទោសមកដល់ ស-២១ ដំបូង ការសួរចម្លើយធ្វើឡើងគ្រាន់តែទាក់ទងនឹង "ការធ្វើនយោបាយ"។ ប្រសិនបើគ្មាន "លទ្ធផល"ទេ **ឌុច** ឬ ចាន់ បញ្ជាឱ្យអ្នកសួរចម្លើយឱ្យសួរឱ្យជ្រៅបន្ថែមទៀត និងប្រសិននៅតែមិនសារភាពទៀត ពួកគេបញ្ជាឱ្យប្រើប្រាស់ការធ្វើទារុណកម្ម[899]។ គោលបំណងនៃការធ្វើទារុណកម្ម គឺ "យកចម្លើយសារភាពដើម្បីស្រាវជ្រាវបណ្តាញរបស់ពួកគេបន្ថែមទៀត"[900]។

21. ជាធម្មតា អ្នកសួរចម្លើយម្នាក់ សួរចម្លើយអ្នកទោសម្នាក់[901]។ អ្នកទោសដែលចេះអក្សរ និងមានសុខភាពល្អ អាចសរសេរចម្លើយសារភាពដោយខ្លួនឯង បើមិនដូច្នេះទេ អ្នកសួរចម្លើយនឹងសរសេរចម្លើយសារភាពឱ្យអ្នកទោស[902]។ សាក្សីប៉ាន់ប្រមាណថា អ្នកទោសប្រហែលពាក់កណ្ដាលនៅ ស-២១ ត្រូវបានគេសួរចម្លើយ[903]។ ជនដែលមានឈ្មោះជាប់ទាក់ទិននៅក្នុងចម្លើយសារភាព នឹងត្រូវបានគេចាប់ខ្លួន និងនាំមក ស-២១ ដើម្បីសួរចម្លើយ[904]។ ប្រសិនបើអ្នកទោសសន្លប់ដោយសារការធ្វើទារុណកម្មធ្ងន់ធ្ងរ គ្រូពេទ្យនឹងមកព្យាបាលអ្នកទោសនោះបណ្ដោះអាសន្ន បន្ទាប់មកនឹងបន្តការសួរចម្លើយទៀត[905]។

22. សាក្សីផ្ដល់ភស្តុតាងថា **ឌុច** បានរៀបចំវិធានសម្រាប់សួរចម្លើយ[906]។ វិធានទាំងនេះត្រូវបានដាក់នៅលើជញ្ជាំង ស-២១ ឬសរសេរនៅលើក្ដារខៀន និងតែងតែបង្ហាញអ្នកទោសក្នុងអំឡុងពេលសួរចម្លើយ[907]។ សាក្សីរៀនអំពីរបៀបសួរចម្លើយ "នៅពេលធ្វើកិច្ចការនេះ"[908] និងរៀនតាមរយៈវគ្គបណ្ដុះបណ្ដាលដែល **ឌុច** រៀបចំ[909]។

23. ការវិភាគដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្ហាញថា ចម្លើយសារភាពនៅសេសសល់ចំនួន៥៦ មានសរសេរឈ្មោះសាក្សីថាជាអ្នកសួរចម្លើយ[910]។ ក្នុងចំណោមអ្នកដែលគាត់សួរចម្លើយទាំងអស់មាន ជនជាតិខ្មែរចំនួន៤២នាក់ ជនជាតិភ្នងចំនួន៥នាក់ ជនជាតិចិនចំនួន២នាក់ ជនជាតិចាមចំនួនមួយនាក់ និងជនជាតិវៀតណាមចំនួនមួយនាក់[911]។ សាក្សីផ្ដល់ភស្តុតាងថា ពេលខ្លះ គាត់សួរចម្លើយអ្នកទោសរហូតដល់បីខែ ហើយយកចម្លើយសារភាពលើសពីមួយរយទំព័រ[912]។ សាក្សីផ្ដល់ភស្តុតាងថា ឥឡូវនេះគាត់ព្រមទទួលថា ចម្លើយសារភាពរបស់អ្នកទោស " មិនពិត ច្រើនជាងពិត"[913] ហើយគាត់ជឿថា **ឌុច** ក៏យល់ឃើញដូចគ្នាដែរ ប៉ុន្តែ **ឌុច** មិនយកចិត្តទុកដាក់បញ្ហានេះ ពីព្រោះ គាត់ "ឆ្កួតនឹងសង្គ្រាម និងធ្វើបាបប្រជាជន"[914]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

24. សាក្សីផ្ដល់ភស្តុតាងថា នៅពេលមានការអនុញ្ញាតពី **ឌុច** និងថ្នាក់លើ[915] គាត់និងអ្នកសួរចម្លើយដូចគាត់នៅក្នុងក្រុមអង្កៀម និងក្រុមក្ដៅ បានប្រើប្រាស់វិធីធ្វើទារុណកម្ម រួមមានការវាយដំនិងការទាត់ធាក់ ការវាត់នឹងមែកឈើ ការឆក់ខ្សែភ្លើង ការចាក់ម្ជុលក្រោមក្រចក ការដកក្រចក ការធ្វើទារុណកម្មឱ្យថប់ដង្ហើមដោយថង់ផ្លាស្ទិក ការជ្រមុជចូលក្នុងទឹក ការប្រើប្រាស់អន្ទាក់ដាក់សត្វ និងការបង្ខំឱ្យស៊ី

00288977



លាមក[916]។ សាក្សីបានបញ្ជាក់អំពីការប្រើប្រាស់ឧបករណ៍ធ្វើទារុណកម្មខុសគ្នា ប៉ុន្តែបានបដិសេធថាមិនបានឃើញអាងជ្រមុជទឹកទេ[917]។

25. យោធាខ្មែរក្រហមដែលរងរបួសនៅក្នុងសង្គ្រាមជាមួយវៀតណាមនៅឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៨ ត្រូវបានគេដឹកទៅភ្នំពេញ និងត្រូវការឈាមជាច្រើនដើម្បីបញ្ចូល ដូច្នេះគេបានបូមឈាមពីអ្នកទោសនៅ ស-២១ និងបញ្ជូនឈាមទាំងនោះទៅមន្ទីរពេទ្យមុន្នីវង្ស និងមន្ទីរពេទ្យ១៧ មេសា[918]។ សាក្សីផ្តល់ភស្តុតាងថា ការបូមឈាមធ្វើឡើងនៅមន្ទីរពេទ្យនៅខាងក្រោមមន្ទីរឃុំឃាំង ដែលមានទីតាំងស្ថិតនៅកែងផ្លូវលេខ១១៣ និងផ្លូវលេខ៣៣០ ដែលនៅជាប់នឹងផ្ទះរបស់សាក្សី[919]។ សាក្សីឈរមើលពីលើផ្ទះរបស់គាត់[920] នៅពេលឈាមត្រូវបានគេបូមចេញពីអ្នកទោសមានសុខភាពល្អពី២០ ទៅ៣០នាក់ ដែលក្នុងម្នាក់ៗបូមបួន ឬប្រាំថង់ផ្លោកឈាម ដែលធ្វើឱ្យអ្នកទោស "សន្លប់ និងដង្ហក់ខ្យល់" មុនពេលពួកគេត្រូវបានគេយកទៅដាក់គរលើគ្នា។ សាក្សីរៀបរាប់ព្រឹត្តិការណ៍ថា "គួរឱ្យភ័យខ្លាច"[921]។ ថ្ងៃមួយ គាត់បានឃើញឡានដឹកអ្នកទោសពេញ "ដែលអ្នកទោសទាំងនោះត្រូវបានគេបូមឈាមហើយ មិនទាន់ស្លាប់ទេ ប៉ុន្តែមានលក្ខណៈខ្សោយ និងដកដង្ហើមផ្អឹកៗ"[922]។ សាក្សីបានប៉ាន់ប្រមាណថា ចាប់តាំងពីឆ្នាំ១៩៧៦ រហូតដល់ចប់នៃរបបនេះ មិនតិចជាង១០០០នាក់ទេ ដែលត្រូវបានសម្លាប់តាមរបៀបនេះ[923]។ "សំបុត្រ" សម្រាប់បូមឈាមពីអ្នកទោស ស-២១ មាននៅកន្លែងទុកឯកសារនៅទួលស្លែង[924]។ គាត់មិនបានឃើញ **ឌុច** នៅកន្លែងបូមឈាមទេ ប៉ុន្តែគាត់បានសន្និដ្ឋានថា ក្នុងនាមជាប្រធាន ស-២១ ប្រសិនបើ **ឌុច** មិនបញ្ជាឱ្យធ្វើ គ្មាននរណាហ៊ានធ្វើនោះទេ[925]។

26. ឌុច បានកោះប្រជុំអ្នកសួរចម្លើយទាំងអស់ ដើម្បីពិភាក្សាអំពីបញ្ហាកុំឱ្យធ្វើទារុណកម្មអ្នកទោសខ្លាំងពេក ដែលអាចឱ្យជននោះស្លាប់។ គាត់បាននិយាយការធ្វើទារុណកម្មធ្ងន់ធ្ងរពេក ជាការ "ធ្វើឱ្យខ្មាំងអាចបំផ្លាញការងាររបស់ខ្លួន"[926]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

27. សាក្សីផ្តល់ភស្តុតាងថា "អ្នកទោសមិនតិចជាងបីបួនពាន់នាក់" ត្រូវបានសម្លាប់នៅ ស-២១[927] ដែលក្នុងនោះ "មិនតិចជាង៣០០នាក់" ដែលជាបុគ្គលិកធ្វើការជាមួយគាត់មកពីកងពលធំលេខ៧០៣ នៅ ស-

២១[928]។ សាក្សីផ្តល់ភស្តុតាងថា គាត់គឺជាអ្នកនៅរស់តែម្នាក់គត់ក្នុងចំណោមអ្នកសួរចម្លើយ១២នាក់ក្នុងក្រុមរបស់គាត់ ដែលអ្នកផ្សេងទៀតត្រូវបានគេបោសសម្អាត[929]។

28. សាក្សីផ្តល់ភស្តុតាងថា គាត់បានឃើញមេគាត់ផ្ទាល់ សម្លាប់ពួកកូនក្មេងជនជាតិវៀតណាម តាមរយៈការទម្លាក់ចេញពីបង្អួចជាន់ទីពីរចុះមកលើប៉េតុង និងគាត់ជឿជាក់ថា ទង្វើនេះកើតឡើងជាញឹកញាប់[930]។ គាត់បានផ្តល់ភស្តុតាងថា អ្នកទោសមិនតិចជាងមួយនាក់ ត្រូវបានសម្លាប់ដោយសារការបូមយកឈាមរបស់ពួកគេ[931]។ គាត់បានផ្តល់ភស្តុតាងថា ចៀម សឿ (អ្នកយាមនៅផ្នែកខាងក្រៅ) បានប្រាប់គាត់ថា ជនជាតិអាមេរិកម្នាក់ និងជនជាតិអូស្ត្រាលីម្នាក់ ត្រូវបានគេដុតរហូតដល់ស្លាប់នៅលើផ្លូវទួលទំពូង[932]។

29. ការសម្លាប់កើតឡើងនៅខាងត្បូងមន្ទីរឃុំឃាំង និងនៅខាងក្រោយអគារ ឃ[933]។ សាក្សីផ្តល់ភស្តុតាងថា ឯកសារ ស-២១ មួយ (ERN 00007270) មានចំណារសរសេរផ្ទាល់ដៃរបស់ **ឌុច** "ដែលស្នើឱ្យសួរចម្លើយនៅចំណុចទៅប្អូនឡើងវិញ និងសម្លាប់អ្នកផ្សេងៗទៀតចោល"[934]។ គាត់បានផ្តល់ភស្តុតាងថា ប៉េង ជាអ្នកប្រមូលអ្នកទោសពីបន្ទប់ឃុំឃាំង នៅពេលដល់ពេលត្រូវយកទៅសម្លាប់[935] និង ហ៊ឹម ហ៊ុយ "ជាអ្នកបញ្ជូនអ្នកទោសទៅជើងឯក" ដើម្បីសម្លាប់ចោល[936]។ សាក្សីផ្តល់ភស្តុតាងថា នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ច្រកទ្វារចេញចូលរបស់ ស-២១ ត្រូវបានបិទ និងអ្នកទោសទាំងអស់ "ត្រូវបានបោសសម្អាត និងដឹកចេញ"។ នៅថ្ងៃទី៧ ខែមករា អ្នកទោសនៅសល់នៅក្នុង អគារ ក "ត្រូវបានសម្លាប់ចោលទាំងអស់"[937]។

## សក្ខីកម្មមុនៗ

30. សាក្សីបានផ្តល់សក្ខីកម្មពីមុនចំនួនដប់បី ទៅឱ្យសហព្រះរាជអាជ្ញា៖

(1) បទសម្ភាសន៍របស់ ប្រាក់ ខន ដោយ ក.ស.ព ចុះថ្ងៃទី12 ដល់ 13 ខែតុលា ឆ្នាំ2006, ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, 23.8, ERN 00146790-00146796 (ភាសាអង់គ្លេស), ERN 00147732-00147738 (ភាសាបារាំង), ERN 00078625-00078639 (ភាសាខ្មែរ).

(2) បទសម្ភាសន៍របស់ ប្រាក់ ខន ដោយ ក.ស.ច.ស ចុះថ្ងៃទី21 ខែកញ្ញា ឆ្នាំ2007, D19/VII, ERN 00161568-00161586 (ភាសាអង់គ្លេស), ERN 00146613-00146634 (ភាសាខ្មែរ).

(3) បទសម្ភាសន៍របស់ ប្រាក់ ខន ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែកញ្ញា ឆ្នាំ2007, D19/VIII, ERN 00161552-00161567 (ភាសាអង់គ្លេស), ERN 00146593-00146612 (ភាសាខ្មែរ).

(4) កំណត់ហេតុនៃការតទល់មុខគ្នារបស់ ប្រាក់ ខន ដោយ ក.ស.ច.ស ចុះថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2008, D54, ERN 00166561-00166570 (ភាសាអង់គ្លេស).

(5) បទសម្ភាសន៍របស់ ប្រាក់ ខន ដោយ ក.ស.ច.ស ស្តីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ (ទួលស្លែង) ចុះថ្ងៃទី11 ខែមេសា ឆ្នាំ2008, D48/2, ERN 00197998-00198008 (ភាសាអង់គ្លេស), ERN 00181347-00181356 (FR), ERN 00181328-00181346 (ភាសាខ្មែរ).

(6) បទសម្ភាសន៍របស់ ប្រាក់ ខន ដោយ DC-Cam (គ្មានកាលបរិច្ឆេទ) មានចំណងជើងថា *ប្រាក់ ខន (Prak Khan) and ការសួរចម្លើយ at ស-២១* ដោយ ឧស្មាន អ៊ីសា (Osman YSA), D61/I, ERN 00002586-00002599 (ភាសាខ្មែរ) (អត្ថបទបកប្រែជាភាសាអង់គ្លេសមិនទាន់មាន ERN និងមិនទាន់ដាក់ចូលក្នុងសំណុំរឿង).

(7) បទសម្ភាសន៍របស់ ប្រាក់ ខន ក្នុងសៀវភៅរបស់ DUNLOP, Nic *ពិឃាតបាត់ខ្លួន* ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ERN 00078697-00078699 (ភាសាអង់គ្លេស).

(8) បទសម្ភាសន៍របស់ ប្រាក់ ខន ក្នុងខ្សែភាពយន្ត *Shadow of the Past* ដោយ Express TV, គ្មានកាលបរិច្ឆេទ, D69, ERN V 00172520.

(9) បទសម្ភាសន៍របស់ ប្រាក់ ខន ក្នុង *Inside Pol Pot"s Secret Prison* ដោយ Bill BRUMMEL ចុះថ្ងៃទី4 ខែកក្កដា ឆ្នាំ2000, D69, ERN V 00172525.

(10) បទសម្ភាសន៍របស់ ប្រាក់ ខន (Prak Khan) ក្នុង *Cambodia Report* ដោយ Phil REES, គ្មានកាលបរិច្ឆេទ, D69, ERN V 00172527.

(11) បទសម្ភាសន៍របស់ ប្រាក់ ខន ក្នុងខ្សែភាពយន្ត *ស-២១, ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម* ដោយ ឫទ្ធី ប៉ាន់, ឆ្នាំ 2002, D69, ERN V 00172620 (ភាសាខ្មែរ)

(12) បទសម្ភាសន៍របស់ ប្រាក់ ខន ក្នុង *Derri—re le portail (Behind the Gate)* ដោយ Jean Baronnet, ឆ្នាំ 2004, D54/I, ERN V 00178355-00178355 (KHM/FRE).

(13) បទសម្ភាសន៍របស់ ប្រាក់ ខន ក្នុងអត្ថបទមានចំណងជើងថា "ការជួបជុំគ្នាឡើងវិញរបស់អតីតយុទ្ធជនមន្ទីរស-២១" ដោយ ហ៊ុយ វណ្ណៈ ក្នុងទស្សនាវដ្តី *ស្វែងរកការពិត* របស់ DC-Cam, លេខ 31, កក្កដា 2002, D5/2, ERN 00104911-00104912 (ភាសាអង់គ្លេស).

## ឯកសារពាក់ព័ន្ធ

31. សាក្សីពោលអំពីឧបករណ៍ដាក់លាក់ជាច្រើនដែលត្រូវបានប្រើក្នុងការធ្វើទារុណកម្ម ក្នុងនោះរួមមាន ម្ជុល ខ្សែភ្លើង ដង្កាប់ និងថង់កៅស៊ូ[938] ដង្កាប់មាននៅឯសារៈមន្ទីរទួលស្លែង។ ឯកសារខាងក្រោមក្នុងចំណោមឯកសារផ្សេងទៀត ក៏មានការពាក់ព័ន្ធផងដែរទៅនឹងភស្តុតាងនៃសាក្សីនេះ៖

(1) ការធ្វើវិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា *អ្នកស៊ើបអង្កេតទាំងឡាយនៅគុកទួលស្លែងស-២១ (1975-1979)* រៀបចំឡើងដោយ សើ សាយ្យាណា និង ឡាច វរល័ក្ខកល្យាណ, គ្មានចុះកាលបរិច្ឆេទ គ្មាន ERN មិនទាន់មាននៅក្នុងសំណុំរឿងនៅឡើយទេ (ខ្មែរ)។

(2) យោងតាមអត្ថបទរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណងជើងថា *ប្រាក់ ខន និងការស៊ើបអង្កេតនៅមន្ទីរស-២១* ដោយ អ៊ីសា ឧស្មាន គ្មានចុះកាលបរិច្ឆេទ D61/I ERN

00002586-00002599 (ខ្មែរ) (ការបកប្រែជាភាសាអង់គ្លេសមិនទាន់មាន ERNនិងមិនទាន់មាននៅក្នុងសំណុំរឿងនៅឡើយ) ចម្លើយសាក្សីខាងក្រោម នៅក្នុងសំណុំរឿង ដែលមានការសរសេរដៃរបស់ ប្រាក់ ខន ៖

(i) ចម្លើយសារភាពរបស់ ធូ ហៃ នៅមន្ទីរស-២១ ចុះថ្ងៃទី11 ខែកុម្ភៈ ឆ្នាំ1978, D32/IV-ឧបសម្ព័ន្ធ 01 ERN 00174122-00174126 (ខ្មែរ)

(ii) ចម្លើយសារភាពរបស់ អែម មីន នៅមន្ទីរស-២១ ចុះថ្ងៃទី3 ខែឧសភា ឆ្នាំ1977 D32/IV-ឧបសម្ព័ន្ធ 34 ERN 00174063-00174064 (ខ្មែរ)

(iii) ចម្លើយសារភាពរបស់ អេង មេង ប៊ាង នៅមន្ទីរស-២១ ចុះថ្ងៃទី6 ខែកុម្ភៈ ឆ្នាំ1977 D32/IV-ឧបសម្ព័ន្ធ 69 ERN 00174575-00174578 (ខ្មែរ)។

## 23. សោម ម៉េត

## ចរិតលក្ខណៈនិងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងនៃជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* ។ ទាក់ទងនឹងមន្ទីរស-២១ សាក្សីនេះផ្តល់ភស្តុតាងនៃតួនាទីរបស់ជនជាប់ចោទ*(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់គុក ការឃុំខ្លួនខុសច្បាប់ កង្វះការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ ការឃើចាប់ខ្លាំងក្លា អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការធ្វើទារុណកម្ម និងការប្រព្រឹត្តអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* និងការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។ ភស្តុតាងរបស់គាត់គឺមានការពាក់ព័ន្ធនឹងបទចោទ1, 2 និង3 នៃដីកាចោទប្រកាន់។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សី ដែលមានអាយុប្រហែល19ឆ្នាំ នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ជាជនជាតិខ្មែរ ភេទប្រុស កើតក្នុងឆ្នាំ 1956[939]។ គាត់ត្រូវបានគេកេណ្ឌឱ្យធ្វើទាហានខ្មែរក្រហមប្រយុទ្ធប្រឆាំងនឹងទាហានលន់ ណុល។ បន្ទាប់ពីខែមេសា ឆ្នាំ1975 គាត់ត្រូវបានគេបញ្ជូនឱ្យទៅសិក្សារយៈពេល៨ខែ នៅសាលាបច្ចេកទេសតាខ្មៅ។ កាលនោះសាក្សីត្រូវបានគេតែងតាំងឱ្យយាមអ្នកទោសនៅកន្លែងបុគ្គលិកទូទៅនៅឯដាំផែងក្បែរមន្ទីរពេទ្យមន្ទីរវង្សក្នុងទីក្រុងភ្នំពេញ គាត់បានធ្វើការនៅទីនោះចាប់ពីឆ្នាំ1976រហូតដល់ដើមឆ្នាំ1977 នៅពេលដែលគាត់ត្រូវបានគេចាត់តាំងទៅមន្ទីរស-២១[940]។ នៅមន្ទីរស-២១ គាត់បានធ្វើការក្នុងកងពិសេសយាមអ្នកទោស "សំខាន់ៗ" អ្នកធំមកពីកងពល និងកម្រិតភូមិភាគ[941]។ សាក្សីបានឋិតនៅក្នុងតួនាទីនេះរហូតដល់ចុងឆ្នាំ1978។ ដោយសារបងប្រុសរបស់គាត់ត្រូវបានគេចាប់ខ្លួនបញ្ជូនទៅមន្ទីរ-២១ សាក្សីត្រូវបានគេផ្ទេរទៅព្រៃស នៅចុងឆ្នាំ1978 គាត់បាននៅទីនោះរហូតដល់វៀតណាមចូល[942]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងនៃការធ្វើជាសមាជិកមួយរូបនៃកងទ័ពរំដោះ ដែលកាលពីដំបូងឡើយគាត់នៅលាយឡំគ្នាជាមួយវៀតកុង។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា កងទ័ពទាំងនេះក្រោយមកបានបំបែកខ្លួនចេញពី

កងទ័ពកម្ពុជាប្រជាធិបតេយ្យ លេចឡើងជាអង្គភាពដោយឡែកមួយ[943]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បាននៅព្រៃស "រហូតដល់វៀតណាមចូល"[944]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺជាប្រធានមន្ទីរស-២១ជាអ្នក "ចេញបញ្ជា" និងជាអ្នកសម្រេចអ្នកចូល និងអ្នកណាចេញ[945]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានធ្វើការជាឆ្មាំក្រោមការត្រួតត្រាផ្ទាល់របស់**ឌុច**[946]។ **ឌុច** បានដឹកនាំការសួរចម្លើយផ្ទាល់ ជាពិសេសអ្នកទោសសំខាន់ៗ[947] និងបានធ្វើទារុណកម្មអ្នកទោស[948]។ **ឌុច** បានទាត់អ្នកទោសបើសិនជាគាត់បានដឹងថា អ្នកទោសទាំង នោះមិនបានបង្ហាញព័ត៌មានគ្រប់គ្រាន់ក្នុងពេលសួរចម្លើយទេ[949]។ សាក្សីក៏នឹងបង្ហាញផងដែរពីឧទាហ រណ៍ជាក់លាក់មួយ នៅពេលដែលគាត់បានឃើញ ឌុច វាយអ្នកទោសម្នាក់នឹងរំពាត់ផ្តៅ[950] ជា ទម្រង់ទូទៅមួយនៃការសួរចម្លើយនៅមន្ទីរស-២១[951]។

5. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញ ឌុច នៅព្រៃស ហើយថាគាត់បានឮថា ឌុច មកទីនេះជារឿយៗ[952]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានធ្វើការជាឆ្មាំមន្ទីរស-២១ ចាប់ពីដើមឆ្នាំ1976 ចុងឆ្នាំ1978។ នៅពេលគាត់បានមកដល់មន្ទីរស-២១ដំបូង សាក្សីបានធ្វើការឱ្យមន្ទីរសន្តិសុខបុគ្គលិកទូទៅនៅមន្ទីរពេទ្យមន្ទីរវង្ស ក្រោមការត្រួតត្រារបស់ តាណាត **ឌុច** និង ហ៊ុំ ប្រហែលជា**ឌុច** មានតួនាទីជាអនុប្រធានម្នាក់[953]។ **ឌុច** បានត្រួតត្រាមន្ទីរស-២១ បន្ទាប់ពីផ្លាស់ទីតាំង។ សាក្សីកត់សម្គាល់ថា ឆ្មាំទាំងឡាយមិនដែលត្រូវបានគេអនុញ្ញាតឱ្យសួរចម្លើយអ្នកទោសដោយខ្លួនឯងទេ[954]។

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីស្ថានភាពព្រៃស ជាកន្លែងដែលគាត់ត្រូវបានគេបញ្ជូនឱ្យទៅធ្វើការនៅវាលស្រែ[955]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ព្រៃសត្រូវបានគេចង្អុលបង្ហាញពីដំបូងសម្រាប់ "អ្នកជាប់ទោសស្រាល"[956]។

## វេចនាសម្ព័ន្ធអំណាច

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺជាប្រធានមន្ទីរស-២១[957] ហើយថាការទទួលខុសត្រូវរបស់គាត់រួមមាន ការបំពេញការងារទូទៅនៅមន្ទីរស-២១ និងការសួរចម្លើយ[958]។ ហ៊ គឺជាអនុប្រធានមន្ទីរស-២១[959] ហ៊ឹម ហ៊ុយ និង ស្រី ទទួលបន្ទុកកងសន្តិសុខផ្ទាល់ខ្លួនរបស់សាក្សីនៅមន្ទីរស-២១[960]។ ធី គឺជាអ្នកកត់ត្រាបញ្ជីឈ្មោះអ្នកទោសចេញចូល[961]។ កងឆ្មាំសាក្សីទទួលបន្ទុកយាមនៅខាងក្រៅអគារដែលជាកន្លែងគេដាក់អ្នកទោស។ ទាំងប៊ុន និងចាន់មកព្រៃស។ ប៊ុន គឺជាស៊ើបអង្កេតម្នាក់[962] ។

9. សាក្សីក៏ធ្វើកំណត់អត្តសញ្ញាណឈ្មោះ ហ៊ុយ ម្នាក់ផ្សេងទៀត ដែលជាប្រធានព្រៃស ប៉ុន្តែគាត់កត់សម្គាល់ថាម្នាក់ឈ្មោះ ហ៊ុយ នោះ ត្រូវបានដកចេញមុនពេលគាត់បានទៅដល់ទីនោះ[963]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ជឿថា អ្នកជាប់ឃុំឃាំងភាគច្រើននៅមន្ទីរស-២១គឺជា "កងទ័ពបដិវត្ត" ដែលប្រឆាំងនឹងសមាជិក "សង្គមចាស់"[964] ហើយថាចំនួនទាហានត្រូវបានចាប់ខ្លួន ហើយនាំយកទៅមន្ទីរស-២១ បានកើនឡើងនៅក្នុងឆ្នាំ1978[965]។ ស្ត្រីទាំងឡាយ ក្នុងនោះមានស្ត្រីសំខាន់ៗក៏ត្រូវជាប់ឃុំនៅមន្ទីរស-២១[966] ផងដែរ ទោះបីគាត់មិនបានយាមពួកគេក៏ដោយ[967]។ គាត់យាមតែមន្ត្រី "ជាន់ខ្ពស់" ដែលក្នុងនោះ មន្ត្រីដែលមកពីកងពល និងមន្ត្រីមកពីកម្រិតភូមិភាគ[968]។ គាត់បានដឹងពីការចាប់ខ្លួន ណាត ប្រធានកងពលលេខ703 ប៉ុន្តែគាត់មិនបានយាមគាត់ទេ[969]។ មានអ្នកទោសថ្មីមកដល់ជាបន្តដើម្បីជំនួសអ្នកទោសដែលត្រូវបានគេយកចេញទៅ[970]។ គាត់មិនបានឃើញជនបរទេសណាម្នាក់នៅមន្ទីរស-២១ទេ គាត់បានឮពីឆ្មាំផ្សេងទៀតថា មានអ្នកទោសជនជាតិវៀតណាមមួយ[971]។ សាក្សីក៏ធ្វើការកត់សម្គាល់ផងដែរថា កម្មាភិបាលនៃមន្ទីរស-២១ មួយចំនួនក៏បានបាត់ខ្លួនផងដែរ ហើយសន្និដ្ឋានថា ពួកគេត្រូវជាប់គុក[972]។

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឆ្មាំផ្លាស់វេនគ្នានៅពេលបាយ ហើយនៅពេលណាដូរវេន ឆ្មាំថ្មីត្រូវបានគេតម្រូវឱ្យពិនិត្យអ្នកទោសរកមើលរបស់ហាមឃាត់ជាមុនសិន។ វិធានច្បាប់នៃមន្ទីរស-២១បានចេញបញ្ជាឱ្យឆ្មាំទាំងឡាយប្រុងប្រយ័ត្ន មិនត្រូវដេក និងនិយាយរកអ្នកទោសឡើយ[973]។

12. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកជាប់ឃុំនៅព្រៃសទាំងអស់មកពីកងពលទី703 មានចំណាត់ថ្នាក់ជាអ្នកប្រព្រឹត្តល្មើសស្រាល ហើយរួមមានស្ត្រីខ្លះដែរ[974]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

13. សាក្សីផ្ដល់ភស្តុតាងបញ្ជាក់អំពីស្ថានភាពរស់នៅរបស់អ្នកជាប់ឃុំ។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា អ្នកជាប់ឃុំត្រូវគេស្រាតនៅសល់តែខោខ្លី ដេកនៅលើកម្រាលចាស់ៗ ហើយជើងជាប់ខ្នោះភ្ជាប់ទៅនឹងច្រវាក់[975]។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់អំពីរបបអាហារមិនគ្រប់គ្រាន់ ដែលអ្នកទោសបានទទួលនៅមន្ទីរស-២១ ក្នុងនោះមានបបរពីរពេល[976]។ អ្នកទោសខ្លះមិនអាចហូបកើតដោយសារពួកគេបានទទួលការធ្វើទារុណកម្មធ្ងន់ធ្ងរពេក[977]។ អ្នកទោសឈឺត្រូវបានពេទ្យព្យាបាល[978]។ អ្នកទោសត្រូវបានគេឱ្យទឹកផឹកនៅពេលស្រេកទឹក ហើយអនុញ្ញាតឱ្យបត់ជើងធំក្នុងធុងមួយ ប៉ុន្តែគេមិនអនុញ្ញាតឱ្យចេញពីបន្ទប់ដើម្បីធ្វើដូច្នោះទេ[979]។ អ្នកទោសជារឿយៗមិនត្រូវបានគេអនុញ្ញាតងូតទឹក អស់រយៈពេលរវាងពី "បួន-ដប់" ថ្ងៃជាប់ៗគ្នា[980] ដូច្នេះពួកមានខ្លិន "ស្អុយ"[981]។ គេឱ្យអ្នកទោសងូតទឹកទាំងជាប់ខ្នោះ[982]។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់អំពីឧទាហរណ៍ជាក់លាក់ជាច្រើន ដែលអ្នកជាប់ឃុំនៅមន្ទីរស-២១ មានបំណងធ្វើអត្តឃាតខ្លួនឯង[983]។

14. សាក្សីផ្ដល់ភស្តុតាងបញ្ជាក់អំពីស្ថានភាពរស់នៅអន់ថយនៅព្រៃស ដែលក្នុងនោះរួមមាន ការបង្ខំឱ្យធ្វើការធ្ងន់ និងទទួលរបបអាហារមិនគ្រប់គ្រាន់[984]។

## ការសួរចម្លើយ

15. សាក្សីបានសង្កេតមើលការសួរចម្លើយ ក្នុងនាមជាឆ្មាំម្នាក់ឈរនៅខាងក្រៅបន្ទប់[985]។ អ្នកទោសត្រូវបានសួរចម្លើយជាច្រើនលើកច្រើនសារ តែមានថ្ងៃសម្រាកពីឬបីថ្ងៃដែរ[986] បន្ទាប់ពីរយៈពេលមួយខែក្រោយមក អ្នកទោសទាំងនោះត្រូវបានគេយកទៅសម្លាប់[987]។ សាក្សីនឹងកំណត់អត្តសញ្ញាណ ទុយ, ណន និង ឈិន ជាអ្នកសួរចម្លើយ ហើយកត់សម្គាល់ថា មនុស្សសំខាន់ៗត្រូវបានអ្នក មកពីកំពង់ឆ្នាំងសួរចម្លើយ[988]។ **ឌុច** ក៏ចូលរួមដែរនៅពេលណាអ្នកទោសមានភាពមិនច្បាស់លាស់។ ក្នុង ឧប្បត្តិហេតុ មួយ **ឌុច** បានទាត់ដំវាមកំហែងអ្នកទោសម្នាក់[989]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

16. សាក្សីបានឃើញគេប្រើវិធីធ្វើទារុណកម្មច្រើនបែបច្រើនយ៉ាងណាស់នៅមន្ទីរស-២១ ក្នុងនោះរួមមាន ការវាយអ្នកទោសនឹងរំពាត់ផ្ដៅ ដកក្រចកដៃក្រចកជើង ដោតម្ជុលចូលក្នុងក្រចកដៃ ឬយកស្បោងច្រកក្នុងក្បាលធ្វើឱ្យថប់ដង្ហើម[990]។ ជួនកាលអ្នកសួរចម្លើយស្រាតខោអាវអ្នកទោសចេញ ហើយប្រើឧបករណ៍ឆក់អង្គជាតិ ឬត្រចៀករបស់អ្នកទោស[991]។ អ្នកសួរចម្លើយធ្វើទារុណកម្មអ្នកទោសតាមរយៈធ្វើឱ្យស្ថានភាព

រស់នៅមិនទ្រាំទ្របាន ក្នុងនោះរួមមាន ការយកគ្រែ និងសំលៀកបំពាក់ចេញ ការចាក់ទឹកលើអ្នកទោស និងដាក់កង្ហារធ្វើឱ្យត្រជាក់[992]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឮអ្នកទោសស្រែកសុំឱ្យអ្នកសួរចម្លើយឈប់ធ្វើទារុណកម្មពួកគេ[993]។ សាក្សីកត់សម្គាល់ថា ការព្យាបាលអ្នកទោស ដែលរងរបួសក្នុងអំឡុងពេលសួរចម្លើយគឺមានតែការប្រើតែថ្នាំអ៊ីយ៉ូដដើម្បីព្យាបាលរបួសប៉ុណ្ណោះ។ អ្នកទោសដែលដួលសន្លប់ក្នុងពេលធ្វើទារុណកម្មដោយការឆក់ មិនត្រូវបានគេជួយទេ[994]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

17. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសត្រូវបានគេ "យកចេញទៅ"ពីមន្ទីរស-២១ រៀងរាល់ថ្ងៃ រាល់យប់។ អ្នកទោសដែលត្រូវបានគេយកចេញទៅមិនដែលឃើញបានត្រឡប់មកវិញទេ[995] ហើយអ្នកទោសថ្មី ត្រូវបានគេនាំចូលមន្ទីរស-២១ ដើម្បីជំនួសអ្នកទោសចាស់[996]។ ស្រ៊ី និង ធី ទទួលខុសត្រូវក្នុងការចាត់ចែងអ្នកទោសដែលត្រូវយកចេញ[997]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឮជនបរទេសដែលត្រូវគេសម្លាប់ ជាពិសេស ជនជាតិអាមេរិក ត្រូវបានគេដុតនៅក្បែរមន្ទីរស-២១[998]។

18. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសទាំងឡាយដែលត្រូវបានគេយកចេញពីព្រៃស មិនដែលឃើញត្រឡប់មកវិញទេ[999]។

## សក្ខីកម្មមុនៗ

19. សាក្សីបានផ្តល់សក្ខីកម្មមុនៗចំនួន៣ជូនទៅសហព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក ឈ្មោះ សោម ម៉ែត ចុះថ្ងៃទី28 ខែវិច្ឆិកា ឆ្នាំ2007 D28/3 ERN 00163658-00163666 (អង់គ្លេស)។

(2) ចម្លើយសាក្សីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាឈ្មោះ សោម ម៉ែត ចុះថ្ងៃទី ផ្សេងៗ ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ ឯកសារលេខ. 19.167 ERN 00051644-00051656 (ថ្ងៃទី25 ខែមករា ឆ្នាំ2003) 00051657-00051678 (31 មករា 2002) 00051679-00051711 (ថ្ងៃទី25 ខែមករា ឆ្នាំ2003) 00051712-00051751 (ថ្ងៃទី13 ខែកញ្ញា ឆ្នាំ2004) (ភាសាខ្មែរ) (ការបកប្រែភាសាអង់គ្លេសសង្ខេប ERN 00185233-00185236)។

(3) កំណត់ហេតុលាយលក្ខណ៍អក្សរនៃការតទល់មុខគ្នារបស់ សោម ម៉ែត នៃសហចៅក្រមស៊ើបអង្កេតរបស់អ.វ.ត.ក ចុះថ្ងៃទី29 កុម្ភៈ 2008 D54 ERN 00166561-00166570(អង់គ្លេស)។

## ឯកសារពាក់ព័ន្ធ

20. សាក្សីនឹងយោងទៅលើឯកសារពាក់ព័ន្ធនៅពេលធ្វើសវនាការ។

## 24. សេក ផន

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងអំពីរចនាសម្ព័ន្ធនិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ សាក្សីនេះផ្តល់ភស្តុតាងអំពីតួនាទីជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត ថេរវេលា និងប្រតិបត្តិការមន្ទីរសន្តិសុខ ស-២១*(20-42)*, រចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់គុក ការឃុំឃាំងខុសច្បាប់ គ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ រងការឈឺចាប់ធ្ងន់ធ្ងរ អំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ (43-45 & 79-84) ការធ្វើទារុណកម្ម និងការប្រព្រឹត្តអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញអ្នកទោស *(141-142)*។ ភស្តុតាងរបស់គាត់មានការជាប់ពាក់ព័ន្ធបទចោទ1, 2 និង3 នៃដីកាចោទប្រកាន់។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុប្រហែល14 ឆ្នាំនៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ជាជនជាតិខ្មែរ ភេទប្រុស កើតឆ្នាំ1961[1000]។ មុនថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីរស់នៅផ្ទះគ្រួសាររបស់គាត់ក្នុងភូមិត្រពាំងក្របៅ ក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ប្រហែលជាក្នុងខែឧសភានៃឆ្នាំនោះ គាត់ត្រូវបានគេដឹកយកទៅ ក្បែរស្ទឹងព្រែកត្នោត ដើម្បីសិក្សាពីបច្ចេកទេសយោធាអស់រយៈពេលបីខែ។ បន្ទាប់ពីការហ្វឹកហាត់របស់គាត់ គាត់ត្រូវបានគេបញ្ជូនទៅធ្វើការនៅវាលស្រែ សង់ទំនប់នៅតាមការដ្ឋានផ្សេងៗជុំវិញទីក្រុងភ្នំពេញ។ ប្រហែលជានៅដើមឆ្នាំ1978 គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរស-២១ ដើម្បីធ្វើការជាពេទ្យកូនក្មេង ហើយបានធ្វើការនៅទីនោះអស់រយៈពេលជិតមួយឆ្នាំ រហូតដល់ចុងរបបក្នុងខែមករា ឆ្នាំ1979[1001]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានអ្នកទោសជនជាតិវៀតណាមជាប់ឃុំនៅមន្ទីរស-២១ គាត់ផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឮសម្លេងកាំភ្លើងធំក្នុងឆ្នាំ1979 នៅពេលគាត់បានរត់ភៀសខ្លួន[1002]។

## រចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

4. សាក្សីកំណត់អត្តសញ្ញាណ ឌុច ជា "មេដឹកនាំជាន់ខ្ពស់បំផុតនៅមន្ទីរស-២១"[1003]។ នៅពេលសាក្សីកំពុងសិក្សាបច្ចេកទេសយោធានៅក្នុងខែដំបូងនៃរបបកម្ពុជា សាក្សីបានដឹងពី "ការកម្ទេចខ្មាំង" ព្រមទាំងផែនការផលិតស្រូវបីតោនក្នុងហិកតា[1004]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីការផ្លាស់ពីតំបន់របស់គាត់ក្នុងឆ្នាំ1975 ជាផ្នែកមួយនៃការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំនិងជាប្រព័ន្ធ[1005]។ នៅមន្ទីរស-២១ សាក្សីដឹងថា ប្រសិនបើបុគ្គលណាម្នាក់ត្រូវបានគេរិះគន់បីដងចំពោះកំហុសឆ្គងដោយមិនបានធ្វើការកែប្រែខ្លួនឯងទេ នោះបុគ្គលទាំងនោះត្រូវបានគេចាត់ទុកថាជាខ្មាំង ហើយទំនងជាត្រូវចាប់ខ្លួន[1006]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីឧទាហរណ៍មួយ ដែលបុគ្គលម្នាក់ត្អូញត្អែរអំពីស្ថានភាពនានា ត្រូវបានគេចាត់ទុកថា ជាខ្មាំងនៃបដិវត្តកុម្មុយនីស្ត ហើយត្រូវបានចាប់ខ្លួន បន្ទាប់មកបាត់ខ្លួនតែម្តង[1007]។ សាក្សីមិនដែលបានឮអំពីផែនការបិទផ្សារ វត្តអារាម ឬសាលារៀនទេ[1008]។ សាក្សីបានចូលរួមមេទិញ "ស្វ័យទិតៀន" បុគ្គលណាដែលទទួលការទិតៀនបីដងចំពោះកំហុសឆ្គង (ដូចជាមិន "គោរពម៉ោងធ្វើការ") ដោយគ្មានការកែប្រែអ្វីសោះនោះ លទ្ធផលនឹងត្រូវចាប់ខ្លួនជាខ្មាំង[1009]។

## តួនាទីរបស់ជនជាប់ចោទ

5. ជាពេទ្យកូនក្មេងម្នាក់សម្រាប់អ្នកទោស និងជាបុគ្គលិកនៅមន្ទីរស-២១ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មេដឹកនាំជាន់ខ្ពស់បំផុតនៅមន្ទីរស-២១ គឺ ឌុច[1010]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុច បានអនុញ្ញាតឱ្យអ្នកស៊ើបអង្កេតប្រើវិធីសាស្ត្រឃោរឃៅក្នុងពេលធ្វើទារុណកម្ម[1011]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានមកដល់មន្ទីរស-២១ នៅដើមឆ្នាំ1978 ជាពេទ្យកូនក្មេងម្នាក់[1012]។ គាត់មានតួនាទីចែកថ្នាំឱ្យអ្នកទោសក្នុងបន្ទប់ទាំងឡាយ។ ផ្ទះសម្រាប់ពេទ្យគឺទៅទិសខាងកើត និងខាងជើងនៃផ្លូវចូលបច្ចុប្បន្ន (កាច់ជ្រុងផ្លូវលេខ310 ឬ320 ឬ330 និង113)[1013]។ សាក្សីបានព្យាបាលអ្នកទោសដែលត្រូវសួរចម្លើយ និងធ្វើទារុណកម្ម។ គាត់បានដឹងថា អ្នកដែលបានស្លាប់នៅមន្ទីរស-២១ត្រូវបានគេដឹកយកទៅកប់នៅក្បែរអគារទាំងឡាយនិងជុំវិញជញ្ជាំង ដោយពេទ្យមនុស្សធំៗ។ គាត់អាចបញ្ជាក់ពីការពិតថា ពីផ្ទះរបស់គាត់ គាត់អាចធំក្លិនសាកសពស្អុយរលួយ[1014]។

## វចនាសម្ព័ន្ធអំណាច

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុច គឺជាប្រធានមន្ទីរស-២១ ហើយទទួលខុសត្រូវក្នុងសម្រេចទាក់ទងនឹងការសួរចម្លើយ និងការធ្វើទារុណកម្ម។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ហ៊ុយ ទទួលខុសត្រូវក្នុង ការចាប់ខ្លួន[1015]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** បានដឹងអំពី និងបានអនុញ្ញាតឱ្យអ្នកស៊ើបអង្កេតប្រើការធ្វើទារុណកម្ម[1016]។ ប្រធានរបស់សាក្សីឈ្មោះ ប៉ោ ត្រូវបានចាប់ខ្លួនដោយសារចាក់ថ្នាំខុស បណ្តាលឱ្យស្លាប់អ្នកមកជំនួសគាត់ឈ្មោះ យឺន បានធ្វើអត្តឃាតខ្លួន ដោយភ័យខ្លាចគេចាប់ខ្លួនដែរ[1017]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅពេលវៀតណាមចូល មានតែពេទ្យកូនក្មេងប៉ុណ្ណោះដែលនៅមន្ទីរស-២១ ដោយសារពេទ្យមនុស្សធំត្រូវបានគេចាប់ខ្លួនយកទៅសម្លាប់ចោល[1018]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានអ្នកទោសច្រើនប្រភេទខុសគ្នា ហើយអ្នកទោសកម្រិតខ្ពស់ត្រូវបានគេដាក់ដាច់ដោយឡែក[1019]។ គាត់មិនបានឃើញអ្នកទោសជាស្ត្រីណាម្នាក់ ឬកូនក្មេងទេ[1020]។ សាក្សីបានឃើញទាហានវៀតណាម និងអ្នកទោសស៊ីវិលត្រូវគេនាំចូលក្នុងមន្ទីរស-២១[1021]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ការព្យាបាលសុខភាពធ្វើឡើងមានបំណងរក្សាជីវិតអ្នកទោសដើម្បីគេអាចសួរចម្លើយបន្ថែមទៀត។ លើសពីនេះទៅទៀត អ្នកទោសភាគច្រើនជានិច្ចកាលមានរបួស ឈឺពាសពេញខ្នងនិងដៃរបស់ពួកគេ បែកក្បាល បាត់ក្រចកដៃជើង និងមានឈាមហូរជារឿយៗ[1022]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឮពីអ្នកដែលបានធ្វើការជាមួយគាត់ថា ឈាមដែលត្រូវបានយកពីអ្នកទោស គេផ្តល់ទៅឱ្យមន្ទីរពេទ្យនៅខាងក្រៅមន្ទីរស-២១។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មួយខែឬពីរខែម្តង គាត់បានឃើញឡានពេទ្យពណ៌សមកដល់ ប៉ុន្តែគាត់មិនដឹងថាតើឡាននោះមកដឹកអ្នកទោស ឬដឹកឈាមទេ[1023]។ សាក្សីមិនដែលបានឮអ្នកទោសស្ត្រីត្រូវគេរំលោភទេ[1024]។

## ការសួរចម្លើយ

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសត្រូវបានគេសួរចម្លើយជាទៀងទាត់នៅមន្ទីរស-២១។ អ្នកទោសបានប្រាប់សាក្សីថា ពួកគេត្រូវបានវាយដោយអ្នកសួរចម្លើយ[1025]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ការសួរចម្លើយដោយអំពើឃោរឃៅត្រូវមានការអនុញ្ញាតពី **ឌុច**[1026] ហើយថា ប្រសិនបើអ្នកចម្លើយ បាន

ប្រព្រឹត្តខុសឆ្គង ការចេញបញ្ជាសម្លាប់ត្រូវធ្វើឡើងដោយ **ឌុច**[1027]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ ថា អ្នកទោសវៀតណាមទទួលទារុណកម្មដូចគ្នានឹងអ្នកទោសទាំងអស់ដទៃទៀតដែរ[1028]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកត្រូវបានគេធ្វើទារុណកម្មយ៉ាងឃោរឃៅក្នុងអំឡុងពេលនៃការសួរចម្លើយរបស់ពួកគេ ដែលជារឿយៗពួកគេមានរបួសនៅលើរាងកាយនិងក្បាល ហើយបាត់ក្រចកដៃ[1029]។ សាក្សីបានដឹងថា ការធ្វើទារុណកម្មនោះមានលក្ខណៈធ្ងន់ធ្ងរធ្វើឱ្យអ្នកទោសខ្លះស្លាប់[1030]។ អ្នកទោសជនជាតិ វៀតណាមត្រូវបានគេធ្វើទារុណកម្មដូចអ្នកទោសផ្សេងទៀតដែរ[1031]។ សាក្សីផ្តល់ភស្តុតាង បញ្ជាក់ថា អ្នកទោសភាគច្រើនមានរបួស[1032]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

12. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានដឹកអ្នកទោសចេញទៅទំនងជាយកទៅសម្លាប់[1033]។ គាត់បានដឹងថា អ្នកទោសទាំងឡាយណាដែលបានស្លាប់នៅមន្ទីរស-២១ ត្រូវបានពេទ្យមនុស្សធំយកទៅកប់ក្បែរអគារ និងជញ្ជាំងព័ទ្ធជុំវិញមន្ទីរស-២១។ លើសពីនេះទៅទៀត សាក្សីបានឃើញអ្នកទោសដែលត្រូវបានគេសួរចម្លើយ ត្រូវគេដឹកឡានចេញទៅ[1034]។ កម្មករផ្សេងទៀតនៅមន្ទីរស-២១ បានដឹងថា អ្នកទោសត្រូវបានគេដឹកយកទៅសម្លាប់[1035]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសបានស្លាប់ដោយការធ្វើការទារុណកម្ម និងខ្វះអាហារ។[1036] សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ក្នុងអំឡុងពេលដែលគាត់នៅមន្ទីរស-២១ ពេទ្យ មនុស្សធំទាំងអស់ត្រូវបានចាប់ខ្លួន និងសម្លាប់ ហើយនៅសល់តែពេទ្យកូនក្មេងប៉ុណ្ណោះ[1037]។

## សក្ខីកម្មមុនៗ

13. សាក្សីបានផ្តល់សក្ខីកម្មមុនមួយជូនទៅសហព្រះរាជអាជ្ញា៖

   a. ចម្លើយសាក្សីរបស់សហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.កឈ្មោះ សេក ដន (SEK Dan) ចុះថ្ងៃទី 16 មករា 2008 D28/16 00163820-00163824 (អង់គ្លេស) ។

## ឯកសារពាក់ព័ន្ធ

14. សាក្សីនឹងយោងរកឯកសារពាក់ព័ន្ធនៅពេលសវនាការ។

## 25. សួស ធី

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្ដល់ភស្តុតាងបញ្ជាក់អំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* ការវាយប្រហារពាលដាល ឬការវាយប្រហារដែលមានចរិតជាប្រព័ន្ធទៅលើជនស៊ីវិល*(10-18 & 131-133)* និងវេចនាសម្ព័ន្ធនិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)* ។ ទាក់ទងនឹងមន្ទីរស-២១ សាក្សីនេះផ្ដល់ភស្តុតាងបញ្ជាក់អំពីតួនាទីជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើតថេរៈវេលា និងការប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* ចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់ពន្ធនាគារការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ទារុណកម្មអំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* ការប្រព្រឹត្តអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការដាក់ជាទាសករការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញអ្នកទោស *(141-142)* ។ ភស្តុតាងរបស់គាត់គឺមានការជាប់ពាក់ព័ន្ធនឹងបទចោទទី1, 2 និង3 នៃការចោទប្រកាន់។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ23 ឆ្នាំនៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ជាជនជាតិខ្មែរ ភេទប្រុស កើតនៅថ្ងៃទី4 ខែមេសា ឆ្នាំ1952 នៅខេត្តកណ្ដាល[1038]។ សាក្សីបានមករស់នៅភ្នំពេញដើម្បីសិក្សា ប៉ុន្តែនៅក្នុងឆ្នាំ1971[1039] បានវិលត្រឡប់ទៅកំណើតវិញ ហើយបានចូលបដិវត្តរបស់ខ្មែរក្រហម ជាទាហានម្នាក់ក្នុងកងទ័ពភូមិភាគពិសេស។ ក្នុងឆ្នាំ1973 គាត់ទទួលរងរបួស ហើយបានធ្វើជាពេទ្យយោធាទទួលបន្ទុកបញ្ជីឈ្មោះ[1040]។ នៅចុងឆ្នាំ1975 ហ៊ី បានយកសាក្សីទៅភ្នំពេញដើម្បីធ្វើការជាអ្នកទទួលបន្ទុកបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ ដំបូងឡើយមន្ទីរនោះមានទីតាំងនៅក្បែរ*នគរបាលយុត្តិធម៌*ក្បែរ*ផ្សារថ្មី* ក្រោមបញ្ជារបស់ណាត ហើយបន្ទាប់មកនៅទួលស្លែង ចាប់ពីដើមឆ្នាំ1976 នៅពេលដែលមន្ទីរនោះត្រូវបានត្រួតត្រាដោយ ឌុច[1041] សាក្សីបានថិតនៅក្នុងមុខតំណែងនេះរហូតដល់ចុងរបប។ សាក្សី បានជាប់គុកអស់រយៈពេល៥ឆ្នាំ ក្រោម វៀតណាម រវាងពីឆ្នាំ1983 និង1988 ពីបទចោទថាជាមនុស្សសំខាន់ម្នាក់នៅមន្ទីរស-២១[1042]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ទាហានវៀតណាមត្រូវបានគេនាំយកទៅមន្ទីរស-២១ជាអ្នកទោស[1043]

## ការវាយប្រហារពលរដ្ឋ ឬជាប្រព័ន្ធ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសត្រូវបានគេបញ្ជូនទៅមន្ទីរស-២១ "ពីគ្រប់ច្រកល្ហកទូទាំងប្រទេស"[1044]។

## វចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

5. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា សុន សេន បានបង្ហាញខ្លួននៅមន្ទីរស-២១ ម្តងដើម្បីបើក មេទិញមួយ គាត់បានណែនាំខ្លួនគាត់ថាជា "មន្ត្រីត្រួតបញ្ជា"[1045]។ គាត់មិនដែលឃើញ ប៉ុល ពត ខៀវសំផន ឬអៀងសារី នៅមន្ទីរស-២១ទេ គាត់បានឮតែឈ្មោះអ្នកទាំងនោះ និងមុខតំណែងរបស់ពួកគេ តាមវិទ្យុប៉ុណ្ណោះ[1046]។

## តួនាទីរបស់ជនជាប់ចោទ

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺជាប្រធានមន្ទីរស-២១[1047] និងទទួលបន្ទុក "ការងារទូទៅ"[1048] សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ "មិនបានឃើញ ឌុច មក [មន្ទីរស-២១] ច្រើនដងទេ"[1049] ប៉ុន្តែគាត់បានកោះប្រជុំមេទិញសិក្សានយោបាយប្រចាំឆ្នាំ[1050] ក្បែរផ្ទះ (**ឌុច**)[1051]។

7. ការសួរចម្លើយបានចាប់ផ្តើមឡើងនៅក្បែរ"ផ្ទះ**ឌុច**" ត្រូវបានត្រួតត្រា[1052] និងបានប្រព្រឹត្តទៅតាមការស្នើសុំរបស់គាត់ ហើយថាទោះបីត្រូវ "យកចេញ" ឬទុកអ្នកទោសក៏ត្រូវសម្រេចពី ឌុច[1053]ផងដែរ។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា "ក្នុងការយកអ្នកទោសចេញពីមន្ទីរឃុំឃាំង **ឌុច** បានបញ្ជា ហ៊ី"[1054]។ ឌុច ម្នាក់ឯង[1055] មានអំណាចចារណ៍ពន្យល់លើបញ្ជីឈ្មោះអ្នកទោសបញ្ជាក់ថា អ្នកទោសណាត្រូវ "កម្ទេច"[1056] បញ្ជីឈ្មោះអ្នកទោសសំខាន់ៗ ដែលធ្លាក់ខ្លួនឈឺ ត្រូវបានបញ្ជូនផ្ទាល់ ទៅ **ឌុច**[1057] ហើយអ្នកទោសទាំងឡាយណាដែលត្រូវបានគេយកឈាម ពេទ្យបានទាក់ទង ហ៊ី ធ្វើសំណើ "តាមរយៈ **ឌុច**" [1058]។

8. **ឌុច** បានដឹងជាស្រេចអំពីការមកដល់នៃអ្នកទោសដែលមិនមែនជាជនជាតិវៀតណាម ដែលត្រូវបានគេយកទៅឃុំតែម្តង ដោយមិនចាំបាច់ធ្វើដូចអ្នកទោសផ្សេងទៀតទេ[1059]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានធ្វើការនៅមន្ទីរស-២១ អស់រយៈពេលស្ទើងតែចាប់ពីចុងឆ្នាំ 1975 ដល់ឆ្នាំ1979 ទៅហើយ។ នៅពេលគាត់បានមកដល់មន្ទីរស-២១ ដំបូង សាក្សីបានធ្វើការនៅឯគុកមានទីតាំង នៅអតីត*នគរបាលយុត្តិធម៌* ក្រោមការត្រួតត្រារបស់តាណាត។ នៅដើមឆ្នាំ1976 **ឌុច** បានធ្វើការយ៉ាងជិតស្និទ្ធជាមួយ តា ណាត នៅឯ*នគរបាលយុត្តិធម៌* អស់រយៈពេលពីរខែ។ **ឌុច** បានក្លាយជាប្រធានមន្ទីរស-២១ បន្ទាប់ពីមន្ទីរស-២១ ត្រូវបានផ្លាស់ពី*នគរបាលយុត្តិធម៌*ទៅកាន់ទួលស្លែងវិញ ហើយតាណាត ត្រូវបានផ្ទេរទៅកាន់មន្ទីរបុគ្គលិកទូទៅ[1060]។

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មន្ទីរស-២១ មានបីកងសំខាន់ៗគឺ មន្ទីរស-២១ក សម្រាប់កងសួរចម្លើយ ក្រោមការត្រួតត្រារបស់ ឌុច មន្ទីរស-២១ខ សម្រាប់កងសន្តិសុខ ក្រោមការត្រួតត្រារបស់ ហ៊ឹម ហ៊ុយ ហើយមន្ទីរស-២១គ សម្រាប់ធ្វើស្រែនៅព្រៃស ក្រោមការត្រួតត្រារបស់ ហ៊ុយ ស្រែ[1061]។ មន្ទីរស-២១ក៏មានឡានចំនួនបីផងដែរ[1062] ហើយមានមនុស្សចំនួនប្រហែល100នាក់នៅក្នុងកងសន្តិសុខ[1063] បែងចែកជា18ក្រុម[1064]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ចាំឈ្មោះពេទ្យពីរនាក់បានគឺ ទ្រី និង រិន ប៉ុន្តែទោះបីយ៉ាងណាក៏មានពេទ្យកូនក្មេងម្នាក់ត្រូវបានចាប់ខ្លួនយកទៅសម្លាប់ចោលដែរ[1065]។ គាត់ក៏ចាំបានអ្នកថតរូបពីរនាក់ផងដែរឈ្មោះ ស្រៀង និង សុង ប៉ុន្តែគាត់មិនដែលបានឮឈ្មោះ ញែម អេន ទេ។ ពី ដំបូងអ្នកថតរូបទាំងនេះឋិតក្រោមការត្រួតត្រារបស់ ម៉េង មុនពេលអ្នកថតរូបឈ្មោះ សុង ត្រូវបាន ចាប់ខ្លួន[1066] ។

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់នៅក្នុងការិយាល័យជាមួយ[1067] នៅចំកណ្តាលបរិវេណស-២១ នៅត្រង់ដែលគាត់អាចសង្កេតមើលអ្នកទោសថ្មីៗត្រូវគេនាំខ្លួនចូលក្នុងមន្ទីរស-២១។ អ្នកទោសបានមកដល់ដោយចងរបាំងមុខនិងដៃជាប់ខ្នោះនៅលើក្នុងឡាន ដែលឈប់នៅឯខ្លោងទ្វារនៃអគារ[1068]។ ពួកអ្នកទោសទាំងនោះត្រូវបានគេនាំយកឱ្យសាក្សីចុះឈ្មោះនិងចងក្រងជីវប្រវត្តិសង្ខេប មុនពេលត្រូវគេថតរូប និងនាំយកទៅកាន់បន្ទប់របស់ពួកគេដោយអ្នកយាម[1069]។ សាក្សីក៏បានទៅបានអគារ គ និងអគារ ឃ ហើយកត់លេខបន្ទប់សម្រាប់អ្នកទោសម្នាក់ៗ និងផ្តល់ព័ត៌មានពីស្ការទៅអ្នកសួរចម្លើយ[1070]។

12. អ្នកទោសបរទេស "សំខាន់" ត្រូវបានយកទៅគុកពិសេសតែម្តង ដោយមិនចាំបាច់រៀបចំតាមវិធីរបស់សាក្សីទេ[1071]។ បញ្ជីឈ្មោះអ្នកទោសសំខាន់ៗត្រូវបានរៀបចំឡើងដោយ[1072]។ អ្នកទោសកូនក្មេងមិនត្រូវបានគេកត់ឈ្មោះទេ[1073]។

13. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ធ្វើរបាយការណ៍ប្រចាំថ្ងៃផ្ញើទៅ ហ៊ី នៅម៉ោង7ព្រឹក។ របាយការណ៍ទាំងនេះមានព័ត៌មានពីស្ថានភាពអំពីអ្នកទោស ដែលត្រូវ "យកចេញ" នៅពេលយប់ ឬអ្នកទោសដែល ផ្តាក់ខ្លួនឈឺ[1074]។ បញ្ជីឈ្មោះអ្នកទោសសំខាន់ ដែលផ្តាក់ខ្លួនឈឺត្រូវផ្ញើទៅឱ្យ **឵ឌុច** តែម្តង[1075]។

14. សាក្សីនឹងពន្យល់ពីរបៀបបង្កើតបញ្ជីឈ្មោះដែលត្រូវសម្លាប់។ **ឌុច** នឹងចារណ៍លើបញ្ជីឈ្មោះបញ្ជាក់ឈ្មោះអ្នកទោសណាម្នាក់គួរត្រូវ "កម្ទេចចោល"។ បន្ទាប់មកបញ្ជីឈ្មោះទាំងនេះត្រូវបានបញ្ជូនទៅឱ្យ ហ៊ី ដែលជាអ្នកនាំយកអ្នកទោសមកឱ្យសាក្សី។ សាក្សីបានដកស្រង់ឈ្មោះដើម្បីធ្វើបញ្ជីឈ្មោះទូទៅដែលត្រូវសម្លាប់ ដោយធានាថាចំនួនសរុបស្របគ្នា ហើយកត់ត្រាលេខបន្ទប់និងលេខអគារ[1076]។ សាក្សីក៏បានបញ្ចូលឈ្មោះអ្នកទោស ដែលត្រូវពេទ្យបូមយកឈាម ទៅក្នុងបញ្ជីឈ្មោះទូទៅដែលត្រូវសម្លាប់[1077] តែសាក្សីនិយាយថា ហ៊ី បានឱ្យគាត់បញ្ចូលឈ្មោះទាំងនោះតែពីរដងប៉ុណ្ណោះ[1078]។ សាក្សីបានបញ្ជូនបញ្ជីឈ្មោះដែលត្រូវសម្លាប់ទៅ ហើយ ហ៊ី បានបញ្ជូនវាទៅ ហ៊ុយ, ប៉េងនិងស្រ៊ី ដើម្បីយកអ្នកទោសចេញពីបន្ទប់របស់ពួកគេ។ មុនពេលអ្នកទោសឡើងឡានដឹកទៅជើងឯក[1079] សាក្សីបានធ្វើការពិនិត្យឈ្មោះចុងក្រោយនៅឯខ្លោងទ្វារគុក។ គាត់ក៏បានចម្លងបញ្ជីឈ្មោះដែលត្រូវសម្លាប់ឱ្យ ទៅ ហ៊ី ហើយដែល ហ៊ី បញ្ជូនទៅឱ្យ **ឌុច**[1080] ។

### វចនាសម្ព័ន្ធអំណាច

15. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺជាប្រធានមន្ទីរស-២១ ហ៊ី គឺជាអនុប្រធាន ហើយ ហ៊ុយ ស្រែ គឺជាសមាជិក[1081]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា "ក្នុងការយកអ្នកទោសចេញពីមន្ទីរឃុំឃាំង" ឌុច បានបញ្ជា "ហ៊ី"[1082] ប៉ុន្តែ ហ៊ី បានបញ្ជា ហ៊ុយ, ប៉េង និង ស្រ៊ី ដើម្បីយកអ្នកទោសចេញ ពីបន្ទប់របស់ពួកគេ ហើយយកទៅជើងឯក[1083] ហ៊ី ក៏បានបញ្ជា ប៉េង ឱ្យយកកូនក្មេងចេញ ដែលប្រហែលជាត្រូវសម្លាប់ដែរ[1084]។ អ្នកយាមឋិតក្រោមការត្រួតត្រារបស់ ហ៊ឹម ហ៊ុយ ហើយបែងចែកចេញជា18ក្រុម[1085]។ គាត់បានផ្តល់ភស្តុតាងបញ្ជាក់ថា សុន សេន បានបង្ហាញមុខនៅមន្ទីរស-២១ ម្តងដើម្បីបើកមេទិញមួយ ហើយគាត់បានណែនាំខ្លួនថាជា "មន្ត្រីត្រួតបញ្ជាម្នាក់"[1086]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

16. សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា នៅពេលមន្ទីរស-២១ មានទីតាំងនៅ*នគរបាលយុត្តិធម៌* អ្នកទោសខ្លះត្រូវបានគេដោះលែង[1087] ប៉ុន្តែក្រោយមក អ្នកទោសដែលមានថាននូវសក្តិបដិវត្តត្រូវបានសម្លាប់ចោលទាំងអស់[1088]។ មានមនុស្សរវាងពី10 និង100នាក់ម្តងត្រូវបានគេយកចេញពីគុកទៅសម្លាប់ចោល[1089]។ សាក្សីបានឃើញប្រជាជនវៀតណាមជាច្រើន[1090] (ប្រុស ស្រី ជនស៊ីវិល និងទាហាន) ព្រមទាំងប្រជាជនខ្មែរសាមញ្ញ ប្រជាជន17មេសា មន្ត្រីខ្មែរក្រហមមានឋានៈទាបខ្ពស់ និងទាហានខ្មែរក្រហម ក៏បានជាប់គុកនៅមន្ទីរស-២១ដែរ។ ក្នុងចំណោមអ្នកទោសរាប់ពាន់នាក់មានប្រពន្ធ កូនរបស់អ្នកទោស ក៏ត្រូវបានគេនាំយកមកមន្ទីរស-២១ ពីបទជាប់ពាក់ព័ន្ធនឹងខ្មាំងរបស់បក្ស[1091] កូនក្មេងត្រូវបានដាក់ដោយឡែកពីឪពុកម្តាយ ហើយសម្លាប់ដោយ ប៉េង តាមការណែនាំរបស់ ហ៊ោ[1092]។ គាត់ផ្ដល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញអ្នកទោសបស្ចឹមប្រទេសតែម្នាក់ប៉ុណ្ណោះ ភេទប្រុស ស្បែកស នាំមកពីកំពង់សោម[1093]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

17. សាក្សីផ្ដល់ភស្តុតាងបញ្ជាក់អំពីរបបអាហារមិនស្អាត និងស្ថានភាពរស់នៅអមនុស្សធម៌នៃអ្នកទោសក្នុងមន្ទីរស-២១ ហើយពន្យល់ថា មានអ្នកទោសជាច្រើនបានឈឺ និងស្លាប់ដោយការធ្វើទារុណកម្មហួសកម្រិត ឬដោយកង្វះចំណីអាហារសមរម្យ[1094]។ មានបន្ទប់សម្រាប់ឃុំឃាំងមនុស្សចំនួនច្រើនមួយចំនួនដែលឃុំអ្នកទោសក្នុងស្ថានភាព ដូចបានពិពណ៌នាក្នុងផ្ទាំងគំនូររបស់ វ៉ាន់ ណាត[1095]។

## ការសួរចម្លើយ

18. សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា **ឌុច,** ចាន់, ប៉ុន និង ទុយ ទទួលខុសត្រូវចំពោះការសួរចម្លើយ[1096] ដែលប្រព្រឹត្តទៅនៅកន្លែងពិសេសខាងក្រៅបរិវេណធំ[1097] នៃមន្ទីរស-២១ ក្នុងផ្ទះតាមបណ្តោយមហាវិថីមន្ទីរវង្ស[1098]។ អ្នកសួរចម្លើយសុំលេខបន្ទប់អ្នកទោសដែលត្រូវសួរចម្លើយ បន្ទាប់មកអ្នកសួរចម្លើយទៅកាន់បន្ទប់ដើម្បីទាញអ្នកទោសចេញដោយខ្លួនឯង[1099]។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា **ឌុច** បានត្រួត ត្រាការសួរចម្លើយ ហើយ **ឌុច** ជាអ្នកសម្រេចថានៅពេលការសួរចម្លើយអ្នកទោសត្រូវបញ្ចប់[1100]។ គាត់ផ្ដល់ភស្តុតាងបញ្ជាក់អំពីសិទ្ធិធ្វើទារុណកម្មត្រូវបានរក្សាទុកសម្រាប់កងសួរចម្លើយ[1101]។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា ការសួរចម្លើយបានចាប់ផ្តើមនៅពេលព្រឹក ហើយប្រព្រឹត្តទៅរហូតដល់ម៉ោង11ព្រឹក ហើយបន្ទាប់មកចាប់បន្តរវាងដល់ម៉ោង1 និងម៉ោង2 រហូតដល់ល្ងាច ក្នុងករណីចាំបាច់បន្តរហូតដល់ពេលយប់[1102]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

19. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោស "ស្គមយ៉ាងខ្លាំងដោយហូបមិនគ្រប់គ្រាន់" អ្នកខ្លះស្លាប់ដោយអត់ឃ្លាន ហើយខ្លះទៀត "ស្លាប់ដោយសារការធ្វើទារុណកម្ម"[1103]។ នៅពេលអ្នកទោសវិលត្រឡប់មកពីការសួរចម្លើយវិញ វាបង្ហាញយ៉ាងច្បាស់ថា ពួកគេត្រូវបានគេធ្វើទារុណកម្ម[1104]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

20. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា "ត្រូវចាប់ខ្លួន មានន័យថា ត្រូវសម្លាប់"[1105]។ អ្នកទោសខ្លះបានស្លាប់ដោយអត់អាហារ ហើយខ្លះទៀត "ត្រូវបានធ្វើទារុណកម្មរហូតទល់ស្លាប់"[1106]។ ក្រោមអំណាចរបស់ ហ៊ា និង ឌុច ពេទ្យប្រមូលឈាមរបស់អ្នកទោស ដែល "មានន័យថាអ្នកទោសបានស្លាប់ [រួចទៅហើយ]"[1107]។ ក្មេងៗដែលជាប់ឃុំខ្លួននៅមន្ទីរស-២១ ត្រូវបានគេយកចេញពីរ ឬបីថ្ងៃបន្ទាប់ពីការមកដល់របស់ពួកគេ សាក្សីសន្និដ្ឋានថា ពួកគេត្រូវសម្លាប់ចោលហើយ[1108]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា កាលដែលមន្ទីរស-២១មានទីតាំងនៅ*នគរបាលយុត្តិធម៌* មានអ្នកទោសមួយចំនួនត្រូវបានដោះលែង[1109] ប៉ុន្តែក្រោយមកអ្នកទោសទាំងនោះត្រូវបានសម្លាប់ចោលទាំងអស់[1110]។ សាក្សីធ្វើការប៉ាន់ប្រមាណថា មានកម្មាភិបាលនៃមន្ទីរស-២១ មិនតិចជាង100នាក់ទេ ដែលត្រូវបានចាប់ខ្លួនយកទៅសម្លាប់ចោល[1111]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានដឹកអ្នកទោសចេញរៀងរាល់ថ្ងៃរាល់យប់[1112]។ អ្នកទោសត្រូវបានគេដាក់ខ្នោះដៃ និងចងរបាំងមុខ ហើយដាក់លើឡានដោយមិនដឹងថា ខ្លួនពិតជាត្រូវគេបញ្ជូនទៅសម្លាប់ចោលផង[1113]។

## សក្ខីកម្មមុនៗ

21. សាក្សីបានផ្តល់សក្ខីកម្មមុនចំនួនដប់ជូនទៅសហព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ សួស ធី របស់សហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី18 ខែតុលា ឆ្នាំ2007 D22/9, ERN 00162608-00162622 (អង់គ្លេស) 00164415-00164428 (ភាសាបារាំង) និង 00162594-00162607 (ភាសាខ្មែរ) ។

(2) កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុរបស់សហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.កលើឈ្មោះ ស្ទួស ធី ចុះថ្ងៃទី27 កុម្ភៈ 2008, D48/2 ERN 00197998-001978008 (អង់គ្លេស) 00181347-00181356 (បារាំង) 00181328-00181346-KH (ខ្មែរ)។

(3) កំណត់ហេតុលាយលក្ខណ៍អក្សរនៃការតទល់មុខគ្នារបស់ ស្ទួស ធី នៃសហចៅក្រមស៊ើបអង្កេតរបស់អ.វ.ត.ក ចុះថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2008 D54, ERN 00166561-000166570 (អង់គ្លេស) 00166571-00155580 (បារាំង) និង 00166588-00166599 (ភាសាខ្មែរ)។

(4) ចម្លើយសាក្សីឈ្មោះ ស្ទួស ធី របស់សហសហព្រះរាជអាជ្ញានៃអ.វ.ត.ក ចុះថ្ងៃទី2 ខែតុលា ឆ្នាំ2006 ISDN 23.9 ERN 000146797-000146802 (ភាសាអង់គ្លេស) និង 0078972-0078985 (ភាសាខ្មែរ) ។

(5) ចម្លើយសាក្សីឈ្មោះ ស្ទួស ធី របស់ DC-Cam ចុះថ្ងៃទី25 សីហា 2003 និងថ្ងៃទី20 តុលា 2004 D61/I-ឧបសម្ព័ន្ធ ERN 00051974-00052009 00052010-00052038 (ខ្មែរ) សង្ខេប ជាភាសាអង់គ្លេស (ERN 00185877-00185880)។

(6) ចម្លើយសាក្សីឈ្មោះ ស្ទួស ធី ក្នុងអត្ថបទមានចំណងជើងថា៖ "អតីតសមមិត្តរួមគ្នានៃមន្ទីរ ស-២១ និងការចងចាំបទពិសោធន៍អតីតរបស់ខ្លួន" ដោយ ហ៊ុយ វណ្ណៈ ទស្សនាវដ្ដីស្វែងរកការពិតរបស់ DC-Cam លេខ31 ខែកក្កដា ឆ្នាំ2002 D5/2, ERN 00104911-00104912 (អង់គ្លេស) ។

(7) ចម្លើយសាក្សីឈ្មោះ ស្ទួស ធី ក្នុង *កម្ពុជា៖ 25 ឆ្នាំបន្ទាប់ពីរបបខ្មែរក្រហម* ដោយ Ker Munthit សម្រាប់កាសែត Associated Press 6 កុម្ភៈ 2004. លេខ ERN មិនមាននៅក្នុងសំណុំរឿងទេ: http://community.seattletimes.nwsource.com/archive/?date=20040106&slug=cambodia06 បើកមើលនៅថ្ងៃទី31 ខែតុលា 2008 (ភាសាអង់គ្លេស)។

(8) ចម្លើយសាក្សីឈ្មោះ ស្ទួស ធី) *ក្នុងមន្ទីរស-២១ ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម* ដោយ ឫទ្ធី ប៉ាន់ ឆ្នាំ2002 D69 ERN V 00172620។

(9) ចម្លើយសាក្សីឈ្មោះ សួស ធី ក្នុងខ្សែភាពយន្ត *ខាងក្នុងគុកសម្ងាត់របស់ប៉ុលពត* ដោយ Bill BRUMMEL ចុះថ្ងៃទី4 ខែកក្កដា ឆ្នាំ2000 D69 V 00172525។

(10) ចម្លើយសាក្សីឈ្មោះ សួស ធី ក្នុងខ្សែភាពយន្ត *កម្ពុជា* ដោយ Channel 4 ព័ត៌មាន (UK), ចុះឆ្នាំ 1998 D69 ERN V 00172404។

## ឯកសារពាក់ព័ន្ធ

22. ក្នុងចំណោមឯកសារផ្សេងៗ ឯកសារខាងក្រោមនេះមានការពាក់ព័ន្ធផងដែរទៅនឹងភស្តុតាងរបស់ សាក្សី៖

(1) ជីវប្រវត្តិនៅមន្ទីរស-២១របស់ សួស ធី ឆ្នាំ1977 D61/I-ឧបសម្ព័ន្ធ ERN 00051642 (ភាសាខ្មែរ) ។

(2) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ឆ្នាំ1978 D57 ERN 00008079-00008081 (ភាសាខ្មែរ)

(3) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី6 ខែមករា ឆ្នាំ1978 ឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូន រឿងឱ្យស៊ើបសួរ 16.81 ERN 00087046-00087047 (ភាសាខ្មែរ)

(4) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី23 ខែមករា ឆ្នាំ1978 D57 ERN 00087048-00087049 (ភាសាខ្មែរ)

(5) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី23 ខែមករា 1978 D57 ERN 00087050-00087050 (ភាសាខ្មែរ)

(6) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី28 ខែមេសា ឆ្នាំ1978 D57 ERN 00087036-00087041 (ភាសាខ្មែរ)

(7) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី24 ខែឧសភា ឆ្នាំ1978 ឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 16.136, ERN 00021269-00021274 (ភាសាខ្មែរ)

(8) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី2 ខែមិថុនា ឆ្នាំ1978 ឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 16.145 ERN 00079359-00079360 (ភាសាខ្មែរ)

(9) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី2 ខែមិថុនា ឆ្នាំ1978 ឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 16.146, ERN 00021149-00021149 (ភាសាខ្មែរ)

(10) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ចុះថ្ងៃទី9ខែមិថុនា ឆ្នាំ1978 D57 ERN 00086964-00086968 (ភាសាខ្មែរ)

(11) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ចុះថ្ងៃទី17ខែមិថុនា 1978 D57 ERN 00086969-00086971 (ភាសាខ្មែរ)

(12) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ចុះថ្ងៃទី30ខែមិថុនា ឆ្នាំ1978 D57 ERN 00021178-00021180 (ភាសាខ្មែរ)

(13) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ចុះថ្ងៃទី11ខែកក្កដា ឆ្នាំ1978 D57 ERN 00021136-00021136 (ភាសាខ្មែរ)

(14) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ ចុះថ្ងៃទី28 ខែកក្កដា ឆ្នាំ1978 ឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ 16.151 ERN 00021184-00021201 (ភាសាខ្មែរ)

(15) បញ្ជីឈ្មោះអ្នកទោសនៃមន្ទីរស-២១ចុះថ្ងៃទី3ខែកញ្ញា ឆ្នាំ1978 D57 ERN 00087014-00087015 (ភាសាខ្មែរ)

## 26. គយ តេង

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្ដល់ភស្ដុតាងបញ្ជាក់ថា រចនាសម្ព័ន្ធនិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹងមន្ទីរស-២១ សាក្សីនេះផ្ដល់ភស្ដុតាងបញ្ជាក់អំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត ថេរៈវេលា និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញអ្នកទោស *(141-142)* ។ ភស្ដុតាង របស់គាត់គឺជាប់ពាក់ព័ន្ធនឹងបទចោទ1, 2 និង 3 នៃដីកាចោទប្រកាន់។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុប្រហែល17ឆ្នាំនៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ជាជនជាតិខ្មែរ ភេទប្រុស កើតក្នុងឆ្នាំ 1958[1114]។ ក្នុងឆ្នាំ1973 គាត់បានចូលធ្វើទាហានខ្មែរក្រហម ក្នុងកងពលធំលេខ12។ បន្ទាប់ពីថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីបានធ្វើស្រែរហូតដល់គាត់ត្រូវផ្ទេរទៅធ្វើការនៅមន្ទីរស-២១ នៅដើមឆ្នាំ 1978[1115]។ សាក្សីផ្ដល់ភស្ដុតាងបញ្ជាក់ថា គាត់បានយាមនៅខាងក្រៅគុកធំ និងស្ថានីយ៍មួយកន្លែងមានចម្ងាយពី200 ទៅ300ម៉ែត្រខាងកើតគុក។ សាក្សីផ្ដល់ភស្ដុតាងបញ្ជាក់ថា ក្រោយមកក្នុងឆ្នាំ1978 គាត់ត្រូវបានគេផ្ទេរឱ្យទៅធ្វើការនៅជើងឯក ជាមួយអ្នកផ្សេងទៀតនៃក្រុមរបស់គាត់ ដើម្បីជីករណ្ដៅ និងយាមអ្នកទោស[1116]។ សាក្សីដោយផ្ទាល់ក៏បានទទួលស្គាល់ការសម្លាប់អ្នកទោសនៅឯជើងឯកផងដែរ[1117]។ រយៈពេលពីរខែមុនពេលការដួលរំលំនៃរបបខ្មែរក្រហម សាក្សីត្រូវបានគេបញ្ជូនទៅព្រៃស ពីព្រោះបងប្អូនជីដូនគាត់ ជាប្រធានកងវរៈសេនាធំក្នុងកងពលធំលេខ703 ត្រូវបានចាប់ខ្លួន[1118]។

## វេចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បងប្អូនជីដូនមួយរបស់គាត់គឺជាប្រធានកងវរៈសេនាធំក្នុងកងពលធំលេខ 703[1119]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានធ្វើមេទិញ"ណែនាំ"ម្តងដែរសម្រាប់មន្ទីរស-២១ ទាំងមូលមិនមែនសម្រាប់ផ្នែកទាំងឡាយទេ ដែលក្នុងមេទិញនោះគេបានប្រាប់ឱ្យមានការប្រុងប្រយ័ត្ន មិនឱ្យអ្នកទោសរត់រួចខ្លួនទេ[1120]។ នៅព្រៃសមាន "មេទិញណែនាំ"ជាច្រើនសម្រាប់ក្រុមនីមួយៗបន្ទាប់បាយល្ងាចរួច អប់រំអ្នកទោស "ឱ្យខិតខំព្យាយាមធ្វើការ"[1121]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺជាប្រធានមន្ទីរស-២១[1122]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញ **ឌុច** ដើរក្នុងគុក ហើយជូនកាលគាត់បើកម៉ូតូ[1123]។ នៅឯមេទិញអប់រំនយោបាយ **ឌុច**បានប្រកាសថា បងប្អូនជីដូនមួយរបស់សាក្សីឈ្មោះ អ៊ុក តែម ត្រូវបានចាប់ខ្លួនហើយ[1124]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

5. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា កាលដែលគាត់ធ្វើការនៅមន្ទីរស-២១ គាត់បានធ្វើស្រែទាំងថ្ងៃទាំងយប់ ពួកគេបានយាមដោយប្តូរវេនគ្នាពីរម៉ោងម្តង ក្រុមផ្សេងទៀតយាមពេលថ្ងៃ ហើយក្រុមរបស់គាត់នៅផ្ទះនៅខាងកើតប្រឡាយលូទឹកស្អុយ[1125]គេធ្វើ "មេទិញណែនាំ"ម្តងដែរសម្រាប់បុគ្គលិកមន្ទីរស-២១ទាំងមូល ប៉ុន្តែមិនមែនសម្រាប់ផ្នែកទាំងឡាយនោះទេ នៅក្នុងមេទិញនោះគេបានប្រាប់ឱ្យប្រុងប្រយ័ត្ន មិនឱ្យអ្នកទោសរត់រួចខ្លួនទេ[1126]។

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញឡានចេញចូលមន្ទីរស-២១ ហើយក្រោយមកគាត់បានដឹងថា ឡានទាំងនោះដឹកអ្នកទោស[1127]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បុគ្គលិកមន្ទីរស-២១ក៏ត្រូវបានគេចាប់ខ្លួនដែរ ប៉ុន្តែមិនមានអ្នកណាម្នាក់ក្នុងក្រុមរបស់គាត់ត្រូវចាប់ខ្លួនទេ[1128]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា កាលគាត់ធ្វើការនៅជើងឯក គាត់បានឃើញឡានដឹកអ្នកទោសមកពីមន្ទីរស-២១ ស្រ៊ីម (SRIM) គឺជាអ្នកបើកបរ អមដោយ ហ៊ុយ និងក្រុមរបស់គាត់[1129]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មិនមានអ្នកណាផ្សេងទៀត ទេនៅជើងឯក មានតែក្រុមរបស់គាត់មានគ្នាចំនួនដប់នាក់ប៉ុណ្ណោះ[1130]។

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ព្រៃសគឺជាកន្លែងលត់ដំសម្រាប់ប្រជាជនដែលជាប់ពាក់ព័ន្ធជាមួយ “បញ្ហាសីលធម៌” និង “ទំនោរនយោបាយ” ជាកន្លែងអ្នកទោសធ្វើស្រែ កសាងទំនប់ ជីកប្រឡាយ[1131] ហ៊ុយ គឺជាប្រធានព្រៃស។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅព្រៃសគាត់បានធ្វើការពីព្រឹកព្រលឹមដល់ម៉ោង12ថ្ងៃត្រង់ ហើយក្រោយមកបន្ទាប់ពីបាយថ្ងៃត្រង់រហូតដល់ម៉ោង5 ឬ6ល្ងាច ហើយបន្ទាប់មកចូលរួមមេទិញនៅពេលល្ងាច។ មិនមានអាហារហូបគ្រប់គ្រាន់ទេ កន្លែងធ្វើការមានការឃាមតឹងរ៉ឹងណាស់នៅពេលយប់[1132]។

## រចនាសម្ព័ន្ធអំណាច

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុច គឺជាប្រធានមន្ទីរស-២១ ហើយ ហ៊ី ជាអនុប្រធាន[1133]។ នៅខណៈនោះគាត់មិនបានដឹងថា **ឌុច** មានមុខមាត់យ៉ាងម៉េចទេ គាត់បានឃើញHorនៅជើងឯកពីរដង[1134]។ ហ៊ឹម ហ៊ុយ គឺប្រធានរបស់ក្រុមសាក្សី គាត់បានមកដល់ដោយដឹកអ្នកទោសមក ហើយបានណែនាំក្រុមរបស់សាក្សីឱ្យជីករណ្តៅ[1135]។ សាក្សីបានរស់នៅក្នុងមន្ទីរស-២១ ជាមួយប្រធានក្រុមម្នាក់ផ្សេងទៀតឈ្មោះ ទ្រី[1136]។ កម្មាភិបាលម្នាក់ផ្សេងទៀតឈ្មោះ ហ៊ុយ ត្រូវគេពិពណ៌នាថាជាប្រធានព្រៃស[1137] សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ណាង បានបញ្ជូនគាត់ឱ្យមកធ្វើការនៅមន្ទីរស-២១[1138]។ សាក្សីក៏បាននិយាយផងដែរថា ស្រ៊ឹម បានបើកឡានដឹកអ្នកទោសពីមន្ទីរស-២១ ទៅជើងឯក ហើយថា ស្រ៊ឹម និងក្រុមរបស់ គាត់បាននាំអ្នកទោសនៅឯជើងឯកទៅសម្លាប់ចោល។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឈួន គឺជា សមាជិកម្នាក់នៃក្រុមរបស់គាត់នៅជើងឯក[1139]។ សាក្សីក៏ស្គាល់មាស ប៉េងគ្រីផងដែរ[1140]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសនៅព្រៃសត្រូវបានគេចោទប្រកាន់ជាប់ពាក់ព័ន្ធនឹង “បញ្ហាសីលធម៌” និង “ទំនោរនយោបាយ” ដូចជាសាច់ញាតិដែលជាអតីតទាហានលន់ ណុល។ មានប្រជាជនចំនួនប្រហែល200នាក់រស់នៅទីនោះ ក្នុងនោះរួមមានបុរសស្ត្រី បែងចែកជាក្រុមមានគ្នា20ទៅ25នាក់[1141]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញកូនក្មេងនៅជើងឯកទេ[1142]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញអ្នកទោសជាប់ខ្នោះ និងបិទរបាំងមុខ[1143]។ សាក្សីក៏បាននិយាយផងដែរថា ជាអ្នកទោសម្នាក់នៅព្រៃស គាត់ត្រូវគេបង្ខំឱ្យធ្វើការពីព្រឹកព្រលឹម រហូតដល់ម៉ោង6ល្ងាច ហើយរបបអាហារហូបចុកមិនគ្រប់គ្រាន់[1144]។

## ការសួរចម្លើយ

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានដឹងថា អ្នកទោសត្រូវបានគេសួរចម្លើយក្នុងផ្ទះខាងក្រៅបរិវេណគុក ហើយគាត់បានឃើញអ្នកទោសទាំងនោះដើរទៅដើរមកពីការសួរចម្លើយ ដោយចងរបាំងមុខ ដៃចងស្ពាយសេក[1145]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

12. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ទោះបីគាត់មិនដែលបានឃើញអ្នកទោសត្រូវគេធ្វើទារុណកម្មក៏ដោយ ក៏គាត់បានឮសំលេងស្រែករបស់ពួកគេជាមួយនឹងការឈឺចាប់នៅឯផ្ទះទាំងឡាយខាងក្រៅបរិវេណគុក ជាកន្លែងដែលពួកគេកំពុងត្រូវគេសួរចម្លើយដែរ[1146]។ គាត់ក៏និយាយផងដែរថា គាត់បានដឹងថា អ្នកទោសត្រូវបានគេវាយ និងឆក់ខ្សែភ្លើង[1147]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញអ្នកណាម្នាក់ត្រូវធ្វើទារុណកម្មនៅព្រៃសទេ[1148]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

13. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសត្រូវបានគេសម្លាប់នៅជើងឯក[1149] ហើយថារួមគ្នាជាមួយសមាជិកផ្សេងទៀតនៃក្រុមរបស់គាត់ គាត់ខ្លួនឯងផ្ទាល់បានអនុវត្តការប្រហារជីវិតទាំងនេះខ្លះដែរ ទោះបីវាមិនមែនជា "ការងារជាទម្លាប់"ក៏ដោយ[1150]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញគេសម្លាប់កូនក្មេងទេ ឃើញតែបុរសនិងស្ត្រី ហើយថា គាត់មិនដែលបានឃើញឈ្លើយសឹកបរទេសទេ[1151]។ ហ៊ុយ បានណែនាំគាត់និងក្រុមរបស់គាត់ឱ្យជីករណ្តៅ បីម៉ែត្រការ៉េ ជំរៅពីម៉ែត្រ ពួកគេជីកនៅពេលថ្ងៃ រណ្តៅនីមួយៗចំណាយពេលជីកប្រហែលពីពីរ ឬបីថ្ងៃទើបរួច[1152]។

14. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសត្រូវបានគេដឹកទៅជើងឯកប្រហែលពី ឬបីដងក្នុងមួយខែ[1153] ឡានមកដល់នៅម៉ោង7ល្ងាចពីមន្ទីរស-២១ បើកបរដោយឈ្មោះ ស្រ៊ុម អមដោយ ហ៊ុយ។ សាក្សី

ផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានទទួលអ្នកទោសនៅពេលមកដល់ជើងឯកពី20ទៅ30នាក់ក្នុងមួយលើក ហើយថា គាត់មានបញ្ជីឈ្មោះកត់ត្រាអ្នកដែលបានមកដល់ និងអ្នកដែលត្រូវបញ្ជូនទៅសម្លាប់ចោល "ដើម្បីធ្វើឱ្យប្រាកដថា គ្មានអ្នកណាម្នាក់បាត់ខ្លួន"[1154]។ នៅពេលមកដល់ អ្នកទោសត្រូវបានគេយកចេញពីឡាន ដោយជាប់ខ្នោះ និងបិទរបាំងមុខ ហើយដាក់ក្នុងផ្ទះធ្វើអំពីឈើមួយក្បែរម៉ាស៊ីនភ្លើង[1155]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបាននាំអ្នកទោសទៅកាន់រណ្តៅបំភ្លឺដោយចង្កៀងប្រេងកាត់ ប្រាប់ឱ្យអ្នកទោសអង្គុយចុះចម្ងាយមួយម៉ែត្រពីមាត់រណ្តៅ ពីរឬបីនាក់អង្គុយក្បែរៗគ្នា ហើយវាយចំកញ្ចឹងកជាមួយនឹងទុយ្យូទឹក ខ្នោះដៃត្រូវបានដោះចេញនៅពេលអ្នកទោសដួល ហើយគេបានប្រើកាំបិតឆ្មោតដើម្បីបញ្ចប់ជីវិតពួកគេ[1156]។

15. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ក្រុមរបស់គាត់ឃាមកុំឱ្យអ្នកទោសរត់គេចខ្លួន គាត់មិនដែលបានឮអ្នកទោសស្រែកទេ ឮតែសម្លេងដួល ហើយក្រុមរបស់គាត់ជាអ្នកលុបរណ្តៅបន្ទាប់ពីសម្លាប់រួច[1157]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់អាចមើលឃើញឈាមនៅមាត់រណ្តៅ រណ្តៅនីមួយៗជាទូទៅមានសាកសពច្រើនជាងដប់នាក់ ដែលជាធម្មតាគេប្រើពីមួយ ឬពីររណ្តៅនៅពេលមានការសម្លាប់វាល់ផង[1158]។ ជាទូទៅគាត់ប៉ាន់ប្រមាណថា មានរណ្តៅចំនួនពី20 ទៅ30រណ្តៅ ហើយមិនបានចាំថាមានរណ្តៅថ្មីៗ មុនពេលគាត់បានមកដល់ទេ[1159]។

## សក្ខីកម្មមុនៗ

16. សាក្សីបានផ្តល់សក្ខីកម្មមុនចំនួនបួនជូនទៅសហព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ តយ តេង របស់សហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី 17 មករា 2008 D28/12 ERN 00163780-00163784 (**អង់គ្លេស**)

(2) ចម្លើយសាក្សីឈ្មោះ តយ តេង របស់សហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី 19 កុម្ភៈ 2008 D50/3 ERN 00164405-00164409 (**អង់គ្លេស**)

(3) កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុរបស់សហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.កលើឈ្មោះ តយ តេង ចុះថ្ងៃទី26 កុម្ភៈ 2008 D48/1 ERN 00197993-00197997 (**អង់គ្លេស**)

(4) កំណត់ហេតុលាយលក្ខណ៍អក្សរនៃការតទល់មុខគ្នារបស់ តយ តេង នៃសហចៅក្រមស៊ើបអង្កេតរបស់អ.វ.ត.ក ចុះថ្ងៃទី 28 កុម្ភៈ 2008 D52 ERN 00165434-00165440 (អង់គ្លេស)

## ឯកសារពាក់ព័ន្ធ

17. សាក្សីនឹងយោងទៅលើឯកសារពាក់ព័ន្ធនៅពេលជំនុំជម្រះ។

## IV. សាក្សីអង្គហេតុផ្សេងទៀតនៃកម្ពុជាប្រជាធិបតេយ្យ

## 27. លោក សំ ហៅ សោម សំអុល

### ចរិតលក្ខណៈ និងខ្លឹមសារនៃការធ្វើសក្ខីកម្ម

1. សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ទាក់ទងនឹងជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* និងវេចនាសម្ព័ន្ធគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)* ។ ទាក់ទងនឹងមន្ទីរស-២១ សាក្សីនេះផ្ដល់ភស្តុតាង បញ្ជាក់អំពីតួនាទីជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើតថេរៈវេលា និង ប្រតិបត្តិការមន្ទីរសន្តិសុខ *(20-42)* វេចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់គុក ការឃុំឃាំងខុសច្បាប់ កង្វះការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ទាសៈកម្ម ការឈឺចាប់ធ្ងន់ធ្ងរ និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសម្លាប់បំផុតពូជ ឃាតកម្ម និងការសម្លាប់អ្នក ទោសដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* ភស្តុតាងរបស់គាត់ គឺជាប់ពាក់ព័ន្ធ នឹងបទចោទ 1 2 និង 3 នៃដីកាចោទប្រកាន់។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ18 ឆ្នាំ នៅថ្ងៃ17 ខែមេសា ឆ្នាំ1975 គឺជាជនជាតិកម្ពុជា ភេទប្រុស កើតនៅថ្ងៃទី25 ខែកក្កដា ឆ្នាំ1957[1160]។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា គាត់គឺជាអ្នកនាំសារឱ្យក្រសួងការបរទេស ពីឆ្នាំ1976 រហូតដល់ចុងរបប និយាយជាមួយ និងឱ្យសំបុត្រនិងឯកសារដោយផ្ទាល់ទៅ **ឌុច** នៅផ្ទះរបស់គាត់[1161]។ គាត់ក៏បានឃើញ **ឌុច** ចូលរួមប្រជុំប្រចាំសប្ដាហ៍ជាមួយមេដឹកនាំជាន់ខ្ពស់ផងដែរ នៅក្រសួងការបរ ទេស[1162]។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា ក្នុងឆ្នាំ1977គាត់បានធ្វើការនៅតាមព្រំដែនកម្ពុជា-វៀតណាមអស់រយៈពេលពីរខែ នៅកន្លែងនោះគាត់បានឃើញកងទ័ពកម្ពុជាប្រជាធិបតេយ្យឈ្លានពានទឹកដីវៀតណាម ហើយចាប់ទាហាននិងជនស៊ីវិលវៀតណាម[1163]។ សាក្សីផ្ដល់ភស្តុតាងបញ្ជាក់ថា គាត់បានចូលរួមអាពាហ៍ពិពាហ៍របស់ **ឌុច**[1164]។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ក្នុងឆ្នាំ1977 គាត់បានធ្វើការនៅតាមព្រំដែនកម្ពុជា-វៀតណាមអស់រយៈពេលពីរខែ នៅកន្លែងនោះគាត់បានឃើញកងទ័ពកម្ពុជាប្រជាធិបតេយ្យឈ្លានពានទឹកដី វៀតណាម ហើយចាប់ទាហាននិងជនស៊ីវិលវៀតណាម[1165]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មេទិញមុនការប្រយុទ្ធ មេបញ្ជាការបានណែនាំឱ្យកងទ័ពរបស់ខ្លួនសម្លាប់គ្រប់ជនជាតិវៀតណាម ដែលគេប្រទះឃើញ "ដើម្បីបោសសំអាតឱ្យអស់"[1166]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា កងទ័ពកម្ពុជាប្រជាធិបតេយ្យមកពីកងពលធំជាច្រើន បញ្ជាដោយ ល្វៃ និង ណាត បានចាប់ខ្លួនប្រជាជនចំនួនប្រហែល40នាក់ ភាគច្រើនជាទាហានវៀតណាមក្នុងឯកសណ្ឋានពណ៌ខៀវ ជាមួយនឹងស្ត្រីនិងជនស៊ីវិលមួយចំនួន[1167] ថាន់, ប៉េង និង ហ៊ី មកពីក្រុមរបស់ ឆេន បានចាប់អ្នកទោសវៀតណាមទាំងអស់នេះដាក់ឡានពាក់ស្លាក់លេខ មន្ទីរស-២១ ផ្ញោះទៅកាន់មន្ទីរស-២១[1168]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញតេឡេក្រាមមួយ មានបញ្ជារបស់ថ្នាក់លើ ឲ្យបាញ់វៀតណាម ដែលចាប់ខ្លួនបាននោះចោលក្នុងសង្គ្រាមពេលយប់ លើកលែងតែអ្នកធំតែប៉ុណ្ណោះ[1169]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានយកសំបុត្រពីក្រសួងការបរទេសទៅឱ្យ **ឌុច** ដោយផ្ទាល់នៅមន្ទីរស-២១ ដោយមានពាក្យថា៖ "គោរពជូនសមមិត្ត **ឌុច** ប្រធានមន្ទីរស-២១"[1170]។ ផ្ទះ ឌុច មានទីតាំងឋិតនៅខាងក្រៅរបងមន្ទីរស-២១ ខាងមុខផ្ទះខ្ពស់ៗ ដែលគេស្គាល់ថា "ស្រះស្រង់"[1171]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា តបមកវិញ ឌុច បានសរសេរថា៖ "បានទទួលលិខិតលេខ..."[1172]។ **ឌុច** បានស្នើសុំសាក្សីកុំឱ្យប្រាប់អ្នកណាអំពីការយកសំបុត្រមកឱ្យគាត់ ហើយប្រសិនបើគាត់ប្រាប់អ្នកណា **ឌុច** នឹងប្រាប់អៀងសារីឱ្យគេចាប់គាត់[1173]។

5. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ក្នុងមួយសប្តាហ៍ម្តង អ្នករត់សំបុត្ររបស់ **ឌុច** ឈ្មោះ ឆេន បាននាំយកឯកសារពីមន្ទីរស-២១ ទៅក្រសួងការបរទេស[1174]។ ឯកសារភាគច្រើនជាឯកសារសរសេរដៃអំពីចម្លើយសារភាពរបស់អ្នកទោស[1175]។ នៅសាក្សីសួរ ឆេន អំពីឯកសារទាំងនោះ គាត់បានឆ្លើយថា គាត់យកឯកសារទាំងនេះទៅឱ្យ "ពូ"ដើម្បីពិនិត្យ[1176]។

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ក្នុងឆ្នាំ1976 គាត់បានឃើញ ប៉េង មកពីមន្ទីរស-២១ ដើម្បីចាប់ប្រជាជនដែលរស់នៅជុំវិញគាត់[1177]។

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ចាប់ពីឆ្នាំ1977 ដល់1979 គាត់បានឃើញ **ឌុច** ចូលរួមក្នុងមេទិញ ប្រចាំសប្តាហ៍នៅឯក្រសួងការបរទេស ជាមួយអៀងសារី ប៉ុលពត, សុន សេន, នួន ជា និងតាម៉ុក[1178]។ ជួនកាល **ឌុច** មកជួបតែ សុន សេន ឬតាម៉ុក និងប្រធានផ្នែកផ្សេងៗទៀតប៉ុណ្ណោះ[1179]។ **ឌុច** កាន់សឺមីឯកសារជានិច្ច គឺជាឯកសារដែលដូចគ្នានឹង ឆេន ដឹកដោយម៉ូតូ[1180]។ សាក្សីជឿ ជាក់ថា ឯកសារទាំងនេះគឺជាឯកសារចម្លើយសារភាព[1181]។

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានចូលរួមអាពាហ៍ពិពាហ៍របស់**ឌុច**[1182]។ អ្នកចូលរួមមាន សុន សេន, នួន ជា អៀងធិរិទ្ធ[1183]។ សាក្សីជឿជាក់ថា **ឌុច**គឺជាមនុស្សសំខាន់ដោយ សារថាមានអ្នកធំជាច្រើនបានចូលរួមអាពាហ៍ពិពាហ៍[1184]។ សាក្សីជឿជាក់ថា អ្នកដែលចូលរួមអាពាហ៍ពិពាហ៍ទាំងនោះសុទ្ធតែ បានដឹងអំពីមន្ទីរស-២១ និងការងាររបស់ឌុច ដោយហេតុថាឌុច បើកចំហអំពីការងាររបស់ខ្លួន[1185]។

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** ពេញចិត្តនឹងការងាររបស់ខ្លួន[1186]។ នៅពេលក៏ដោយឱ្យតែសាក្សីបានជួប**ឌុច** គាត់តែងតែញញឹម និងបានធ្វើការយ៉ាងសកម្ម[1187]។ ជួនកាល**ឌុច**សុំឱ្យសាក្សីវិលត្រឡប់មកកន្លែងរបស់គាត់ពីព្រលឹម ដើម្បីកុំឱ្យឌុចខាតពេលក្នុងការនិយាយគ្នាយូរ[1188]។ ស្ទើងគ្រប់ពេល ឌុច ជិះម៉ូតូ CLរបស់គាត់ ហើយជួនកាលបើកឡានហ្ស៊ីបផងដែរ[1189]។

## ការបង្កើត ថេរៈវេលា និងប្រតិបត្តិការ

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានដឹងអំពីមន្ទីរស-២១ក្នុងឆ្នាំ1976 នៅពេលដែលគាត់បានឃើញ ប៉េង មកមន្ទីរស-២១ ដើម្បីចាប់ប្រជាជនរស់នៅជុំវិញគាត់[1190]។

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ចាប់ពីឆ្នាំ1977 ដល់ឆ្នាំ1979 គាត់បានឃើញ**ឌុច** ចូលរួមមេទិញប្រចាំសប្តាហ៍នៅក្រសួងការបរទេសជាមួយ អៀង សារី ប៉ុល ពត, សុន សេន, នួន ជា និងតាម៉ុក[1191]។

12. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បុគ្គលិកមន្ទីរស-២១ឈ្មោះ ថាន់, ប៉េងនិង ហ៊ី មកពីក្រុមរបស់ ឆេន ទាំងអស់គ្នាបានចាប់អ្នកទោសវៀតណាមពីសមរភូមិទៅកាន់មន្ទីរស-២១[1192]។

## វេទនាសម្ព័ន្ធអំណាច

13. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានរត់សំបុត្រពីក្រសួងការបរទេសយកទៅឱ្យ ឌុច ដោយផ្ទាល់នៅមន្ទីរស-២១ មានដែលមានសរសេរពាក្យថា៖ "ជូនចំពោះសមមិត្ត ឌុច ប្រធានមន្ទីរស-២១"[1193]។ ថាន់, ប៉េង និង ហ៊ិ មកពីក្រុមរបស់ ឆេន ទទួលខុសត្រូវក្នុងការចាប់អ្នកទោសវៀតណាម ពីសមរភូមិទៅកាន់មន្ទីរស-២១[1194]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

14. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ក្នុងឆ្នាំ1976 ប៉េង មកពីមន្ទីរស-២១មកចាប់ប្រជាជនដែលរស់នៅជុំវិញគាត់[1195]។ សមាជិកពីរនាក់នៃកងពលធំលេខ310 ត្រូវបានចាប់ខ្លួនដោយសារមេដឹកនាំរបស់ខ្លួនត្រូវបានគេចាប់ខ្លួនរួចហើយ[1196]។

15. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ក្នុងឆ្នាំ1977 ទាហានវៀតណាម ស្ត្រីនិងជនស៊ីវិល ត្រូវបានចាប់ខ្លួនហើយបញ្ជូនទៅមន្ទីរស-២១[1197]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

16. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញតេឡេក្រាមមួយ មានបញ្ជារបស់ថ្នាក់លើឱ្យបាញ់វៀតណាម ដែលចាប់ខ្លួនបាននោះចោល ក្នុងសង្គ្រាមពេលយប់ លើកលែងតែអ្នកធំតែប៉ុណ្ណោះ[1198]។

## សក្ខីកម្មមុនៗ

17. សាក្សីបានផ្តល់ចម្លើយដំបូងចំនួនពីរជូនទៅសហព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ ចេក សំ របស់ DC-Cam ចុះថ្ងៃទី12 ខែកក្កដា ឆ្នាំ2002 ឧបសម្ព័ន្ធ គ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឯកសារលេខ 19.20 ERN 00054752-54814 (ភាសាខ្មែរ) សង្ខេបខ្លីជាភាសាអង់គ្លេស 00184117-00184119។

(2) ចម្លើយសាក្សីឈ្មោះ សោម សំអុល របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី1 ខែមេសា ឆ្នាំ2008 D78/6 ERN 00186772-00186775 (ភាសាខ្មែរ) 00209205-00209208 (ភាសាអង់គ្លេស)។

# ឯកសារពាក់ព័ន្ធ

18. សាក្សីនឹងយោងទៅលើឯកសារពាក់ព័ន្ធនៅពេលជំនុំជម្រះ។

# V. អ្នកទោសមន្ទីរស-24

## 28. ប៊ូ ម៉ុន

### ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីចរិតលក្ខណៈនៃការវាយប្រហារជាប្រព័ន្ធ ឬវាលដាលលើប្រជាជនស៊ីវិល *(10-18 & 131-133)* និងរចនាសម្ព័ន្ធនិងគោលនយោបាយនៃកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)* ។ ទាក់ ទងនឹងមន្ទីរស -24 សាក្សីនេះផ្តល់ភស្តុតាងបញ្ជាក់អំពីតួនាទីជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)*, ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* និង ការធ្វើទុក្ខបុកម្នេញអ្នកទោស *(141-142)* ។ ការធ្វើសក្ខីកម្មរបស់គាត់គឺជាប់ពាក់ព័ន្ធនឹងបទចោទ1, 2 និង 3 នៃដីកាចោទប្រកាន់។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ29ឆ្នាំនៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ជាជនជាតិខ្មែរ ភេទប្រុស កើតនៅក្នុងឆ្នាំ1946។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មុនថ្ងៃទី17 ខែមេសា ឆ្នាំ1975 ប្តីរបស់គាត់បើករ៉ឺម៉កនៅភ្នំពេញ ក្រោយមកគេ បញ្ជូនគាត់ឱ្យទៅធ្វើការនៅក្រសួងថាមពល ប៉ុន្តែគាត់ត្រូវបានគេចាប់ខ្លួននៅក្នុងឆ្នាំ 1977។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ខ្លួនឯងក៏ត្រូវបានចាប់ខ្លួនយកទៅអណ្តូងកុង ផ្នែកមួយនៃព្រៃសដែរ[1199]។ ក្នុងឆ្នាំ1979 សាក្សីបានភៀសខ្លួនទៅអមលាំង ជាអ្នកទោសម្នាក់របស់ឌុច[1200]។

## ការវាយប្រហារជាប្រព័ន្ធ ឬរាលដាល

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីការកំទេចបុគ្គលនិងជនទាំងឡាយជាប់ខ្សែក្បត់នៅថ្ងៃទី17មេសា ដោយសារការជាប់ពាក់ព័ន្ធខ្សែនេះ គាត់ជឿជាក់ថា ប្តីរបស់គាត់ត្រូវគេចាប់ខ្លួន[1201]។ សាក្សីក៏បានបញ្ជាក់ថា ការចាប់ខ្លួនប្តីរបស់គាត់អាចដោយសារមុខតំណែងរបស់គាត់នៅក្រសួង គឺខណៈដែលបណ្តាញក្រសួងទាំងមូលត្រូវបានចាប់ខ្លួន និងការជាប់ពាក់ព័ន្ធប្តីខ្ញុំជាមួយភូមិភាគឧត្តរ និងការកំទេចភូមិភាគទាំងនេះ[1202]។ សាក្សីក៏អាចធ្វើសក្ខីកម្មផងដែរចំពោះការផ្ទេរដោយបង្ខំនិងការវាយប្រហារជាប្រព័ន្ធ ដែលកើតឡើងក្នុងអំឡុងពេលនៃការជម្លៀសមនុស្សពីទីក្រុងភ្នំពេញ ឃើញមានសាកសពហើយជាច្រើន នៅពេលដែលគាត់បានវិលត្រឡប់ទៅកាន់ទីក្រុងវិញ បន្ទាប់ពីត្រូវបានជម្លៀសមនុស្សអស់[1203]។

## វចនាសម្ព័ន្ធនិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ អំពីគោលនយោបាយកម្ពុជាប្រជាធិបតេយ្យនៃការចាប់ខ្លួនប្តីប្រពន្ធ និងកូនរបស់ជនទាំងឡាយ ដែលត្រូវបានគេចាប់ខ្លួនរួចហើយ ដូចដែលគាត់ត្រូវបានគេបញ្ជូនទៅព្រៃសបន្ទាប់ពីគេចាប់ប្តីរបស់គាត់។ គាត់ក៏អាចធ្វើសក្ខីកម្មផងដែរអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យនៃការធ្វើឱ្យអ្នកទាំងនោះត្រូវគេសង្ស័យថាជាជនក្បត់ ផ្តល់ជីវប្រវត្តិពីស្តារ[1204]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីបានប្រទះឃើញ**ឌុច**តែនៅពេលដែលពួកគេកំពុងរត់ភៀសខ្លួនក្នុងឆ្នាំ1979ប៉ុណ្ណោះ[1205]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានដឹងថា គាត់គឺប្រធានមន្ទីរស-២១[1206]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានបញ្ជូនគាត់ទៅព្រៃសក្នុងខែសីហា ឆ្នាំ1977 ហើយបាននៅទីនោះរហូតដល់ឆ្នាំ1979 នៅពេលដែលវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ[1207]។ នៅពេលគាត់បានមកដល់ គេបានថតរូបពាក់កណ្តាលខ្លួនគាត់[1208]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសធ្វើការនៅក្នុងវាលស្រែ រកត្រី ដាំបន្លែ[1209] ហើយចូលរួមមេទិញ ដែលក្នុងមេទិញនោះគេព្រមានមិនល្មួចអីហូបទេ[1210]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ អំពីអ្នកទោសនៅព្រៃសភាគច្រើន គឺជាសមាជិកគ្រួសារនៃប្រជាជនដែលត្រូវបានគេចាប់ខ្លួន ក្នុងនោះរួមមានកូនក្មេងផងដែរ[1211]។ មានអ្នកទោសប្រុសស្រីជាច្រើនរយនាក់មកពីការដ្ឋានជាច្រើនកន្លែង[1212]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញអ្នកទោសដែលមិនមែនជាជនជាតិខ្មែរទេ[1213]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ការងារមានការលំបាក់ អ្នកទោសត្រូវក្រោកនៅម៉ោង6ព្រឹក ហើយត្រូវធ្វើរហូតដល់ម៉ោង5ព្រឹក ដោយឱ្យឈប់សម្រាកតែមួយម៉ោងប៉ុណ្ណោះ[1214]។ អ្នកទោសដេកជាជួរនៅក្នុងផ្ទះវែងមួយ ហើយគេឱ្យហូបតែបន្តិចបន្តួចប៉ុណ្ណោះ បានបបររាវៗតែមួយចាននៅម៉ោង11 ហើយបាយមួយចាននៅពេលល្ងាច ហើយមិនឱ្យហូបផលដំណាំ ដែលអ្នកទោសទាំងនោះបានដាំដោយខ្លួនឯងនោះទេ[1215]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញអ្នកស្លាប់ដោយសារជំងឺណាស់[1216]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីរបៀបដែលគាត់ត្រូវបានគេវាយដោយសារការបេះផ្លែចេក បន្សល់ទុកស្លាក់ស្នាមពីឧប្បត្តិហេតុនោះ[1217]។ យោងតាមចម្លើយសាក្សីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលើកមុននេះគឺជាផ្នែកមួយនៃគោលនយោបាយដ៏ធំ ដែលអ្នកទោសត្រូវបានគេវាយដោយសារកំហុសស្រាល[1218]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីប្រជាជនបាត់ខ្លួននៅពេលយប់បន្ទាប់ពីគេហៅឈ្មោះរបស់ពួកគេ។ គាត់ក៏បានឃើញផ្ទាល់ភ្នែកផងដែរនូវការដឹកប្រជាជនចេញពីព្រៃស មិនឃើញត្រឡប់មកវិញទេ[1219]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បានទស្សនាជើងឯកបន្ទាប់ថ្ងៃទី7 ខែមករា ឆ្នាំ1979ហើយគាត់បានឃើញចម្រៀកខោអាវ និងកូនក្មេងសក់ពណ៌ក្រហម គាត់បានជឿថា អ្នកដែលបានបាត់ខ្លួន ត្រូវបានគេសម្លាប់នៅទី នោះ[1220]។

## សក្ខីកម្មមុនៗ

11. សាក្សីផ្តល់ចម្លើយដំបូងចំនួនពីរជូនទៅព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ ប៊ូ ផុន របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី11 ខែមករា ឆ្នាំ2008 ERN 00163760-00163763 ឯកសារ D28/10 (ភាសាអង់គ្លេស)

(2) ចម្លើយសាក្សីឈ្មោះ ប៊ូ ផុន របស់ DC-Cam ចុះថ្ងៃទី5 ខែធ្នូ ឆ្នាំ2002, ERN 00054505-00054571 (ភាសាខ្មែរ) ERN 00184111 (សង្ខេបភាសាអង់គ្លេស) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឯកសារលេខ 19.12.

## ឯកសារពាក់ព័ន្ធ

12. ឯកសារខាងក្រោមក្នុងចំណោមឯកសារផ្សេងៗ គឺមានការជាប់ពាក់ព័ន្ធនឹងភស្តុតាងរបស់សាក្សីផងដែរ៖

(1) ជីវប្រវត្តិរបស់ ប៊ូ ផុន ចុះថ្ងៃទី5 ខែធ្នូ ឆ្នាំ2002 ERN 00184111 (ភាសាខ្មែរ) (គ្មានសង្ខេបជាភាសាអង់គ្លេសទេ) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឯកសារលេខ 19.12 ។

## 29. ផាច សៀក ហៅ ថាច សៀក

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145) (10-18 & 131-133)* និងរចនាសម្ព័ន្ធនិងគោលនយោបាយនៃកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)* ។ ទាក់ ទងនឹងមន្ទីរស -24 សាក្សីនេះផ្តល់ភស្តុតាងបញ្ជាក់អំពីតួនាទីជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើតរយៈពេល និងប្រតិបត្តិការមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)*, ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី]) (107-128, 138, 139-140, 151 & 152 [ថ្មី])*។ ការធ្វើសក្ខីកម្មរបស់គាត់គឺជាប់ ពាក់ព័ន្ធនឹងបទចោទ1, 2 និង 3 នៃដីកាចោទប្រកាន់។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ20ឆ្នាំ នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975[1221] ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំប្រហែល 1955។ មុនថ្ងៃទី17 ខែមេសា ឆ្នាំ1975 សាក្សីគឺជាសមាជិកម្នាក់នៃរណៈសិរ្សរួបរួមជាតិសីហនុ។ កាលនោះគាត់ ចូលរួមក្នុងកងវរសេនាតូចពិសេសស្ត្រី ប្រយុទ្ធនៅកំពង់ចាម សៀមរាប និងជួយកាន់កាប់ភ្នំពេញ។ បន្ទាប់ពីថ្ងៃទី17 ខែមេសា ឆ្នាំ1975 កងពលធំរបស់គាត់ទទួលខុសត្រូវវត្តភ្នំ និងតំបន់ទួលគោក។ បន្ទាប់មក គាត់ត្រូវបានគេផ្ទេរឱ្យទៅធ្វើការនៅមន្ទីរពេទ្យយោធា ក្នុងគ្លីនិកអង្គឌួង។ សាក្សីត្រូវបានគេចាប់ខ្លួនបញ្ជូន ទៅព្រៃសនៅថ្ងៃទី18 ខែមីនា ឆ្នាំ1977[1222]។ សាក្សីត្រូវបានគេឃុំខ្លួននៅព្រៃសរហូតដល់របបកម្ពុជាប្រជាធិប តេយ្យដួលរលំ នៅខែមករា ឆ្នាំ1979។

## ជម្លោះប្រដាប់អាវុធ

3. សាក្សីគឺជាសមាជិកម្នាក់នៃក្រុមឃោធាពីរគឺ រណៈសិរ្សរួបរួមជាតិសីហនុ និងកងពលធំលេខ1 ជាកងពលដែលបង្កើតឡើងដោយស្រ្តីសុទ្ធសាធ[1223]។ ក្រុមទីពីរគឺជាផ្នែកមួយរបស់ខ្មែរក្រហម ដែល "រំដោះភ្នំពេញក្នុងខែមេសា ឆ្នាំ1975"[1224]។

## វចនាសម្ព័ន្ធ និងគោលនយោបាយក្នុងរបបកម្ពុជាប្រជាធិប្បតេយ្យ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ការដឹកនាំកងពលធំស្រ្តីត្រួយកា[1225]។ គាត់ក៏អាចបញ្ជាក់អំពីគោលនយោបាយនៃបក្សកុម្មុយនិស្តកម្ពុជាគឺ ការកំទេចនិងបាត់ខ្លួន "ជនក្បត់" និងការបង្ខំឱ្យធ្វើការនៅព្រៃស[1226]។

## តួនាទីរបស់ជនជាប់ចោទ

5. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុចមកចូលរួមមេទិញនៅព្រៃសក្នុងឆ្នាំ1978 ហើយបានប្រកាសថា គាត់គឺប្រធានគុកទួលស្លែងនិងគុកព្រៃស[1227]។ ក្នុងមេទិញនេះ គាត់បានអនុញ្ញាតឱ្យអ្នកទោសបញ្ចេញយោបល់របស់ខ្លួន និងបានពិភាក្សាអំពីរបៀបនៃទាហានភូមិភាគបូព៌ានិងភូមិភាគឧត្តរចូលជាមួយយួន[1228]។ គាត់បាននិយាយថា គាត់សោកស្តាយចំពោះការសម្លាប់សមមិត្តល្អៗ នៅពេលដែលមេដឹកនាំរបស់ពួកគេគឺជាជនក្បត់[1229]។

6. ឌុចក៏បានមកព្រៃសផងដែរនៅថ្ងៃទី5 ខែមករា ឆ្នាំ1979 ដើម្បីអ្នកដែលនៅសល់ពីស្លាប់ឱ្យត្រៀមខ្លួនដើម្បីរត់ភៀសខ្លួនចូលភ្នំឱរាល់[1230]។ សាក្សីបានឃើញ ឌុច មកទស្សនៈកិច្ចជាច្រើនលើកច្រើនសារ ប៉ុន្តែកម្មាភិបាលមន្ទីរស-24 ជាអ្នកវាយនិងធ្វើទារុណកម្មអ្នកទោសយ៉ាងធ្ងន់ធ្ងរ[1231]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** បានបញ្ជាឱ្យគេចាប់ខ្លួនប្រជាជន25នាក់យកទៅសម្លាប់ចោល ក្នុងនោះរួមមានរូបគាត់ផងដែរ ប៉ុន្តែតាមពិតគាត់គឺជាមនុស្សម្នាក់ក្នុងចំណោម6នាក់ត្រូវបានដោះលែង[1232]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

សាក្សីបានធ្វើការនៅព្រៃស[1233]។ តាមពិតទៅគាត់មិនដឹងអំពីមន្ទីរស-២១ទេ ប៉ុន្តែបានដឹងពីមុខតំណែងជាន់ខ្ពស់របស់**ឌុច** នៅពេល ដែលគាត់បានមកមើលព្រៃសម្តង[1234]។ សមមិត្ត ប៉ុង និងសមមិត្ត រឿង គឺជាប្រធាន និងអនុប្រធានទទួលបន្ទុកអ្នកទោសដែលត្រូវរៀបការ[1235]។ ព្រៃសមានទំហំ 4x4គីឡូម៉ែត្រការ៉េ គ្មានរបងព័ទ្ធ

ជុំវិញទេ ប៉ុន្តែខាងក្នុងមានកន្លែងធ្វើស្រែមួយកន្លែង និងអគារមន្ទីរជាច្រើន[1236]។ អ្នកទោសរស់នៅក្នុងផ្ទះនីមួយៗ ជាប់សោរនៅពេលយប់[1237]។ មានកងស្ត្រីវ័យចំណាស់ដែលបានរៀបការ និងកងស្ត្រីដែលមិនទាន់រៀបការ[1238]។

**រចនាសម្ព័ន្ធអំណាច**

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** បានមកមើលមន្ទីរស-២៤ (ព្រៃស) យូរៗម្តង ហើយកាន់មុខតំណែងជាន់ខ្ពស់[1239]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ធី ទទួលបន្ទុកព្រៃស ហើយ ផង គឺជាអនុប្រធាន[1240]។

**ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌**

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឮសម្លេងឡានចូលមកព្រៃស និងសម្លេងប្រមូលផ្តុំអ្នកទោស ហើយយកអ្នកទោសទាំងនោះទៅកន្លែងផ្សេងទៀត ប៉ុន្តែគាត់មិនដឹងយកទៅកន្លែងណា[1241]។ គាត់ផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញគេដោះលែងអ្នកទោសណាម្នាក់មកវិញទេ[1242]។

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានអ្នកទោសចំនួនពី500ទៅ600នាក់នៅព្រៃស ទាំងប្រុសទាំងស្រី[1243]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសជាច្រើននៅព្រៃសមកពីកងទ័ពប្រយុទ្ធ ដោយហេតុថាគេឃើញថាពួកទាំងនោះជាជនក្បត់[1244]។ អំពើក្បត់រួមមាន ការបង្ហាញការអាណិតអាសូរចំពោះការកំទេចជនរងគ្រោះ ឬត្រូវគេមើលឃើញថា "មានទំនោរទៅរក"វៀតណាម[1245]។ ប្រជាជន17មេសា នៅព្រៃសផងដែរ ប៉ុន្តែសាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញជនបរទេស ដូចជា វៀតណាមទេ[1246]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ប៉ុង បើកមេទិញនិយាយថា មន្ទីរស-២១គឺជាគុកសម្រាប់ដាក់អ្នកទាំងឡាយណាដែលក្បត់ជាតិ និងសម្រាប់ឃុំឃាំងអ្នកទោសកម្មាភិបាលថ្នាក់ខ្ពស់មកពីកម្រិតកងវរសេនាធំ មេបញ្ជាការកងពលធំ និងមេដឹកនាំភូមិភាគ ឯចំណែក ព្រៃសគឺជាគុកសម្រាប់អ្នកទោសថ្នាក់ទាប[1247]។

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ត្រូវបានគេចាប់ខ្លួនដោយគ្មានមូលហេតុ[1248]។ នៅពេលគាត់បានមកដល់ព្រៃសគាត់បានដឹងថា គាត់ត្រូវបានគេចាប់ខ្លួនដោយមូលហេតុជាជនក្បត់ និងសហការជាមួយយួន [1249]។ គាត់មិនដែលត្រូវបានគេសួរចម្លើយ ឬដាក់ច្រវាក់ទេ[1250]។

**ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌**

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីការងារនៅព្រៃស ចាប់ផ្តើមនៅម៉ោង2ព្រឹក រហូតដល់ថ្ងៃត្រង់[1251]។ មានការឈប់សម្រាកបាយថ្ងៃត្រង់ ដែលអ្នកទោសហូបបបរពីរវែក ហើយបន្ទាប់មកពួកគេត្រឡប់ទៅធ្វើការ

វិញចាប់ពីម៉ោង1:30ថ្ងៃរសៀល រហូតដល់5:30ល្ងាច[1252]។ បានឈប់សម្រាកហូបបបរទៀត ហើយបន្ទាប់មកពួកគេបន្តធ្វើការរហូតដល់ម៉ោង10យប់[1253]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា របបអាហាររបស់ពួកគេមិនគ្រប់គ្រាន់ទេ ហើយនៅពេលអ្នកទោសឈឺ ពួកគេបានថ្នាំពីរឬបីគ្រាប់ គ្មានការចាក់ថ្នាំអីទេ[1254]។ នៅព្រៃស អ្នកទោសមិនត្រូវបានគេអនុញ្ញាតឱ្យនិយាយរកគ្នាទេ ពួកគេត្រូវបានហាមឃាត់ពីការដើរហើរដោយសេរី ពួកគេត្រូវបានគេឃាមកាមទាំងថ្ងៃទាំងយប់[1255]។

12. អ្នកទោសលើកដីជាច្រើនម៉ែត្រគីប។ ការប្រមូលផលធ្វើឡើងនៅពេលងងិត អង្គុយនៅក្នុងទឹក។ ប្រសិនគុម្ពស្រូវនៅសល់តែមួយគុម្ព ទណ្ឌកម្មគឺការកាត់របបអាហារ[1256]។ សាក្សីត្រូវបានគេចាត់តាំងឱ្យធ្វើការស្រាលជាយថាហេតុ ត្បាញ់កន្ទេល។ កម្មករត្រូវគេវាយនឹងខ្សែតី និងធ្វើទារុណកម្ម[1257]។ គេចាក់សោទុកនៅពេលយប់ កម្មករខ្លះត្រូវបានគេឃុំទុកក្នុងគុកសម័យសង្គមចាស់ ហើយខ្លះទៀតឃុំទុកនៅក្បែរគុក [1258]។

13. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ប្រសិនអ្នកទោសប្រព្រឹត្តល្មើស ពួកគេទទួលទណ្ឌកម្មដោយកាត់បបរហូប និងទទួលការវាយដំ[1259]។ មានបន្ទប់មួយសម្រាប់ឆក់ខ្សែភ្លើងដើម្បីសួរចម្លើយអ្នកទោសផងដែរ[1260]។ ការប្រព្រឹត្តបទល្មើសរួមមាន ការលួចក្តាមខ្យង ត្នោតទុំ និងផ្លែឈើទុំដទៃទៀត[1261]។

14. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ការងារនៅព្រៃសគឺធ្វើការនៅវាលស្រែ លើកភ្លឺស្រែ ជីកប្រឡាយ និង លាយជី[1262]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

15. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញអ្នកណាម្នាក់ត្រូវគេធ្វើទារុណកម្ម ឬវាយ ដោយផ្ទាល់ភ្នែកទេ[1263]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

16. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានប្រជាជនបាត់ខ្លួនជាច្រើនពីព្រៃស ប៉ុន្តែគាត់មិនបានដឹងគេយកប្រជាជនទាំងនេះទៅណា ឬអត់ទេ[1264]។ ក្នុងឆ្នាំ1978 សាក្សីប្រាកដថា នៅពេលកម្មករកំពុងត្រូវបានគេយកចេញ ពួកគេកំពុងត្រូវបានគេយកទៅសម្លាប់ចោល[1265]។

## សក្ខីកម្មមុនៗ

17. សាក្សីបានផ្តល់ចម្លើយចំនួនពីដំបូងជូនទៅព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ ថាច សៀក របស់DC-Cam ចុះថ្ងៃទី25 ខែវិច្ឆិកា ឆ្នាំ2002 ERN 00055071-00055087 (ភាសាខ្មែរ) សង្ខេបជាភាសាអង់គ្លេស (គ្មាន ERN)ទេ។

(2) ចម្លើយសាក្សីឈ្មោះ ផាច សៀក របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត នៃអ.វ.ត. ក ចុះថ្ងៃទី1 ខែមេសា ឆ្នាំ2008 ERN 00195387-00195394 ឯកសារ D78/5 (អង់គ្លេស)។

## ឯកសារពាក់ព័ន្ធ

18. សាក្សីនឹងយោងទៅលើឯកសារពាក់ព័ន្ធនៅពេលសវនាការ។

## 30. អ៊ុក បុនសេង

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ទាក់ទងនឹងមន្ទីរស-២១ សាក្សីនេះផ្តល់ភស្តុតាងបញ្ជាក់អំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [new]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* និងការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])*។

2. ចំពោះព្រៃស ការបង្កើត រយៈពេល និងប្រតិបត្តិការ *(30)* ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(72-78)* ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(106, 135)* ។ ការធ្វើសក្ខីកម្មរបស់គាត់គឺជាជាប់ពាក់ព័ន្ធបទចោទ1, 2 និង3 នៃដីកាចោទប្រកាន់។

## ជីវប្រវត្តិរបស់សាក្សី

3. សាក្សីមានអាយុ19ឆ្នាំនៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ភេទប្រុស ជនជាតិខ្មែរ កើតនៅថ្ងៃទី4 ខែមេសា ឆ្នាំ1955[1266]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ធ្វើទាហានខ្មែរក្រហម ហើយបានចូលភ្នំពេញជាមួយនឹងក្រុមមួយដ៏ធំមកពីតំបន់25[1267]។ ដោយសារមាន "ប្រវត្តិផ្ទាល់ខ្លួនអាក្រក់" និងសាច់ញាតិក្រុមគ្រួសារ សាក្សីត្រូវបានគេបញ្ជូនទៅការដ្ឋានលត់ដំមួយចំនួនដើម្បីអប់រំនយោបាយ ដែលក្នុងនោះរួមមាន បឹងជើងឯក និងកន្លែងមួយទៀតនៅក្បែរព្រៃស[1268]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅបឹងជើងឯកគាត់បានជីកប្រឡាយ លើកទំនប់[1269]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បាននៅមន្ទីរស-24 រហូតដួលរំលំរបបខ្មែរក្រហមក្នុងឆ្នាំ1979[1270]។

## តួនាទីរបស់ជនជាប់ចោទ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានចូលរួមក្នុងការសិក្សានយោបាយ ដែលរៀបចំឡើងដោយ**ឌុច**នៅមន្ទីរស-២១ ក្នុងឆ្នាំ1978[1271]។ នៅក្នុងវគ្គសិក្សាមួយ គេបានប្រកាសថា **ឌុច**ជាប្រធានរបស់ ហ៊ុយ ស្រែ ដែលជាអ្នកទទួលបន្ទុកព្រៃសដោយផ្ទាល់[1272] ការសិក្សានយោបាយនោះរៀបចំឡើងដោយឌុច និងសុន

សេន ដែលក្នុងការសិក្សានយោបាយនោះ មានការណែនាំទាក់ទងនឹងសកម្មភាពរបស់ខ្មាំងផ្ទៃក្នុង និងប្រទេសក្រៅមួយចំនួន[1273]។

5. បន្ទាប់ពីបែកភ្នំពេញក្នុងឆ្នាំ1979 និងជួបប្រទះតាម៉ុកក្នុងព្រៃនៅអមលាំង សាក្សីបានជួបឌុចនៅភ្នំក្រវាញ (ខេត្តពោធិ៍សាត់) ហើយបាននៅជាមួយគាត់មួយរយៈ[1274]។ សាក្សីសង្កត់ធ្ងន់ថា **ឌុច**នៅពេលនោះគាត់នៅមានអ្នកក្រោមបង្គាប់ស្តាប់បញ្ជាគាត់នៅឡើយ។ **ឌុច** បានណែនាំអ្នកក្រោមបង្គាប់គាត់ឱ្យធ្វើទារុណកម្ម និងសម្លាប់"អ្នកទោស"ចំនួនប្រាំពីរនាក់[1275]។ **ឌុច** បានដឹងថា គេបានអនុវត្តរបស់បញ្ជាទាំងនេះដោយសារគាត់បាននៅក្បែរកន្លែងធ្វើទារុណកម្មនោះ[1276]។

6. ចរិតលក្ខណៈរបស់ឌុច សាក្សីបានបញ្ជាក់ថា ឌុច គឺជាមនុស្ស "រួសរាយរាក់ទក់ ប៉ុន្តែម៉ត់ចត់"[1277]។ ប្រសិនបើ**ឌុច** ចេញបញ្ជាហើយ បញ្ជារបស់គាត់ត្រូវតែគោរព និងអនុវត្ត[1278]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ព្រៃសគឺជាកន្លែងលត់ដំ[1279]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ព្រៃស និងបឹងជើងឯក (មានទីតាំងឋិតនៅខាងកើតវាលពិឃាត)គឺនៅក្រោមបង្គាប់មន្ទីរស-២១[1280]។ ក្នុងអំឡុងពេលដែលគាត់នៅបឹងជើងឯក សាក្សីនិយាយថា គាត់ត្រូវបានបុគ្គលិកមន្ទីរស-២១ថតរូប[1281]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា កងវរសេនាធំនៅបឹងជើងឯកបានរាយការណ៍ប្រចាំខែទៅឱ្យ**ឌុច**[1282] ។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឮគេថាដឹកប្រជាជនចេញពីបឹងជើងឯកនៅពេលយប់ទៅមន្ទីរស-២១[1283]។ សាក្សីពិពណ៌នាអំពីការដឹកប្រជាជនពីមន្ទីរស-២១ "ហៅឈ្មោះឱ្យចុះពីលើផ្ទះ ចងរបាំងមុខ។ អ្នកដែលត្រូវបានគេចាប់មិនដែលឃើញវិលត្រឡប់មកវិញទេ"[1284]។

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានដឹកទាហានរាប់រយនាក់ពីភូមិភាគបូព៌ា[1285]។ រឿងនេះបានកើតឡើងជាច្រើនដងរួចមកហើយ[1286]។ គេបានប្រាប់សាក្សីថា ពួកគេគ្រាន់តែស្នាក់នៅព្រៃសមួយយប់ ហើយបន្ទាប់មកបញ្ជូនទៅមន្ទីរស-២១[1287]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅមន្ទីរស-24 គេបែងចែកការងារជាបឹកម្រិត ក្រុមភ្ជួរដី ក្រុមភ្ជួររាស់ និងក្រុមថែទាំសត្វពាហនៈក្នុងស្រុក។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញប្រជាជនជារឿយៗត្រូវបានគេចាប់ខ្លួននៅជើងឯក[1288]។

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេលត់ដំប្រជាជននៅបឹងជើងឯក ដែលពួកគាត់មិនអាចចេញពីតំបន់ដែលបានកំណត់រួចទេ ដោយភ័យខ្លាចគេឃើញ[1289]។

## វចនាសម្ព័ន្ធអំណាច

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ហ៊ុយ ស្រែ ប្រធានព្រៃស និងក្រុមរបស់គាត់ទទួលខុសត្រូវចំពោះឌុច[1290]។ ឧទាហរណ៍ វត្តខ្ពុលត្រូវបាន ហ៊ុយ បំផ្លិចបំផ្លាញក្រោមការណែនាំរបស់ឌុច[1291]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

12. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា របបអាហារនៅបឹងជើងឯកគឺមិនមានភាពទៀតទាត់ទេ បានបបររាវៗតែបីវែកប៉ុណ្ណោះ ប្រសិនបើការលត់ដំខ្លាំង។ ធ្វើការចាប់ពីម៉ោង3ព្រឹក រហូតដល់ម៉ោង11ព្រឹក ពីម៉ោង2ថ្ងៃរសៀលរហូតដល់ម៉ោង5ល្ងាច និងពីម៉ោង7យប់រហូតដល់ម៉ោង12កណ្តាលអាធ្រាត[1292]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

12. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅភ្នំក្រវាញ ជាកន្លែងដែលគាត់បានជួបឌុច បន្ទាប់ពីរត់គេចខ្លួនពីវៀតណាម **ឌុច**បានបញ្ជាឱ្យចាប់ខ្លួន និងសួរចម្លើយអ្នកទោស6នាក់ និងកូនក្មេងម្នាក់[1293]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញអ្នកទោសម្នាក់ត្រូវបានគេធ្វើទារុណកម្ម ដោយញាត់ភ្លើងចន្លុះចូលក្នុងមាត់ ហើយកាត់បំពង់ក[1294]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

13. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកដែលមិនលត់ដំខ្លួនបានល្អនៅព្រៃស ត្រូវបានគេបញ្ជូនទៅមន្ទីរស-២១ ហើយមិនដែលបានវិលត្រឡប់មកវិញទេ[1295]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មន្ទីរស-២១គឺជាកន្លែងសម្លាប់មួយ[1296]។

14. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកដែលបានវិលត្រឡប់មកពីការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ត្រូវបានគេបញ្ជូនទៅសម្លាប់នៅមន្ទីរស-២១[1297]។

15. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឮថា ហ៊ុយ ត្រូវបានគេចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ ហើយបន្ទាប់មកត្រូវបានគេសម្លាប់នៅទីនោះ[1298]។

## សក្ខីកម្មមុនៗ

16. សាក្សីបានផ្តល់ចម្លើយចំនួនពីរដំបូងជូនទៅព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ អ៊ុក ប៊ុនសេង របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី2 ខែមេសា ឆ្នាំ2008 ERN 00189046-0018952 ឯកសារ D78/7 (ភាសាអង់គ្លេស)។

(2) ចម្លើយសាក្សីឈ្មោះ អ៊ុក ប៊ុនសេង របស់ DC-Cam ចុះថ្ងៃទី14 ខែមីនា ឆ្នាំ2003 មិនមែនជាផ្នែក មួយនៃសំណុំរឿងក្តី (អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបានប្រើ ចម្លើយសាក្សីនេះក្នុងកិច្ចសម្ភាសន៍របស់ខ្លួន ចូរមើលទំព័រ 2 នៃសេចក្តីថ្លែងការណ៍របស់ការិ យាល័យសហចៅក្រមស៊ើបអង្កេត)។

## ឯកសារពាក់ព័ន្ធ

17. សាក្សីនឹងយោងទៅលើឯកសារពាក់ព័ន្ធនៅពេលសវនាការ

## VI. សាក្សីនៅមន្ទីរម-១៣

### 31. ចាន់ ខន

### ចរិតលក្ខណៈនិងខ្លឹមសារនៃសក្ខីកម្ម

1. សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីជម្លោះប្រដាប់អាវុធ *(16-18 & 144-145)* រចនាសម្ព័ន្ធ និងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ *(10-15 & 32-35)*។ ទាក់ទងនឹងមន្ទីរម-១៣ សាក្សីនេះផ្តល់ភស្តុតាងបញ្ជាក់អំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញអ្នកទោស *(141-142)* ។ ភស្តុតាងរបស់គាត់គឺជាប់ពាក់ព័ន្ធបទចោទ1, 2 និង3 នៃដីកាចោទប្រកាន់។ ការធ្វើសក្ខីកម្មរបស់សាក្សីត្រូវរួមបញ្ចូលអង្គហេតុទាំងឡាយដែលពិពណ៌នាខាងក្រោម ប៉ុន្តែមិនចាំបាច់កម្រិតចំពោះអង្គហេតុពេកទេ។

### ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុ18ឆ្នាំនៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ភេទប្រុស ជនជាតិខ្មែរ កើតប្រហែលជាក្នុងឆ្នាំ1957[1299]។ ក្នុងឆ្នាំ1973 ប្រធានភូមិបានសាក្សីទៅឃុំ ហើយបន្ទាប់មកឱ្យទៅធ្វើការជាអ្នកយាមម្នាក់នៅឯមន្ទីរ សន្តិសុខម-១៣ រហូតដល់ខ្មែរក្រហមបានកាន់អំណាចក្នុងឆ្នាំ1975។ បន្ទាប់ពីនេះ ដោយសារគាត់មិនមានជីវប្រវត្តិល្អ គេបានបញ្ជូនគាត់ទៅកងចល័ត ជំនួយឱ្យបញ្ជូនទៅមន្ទីរស-២១ ជាមួយកម្មាភិបាលដទៃទៀត[1300]។

### តួនាទីរបស់ជនជាប់ចោទ

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុច គឺជាប្រធានម-១៣។ គាត់បានបញ្ជាឱ្យអ្នកយាមយកអ្នកទោសចេញមកសួរចម្លើយ គាត់បានដឹកនាំការសួរចម្លើយដោយផ្ទាល់[1301] ហើយគាត់បានព្រមានអ្នកយាមឱ្យបាញ់

អ្នកទោសចោលភ្លាម ប្រសិនបើពួកគេព្យាយាមគេចខ្លួន[1302]។ សាក្សីបាននិយាយថា គាត់បានឃើញ **ឌុច** បាញ់សម្លាប់អ្នកទោសនៅមន្ទីរ ស-២១[1303]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់ជឿជាក់ថា ការសម្លាប់ទាំងអស់នៅមន្ទីរ ស-២១ ត្រូវមានការអនុញ្ញាតពីឌុច ហើយថា ឌុច ជាអ្នកចេញបញ្ជាឱ្យ "កម្ទេច"អ្នកទោសចោល[1304]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺជា "ប្រកាន់ពាក្យសំដី" ដូច្នេះហើយអ្នកណាក៏ខ្លាចគាត់ដែរ។ គាត់គឺមនុស្ស "ប្តេជ្ញាចិត្តខ្ពស់ចំពោះការងារ" ហើយនៅក្នុងមេទិញគាត់ប្រាប់អ្នកយាមឱ្យ រក្សាការសម្ងាត់ និងការសម្លាប់នៅមន្ទីរ ស-២១ គាត់កាន់កាំភ្លើងខ្លីK-54k នៅនឹងចង្កេះរបស់គាត់ គាត់ជក់ បារី ហើយសើចលែង[1305]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅពេលគាត់បានមកដល់មន្ទីរ ស-២១ ក្នុងឆ្នាំ1973 អ្នកទោសបាននៅទីនោះរួចជាស្រេចទៅហើយ[1306]។ មានឆ្មាំសន្តិសុខរវាងពី10ទៅ20នាក់ ត្រូវបានគេជ្រើសរើសពីកន្លែងផ្សេងៗ[1307]។ គុកនោះព័ទ្ធជុំវិញដោយដែកលួស[1308]។ ក្នុងឆ្នាំ1973 គេបានជីករណ្តៅក្នុងដីដើម្បីដាក់អ្នកទោស[1309]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានប្រាប់អ្នកយាមថា បើសិនអ្នកយាមឱ្យអ្នកទោសរត់ គេនឹងបាញ់អ្នកយាមនោះ។ អ្នកយាមម្នាក់ឈ្មោះ ចាន់ វឿន បានរត់គេចខ្លួន [ដើម្បីជៀសវាការបាញ់សម្លាប់] នៅពេលដែលគាត់បានឱ្យអ្នកទោសរត់គេចខ្លួន ពេលគាត់កំពុងយាម[1310]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសដែលត្រូវយកចេញចូលត្រូវបានគេកត់ត្រាទាំងអស់ក្នុងសៀវភៅកំណត់ហេតុមួយ[1311]។ គាត់ផ្តល់ភស្តុតាងបញ្ជាក់ថា ដុន និង ឆេន គឺជាអ្នកនាំសារឱ្យ **ឌុច** និងក្រុមរបស់គាត់ក្នុងមន្ទីរ13[1312]។ បន្ទាប់ពីខ្មែរក្រហម កាន់អំណាច អ្នកទោសទាំងអស់នៅមន្ទីរ ស-២១ ត្រូវបានគេដោះលែងឱ្យទៅភូមិរបស់ពួកគេវិញ ដែលជាពេលវេលាតែមួយដែលសាក្សីបានឃើញអ្នកទោសត្រូវគេចាប់។ កម្មាភិបាលមន្ទីរ ស-២១ បានផ្លាស់ទៅភ្នំពេញ។ អ្នកខ្លះត្រូវបានគេបញ្ជូនទៅកងចល័ត ឬទៅមន្ទីរសន្តិសុខ[1313]។

## រចនាសម្ព័ន្ធអំណាច

5. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺប្រធានមន្ទីរ ស-២១ ចាន់ គឺជាអនុប្រធាន ហើយ ប៉ុន, ផល និង មាស គឺជាមន្ត្រីជាន់ខ្ពស់[1314]។ **ឌុច** ចាន់ និងមន្ត្រីជាន់ខ្ពស់ផ្សេងទៀតគឺជាអ្នកសួរចម្លើយទាំងអស់[1315]។ គេឱ្យតែអ្នកយាមក្មេងៗយាមអ្នកទោសនៅខាងក្នុងប៉ុណ្ណោះ ហើយអ្នកយាមមនុស្សធំយាមអ្នកទោសធ្វើការនៅខាងក្រៅបរិវេណគុក[1316]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសរួមមាន ប្រុស ស្រី និងកូនក្មេងក្នុងភូមិ កម្មាភិបាលខ្មែរក្រហម ទាហានខ្មែរក្រហម ទាហាន លន់ ណុល ឬកម្មាភិបាលមកពីហាន់ណូយ[1317]។ ពួកអ្នកទោសទាំងនោះត្រូវ បានគេនាំមកជារៀងរាល់ថ្ងៃ ហើយត្រូវគេបែងចែកជាអ្នកទោសធ្ងន់ ឬអ្នកទោសស្រាល[1318]។ ជាទូទៅ អ្នកទោសត្រូវបានគេរក្សាទុកក្នុងរណ្តៅជីកក្នុងដី ពោលគឺ មានរណ្តៅពីពីរទៅបីផ្ទុកអ្នកទោស 70ទៅ80នាក់ក្នុងរណ្តៅនីមួយៗ[1319]។ អ្នកទោសភាគច្រើនត្រូវបានគេប្រហារជីវិត ខ្លះបានស្លាប់ដោយអត់ឃ្លាន និងមួយចំនួនដែលជាប់ខ្សែកម្មាភិបាលជាន់ខ្ពស់ ត្រូវបានដោះលែងនៅពេលយប់ "ជាធម្មតាគេលួចដោះលែង"[1320]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសធ្ងន់ ដូចជា ទាហានសាធារណៈរដ្ឋខ្មែរ និងទាហានខ្មែរក្រហម ពួកគេត្រូវបានដាក់ខ្នោះ ហើយរក្សាទុកក្នុងរណ្តៅជម្រៅប្រហែលបីម៉ែត្រ។ មានជណ្តើរឫស្សីធ្វើសម្រាប់អ្នកទោសចុះឡើង ហើយយកចេញបន្ទាប់ពីប្រើរួច[1321]។ ក្នុងអំឡុងពេលទឹកជំនន់ក្នុងឆ្នាំ1974 មានអ្នកទោសជាច្រើនត្រូវបានសម្លាប់ដោយសារពួកគេជាប់ច្រវាក់ក្នុងរណ្តៅឃុំឃាំង[1322]។ អ្នកទោសត្រូវបានគេយកទៅងូតទឹកក្នុងត្រពាំងច្រាប មួយថ្ងៃមួយដង អ្នកទោសបត់ជើងធំខ្លួនឯងក្នុងបំពង់ឫស្សី ហើយលាមកត្រូវបានបោះចោលពីរដងក្នុងមួយថ្ងៃ[1323]។ ដើម្បីរារាំងអ្នកទោសកុំឱ្យធ្វើអត្តឃាត គេបានបញ្ជាអ្នកទោសឱ្យទុកក្រម៉ា និងរបាដែកចេញឱ្យឆ្ងាយ[1324]។ អ្នកទោសធ្ងន់ធ្ងរត្រូវបានគេដាក់ខ្នោះភ្ជាប់នឹងរបាដែកវែងមួយ[1325]។ ក្នុងអំឡុងពេលធ្វើការនៅពេលថ្ងៃ អ្នកទោសធ្ងន់ធ្ងរនៅតែជាប់ច្រវាក់លើករបស់ខ្លួន ហើយត្រូវបានអ្នកយាមប្រដាប់ដោយអាវុធតាមឃ្លាំមើល[1326]។ អ្នកទោសទទួលបានរបបអាហារបន្តិចបន្តួចប៉ុណ្ណោះ។ ពួកគេទទួលហូបបបររាវៗ ខណៈដែលអ្នកយាមហូបបាយលាយជាមួយដំឡូងនិងសម្ល[1327]។ អ្នកទោសមួយចំនួនបានស្លាប់ដោយសារខ្វះចំណីអាហារ[1328]។

## ការសួរចម្លើយ

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ការសួរចម្លើយត្រូវបានធ្វើឡើងដោយឌុច និងមន្ត្រីជាន់ខ្ពស់ ឬដោយក្រុមសួរចម្លើយ យោងតាមឋានៈរបស់អ្នកទោស[1329]។ ការសួរចម្លើយប្រព្រឹត្តទៅនៅឆ្ងាយ ខាងជើងត្រពាំងច្រាប[1330]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញឈ្មោះអ្នកទោស ដែលកំពុងត្រូវបាន

គេសួរចម្លើយសរសេរនៅលើបញ្ជី[1331]។ ការសួរចម្លើយដោយ**ឌុច** ប្រព្រឹត្តទៅនៅផ្ទះរបស់គាត់ក្បែរគុក[1332]។ **ឌុច** បានបញ្ជាឆ្មាំសន្តិសុខឱ្យនាំអ្នកទោសចេញមកសួរចម្លើយ។ បន្ទាប់ពីសួរចម្លើយរួចជារឿយៗអ្នកទោស ហើម ហើយប្រឡាក់ទៅដោយឈាម ឬមិនដែលបានវិលត្រឡប់មកវិញទេ[1333]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញដំបងឬស្សីប្រើសម្រាប់ធ្វើទារុណកម្ម ហើយបានឮសម្រែករបស់អ្នកទោសត្រូវគេសួរចម្លើយ និងត្រូវគេវាយ[1334]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញអ្នកទោសហើម ហើយប្រឡាក់ឈាមនៅពេលត្រឡប់មកពីសួរចម្លើយវិញ ជួនកាលមិនដែលបានឃើញវិលត្រឡប់មកវិញទេ[1335]។ ប្រសិនបើអ្នកទោសរត់ អ្នកយាមអាចបាញ់ពួកគេ[1336]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ខ្មែរក្រហមនៅឯគុកចង់ធ្វើឱ្យស្លុតអ្នកទោសផ្សេងទៀតគឺៈ គាត់បានឃើញបង្គោលបួន ឬប្រាំដើមសម្រាប់ចងបាញ់សម្លាប់អ្នកទោស[1337]។ អ្នកយាមដែលឱ្យអ្នកទោសរត់រួច ត្រូវជាប់គុក និងទទួលទារុណកម្មផងដែរ ដូចជា វឿន បានទទួលការធ្វើទារុណកម្មពី**ឌុច**[1338]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

10. អ្នកទោសភាគច្រើនត្រូវបានគេសម្លាប់ ខ្លះស្លាប់ដោយអត់អាហារ[1339]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បន្ទាប់ពីការសួរចម្លើយចប់ អ្នកទោសខ្លះត្រូវបានអ្នកយាម ឬអ្នកស៊ើបអង្កេតខ្លួនឯងសម្លាប់ បន្ទាប់ពីសំណុំឯកសាររបស់ពួកគេត្រូវបានបញ្ចប់ និងត្រូវបានអានដោយ**ឌុច** ដោយ**ឌុច**ជាបញ្ជាឱ្យសម្លាប់[1340]។ នៅប៉ែកខាងកើតគុក មានបង្គោលបួន ឬប្រាំដើម ដែលគេបានចងអ្នកទោសភ្ជាប់ ហើយបន្ទាប់មកពួកវាបាញ់អ្នកទោសចោល[1341]។ អ្នកទោសក៏ត្រូវបានគេយកចូលទៅក្នុងព្រៃ សម្លាប់ដោយវាយពីក្រោយក្បាល ជាមួយនឹងដំបងឬស្សីធំមួយ[1342]។

11. សាក្សីបានឃើញឌុច សម្លាប់អ្នកទោសនៅចំពោះមុខគាត់ ហើយបានបញ្ជាឱ្យអ្នកផ្សេងទៀតយកសាកសពចេញ[1343]។ សាក្សីក៏បានឃើញ**ឌុច** បញ្ជាកម្មាភិបាលរបស់ខ្លួនឱ្យសម្លាប់អ្នកទោសផងដែរ[1344]។ អ្នកយាមដែលប្រព្រឹត្តខុសក៏ត្រូវជាប់ឃុំដែរ[1345]។ ក្នុងពេលអ្នកយាមកំពុងភារកិច្ច សាក្សីបានឃើញសាកសព ឬផ្នូរខ្មោចអ្នកទោស ដែលត្រូវបានគេសម្លាប់នៅឯកន្លែងសម្លាប់ទាំងឡាយ[1346]។

## សក្ខីកម្មមុនៗ

12. សាក្សីបានផ្តល់ចម្លើយចំនួនពីរដំបូងជូនទៅព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ ចាន់ ខន របស់ DC-Cam ចុះថ្ងៃទី30 ខែមេសា ឆ្នាំ2003 D59 ERN 00231893-00231911 (ភាសាអង់គ្លេស) 00002174-00002194(ភាសាខ្មែរ)

(2) ចម្លើយសាក្សីឈ្មោះ ចាន់ ខន ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី31 ខែមីនា ឆ្នាំ2008 D78/4 ERN 00195541-00195545 (ភាសាអង់គ្លេស) 00186760-00186764 (ភាសាខ្មែរ)

## ឯកសារពាក់ព័ន្ធ

13. សាក្សីនិងយោងទៅលើឯកសារពាក់ព័ន្ធផ្សេងទៀតនៅពេលសវនាការ។

## 32. ចាន់ វឿន

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ចំពោះមន្ទីរ ស-២១ សាក្សីនេះផ្តល់ភស្តុតាងបញ្ជាក់អំពីតួនាទីរបស់ជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)*, ការសួរចម្លើយ *(43-45 & 79-84)* អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញអ្នកទោស *(141-142)*។ ភស្តុតាងរបស់គឺជាពាក់ព័ន្ធនឹងបទចោទ1, 2 និង3 នៃដីកាចោទប្រកាន់។ សក្ខីកម្មរបស់សាក្សីរួមមានដូចអង្គហេតុខាងក្រោម ប៉ុន្តែនៅមានអង្គហេតុច្រើន ជាងនេះទៀត។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុប្រហែល22ឆ្នាំ នៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ1953[1347]។ គាត់បានចូលបដិវត្តខ្មែរក្រហមក្នុងឆ្នាំ1970[1348]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ប្រហែលក្នុងឆ្នាំ1974 គាត់ត្រូវបានគេបញ្ជូនឱ្យទៅធ្វើការជាអ្នកយាមម្នាក់នៅមន្ទីរសន្តិសុខស-២១[1349]។ នៅចុងឆ្នាំ1974 គាត់បានដោះលែងអ្នកទោសបីនាក់ ហើយត្រូវបានចាប់ខ្លួន ប៉ុន្តែមិនរត់រួចបានទេ[1350]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច**គឺជាប្រធានមន្ទីរស-២១[1351] ដែលមានអំណាចសួរចម្លើយ បញ្ជា និងធ្វើ ទារុណកម្ម បញ្ជាសម្លាប់ និងបញ្ជាដោះលែងអ្នកទោស[1352]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា "ឌុចគឺជាមនុស្សឃោរឃៅ កាចសាហាវខ្លាំងណាស់" ពោលគឺក្រៅពីការវាយដំ គាត់បានធ្វើទារុណកម្មអ្នកទោស គាត់បានចងអ្នកទោសព្យួរលើដើមឈើ ហើយដុតអ្នកទោសនឹងភ្លើងចន្លុះ និងដុតដោះអ្នកទោសស្ត្រីផងដែរ[1353]។ **ឌុច** ក៏បានបញ្ជាផងដែរថា អ្នកទោសទាំងឡាយណាដែលមិនឆ្លើយសំណួរ មិនឱ្យអាហារ និងទឹកទេ ពោលគឺ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញមនុស្សពីរនាក់ស្លាប់

ដោយទង្វើនេះ[1354]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញ **ឌុច** បាញ់អ្នកទោសសម្លាប់ក្នុងឧប្បត្តិហេតុមួយ គាត់បានប្រើកាំភ្លើងខ្លីមួយដើមដើម្បីសម្លាប់អ្នកទោសម្នាក់ ដែលចងភ្ជាប់នឹងដើមឈើ ក្នុងឧប្បត្តិហេតុមួយទៀត គាត់បានប្រើកាំភ្លើងAK-47 ហើយក៏មានឧប្បត្តិហេតុទីបីដែរនៅពេលដែលគាត់ប្រើកាំភ្លើងខ្លីនោះ[1355]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ជួនកាលនៅពេល**ឌុច**បានធ្វើទារុណកម្មអ្នកទោស គាត់ហាក់ដូចជាសើច "គាត់ដូចជាទៅជាឆ្កួតនឹងការធ្វើទារុណកម្ម"[1356]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មន្ទីរម-១៣ មានទីតាំងនៅត្រពាំងច្រាប គាត់បានធ្វើការនៅទីនោះអស់ក្នុងឆ្នាំ1974[1357] ជាមួយក្រុមពីរ ក្រុមយាមនិងក្រុមសួរចម្លើយ[1358]។ សាក្សីបានធ្វើការនៅមន្ទីរម-១៣ជាមួយ មនុស្សពី13ទៅ15នាក់ ក្នុងចំណោមនោះមាន ចុងភៅ អ្នកយាម អ្នកសួរចម្លើយ និងពេទ្យបីនាក់[1359]។ មានរបងឫស្សីព័ទ្ធជុំវិញកន្លែងឃុំឃាំង ហើយមានអគារជាច្រើនសម្រាប់អ្នកយាមខាងក្រៅគុក[1360]។ នៅខាងក្នុងគុក មានរណ្តៅចំនួនបី ទំហំបួនម៉ែត្រការ៉េ ជម្រៅពីរម៉ែត្រ ដែលគេបានដាក់អ្នកទោសធ្ងន់នៅទីនោះ ហើយគ្រប់ជ្រុងទាំងអស់មានអគារសម្រាប់អ្នកទោសស្រាល។ អ្នកទោសស្រាលត្រូវបានគេយកឱ្យទៅធ្វើការនៅខាងក្រៅគុក ចំណែកឯអ្នកទោសធ្ងន់វិញជាប់ឃុំនៅក្នុងរណ្តៅរហូត[1361]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា រណ្តៅធំដាក់អ្នកទោសពី 5ទៅ6នាក់ប៉ុណ្ណោះ អគារធំទៅទិសខាងកើតដាក់អ្នក ទោសចំនួន10នាក់ ហើយអគារតូចទៅទិសខាងលិចដាក់អ្នកទោសប្រហែល6 ឬ7នាក់[1362]។ កងសួរ ចម្លើយត្រូវបានគេបែងចែកជាផ្នែកផ្សេងៗ ដែលចំណុះឱ្យ**ឌុច,** ចាន់, ប៉ុន និង ផល[1363]។ អ្នកទោស ស្រាលមួយចំនួនត្រូវបានគេដោះលែងបន្ទាប់ពីសួរចម្លើយ[1364]។

## រចនាសម្ព័ន្ធអំណាច

5. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច**គឺជាប្រធានមន្ទីរម-១៣ ចាន់ ជាអនុប្រធាន ហើយ មាស ជាសមាជិក ប៉ុន ជាអ្នកស៊ើបអង្កេត[1365]។ ទាំងអស់គ្នាគឺជាអ្នកស៊ើបអង្កេត ក្នុងនោះរួមមានឌុចខ្លួនឯងផងដែរ[1366]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានចាត់ចែងអ្នកយាមជាក្រុម។ អ្នកយាមការពារភាគច្រើនជាកូនក្មេង[1367]។ អ្នកយាមទាំងនោះមានឈ្មោះ សឿង, ចេវ, និន និង ខន ជាអ្នកទទួលបន្ទុកក្នុងការ ចាត់ចែងការសម្លាប់ក្រោមបញ្ជាពីឌុច[1368]។ ឌុចបានចេញបញ្ជាឱ្យអ្នកយាមនាំយកអ្នកទោសទៅសួរចម្លើយ[1369]។ មានតែឌុច

ប៉ុណ្ណោះទើបអាចធ្វើទារុណកម្ម ឬចេញបញ្ជាឱ្យដោះលែងអ្នកទោសបាន[1370]។ សាក្សីបាននិយាយថា ការងារនៅមន្ទីរ ស-២១ ត្រូវបានសម្រេចក្រោមអំណាចរបស់**ឌុច**[1371]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានរណ្តៅចំនួនបី ទំហំបួនម៉ែត្រការ៉េ និងជម្រៅពីរម៉ែត្រ នៅទីនោះ គេដាក់អ្នកទោសធ្ងន់ ហើយគ្រប់ជ្រុងទាំងអស់មានអគារសម្រាប់អ្នកទោសស្រាល[1372]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានអ្នកទោសប្រុសស្រី អ្នកទោសមនុស្សធំនិងអ្នកទោសកូនក្មេង[1373]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ជួនកាលគាត់បានឃើញអ្នកទោសក្នុងចំនួនដ៏ច្រើន ឬជួនកាលចំនួនតិចតួច រួមមានកូនក្មេងផងដែរ[1374]។ អ្នកទោសទាំងនោះមានអ្នកភូមិ ដែលបានរស់នៅក្នុងឃុំអមលាំង[1375]។ សាក្សីបាននិយាយថា គាត់មិនដែលបានឃើញគេឃុំខ្លួនទាហាន លន់ ណុល ទេ[1376]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

7. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា អ្នកទោសធ្ងន់ត្រូវបានគេឃុំនៅក្នុងរណ្តៅដោយជើងរបស់ពួកគេជាប់ខ្នោះទាំងថ្ងៃទាំងយប់[1377]។ ចំពោះអ្នកទោស ដែលមិនបានឆ្លើយនឹងសំណួរក្នុងពេលសួរចម្លើយវិញ **ឌុច**បានចេញបញ្ជាឱ្យបង្អត់អាហារនិងទឹក អ្នកទោសខ្លះបានស្លាប់ដោយការប្រព្រឹត្តបែបនេះ[1378]។ អ្នកទោសជាធម្មតាទទួលបានបបររាវៗពីរពេលក្នុងមួយថ្ងៃ[1379]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បន្ទាប់ពីក្លាយខ្លួនជាអ្នកទោស គេបានដាក់ខ្នោះក្នុងគុកឫស្សីបន្ទាប់ពីត្រូវគេស្រាតខោអាវរបស់គាត់អស់ ដាក់ច្រវាក់កជាប់នឹងដើមឈើ ហើយបន្ទាប់មកឌុច បានបញ្ជាឱ្យជីកដី[1380]។ ក្នុងអំឡុងពេលរដូវភ្លៀង ទឹកជំនន់បានជន់លិចរណ្តៅសម្លាប់អ្នកទោសអស់ជាច្រើននាក់[1381] ។

## ការសួរចម្លើយ

8. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ការសួរចម្លើយត្រូវបានធ្វើឡើងដោយឌុច ចាន់, មាសនិង ប៉ុន ប៉ុន្តែ **ឌុច** ជាអ្នកអនុញ្ញាតឱ្យសួរចម្លើយ ជាអ្នកកត់ត្រាចម្លើយក្នុងសៀវភៅ និងបន្ទាប់មកជាអ្នកធ្វើវិភាគចម្លើយ[1382]។ ប្រសិនបើអ្នកទោសមិនបានឆ្លើយទេ ចាន់ និង មាស នឹងរាយការណ៍ទៅ **ឌុច** ដែល បន្ទាប់មក **ឌុច** ជាអ្នកសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោសដោយខ្លួនឯង[1383]។ ការសួរចម្លើយប្រព្រឹត្ត ទៅនៅខាងក្នុងរបងគុក[1384]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

9. អ្នកទោសផ្តល់ភស្តុតាងបញ្ជាក់ថា ការធ្វើទារុណកម្មបានកើតឡើងជាប្រចាំ ទាំងថ្ងៃទាំងយប់។ គ្មានអ្នកទោសណាម្នាក់អាចគេចរួចពីការធ្វើទារុណកម្មបានទេ[1385]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** គឺជាមនុស្សឃោរឃៅកាចសាហាវណាស់ ពោលគឺក្រៅពីការវាយដំ គាត់បានធ្វើទារុណកម្មអ្នកទោសដោយចងព្យួរពីលើដើមឈើ ហើយដុតអ្នកទោសនឹងភ្លើងចន្លុះ ហើយក៏ដុតដោះអ្នកទោសស្ត្រីផងដែរ[1386]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ជួនកាលនៅពេលឌុច ធ្វើទារុណកម្មអ្នកទោស គាត់ហាក់ដូចជាសើច "ដូចចង់ទៅជាឆ្កួតក្នុងពេលធ្វើទារុណកម្មអ្នកទោស"[1387]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** បាញ់សម្លាប់អ្នកទោសបីនាក់ នៅពេលដែលគាត់មិនបានទទួលចម្លើយគួរជាទីពេញចិត្តពីអ្នកទោសក្នុងអំឡុងពេលសួរចម្លើយ[1388]។ មានអ្នកទោសម្នាក់ត្រូវបានចងភ្ជាប់នឹងបង្គោលមួយហើយបន្ទាប់មកបាញ់បីដង[1389]។ សាក្សីមិនបានដឹងអំពីរបៀបសម្លាប់អ្នកទោសផ្សេងទៀតទេ[1390]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅពេលមួយនោះនៅពេលដែលគាត់បានទៅបាញ់សត្វជាមួយអ្នកទោសប្រហែលពីរបីនាក់ គាត់បានឃើញកន្លែងសម្លាប់ក្នុងបរិវេណឃុំឃាំងមនុស្ស ជាកន្លែងដែលគាត់បានឃើញសាកសពជាច្រើន ដែលគាត់មិនដែលបានដឹងពីមុនមក[1391]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញឌុច សម្លាប់ ប៊ុន ពីព្រោះ ប៊ុន ឱ្យអ្នកទោសរត់រួច ខណៈពេលសួរចម្លើយ[1392]។ សាក្សីត្រូវបានសម្ភាសន៍ដោយ Nic DUNLOP ហើយសាក្សីបានប្រាប់គាត់ថា នៅមន្ទីរម-១៣ **ឌុច**បានសម្លាប់មនុស្សជាច្រើនដោយផ្ទាល់ដៃ ហើយថា គាត់ ចាន់ វឿន បានឃើញ **ឌុច** បាញ់អ្នកទោសសម្លាប់ ដោយផ្ទាល់ដៃ[1393]។

## សក្ខីកម្មមុនៗ

11. សាក្សីបានផ្តល់ចម្លើយដំបូងចំនួនបីជូនទៅព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ ចាន់ វឿន របស់ DC-Cam ចុះថ្ងៃទី30 ខែមេសា ឆ្នាំ2003 D59/I-00002 ERN 00001983-00002005 (ភាសាខ្មែរ)។

(2) ចម្លើយសាក្សីឈ្មោះ ចាន់ រឿន របស់ការិយាល័យសហចៅក្រមស៊ើប អង្កេតនៃអ.វ.ត.ក ចុះថ្ងៃទី 27 ខែមីនា ឆ្នាំ2008 D78/1 ERN 00194711-00194716 (ភាសាអង់គ្លេស) 00186741-00186746(ភាសាខ្មែរ)។

(3) ចាន់ រឿន ក្នុង Nic DUNLOP *ពេជ្ឈឃាតបាត់ខ្លួន* ទំព័រ 284-285

## ឯកសារពាក់ព័ន្ធ

12. សាក្សីនឹងយោងទៅលើឯកសារពាក់ព័ន្ធនៅពេលសវនាការ។

## 33. អ៊ុច ស៊ិន ហៅ អ៊ុច សាន

## ចរិតលក្ខណៈ និងខ្លឹមសារនៃសក្ខីកម្ម

1. ចំពោះមន្ទីរម-១៣ សាក្សីផ្តល់ភស្តុតាងបញ្ជាក់អំពីតួនាទីជនជាប់ចោទ *(55-59, 90-99, 107-111 & 153 [ថ្មី]-161)* ការបង្កើត រយៈពេល និងប្រតិបត្តិការនៃមន្ទីរសន្តិសុខ *(20-42)* រចនាសម្ព័ន្ធអំណាច *(20-25)* ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌ *(47-54, 60-61, 134, 146, 147)* ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌ *(62-71, 135, 143 & 148)* ការសួរចម្លើយ *(43-45 & 79-84)* អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌ *(85-89, 100-105, 136, 149, 150 & 152 [ថ្មី])* ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា *(107-128, 138, 139-140, 151 & 152 [ថ្មី])* និងការធ្វើទុក្ខបុកម្នេញអ្នកទោស *(141-142)* ភស្តុតាងរបស់គាត់គឺជាប់ពាក់ព័ន្ធនឹងបទ ចោទ 1 2 និង 3 នៃដីកាចោទប្រកាន់។ សក្ខីកម្មរបស់សាក្សីរួមមានដូចអង្គហេតុខាងក្រោម ប៉ុន្តែនៅមានអង្គហេតុច្រើន ជាងនេះទៀត។

## ជីវប្រវត្តិរបស់សាក្សី

2. សាក្សីមានអាយុប្រហែល39ឆ្នាំនៅថ្ងៃទី17 ខែមេសា ឆ្នាំ1975 ភេទប្រុស ជនជាតិខ្មែរ កើតក្នុងឆ្នាំ1936[1394]។ ក្នុងឆ្នាំ1973 គាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរម-១៣ ក្នុងភូមិភាគពិសេស ក្បែរ *អមលាំង*[1395]។ បន្ទាប់ពីនោះ គាត់បានធ្វើជាកម្មករនៅគុក ទទួលបន្ទុកជីករណ្តៅកប់អ្នកទោសស្លាប់[1396]។

## តួនាទីរបស់ជនជាប់ចោទ

3. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុច គឺជាប្រធានធំក្នុងមន្ទីរម-១៣[1397]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញ**ឌុច** កាន់កាំភ្លើងខ្លីមួយដើម នៅពេលគាត់ដើរចេញពីគុក[1398]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញ**ឌុច** ជួបជាមួយប្រធានមន្ទីរផ្សេងទៀត[1399]។

4. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុច បានជ្រើសរើសអ្នកយាមណាត្រូវសួរចម្លើយអ្នកទោសណា។ **ឌុច** បានមកពិនិត្យរណ្តៅឃុំឃាំង និងអ្នកទោសជាប់ខ្នោះ យូរៗម្តងគាត់បានចូលរួមក្នុងការវាយដំនិងធ្វើទារុណកម្ម។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅពេលមួយនោះ គាត់បានឃើញឌុច វាយអ្នកទោសនឹងខ្សែតី ហើយសើចនៅពេលដែលការវាយនោះត្រូវបានធ្វើបន្តដោយអ្នកយាមម្នាក់ ដោយអ្នកទោសឈឺប្រកាច់

ដួលទៅលើដី[1400]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញ ចាន់ បាញ់អ្នកទោសសម្លាប់ ហើយជឿជាក់ថា ប្រសិនបើ **ឌុច** មិនបានចេញបញ្ជាការសម្លាប់ទាំងនេះទេ វាមិនអាចកើតឡើងបានទេ[1401]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បើគ្មានបញ្ជាពីឌុច ទេ "គ្មានអ្នកណាហានធ្វើអ្វីមួយនោះទេ"[1402]។

5. នៅពេលនិយាយទៅកាន់អ្នកភូមិក្បែរៗនោះ **ឌុច**បានប្រកាសថា "មន្ទីរម-១៣ គឺជាកន្លែងស្លាប់រស់ ជាកន្លែងគ្មានការជំនុំជម្រះ[តុលាការ] និងគ្មានអ្នកណាម្នាក់រត់រួចឡើយ"[1403]។

## ការបង្កើត រយៈពេល និងប្រតិបត្តិការ

6. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មន្ទីរម-១៣មានទីតាំងឋិតនៅក្នុងព្រៃ ក្នុងទីតាំងសម្ងាត់នៅ*អមលាំង*[1404]។ នៅពេលគាត់ត្រូវបានគេចាប់ខ្លួននាំយកមកកាន់មន្ទីរម-១៣ គាត់ត្រូវបានគេដាក់ខ្នោះអស់រយៈពេលបីថ្ងៃ ហើយបន្ទាប់មកគេបានបញ្ជាគាត់ឱ្យជីករណ្តៅជម្រៅបីម៉ែត្រ សម្រាប់ដាក់អ្នកទោស។ គាត់បានឃើញខ្ទមតូចៗពី5 ទៅ6ខ្ទមមានអ្នកទោសជាប់ខ្នោះពី100ទៅ200នាក់[1405]។ នៅពេលយប់ សាក្សីបានដេកក្នុងរណ្តៅឃុំឃាំងជាមួយអ្នកទោសផ្សេងទៀត។ អ្នកទោសថ្មីមកដល់រាល់ថ្ងៃ[1406]។ សរុបទាំងអស់សាក្សីនិយាយថា មានអ្នកទោសជាង10000នាក់បានស្លាប់នៅមន្ទីរម-១៣[1407]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ប្រជាជនក្មេងៗមកពីគ្រួសារក្រីក្រក្នុងស្រុក "ធ្វើការធម្មតា"នៅមន្ទីរម-១៣[1408]។

## រចនាសម្ព័ន្ធអំណាច

7. សាក្សីនិយាយថា **ឌុច** គឺជាប្រធានធំក្នុងមន្ទីរម-១៣ ចាន់ ជាអនុប្រធាន ហើយ ប៉ុន ឬ មាស ជាសមាជិក មាស និង ម៉ាន ជាអ្នកទទួលបន្ទុកទាហានសួរចម្លើយ[1409]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា បើគ្មានបញ្ជាពី **ឌុច** ទេ "គ្មានអ្នកណាហានធ្វើអ្វីទេ"[1410]។ ករណីនេះក៏មានការអនុវត្តចំពោះ ម៉ម ណៃ ហៅ ចាន់ ដែរ ដែលគាត់យ៉ាងហោចណាស់បានបាញ់អ្នកសម្លាប់ពីរដង[1411]។ សាក្សីក៏ជឿជាក់ដែរថា ឌុច បានចាត់តាំងអ្នកស៊ើបអង្កេតសម្រាប់អ្នកទោសជាក់លាក់ផងដែរ[1412]។

8. សាក្សីប្រកាសថា **ឌុច**បានប្រាប់គាត់ថា បន្ទាប់ពីខ្មែរក្រហមរំដោះភ្នំពេញមក សាក្សីគួរក្លាយខ្លួនជាប្រធានគុកម្នាក់នៅទីនោះ[1413]។ ភ្លាមៗបន្ទាប់ពី **ឌុច** បានប្តូរគំនិត **ឌុច**បានជូនដំណឹងប្រាប់សាក្សីអំពីតួនាទីថ្មីរបស់គាតក់ ត្រូវធ្វើការនៅតាមវាលស្រែ ក្បែរអមលាំង[1414]។

## ការដាក់ពន្ធនាគារ ការឃុំឃាំងខុសច្បាប់ និងគ្មានការជំនុំជម្រះដោយយុត្តិធម៌

9. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គេបានឃុំខ្លួនអ្នកទោសក្នុងខ្ទមតូចៗ និងក្នុងរណ្តៅជម្រៅបីម៉ែត្រក្នុងដីផងដែរ[1415]។ គាត់បានឃើញខ្ទមពី5 ទៅ6មានអ្នកទោសជាប់ខ្នោះពី100ទៅ200នាក់[1416]។ អ្នកទោសថ្មីមកដល់ជារៀងរាល់ថ្ងៃ ហើយមកពីឆ្ងាយនិងជិតឃុំ[1417]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានអ្នកទោសច្រើនជាង10000នាក់បានស្លាប់នៅមន្ទីរម-១៣ អ្នកទោសជាច្រើនស្លាប់ដោយអត់ឃ្លាន[1418]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅមន្ទីរម-១៣ អ្នកទោសភាគច្រើនជាជនស៊ីវិលប្រុសស្រី[1419]។ ជួនកាល សាក្សីបានឃើញសមាជិកក្រុមគ្រួសារទាំងអស់ រួមមានកូនចៅផងដែរ[1420]។ អ្នកទោសភាគច្រើនជាប់ចោទពីបទយកការណ៍ពីខ្មែរក្រហមឱ្យពួកលន់ ណុល[1421]។

10. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា **ឌុច** បានប្រាប់អ្នកភូមិថា បើសិនជាមានជម្លោះបន្តិចបន្តួចកើតឡើង "គ្រាន់តែឱ្យគេអប់រំប្រជាជនមានជម្លោះទាំងនោះក្នុងភូមិ ដោះស្រាយបញ្ហានៅកម្រិតភូមិ មិនត្រូវបញ្ជូនពួកគេទៅមន្ទីរម-១៣ទេ ពីព្រោះមន្ទីរម-១៣គឺជាកន្លែងស្លាប់រស់ ជាកន្លែងគ្មានការជំនុំជម្រះ[តុលាការ] និងជាកន្លែងគ្មានអ្នកណាម្នាក់អាចរត់រួចឡើយ[1422]។

## ការដាក់ជាទាសករ ការបង្កទុក្ខវេទនាដោយចេតនា និងអំពើអមនុស្សធម៌

11. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅពេលគាត់មកដល់មន្ទីរម-១៣ គាត់ត្រូវបានគេដាក់ខ្នោះជើង ហើយចងជាប់ ចំណែកឯមិត្តភក្តិរបស់គាត់ត្រូវបានគេចងនឹងខ្សែអង្រឹង[1423]។ គេបានដាក់នៅក្នុងខ្ទមមួយអស់រយៈពេលបីថ្ងៃ[1424]។ សាក្សីបានឃើញខ្ទមតូចៗពី5 ទៅ6ខ្ទមនៅមន្ទីរម-១៣ ដាក់អ្នកទោសពី100 ទៅ 200នាក់ អ្នកទោសភាគច្រើនត្រូវបានគេដាក់ខ្នោះជើង[1425]។ បន្ទាប់ពីរយៈពេលបីថ្ងៃមក គេបានដោះខ្នោះសាក្សីចេញ ហើយគេបានប្រាប់ឱ្យជីករណ្តៅគុក កប់សាកសព[1426]។ គាត់បានធ្វើការងារនេះអស់រយៈពេល7ខែ[1427]។ ចំនួនរណ្តៅសាកសពរាប់មិនអស់[1428]។ មានអ្នកប្រហែលពី20 ទៅ30នាក់ត្រូវបានកប់ជារៀងរាល់ថ្ងៃ។ យ៉ាងហោចណាស់មានអ្នកទោសពី5 ទៅ6នាក់បានស្លាប់ជារៀងរាល់ថ្ងៃដែរ[1429]។

12. នៅពេលយប់សាក្សីដេកក្នុងរណ្តៅផ្ទាល់ដីគ្មានកន្ទេល[1430]។ អ្នកទោសដែលបាននៅក្នុងរណ្តៅនោះយូរជាងគេ "មានដំបៅស្អុយរលួយ"[1431]។ គេឱ្យអ្នកទោសហូបបបរមួយវែកពីរដងក្នុងមួយថ្ងៃ[1432]។ មាន

អ្នកទោសជាច្រើនស្លាប់ដោយអត់អាហារ ក្នុងមួយថ្ងៃមានមនុស្សស្លាប់ប្រហែលពី10 ទៅ20នាក់ដោយអត់អាហារ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ហេតុផលដែលគេមិនឱ្យអាហារដល់អ្នកទោសបានគ្រប់គ្រាន់ គឺ "កំទេចអ្នកទោសទាំងអស់ចោល"[1433]។ សាក្សីជឿជាក់ថា គេឱ្យអ្នកទោសហូបតូច មិនមែនដោយសារខ្វះអង្ករនោះទេ គឺដោយសារអ្នកទោសទាំងអស់មាន "ទំនាស់ស្លាប់រស់[ជាមួយអង្គការ]"[1434]។

13. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់មិនដែលបានឃើញបុគ្គលិកពេទ្យ ឬថ្នាំពេទ្យនៅមន្ទីរម-១៣ទេ នៅពេលអ្នកទោសឈឺ[1435]។

## ការសួរចម្លើយ

14. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា នៅមន្ទីរម-១៣ គាត់បានឃើញអ្នកទោសម្នាក់ត្រូវគេយកទៅសួរចម្លើយ ដោយជាប់ច្រវាក់នៅលើកនិងជើងរបស់គាត់[1436]។ នៅពេលគេនាំអ្នកទោសត្រឡប់មកពីសួរចម្លើយវិញ អ្នកទោសម្នាក់នោះបានដួលស្លាប់[1437]។ អ្នកទោសខ្លះខណៈពេលដែលគេសួរចម្លើយ គេបានច្រមុជទៅក្នុងទឹកត្រពាំងច្រាប ក្បែរមន្ទីរម-១៣[1438]។ ថ្ងៃមួយ សាក្សីបានឃើញបុរសម្នាក់មកពីភូមិរបស់គាត់ ត្រូវយកមកសួចម្លើយ[1439]។ នៅពេលគាត់ត្រឡប់មកវិញ មានស្នាមរបួសលើរាងកាយ និងមុខរបស់គាត់មើលលែងស្គាល់[1440]។ នៅពេលបុរសនេះបានព្យាយាមរត់ អ្នកយាមបានបាញ់គាត់ស្លាប់[1441]។

## អំពើទារុណកម្ម និងការប្រព្រឹត្តិអំពើអមនុស្សធម៌

15. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ពេលមួយនោះ គាត់បានឃើញ**ឌុច** វាយអ្នកម្នាក់នឹងខ្សែតី ហើយសើច នៅពេលដែលអ្នកយាមម្នាក់បានវាយបន្ត ដោយអ្នកទោសនោះឈឺប្រកាច់នៅលើដី[1442]។

16. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញអ្នកយាមម្នាក់នៅមន្ទីរម-១៣ វាយបុរសម្នាក់និងស្ត្រីម្នាក់[1443]។ អ្នកយាមនោះបានប្រើចបកាបវាយចំករបស់ពួកគេ[1444]។ នៅពេលស្ត្រីនោះមិនស្លាប់ភ្លាម អ្នកយាមនោះបានកប់ស្ត្រីនោះទាំងរស់[1445]។

17. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញប្រភេទផ្សេងៗនៃការធ្វើទារុណកម្មលើអ្នកទោសនៅមន្ទីរម-១៣[1446]។ គាត់បានឃើញគេប្រើដង្កាប់ដកក្រចកដៃ និងម្ជុលនិងគល់ឫស្សីទម្លុះម្រាមដៃ[1447]។ គាត់បានឃើញគេចងដៃរបស់អ្នកទោស និងដាក់ខ្នោះជើងច្រមុជចូលទៅក្នុងទឹកត្រពាំងច្រាប[1448]។

## ការសម្លាប់បំផុតពូជ អំពើឃាតកម្ម និងការសម្លាប់ដោយចេតនា

18. សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ឌុច បានប្រកាសថា មន្ទីរ ស-២១គឺជាកន្លែងស្លាប់រស់ហើយ គ្មានការជំនុំជម្រះ[តុលាការ]ទេ ហើយក៏គ្មានអ្នកម្នាក់អាចរត់រួចដែរ[1449]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា មានអ្នកទោសច្រើនជាង10000នាក់បានស្លាប់ដោយមន្ទីរ ស-២១[1450]។ អ្នកទោសជាច្រើនស្លាប់ដោយអត់អាហារ មានមនុស្សស្លាប់ដោយអត់អាហារប្រហែលពី10 ទៅ20នាក់ក្នុងមួយថ្ងៃ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា ហេតុផលដែលគេមិនឱ្យអ្នកទោសហូបគ្រប់គ្រាន់គឺ "ដើម្បីកម្ទេចអ្នកទោសចោលទាំងអស់"[1451] ។ ការងារដែលគាត់ធ្វើមាន កប់សាកសព[1452]។ សាក្សីផ្តល់ភស្តុតាងបញ្ជាក់ថា គាត់បានឃើញ ចាន់ បាញ់អ្នកទោសសម្លាប់ ហើយគាត់ជឿជាក់ថា បើសិនឌុចមិនចេញបញ្ជាឱ្យសម្លាប់ទេ រឿងនោះមិនកើតឡើងទេ[1453]។

## សក្ខីកម្មមុនៗ

19. សាក្សីបានផ្តល់ចម្លើយចំនួនមួយដំបូងជូនទៅព្រះរាជអាជ្ញា៖

(1) ចម្លើយសាក្សីឈ្មោះ អ៊ុច ស៊ន របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី 28 មីនា 2008 D78/2 ERN 00195530-00195534 (អង់គ្លេស)។

## ឯកសារពាក់ព័ន្ធ

20. សាក្សីនឹងយោងទៅលើឯកសារពាក់ព័ន្ធនៅពេលសវនាការ។

---

1 អត្ថបទអត្ថាធិប្បាយជាលាយល័ក្ខអក្សររបស់ ឌុច ត្រូវភ្ជាប់មកជាមួយរបាយការណ៍ស្តីពីស្តាប់ចម្លើយរបស់គាត់ ដោយ ក.ស.ច.ស កាលពីថ្ងៃទី5 ខែឧសភា ឆ្នាំ2008, D72, នៅ ERN 00204292-00204300, ERN 00204282-00204300 (ភាសាអង់គ្លេស).

2 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 71 នៅ ERN 00192750, ERN 00192667-00192932 (ភាសាអង់គ្លេស).

3 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 71 នៅ ERN 00192750, ERN 00192667-00192932 (ភាសាអង់គ្លេស).

4 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 72 នៅ ERN 00192751, ERN 00192667-00192932 (ភាសាអង់គ្លេស).

---

[5] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 72-4 នៅ ERN 00192751-00192753, ERN 00192667-00192932 (ភាសាអង់គ្លេស).

[6] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 72-3 នៅ ERN 00192751-00192752, ERN 00192667-00192932 (ភាសាអង់គ្លេស).

[7] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 14 នៅ ERN 001926930, ERN 00192667-00192932 (ភាសាអង់គ្លេស).

[8] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 14-15 នៅ ERN 001926930-001926931, ERN 00192667-00192932 (ភាសាអង់គ្លេស).

[9] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 15 នៅ ERN 001926931, ERN 00192667-00192932 (ភាសាអង់គ្លេស).

[10] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 45-49, 54-60, 68-70, 74-76 នៅ ERN 00192724-00192728, 00192733-00192739, 00192747-00192749, 00192753-00192755, ERN 00192667-00192932 (ភាសាអង់គ្លេស).

[11] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 60-68 នៅ ERN 00192739-00192748, ERN 00192667-00192932 (ភាសាអង់គ្លេស).

[12] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 154 នៅ ERN 00192847, ERN 00192667-00192932 (ភាសាអង់គ្លេស).

[13] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 22 នៅ ERN 00192701, ERN 00192667-00192932 (ភាសាអង់គ្លេស).

[14] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 22 នៅ ERN 00192701, ERN 00192667-00192932 (ភាសាអង់គ្លេស).

[15] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 22 នៅ ERN 00192701, ERN 00192667-00192932 (ភាសាអង់គ្លេស).

[16] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 22 នៅ ERN 00192701, ERN 00192667-00192932 (ភាសាអង់គ្លេស).

[17] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 191, លេខយោង 55 នៅ ERN 00192884, ERN 00192667-00192932 (ភាសាអង់គ្លេស).

[18] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 152-153 [ថ្មី] នៅ ERN 00192845-00192846, ERN 00192667-00192932 (ភាសាអង់គ្លេស).

[19] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 58, 67 និង 132 នៅ ERN 00192737, 00192746 and 00192825, ERN 00192667-00192932 (ភាសាអង់គ្លេស).

[20] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 66 នៅ ERN 00192745, ERN 00192667-00192932 (ភាសាអង់គ្លេស).

[21] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 154 នៅ ERN 00192847, ERN 00192667-00192932 (ភាសាអង់គ្លេស).

[22] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 16-17 នៅ ERN 00192695-00192696, ERN 00192667-00192932 (ភាសាអង់គ្លេស).

[23] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 49-51 នៅ ERN 00192728, ERN 00192667-00192932 (ភាសាអង់គ្លេស).

[24] CHANDLER CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 20 នៅ ERN 00192699, ERN 00192667-00192932 (ភាសាអង់គ្លេស).

[25] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 23-27 នៅ ERN 00192702-00192706, ERN 00192667-00192932 (ភាសាអង់គ្លេស).

[26] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 23 នៅ ERN 00192702, ERN 00192667-00192932 (ភាសាអង់គ្លេស).

[27] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 18 នៅ ERN 00192697, ERN 00192667-00192932 (ភាសាអង់គ្លេស).

[28] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 15 នៅ ERN 00192694, ERN 00192667-00192932 (ភាសាអង់គ្លេស).

[29] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 35-36 នៅ ERN 00192714-00192715, ERN 00192667-00192932 (ភាសាអង់គ្លេស).

[30] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 36 នៅ ERN 00192715, ERN 00192667-00192932 (ភាសាអង់គ្លេស).

[31] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 38 នៅ ERN 00192717, ERN 00192667-00192932 (ភាសាអង់គ្លេស).

[32] CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 15 នៅ ERN 00192694, ERN 00192667-00192932 (ភាសាអង់គ្លេស).

33 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 103 នៅ ERN 00192796, ERN 00192667-00192932 (ភាសាអង់គ្លេស).

34 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 38-39 នៅ ERN 00192717, ERN 00192667-00192932 (ភាសាអង់គ្លេស).

35 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 77 នៅ ERN 00192756, ERN 00192667-00192932 (ភាសាអង់គ្លេស).

36 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 79-80 នៅ ERN 00192772-00192773, ERN 00192667-00192932 (ភាសាអង់គ្លេស).

37 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 80-81 នៅ ERN 00192773-00192774, ERN 00192667-00192932 (ភាសាអង់គ្លេស).

38 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 82-87 នៅ ERN 00192775-00192780, ERN 00192667-00192932 (ភាសាអង់គ្លេស).

39 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 87 នៅ ERN 00192780, ERN 00192667-00192932 (ភាសាអង់គ្លេស).

40 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 88-90 នៅ ERN 00192781-00192783, ERN 00192667-00192932 (ភាសាអង់គ្លេស).

41 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 89 នៅ ERN 00192782, ERN 00192667-00192932 (ភាសាអង់គ្លេស).

42 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 82 នៅ ERN 00192775, ERN 00192667-00192932 (ភាសាអង់គ្លេស).

43 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 113 នៅ ERN 00192806, ERN 00192667-00192932 (ភាសាអង់គ្លេស).

44 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 113 នៅ ERN 00192806, ERN 00192667-00192932 (ភាសាអង់គ្លេស).

45 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 113 នៅ ERN 00192806, ERN 00192667-00192932 (ភាសាអង់គ្លេស).

46 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 114 នៅ ERN 00192807, ERN 00192667-00192932 (ភាសាអង់គ្លេស).

47 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 115-6 នៅ ERN 00192808-00192809, ERN 00192667-00192932 (ភាសាអង់គ្លេស).

48 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 141 នៅ ERN 00192834, ERN 00192667-00192932 (ភាសាអង់គ្លេស).

49 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 128 នៅ ERN 00192821, ERN 00192667-00192932 (ភាសាអង់គ្លេស).

50 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 130 នៅ ERN 00192823, ERN 00192667-00192932 (ភាសាអង់គ្លេស).

51 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 132, 133-137 នៅ ERN 00192825, 00192826-00192830, ERN 00192667-00192932 (ភាសាអង់គ្លេស).

52 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 132-134 នៅ ERN 00192825-00192827, ERN 00192667-00192932 (ភាសាអង់គ្លេស).

53 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 35-36 នៅ ERN 00192714-00192715, ERN 00192667-00192932 (ភាសាអង់គ្លេស).

54 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 140 នៅ ERN 00192833, ERN 00192667-00192932 (ភាសាអង់គ្លេស).

55 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 141 នៅ ERN 00192834, ERN 00192667-00192932 (ភាសាអង់គ្លេស).

56 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 2 នៅ ERN 00192681, ERN 00192667-00192932 (ភាសាអង់គ្លេស).

57 CHANDLER, David *សម្លេងពីមន្ទីរស-២១* ទំព័រ 3-13 នៅ ERN 00192682-00192692, ERN 00192667-00192932 (ភាសាអង់គ្លេស).

58 បទសម្ភាសន៍របស់ ជ័យ សុភាព ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188803, ERN 00188801-00188804.

59 បទសម្ភាសន៍របស់ ជ័យ សុភាព ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188802, ERN 00188801-00188804.

60 បទសម្ភាសន៍របស់ ជ័យ សុភាព ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188802, ERN 00188801-00188804.

61 បទសម្ភាសន៍របស់ ជ័យ សុភាព ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188803, ERN 00188801-00188804.

62 បទសម្ភាសន៍របស់ ជ័យ សុភាព ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188803, ERN 00188801-00188804.

63 បទសម្ភាសន៍របស់ ជ័យ សូភារ៉ា ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188803, ERN 00188801-00188804.

64 បទសម្ភាសន៍របស់ ជ័យ សូភារ៉ា ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188803, ERN 00188801-00188804.

65 បទសម្ភាសន៍របស់ ជ័យ សូភារ៉ា ដោយ ក.ស.ច.ស ចុះថ្ងៃទី25 ខែមីនា ឆ្នាំ2008, D 83/1, នៅ ERN 00188804, ERN 00188801-00188804.

66 ដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, ERN 00078697-00078699 (ភាសាអង់គ្លេស).

67 អត្ថបទអត្ថាធិប្បាយជាលាយល័ក្ខអក្សររបស់ ឌុច ត្រូវភ្ជាប់មកជាមួយរបាយការណ៍សួរយកចម្លើយរបស់គាត់ ដោយ ក.ស.ច.ស កាលពីថ្ងៃទី27 ខែមីនា ឆ្នាំ2008, D63, នៅ ERN 00194554-00194555, ERN 00194545-00194555 (ភាសាអង់គ្លេស).

68 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 29-31, 33-36, 46-53, 54-65

69 Nic DUNLOP*ពិជ្ឈឃាតបាត់ខ្លួន*: រាប់បញ្ចូលទាំងរយៈពេល ៥ឆ្នាំភ្លាមៗក្រោយពេលរដ្ឋប្រហារ លន់ ណុល (ទំព័រ79).

70 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 84-89

71 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 88..

72 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 88-89.

73 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 284-285.

74 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 100.

75 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 101.

76 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 104.

77 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 145.

78 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 171-176.

79 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 173-174.

80 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 199.

81 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 249-250, 303-306.

82 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន ទំព័រ* 267-269.

83 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 270-278.

84 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 16-18.

85 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 16-18.

86 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 84-88 និង 91-92. ចំនុចនេះមាននៅក្នុងខ្សែវីដេអូថតដោយវៀតណាម នៅពេលរកឃើញមន្ទីរ ស-២១ ក៏ដូចជាមាននៅក្នុងខ្សែភាពយន្តរបស់ James GERRAND _*Cambodia-Kampuchea* (ក្នុងចន្លោះពេល 00:21:21-00:22:38, ERN V 00172621-00172621).

87 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 18-24.

88 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 152-164, 168-170.

89 Nic DUNLOP *ពិជ្ឈឃាតបាត់ខ្លួន* ទំព័រ 298-299.

90 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 117-124.

91 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 122.

92 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 117-124.

93 **Nic DUNLOP** *ពិឃ្ឍឃាតបាត់ខ្លួន ទំព័រ* 125-128.

94 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 126.

95 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 117-124.

96 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 128-137, 145-6. សាក្សីក៏បានបង្ហាញដល់ ប្រាក់ ខន អំពីការសារភាពរបស់ ណៃ ណន, គិលាណុបដ្ឋាយិកាវ័យក្មេងមកពីមន្ទីរពេទ្យ ព-98។ ប្រាក់ ខន បានសារភាពថាគាត់បានប្រឌិតឡើងនូវអត្ថបទទាំងមូល, (*ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 135)។

97 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 145.

98 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 198.

99 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 117-124.

100 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 128-137, 145-6. សាក្សីក៏បានបង្ហាញដល់ ប្រាក់ ខន អំពីការសារភាពរបស់ ណៃ ណន, គិលាណុបដ្ឋាយិកាវ័យក្មេងមកពីមន្ទីរពេទ្យ ព-98។ ប្រាក់ ខន (Prak Khan) បានសារភាពថាគាត់បានប្រឌិតឡើងនូវអត្ថបទទាំងមូល, (*ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 135)។

101 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 146.

102 Nic DUNLOP *ពិឃ្ឍឃាតបាត់ខ្លួន* ទំព័រ 284-285.

103 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163736, ERN 00163735-00163755 (ភាសាអង់គ្លេស).

104 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163737, ERN 00163735-00163755 (ភាសាអង់គ្លេស); បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ព-អ.វ.ត.ក, ចុះថ្ងៃទី14 ខែសីហា ឆ្នាំ2006, D2.11, នៅ ERN 00146810 ERN 00146810-6812 (ភាសាអង់គ្លេស).

105 កំណត់ហេតុនៃការតទល់មុខគ្នារបស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2008, D54, នៅ ERN 00166563, ERN 00166561-00166570 (ភាសាអង់គ្លេស).

106 សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ1998, ទំព័រ 100-102 (ភាសាអង់គ្លេស); 12 គូរដោយ វ៉ាន់ ណាត, ចុះថ្ងៃទី 1979-1980, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ គ, ERN P 0000022-0000033.

107 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163739, ERN 00163735-00163755 (ភាសាអង់គ្លេស).

108 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163741, ERN 00163735-00163755 (ភាសាអង់គ្លេស).

---

[109] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163740, ERN 00163735-00163755 (ភាសាអង់គ្លេស); ក្នុងបទសម្ភាសន៍លើកមុនសាក្សីបាននិយាយថា ឌុច បានមកមួយថ្ងៃៗ ៣ឬ៤ដង ដើម្បីណែនាំអំពីការគូររូប: សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ1998, ទំព័រ 61 (ភាសាអង់គ្លេស).

[110] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ព-អ.វ.ត.ក, ចុះថ្ងៃទី14 ខែសីហា ឆ្នាំ2006, D2.11, នៅ ERN 00146811, ERN 00146810-6812 (ភាសាអង់គ្លេស)

[111] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163739, ERN 00163735-00163755 (ភាសាអង់គ្លេស); សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ1998, ទំព័រ 48, 49 (ភាសាអង់គ្លេស).

[112] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163739, ERN 00163735-00163755 (ភាសាអង់គ្លេស).

[113] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163739, ERN 00163735-00163755 (ភាសាអង់គ្លេស).

[114] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163739-00163740, ERN 00163735-00163755 (ភាសាអង់គ្លេស) – ជាពិសេសពាក់ព័ន្ធទៅនឹងឧប្បត្តិហេតុជាមួយ ប៊ូ ម៉េង នៅពេលដែល ឌុច បានសួរអ្នកគូររូបនិងអ្នកចម្លាក់ដទៃទៀតថាតើ ប៊ូ ម៉េង (BOU Mភាសាអង់គ្លេស) គួរទុកប្រើតទៅទៀតឬអត់។

[115] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ព-អ.វ.ត.ក, ចុះថ្ងៃទី14 ខែសីហា ឆ្នាំ2006, D2.11, នៅ ERN 00146812, ERN 00146810-6812 (ភាសាអង់គ្លេស).

[116] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163740, ERN 00163735-00163755 (ភាសាអង់គ្លេស); នៅក្នុងបទសម្ភាសន៍លើកមុនសាក្សីបាននិយាយថា ឌុច បាននាំមនុស្ស (មិនមែនថ្នាក់ ទាបទេ) មកមើលគាត់គូររូប: សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ 1998, ទំព័រ 76 (ភាសាអង់គ្លេស).

[117] សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ 1998, ទំព័រ 68-70 (ភាសាអង់គ្លេស).

[118] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163741, ERN 00163735-00163755 (ភាសាអង់គ្លេស); សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ1998, ទំព័រ 89 (ភាសាអង់គ្លេស).

[119] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163737, ERN 00163735-00163755 (ភាសាអង់គ្លេស); សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ 1998, ទំព័រ 36 (ភាសាអង់គ្លេស).

[120] បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163737, ERN 00163735-00163755 (ភាសាអង់គ្លេស).

121 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163737, ERN 00163735-00163755 (ភាសាអង់គ្លេស); បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ស្តីពីកំណត់ហេតុនៃការចុះ ធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2008, D48/2, នៅ ERN 00198001, ERN 00197998-00198008 (ភាសាអង់គ្លេស); សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ1998, ទំព័រ 41 (ភាសាអង់គ្លេស).

122 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163738, ERN 00163735-00163755 (ភាសាអង់គ្លេស).

123 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163739, ERN 00163735-00163755 (ភាសាអង់គ្លេស).

124 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ស្តីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេត ដល់កន្លែងកើតហេតុ ចុះថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2008, D48/2, នៅ ERN 00198001, ERN 00197998-00198008 (ភាសាអង់គ្លេស);ក្នុងបទសម្ភាសន៍លើកមុន គាត់បាននិយាយថាបានឃើញបទបញ្ជាទាំងនេះនៅក្នុងបន្ទប់រួមដែលគាត់បានជាប់គុកលើកដំបូងនៅ ស-២១: បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163738, ERN 00163735-00163755 (ភាសាអង់គ្លេស): សាក្សីបាននិយាយលើកមុនផងដែរថាសន្តិសុខបានបញ្ជាអ្នកទោសម្នាក់ឲ្យអានបទបញ្ជាទាំងនោះខ្លាំងៗ។: សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ1998, ទំព័រ 41 (ភាសាអង់គ្លេស).

125 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163740, ERN 00163735-00163755 (ភាសាអង់គ្លេស).

126 សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា *A Cambodian Prison Portrait* ឆ្នាំ1998, ទំព័រ 86 (ភាសាអង់គ្លេស).

127 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ចុះថ្ងៃទី8 ខែមករា ឆ្នាំ2008, D28/9 នៅ ERN 00163740, ERN 00163735-00163755 (ភាសាអង់គ្លេស).

128 សាក្សីក៏បាននិយាយផងដែរថា គាត់បានមកដល់បន្ទប់គូររូបនៅថ្ងៃទី5 ខែកុម្ភៈ ឆ្នាំ1978 5 កុម្ភៈ 1978: បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ច.ស-អ.វ.ត.ក ស្តីពីកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី27 ខែកុម្ភៈ ឆ្នាំ2008, D48/2, នៅ ERN 00198001, ERN 00197998-00198008 (ភាសាអង់គ្លេស); កំណត់ហេតុនៃការតទល់មុខគ្នារបស់ វ៉ាន់ ណាតដោយ ក.ស.ច.សអ.វ.ត.ក ចុះថ្ងៃទី29 ខែកុម្ភៈ ឆ្នាំ2008, D54, នៅ ERN 00166563, ERN 00166561-00166570 (ភាសាអង់គ្លេស).

129 បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ព-អ.វ.ត.ក, ចុះថ្ងៃទី14 ខែសីហា ឆ្នាំ2006, D2.11, នៅ ERN 00146811, ERN 00146810-6812 (ភាសាអង់គ្លេស).

130 បទសម្ភាសន៍របស់ វ៉ាន់ ណាត ក្នុងខ្សែភាពយន្តរបស់ ឫទ្ធី ប៉ាន់ ស-២១: *ម៉ាស៊ីនសម្លាប់មនុស្ស របស់ខ្មែរក្រហម* ក្នុងចន្លោះពេលពី 00:21:00 ដល់ 00:21:50; បទសម្ភាសន៍របស់ វ៉ាន់ ណាត ដោយ ក.ស.ព-អ.វ.ត.ក, ចុះថ្ងៃទី 14 សីហា

